# អំណាច

## របស់អ្នកជឿ

### របៀបនៃការបាត់បង់ និងការ
### ចាប់ផ្តើមនៃជ័យជម្នះ

ដោយលោក

អេ.អែល និង ហ្គីល

# អំណាចរបស់អ្នកជឿ

## របៀបនៃការបាត់បង់
## និងការចាប់ផ្តើមនៃជ័យជម្នះ

**ដោយលោក អេ.អែល និងអ្នកស្រី ហ្គីល**

I. S. B. N

បោះពុម្ពនៅឆ្នាំ ១៩៨៨ បានកែប្រែនៅឆ្នាំ ១៩៩៥

ហាមបោះពុម្ព ឬក៏ថតចម្លង

ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ

Powerhouse Publishing
P.O. Box 99
Fawnskin CA 92333
(909) 866-3119

**សៀវភៅដែលសរសេរដោយលោកអេ.អិល និងអ្នកស្រីចយ ហ្គីល**

និយាយពី

សេចក្ដីសន្យារបស់ព្រះសម្រាប់សេចក្ដីត្រូវការរបស់លោកអ្នកគ្រប់ៗគ្នា

ទុកសម្រាប់ការគ្រប់គ្រងនៅក្នុងព្រះនាមព្រះយេស៊ូវគឺជាជ័យជម្នះលើភាពខកចិត្ត ។

**ក្បួនដែលមាននៅក្នុងចលនានាវិចនេះគឺៈ**

**អំណាចនៃសេចក្ដីជំនឿ**

របៀបដែលមានការបាត់បង់

និងរបៀបដែលចាប់ផ្ដើមទទួលជ័យជម្នះ

**ពួកជំនុំដែលមានជ័យជម្នះ**

តាមរយៈព្រះគម្ពីរកិច្ចការ

**ការប្រទានពររបស់ព្រះសម្រាប់ការប្រោសឱ្យជា**

ការទទួលការងារនូវអំណាច

នៃការប្រោសឱ្យជា ដែលមកពីព្រះ

**អំណោយទានការងារជាៈ**

សាវ័ក ហោរា អ្នកផ្សាយដំណឹងល្អ

គ្រូគង្វាល និងគ្រូបង្រៀន

**ការផ្សាយដំណឹងល្អដោយការអស្ចារ្យ**

ផែនការរបស់ព្រះគឺជាការឈោងចាប់ពិភពលោកទាំងមូល

**ការរស់នៅជាគំរូ**

ចាប់ផ្ដើមពីព្រះគម្ពីរសញ្ញាចាស់

**ការសរសើរនិងការថ្វាយបង្គំ**

ការក្លាយមកជាអ្នកថ្វាយបង្គំព្រះ

**ការរស់នៅក្នុងជីវិតដែលពេញដោយអធិធម្មជាតិ (ការអស្ចារ្យ)**

តាមរយៈអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ

# អំពីអ្នកនិពន្ធ

លោកអេ.អែល និងអ្នកស្រីចយ ហ្គីល គឺជាអ្នកមានចំណេះវោហាជាអន្តរជាតិ ជាអ្នកនិពន្ធ ព្រមទាំងជាអ្នកបង្រៀនព្រះគម្ពីរ ។ នៅក្នុងបេសកកម្មការងារជាសាវករបស់លោកអេ.អែល គាត់បានធ្វើដំណើរទៅជាច្រើនប្រទេសនៃជនជាតិនានា ជាង៥០ជនជាតិលើ ពិភពលោក ដោយបានអធិប្បាយទៅកាន់ហ្វូងមនុស្សរាប់រយពាន់នាក់ និងមានមនុស្សជាច្រើនរាប់លាននាក់ បានស្តាប់តាមវិទ្យុ និងទស្សនាតាមទូរទស្សន៍ផងដែរ ។

ពួកគេមានសៀវភៅមេរៀនជាច្រើន ដែលមានជាងពីរលានក្បាល បានដាក់លក់នៅសហរដ្ឋអាមេរិក ។ គេបានសរសេរសៀវភៅ ជាច្រើន ដែលបានបកប្រែជាច្រើនភាសា និងត្រូវបានគេយកទៅប្រើនៅសាលាព្រះគម្ពីរ ព្រមទាំងថ្នាក់សិក្ខាសាលានៅជុំវិញពិភពលោក ។

ជីវិតដែលមានការផ្លាស់ប្រែពេញដោយអំណាច ដែលបានមកពីសេចក្តីពិតដោយសារព្រះបន្ទូលនៃព្រះ បានផ្ទុះចេញឡើងទៅដល់ជីវិតអ្នកដទៃទៀត តាមរយៈការអធិប្បាយ ការបង្រៀន ការសរសេរដ៏មានទឹកដមរបស់ពួកគេ ព្រមទាំងការផ្សាយតាមវីដេអូ និងការស្តាប់តាមរយៈអូឌីយ៉ូរបស់ពួកគេ ។

សិរីល្អដ៏គួរឱ្យព្រឺព្រួចនៃព្រះវត្តមានរបស់ព្រះ គឺត្រូវបានទទួលការពិសោធន៍នៅក្នុងការសរសើរ និងការថ្វាយបង្គំ នៅក្នុងកម្មវិធីសិក្ខាសាលាផ្សេងៗ ពេលដែលអ្នកជឿទាំងឡាយបានស្រាវជ្រាវរកឃើញ នូវរបៀបដែលធ្វើឱ្យពួកគេបានក្លាយជាអ្នកថ្វាយបង្គំព្រះដោយសេចក្តីពិត និងដោយអស់ពីចិត្ត ។ មានមនុស្សជាច្រើនបានស្រាវជ្រាវរកឃើញ នូវខ្នាតនៃជ័យជម្នះថ្មីៗ និងគួរឱ្យភ្ញាក់ផ្អើល ព្រមទាំងមានភាពក្លាហាន តាមរយៈការបង្រៀនរបស់ពួកគេ អំពីការអស្ចារ្យនៃអ្នកជឿ ។

រីឯអ្នកស្រីហ្គីលបានបណ្តុះបណ្តាលដល់អ្នកជឿជាច្រើន ជាជំហានៗឆ្ពោះទៅកាន់ការងារដ៏អស្ចារ្យ ដែលព្រះទ្រង់បានប្រទានដល់គេដោយផ្ទាល់ខ្លួនម្នាក់ៗ ដោយអំណាចនៃការប្រោសឱ្យជារបស់ព្រះ ដែលហូរតាមយោះដៃរបស់ពួកគេ ។ មានមនុស្សជាច្រើនបានរៀន ដើម្បីឱ្យបានទទួលនូវការអស្ចារ្យតាមរបៀបអធិធម្មជាតិ ដែលពួកគេបានបង្ហូរតៗគ្នា ទៅដល់អ្នកដទៃទៀត តាមរយៈអំណោយទាន ទាំង៩ នៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងការរស់នៅ និងការបំពេញការងាររបស់ពួកគេ ។

ទាំងលោកអេ.អែល និងអ្នកស្រីចយ បានសិក្សានិងបានទទួលនូវកម្រិតថ្នាក់ ម៉ាស្ទ័រនៃទេវវិទ្យា ។ រីឯលោកអេ.អែល ក៏ចង់បានទទួលតំណែងបណ្ឌិតផ្នែកទស្សនវិជ្ជា នៅក្នុងកម្រិតថ្នាក់ទេវវិទ្យា ដែលចេញពីសកលវិទ្យាល័យទស្សនគ្រិស្ទានផងដែរ ។ កិច្ចការងាររបស់ គេ គឺបានតាំងមូលដ្ឋានគ្រឹះនៅលើព្រះបន្ទូលព្រះ គឺបានតាំងលើព្រះយេស៊ូវ ដើម្បីឱ្យមានសេចក្តីជំនឿរឹងមាំ ព្រមទាំងបានបង្រៀនដោយនូវអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ ។

ការងាររបស់គេ គឺជាការបង្ហាញបំភ្លឺមកពីសេចក្តីស្រឡាញ់ដ៏អស់ពីចិត្តនៃព្រះដ៏ជាព្រះវរបិតា ។ ការអធិប្បាយ និងការបង្រៀន របស់គេ គឺបានប្រព្រឹត្តទៅដោយអំណាចនៃការចាក់ប្រេងតាំង ដែលមានទីសម្គាល់ ការអស្ចារ្យ និងការប្រោសឱ្យជា គឺជាការអស្ចារ្យដែល មានរលករំពើកក្រោមអំណាចព្រះចេស្តារបស់ព្រះ ។

ទីសម្គាល់ដ៏រស់រវើក ដែលរាប់បញ្ចូលនូវសំណើចបរិសុទ្ធ ការយំនៅចំពោះព្រះភក្ត្ររបស់ព្រះអម្ចាស់ ព្រមទាំងការសម្តែងនូវការ ព្រឺព្រួចនៃសិរីល្អរបស់ព្រះ និងអំណាចដែលត្រូវបានទទួលការពិសោធន៍តាមមនុស្សជាច្រើន ដែលបានចូលរួមប្រជុំរបស់ពួកគេ ។

# ព្រះបន្ទូលទៅកាន់គ្រូបង្រៀន និងសិស្ស

ការសិក្សាដែលពេញដោយអំណាចតាមរយៈមេរៀន **អំណាចរបស់អ្នកជឿ** នេះ នឹងនាំមកនូវអំណាចចូលទៅក្នុងជីវិតរបស់សិស្សម្នាក់ៗជាមិន ខាន ។ ពួកគេនឹងសិក្សានូវរបៀបដែលធ្វើឱ្យបាត់បង់ និងរបៀបដែលចាប់ផ្តើមមានជ័យជម្នះពីគ្រប់ការប្រយុទ្ធនៅក្នុងជីវិត ។ អ្នកជឿទាំងឡាយនឹង ត្រូវបានមានចំណង់ ដោយសារការបើកសម្តែងថ្មីៗពីរយ៉ាង ដែលមាននៅក្នុងព្រះយេស៊ូវគ្រីស្ទ ។ ការសិក្សានេះ នឹងរិតតែបង្កើនកម្លាំង និងបង្កើនសេចក្តី ទុកចិត្តឱ្យមានជ័យជម្នះ ចូលទៅក្នុងជីវិតនៃសិស្សទាំងឡាយ ។

យើងមានសំណូមពរមុនពេលបង្រៀនមេរៀននេះ សូមឱ្យលោកអ្នកមើល ឬស្តាប់តាមអូឌីយ៉ូ ឬតាមកាសែតវីដេអូជាដើម ព្រមទាំងអាន សៀវភៅដែលបានធ្វើបញ្ជីជា **របៀបសម្រាប់អាន** ។ លោកអ្នកទុកចិត្តលើព្រះបន្ទូលតាមរយៈមេរៀន អំណាចរបស់អ្នកជឿ ព្រមទាំងមេរៀនសង្គ្រាម ខាងវិញ្ញាណកាន់តែច្រើនកាលណា នោះនឹងអាចបំផ្លាស់បំប្រែពីគំនិតរបស់លោកចូលទៅក្នុងវិញ្ញាណច្រើនប៉ុណ្ណោះដែរ ។ បន្ទាប់ពីនោះមក ក្បួននេះនឹង ផ្តល់នូវការសង្ខេបដល់ លោកអ្នកដើម្បីឱ្យបានប្រើប្រាស ដូចជាលោកអ្នកចែកឱ្យនូវសេចក្តីទុកចិត្តទាំងនេះ ទៅដល់អ្នកដទៃទៀតដែរ ។

ការបើកសម្តែងពីជីវិតដែលមានលក្ខណៈជាបុគ្គល គឺជាតម្រូវការនៃសេចក្តីបង្រៀនដ៏ជាក់លាក់បំផុត ។ អ្នកនិពន្ធទាំងឡាយបានលុបចេញនូវ ការបង្រៀនទាំងនេះពីកិច្ចការងារនេះ ដូច្នេះគ្រូបង្រៀននឹងត្រូវតែផ្តល់នូវការបើកសម្តែង ពីការពិសោធន៍របស់ខ្លួនផ្ទាល់ ទៅដល់សិស្សទាំងឡាយណា ដែលមានលទ្ធភាពអាចទទួលបាន ។

គួរគប្បីឱ្យគ្រប់គ្នាបានចងចាំជានិច្ចថា ព្រះវិញ្ញាណបរិសុទ្ធទ្រង់បានមកបង្រៀនយើងពីគ្រប់ការទាំងអស់ ហើយការទាំងនោះ ពេលដែលយើង កំពុងសិក្សា ឬពេលដែលយើងកំពុងតែបង្រៀន យើងក៏គួរគប្បីអនុញ្ញាតឱ្យព្រះវិញ្ញាណបរិសុទ្ធទ្រង់ដឹកនាំផងដែរ ។

ការសិក្សានេះគឺជាការល្អបំផុត សម្រាប់ការសិក្សាជាលក្ខណៈបុគ្គល ឬជាការសិក្សាតាមក្រុម សាលាព្រះគម្ពីរ សាលារៀនថ្ងៃអាទិត្យ ព្រមទាំង ក្រុមសិក្សាតាមផ្ទះ ។ គឺជាការសំខាន់ ទាំងគ្រូទាំងសិស្ស ដែលត្រូវតែមាននូវក្បួនមេរៀនឱ្យបានគ្រប់ដៃ ក្នុងពេលដែលកំពុងសិក្សា ។

សៀវភៅមេរៀនល្អៗ យើងត្រូវតែសរសេរកត់ត្រាចុះ គូសបន្ទាត់ខាងក្រោមពាក្យសំខាន់ៗ ពិនិត្យពិចារណានូវគ្រប់ទាំងពាក្យនីមួយៗ ព្រមទាំង ចេះសង្ខេបអត្ថបទផងដែរ ។ យើងបានទុកឱ្យមានចន្លោះសម្រាប់លោកអ្នកកត់ត្រា និងធ្វើសេចក្តីសង្ខេប ។ របៀបត្រូវបានគេរៀបចំទុកជាមុន ដោយមាន ប្រព័ន្ធខយោង អាចមើលបានរហ័សទាន់ចិត្ត សម្រាប់ឱ្យលោកអ្នកមើលសារឡើងវិញ និងជួយឱ្យលោកអ្នកបានរកឃើញនៅកន្លែង ដដែលៗម្តងទៀតបាន ។ មានរបៀបពិសេសៗ ដែលធ្វើឱ្យមានលទ្ធភាពសម្រាប់ម្នាក់ៗ ពួកគេបានសិក្សាតែម្តងប៉ុណ្ណោះតាមរយៈសម្ភារៈនេះ ដើម្បីបង្រៀននូវមាតិកានេះ ទៅដល់ អ្នកដទៃទៀត ។

លោកសាវកប៉ុល បានសរសេរទៅកាន់លោកធីម៉ូថេថា:

*ឯអស់ទាំងសេចក្តីដែលអ្នកបានឮអំពីខ្ញុំ នៅមុខស្មរបន្ទាល់ជាច្រើន នោះក៏ត្រូវផ្ញើទុកនឹងមនុស្សស្មោះត្រង់ ដែលអាចនឹងបង្វឹកបង្រៀន តទៅអ្នកឯទៀត ដែរ* (២ធីម៉ូថេ ២:២) ។

ថ្នាក់រៀននេះ បានរៀបចំឡើងជារបៀបការសិក្សាព្រះគម្ពីរសម្រាប់អនុវត្តនៅក្នុង ម៉ាញស៍ (ប្រព័ន្ធអភិវឌ្ឍន៍ការងារ= MINDS= Ministry Development System) ។ របៀបរៀបចំដែលពិសេសបំផុត គឺធ្វើឱ្យកម្មវិធីសិក្សាមានការរីកចម្រើន ។ គំនិតនេះ គឺត្រូវបានរៀបចំឡើង ឱ្យបាន ជាពហុគុណ នៅក្នុងជីវិតចំពោះការងារ និងបង្រៀនដល់សិស្សជាច្រើននៅពេលអនាគត ។ ចំពោះរបៀបរបបនៃសិស្ស ត្រូវតែប្រើក្បួននេះ ដើម្បីឱ្យអាច បង្រៀនមេរៀននេះ បានយ៉ាងងាយស្រួលទៅដល់អ្នកដទៃទៀត ។

# មាតិកា


| | | |
|---|---|---|
| មេរៀនទី១ | ការស្គាល់ខ្មាំងសត្រូវរបស់លោកអ្នក | ០០១ |
| មេរៀនទី២ | អំណាចនៅផែនដី | ០០៩ |
| មេរៀនទី៣ | ផែនការរបស់សាតាំងគឺជាការបោកប្រាស់ | ០១៩ |
| មេរៀនទី៤ | ពេលដែលព្រះយេស៊ូវយាងមកគឺជាផែនការរបស់ព្រះ | ០២៧ |
| មេរៀនទី៥ | ព្រះយេស៊ូវទ្រង់បានបំពេញព្រះរាជកិច្ចដោយអំណាច | ០៣៧ |
| មេរៀនទី៦ | ពីឈើឆ្កាងទៅដល់បល្ល័ង្ករាជ | ០៤៥ |
| មេរៀនទី៧ | អំណាចបានកែជាថ្មីឡើងវិញឱ្យដល់មនុស្សជាតិ | ០៥៥ |
| មេរៀនទី៨ | យុទ្ធសាស្ត្ររបស់សាតាំងនៅពេលបច្ចុប្បន្ននេះ | ០៦៧ |
| មេរៀនទី៩ | ពួកជំនុំ និងអំណាច | ០៧៥ |
| មេរៀនទី១០ | កូនសោរនគរស្ថានសួគ៌ | ០៨៥ |
| មេរៀនទី១១ | ព្រះនាមព្រះយេស៊ូវ | ០៩៥ |
| មេរៀនទី១២ | ជោគជ័យនៅក្នុងសង្គ្រាមខាងឯវិញ្ញាណ | ១០៥ |
| | ខគម្ពីរចងចាំ | ១១៥ |



ខគម្ពីរនៅក្នុងមេរៀនអំណាចរបស់អ្នកជឿ

បានដកស្រង់ចេញពី**ព្រះគម្ពីរបរិសុទ្ធ**

បោះពុម្ពនៅឆ្នាំ១៩៧៩.១៩៨០.១៩៨២

ដោយលោកថូម៉ាស ណែលសាន់

Inc., Publisher

# មេរៀនទី១
# ការស្គាល់ខ្មាំងសត្រូវរបស់លោកអ្នក

## យើងស្ថិតនៅក្នុងសង្គ្រាម

### សង្គ្រាម

ក្នុងភាពជាគ្រីស្ទាន យើងត្រូវតែមានការប្រយុទ្ធ គឺយើងត្រូវតែដោះស្រាយនៅក្នុងការធ្វើសង្គ្រាមនោះ ។ យុទ្ធសាស្ត្រសំខាន់មួយរបស់សាតាំង គឺបានបិទភ្នែកយើង ដើម្បីឱ្យយើងមានការប្រយុទ្ធនេះ ហើយវាធ្វើឱ្យយើងបាត់បង់នូវការការពារ ប្រឆាំងជាមួយវាបាន ។ ប៉ុន្តែព្រះទ្រង់បានប្រទានឱ្យយើងមានគ្រប់ទាំងអាវុធ ដើម្បីឱ្យបានទទួលនូវជ័យជម្នះលើខ្មាំងសត្រូវរបស់យើងបាន ។

ព្រះគម្ពីរ ២កូរិនថូស ១០:៣-៤ ចែងថា: **ដ្បិតទោះបើយើងខ្ញុំដើរដោយសាច់ឈាមមែន គង់តែមិនតយុទ្ធតាមសាច់ឈាមទេ ព្រោះគ្រឿងសស្ត្រាវុទ្ធពិជ័យសង្គ្រាមរបស់យើងខ្ញុំ មិនមែនជារបស់ខាងសាច់ឈាមទេ គឺជាឥទ្ធិឫទ្ធិដែលមកពីព្រះសំរាប់នឹងរំលំទីមាំមួនវិញ** ។

ព្រះគម្ពីរ ១ធីម៉ូថេ ៦:១២ ចែងទៀតថា: **ចូរខំប្រឹងតស៊ូ ដោយការតយ៉ាងល្អនៃសេចក្តីជំនឿ ចូរតោងចាប់ជីវិតអស់កល្បជានិច្ចឱ្យខ្ជាប់ ដែលព្រះបានហៅអ្នកមកទទួល ហើយអ្នកក៏បានធ្វើបន្ទាល់យ៉ាងល្អ នៅមុខសាក្សីជាច្រើនដែរ** ។

វាជាការសំខាន់ដែលយើងត្រូវតែចងចាំថា អាវុធទាំងនេះមិនមែនជាធម្មជាតិរបស់លោកិយនោះទេ គឺវាជារឿងខាងវិញ្ញាណវិញ ។

មានអ្នកនិពន្ធជាច្រើននៅគម្ពីរសញ្ញាថ្មី បានប្រើចំណែកនៃសង្គ្រាមនេះ ។ ការទាំងនេះមិនមែនគ្រាន់តែជានិមិត្តរូបនោះទេ តែជាការពិពណ៌នាអំពីសមរភូមិដែលយើងបានចុះដៃប្រយុទ្ធហើយនោះវិញ ។ សមរភូមិទាំងនេះ គឺត្រូវបានគេនាំមកក្នុងសៀវភៅផ្នែកវិញ្ញាណរួចទៅហើយ ។

### សត្រូវរបស់យើង

យើងនៅក្រោមការប្រយុទ្ធពីខ្មាំងសត្រូវរបស់យើង ដែលនៅក្នុងគ្រប់សៀវភៅទាំងអស់នៃជីវិតរស់នៅប្រចាំថ្ងៃ និងការប្រកបទាក់ទងរបស់យើងដូចតទៅ :

- ⇨ *ផ្នែកគ្រួសារ*
- ⇨ *ផ្នែកថវិកា*
- ⇨ *ផ្នែកការងារ*
- ⇨ *ផ្នែកគំនិត(ខួរក្បាល)*
- ⇨ *ផ្នែករូបកាយ(សុខភាព)*
- ⇨ *ផ្នែកផ្ទះសម្បែង*
- ⇨ *ផ្នែកអ្នកជិតខាង*
- ⇨ *ផ្នែកស្រុកទេស*

➪ *ផ្នែកជនជាតិ*

➪ *ផ្នែកលោកិយទាំងមូល*

រឿងដ៏សំខាន់បំផុតមួយចំពោះការសិក្សាដែលយើងធ្វើសង្គ្រាម នោះមិនមែនជាមួយមនុស្សទេ គឺជាការប្រឆាំងទាស់នឹងសាតាំង និងវិញ្ញាណរបស់ពួកវាវិញ ។ វានៅក្នុងនគរខាងឯវិញ្ញាណ ។ ការទទួលទំនាក់ទំនងជាមួយមនុស្ស គឺត្រឹមតែដឹកនាំឱ្យមានការរសាយចិត្ត និងធ្វើឱ្យចុះចាញ់តែប៉ុណ្ណោះ ។

## តើអ្នកណាជាខ្មាំងសត្រូវរបស់យើង?

ប្រសិនបើយើងដឹងថា យើងនៅឯទីសង្គ្រាម ជាការសំខាន់យើងត្រូវតែដឹងថា អ្នកណាជាខ្មាំងសត្រូវរបស់យើង ។

ខ្មាំងសត្រូវរបស់យើងនោះគឺ:

➪ *ជាក្រុមគ្រួសាររបស់យើងឬ?*

➪ *ជាមនុស្សដែលយើងធ្វើការជាមួយឬ?*

➪ *ជារដ្ឋាភិបាលរបស់យើងឬ?*

➪ *ឬក៏ជាផ្នែកថវិការបស់យើង?*

*ទេ! មិនមែនឡើយ*

**ច្បាប់ -អំណាច**

**តេជៈ -កម្លាំងខាងឯវិញ្ញាណ**

លោកសាវកប៉ុលបានពណ៌នាពីខ្មាំងសត្រូវពិតរបស់យើង គាត់បានបញ្ជាក់ប្រាប់យើងនូវយុទ្ធសាស្ត្ររបស់យើង មិនមែនជាមួយមនុស្សដែលនៅជុំវិញយើងនោះទេ គឺគាត់មានប្រសាសន៍ថា យើងមិនមែនប្រយុទ្ធតតាំងនឹងសាច់ និងឈាមនោះទេ ។

ព្រះគម្ពីរអេភេសូរ ៦:១២ ចែងថា: **ដ្បិតយើងរាល់គ្នាមិនមែនតយុទ្ធនឹងសាច់ឈាមទេ គឺនឹងពួកគ្រប់គ្រង ពួកមានអំណាច និងពួកម្ចាស់នៃសេចក្តីងងឹតនៅលោកិយនេះវិញ ហើយទាស់នឹងអំណាចអាក្រក់ខាងវិញ្ញាណ នៅស្ថានដ៏ខ្ពស់ដែរ ។**

**វិញ្ញាណអាក្រក់**

លោកសាវកពេត្រុសបានបញ្ជាក់ថា សត្រូវរបស់យើងគឺជាវិញ្ញាណអាក្រក់ ។

១ពេត្រុស ៥:៨ ចែងថា: **ចូរឱ្យដឹងខ្លួន ហើយចាំយាមចុះ ព្រោះអារក្សដែលជាខ្មាំងសត្រូវរបស់អ្នករាល់គ្នា វាតែងដើរក្រវែល ទាំងគ្រហឹមដូចជាសិង្ហ ដើម្បីនឹងរកអ្នកណាដែលវានឹងត្របាក់លេបបាន ។**

**ផែនការ**

ផែនការរបស់វិញ្ញាណអាក្រក់ គឺជាយុទ្ធសាស្ត្រ និងគម្រោងការដើម្បីទាស់ប្រឆាំងនឹងយើង ។ វាមានប្រភេទនៃកងទ័ព និងផែនការដើម្បីប្រយុទ្ធយកជ័យជម្នះលើយើង ។ ទោះជា

យ៉ាងណាក៏ដោយ ពេលដែលយើងដឹងពីគម្រោងផែនការរបស់ពួកវា យើងត្រូវតែដឹងពីរបៀបប្រើអាវក្រោះ និងអាវុធដែលព្រះទ្រង់បានប្រទានឱ្យយើងនៅពេលប្រយុទ្ធ ។ អាវក្រោះគឺសម្រាប់ការពារ រីឯអាវុធ គឺសម្រាប់ប្រយុទ្ធយកជ័យជម្នះប្រឆាំងនឹងខ្មាំងសត្រូវរបស់យើង ។

ព្រះគម្ពីរអេភេសូរ ៦:១១ ចែងថា: **ចូរពាក់គ្រប់គ្រឿងសឹករបស់ព្រះ ដើម្បីឱ្យអាចនឹងឈរមាំមួន ទាស់នឹងឧបាយកលទាំងអំបាលម៉ានរបស់អារក្ស** ។

### ក.ពាក្យចាស់តើ្រន

⇨ *ត្រូវបាននៅជាមួយនឹងព្រះយេស៊ូវ*

⇨ *ត្រូវស្គាល់នូវអំណាច*

⇨ *មិនត្រូវបានទទួលការគម្រាមដោយវិញ្ញាណអាក្រក់*

យើងមិនត្រូវជាប់នៅ ឬធ្វើឱ្យមានការជិតដាមដោយវិញ្ញាណអាក្រក់ ដែលមានវិញ្ញាណខ្មោចព្រាយបិសាចឺ ឬក៏ផែនការរបស់វានោះទេ ។ ជំនួសនូវការនេះ យើងត្រូវតែនៅជាមួយនឹងព្រះយេស៊ូវ ។ ពេលដែលយើងរក្សាភ្នែករបស់យើងនៅនឹងទ្រង់ យើងនឹងបានដឹងខ្លួនជានិច្ចថា យើងបាននៅក្នុងព្រះអង្គ ។ ពេលដែលយើងដឹងខ្លួនថា អំណាចដែលយើងមានដោយសារព្រះយេស៊ូវ នោះភាពខ្លាំងក្លានឹងផុសចេញឡើង នៅក្នុងវិញ្ញាណរបស់យើងជាមិនខាន ។ យើងនឹងមិនត្រូវទទួលការគម្រាមកំហែងដោយវិញ្ញាណអាក្រក់ ឬគម្រោងផែនការរបស់ពួកវាទៅបានឡើយ ។

## ព្រះទ្រង់បានបង្កើតទេវតាឱ្យមានឡើង

### ព្រះទ្រង់គង់នៅអស់កល្បជានិច្ច

ព្រះដ៏ជាព្រះទ្រង់គង់នៅអស់កល្បជានិច្ច ទ្រង់ក៏មានព្រះវត្តមានជានិច្ចដែរ ហើយទ្រង់គឺជាអ្នកបង្កើតរបស់សព្វសារពើ ។

ព្រះគម្ពីរយ៉ូហាន ១:១-៣ ចែងថា: **កាលដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះ ទ្រង់គង់នៅជាមួយនឹងព្រះ តាំងអំពីដើមមក គ្រប់របស់ទាំងអស់បានកើតមកដោយសារទ្រង់ ហើយក្នុងបណ្តារបស់ដែលបានបង្កើតមកទាំងប៉ុន្មាន នោះគ្មានអ្វីណាមួយកើតមកក្រៅពីទ្រង់ឡើយ** ។

មានព្រះគម្ពីរបន្តទៅទៀត យ៉ូហាន ១:១៤ ចែងថា: **ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម ហើយបានស្នាក់នៅជាមួយនឹងយើងរាល់គ្នា យើងរាល់គ្នាបានឃើញសិរីល្អទ្រង់ គឺជាសិរីល្អនៃព្រះរាជបុត្រាតែ១ ដែលមកពីព្រះវរបិតា មានពេញជាព្រះគុណ និងសេចក្តីពិត** ។

"ព្រះបន្ទូល" គឺជាព្រះយេស៊ូវ ។

### ព្រះទ្រង់បានបង្កើតទេវតា

គឺជាព្រះរាជបុត្រានៃព្រះ ព្រះនាមព្រះយេស៊ូវគ្រីស្ទ ទ្រង់បានបង្កើតគ្រប់របស់ទាំងអស់ រួមទាំងពួកទេវតា ។ គ្រប់របស់ទាំងអស់ មិនមែនត្រឹមតែត្រូវបានបង្កើតឡើងដោយសារព្រះអង្គប៉ុណ្ណោះទេ គឺត្រូវបានបង្កើតឡើងសម្រាប់ជាគោលបំណងដ៏ល្អឥតខ្ចោះរបស់ទ្រង់ថែមទៀតផង។

ព្រះគម្ពីរកូល៉ុស ១:១៦-១៧ ចែងថា: **ដ្បិតគឺទ្រង់ហើយ ដែលបង្កើតគ្រប់របស់ទាំងអស់ ទាំងរបស់នៅស្ថានសួគ៌ និងនៅផែនដី ទាំងរបស់ដែលមើលឃើញ ហើយដែលមើលមិនឃើញផង ទោះបើរាជ្យ ឬអំណាចជាព្រះអម្ចាស់ ឬអំណាចគ្រប់គ្រង ឬអំណាចណាក៏ដោយ នោះសុទ្ធតែកើតមកដោយសារទ្រង់ ហើយសំរាប់ទ្រង់ទាំងអស់ផង ទ្រង់គង់នៅមុនទាំងអស់ ហើយរបស់ទាំងអស់ក៏នៅស្ថិតស្ថេរ ដោយសារទ្រង់** ។

### ពួកទេវតាត្រូវបានព្រះរៀបចំចាត់ចែង

ពេលដែលលោកសាវកប៉ុលបានរៀបចំតារាងជាបល្ល័ង្ក អំណាច ឋានៈជាក្សត្រ និងតេជៈ ទាំងអស់នេះគឺជាមុខងាររបស់ពួកទេវតា ។ គាត់បានប្រើឱ្យឈ្មោះសម្រាប់បញ្ជាក់ ពីមុខងាររបស់ពួកគេ ។

ពួកគេមានមុខងារផ្សេងៗពីគ្នាដូចខាងក្រោមនេះ:

- *មហាទេវតា*
- *ចេរ៉ូប៊ីន*
- *សេរ៉ាភីម*
- *តួមានជីវិត*

ពួកគេមានមុខងារផ្សេងៗគ្នា គឺ:

- *តួបល្ល័ង្ក*
- *តួអំណាច*
- *អំណាចជាក្សត្រ*
- *និងតេជៈ*

## សង្គ្រាមនៅស្ថានសួគ៌_លុស៊ីហ្វើរបានត្រូវធ្លាក់ចុះ

### បុព្វហេតុដោយសេចក្តីអំនួត/ការទាស់ទទឹង

ការទាស់ទទឹងរបស់ទេវតាលុស៊ីហ្វើរ គឺវាបានធ្លាក់ចុះដោយសារលទ្ធផលនៃសង្គ្រាម ដែលនៅស្ថានសួគ៌ បានផ្តល់ឱ្យយើងនូវការយល់ដឹងពីសេចក្តីសំខាន់នៃសង្គ្រាម ដែលយើងឥឡូវនេះ កំពុងតែជាប់ដៃប្រយុទ្ធនៅផែនដីនេះ ។

ព្រះគម្ពីរអេសេគាល ២៨:១៥,១៧ ចែងថា: **ចាប់តាំងពីថ្ងៃដែលឯងកើតមក នោះឯងបានគ្រប់លក្ខណ៍ក្នុងគ្រប់ទាំងផ្លូវរបស់ឯង ដរាបដល់វេលាដែលឃើញមាន សេចក្តីសុចរិតនៅក្នុងឯង... ចិត្តឯងបានស្ទួយឡើង ដោយព្រោះសេចក្តីលំអរបស់ឯង ឯងបានបង្ខូចប្រាជ្ញាឯង ដោយពន្លឺរស្មីរបស់ឯង អញបានបោះឯងចុះដល់ដី ព្រមទាំងដាក់ឯងនៅមុខពួកស្តេច ឱ្យគេបានពិចារណាឯង** ។

ទេវតាលុស៊ីហ្វើរបានគ្រប់លក្ខណ៍ រហូតទាល់តែវាបានតាំងនៅជាកណ្តាល នៃការប្រុងប្រយ័ត្នពីភាពល្អជិនួសនូវភាពល្អរបស់ព្រះ ដែលបានបង្កើតវាមក ។ សេចក្តីអំនួតបានតាំងនៅជា

កណ្តាល ។ វាបានគិតអំពីភាពសុចរិតជំនួសនូវការប្រុងប្រយ័ត្នរបស់វា ថាជាភាពសុចរិតដែលភាយចេញពីព្រះអង្គទ្រង់ផ្ទាល់មកវិញ ។

**“អញនឹង”**

មានបំណងមួយ គឺជាបំណងព្រះហឫទ័យរបស់ព្រះ ដែលទ្រង់បានដាក់ជាច្បាប់សម្រាប់សកលលោកទាំងមូល រហូតដល់មានសេចក្តីអំនួតបានចូលមកក្នុងទេវតាលុស៊ីហ្វើរ ។

ព្រះគម្ពីរអេសាយ ១៤:១២-១៧ បានចែងថា: **ឱតារាប្រចាំថ្ងៃ ជាផ្កាយព្រឹកអើយ នែ៎ ឯងបានធ្លាក់ចុះពីលើមេឃមកហើយ ឯងដែលបានផ្តេកអស់ទាំងនគរឱ្យរាប ឯងត្រូវបានកាប់រំលំដល់ដីដែរហ្ន៎ ឯងបានគិតក្នុងចិត្តថា:**

**អញនឹងឡើងទៅឯស្ថានសួគ៌**

**អញនឹងដំកើងបល្ល័ង្កអញ ឱ្យខ្ពស់អស់ទាំងផ្កាយរបស់ព្រះ**

**ហើយអញនឹងអង្គុយលើភ្នំជាទីប្រជុំជំនុំ នៅទីបំផុតនៃទិសខាងជើង**

**អញនឹងឡើងទៅផុតទីខ្ពស់នៃពពក**

**អញនឹងលើកខ្លួនឱ្យបានដូចជាព្រះដ៏ខ្ពស់បំផុត**

**តែឯងបានត្រូវទំលាក់ចុះដល់ស្ថានឃុំព្រលឹងមនុស្សស្លាប់វិញ គឺដល់ទីជំរៅនៃជង្ហុកធំ ពួកអ្នកដែលឃើញឯង គេនឹងសំឡឹងមើលចំឯង ហើយពិចារណាឯងដោយពាក្យថា តើមនុស្សនេះឬអី ដែលធ្លាប់ធ្វើឱ្យផែនដីញាប់ញ័រ ហើយឱ្យនគរទាំងប៉ុន្មានកក្រើករំពើកនោះ ជាអ្នកដែលបានធ្វើឱ្យលោកិយរលីងដូចជាសមុទ្រខ្សាច់ ព្រមទាំងបំផ្លាញទីក្រុងទាំងប៉ុន្មានឥតដែលលែងឱ្យពួកឈ្លើយឱ្យត្រឡប់ទៅឯផ្ទះគេវិញឡើយ** ។

រហូតដល់ពេលភ្លាមៗនេះ មានគោលបំណងតែមួយនៅក្នុងចក្រវាលទាំងមូល គឺជាបំណងព្រះហឫទ័យនៃព្រះ ។ អារក្សលុស៊ីហ្វើរបានចាប់អនុវត្តនូវការទាស់ទទឹងនោះ ដោយការធ្វើតាមបំណងចិត្តរបស់វា ដែលផ្ទុយនឹងបំណងព្រះហឫទ័យរបស់ព្រះ ។ ក៏បានបង្ហាញនូវ "បំណងមួយ" នៃបំណងទាំងប្រាំរបស់អារក្សលុស៊ីហ្វើរ គឺជាការបោកប្រាស់ ដែលបង្ហាញនូវការទាស់ទទឹងរបស់វា ដែលបានចម្រើនឡើងជាលំដាប់ គឺជាចំណុចនៃការខំប្រឹងប្រែង ដើម្បីផ្លាស់ប្តូរបល្ល័ង្កព្រះនៅឯស្ថានសួគ៌ ។

**សមរភូមិ**

ព្រះគម្ពីរវិវរណៈ ១២:៧-១០ ចែងថា: **នោះមានចំបាំងនៅលើមេឃ គឺមីកែល និងពួកទេវតារបស់លោកច្បាំងនឹងនាគ ហើយនាគ និងទេវតាវា ក៏ច្បាំងនឹងលោកដែរ តែមិនបានឈ្នះទេ ក៏មិនឃើញមានកន្លែងណាឱ្យវា នៅលើមេឃទៀតផង** ។

⇨ *សាតាំង និងទេវតារបស់វាត្រូវទម្លាក់ចុះ*

**នោះនាគធំត្រូវបោះទំលាក់ទៅ គឺជាពស់ពីបុរាណ ដែលឈ្មោះហៅថា អារក្ស ហើយសាតាំងផង ដែលបាននាំលោកិយទាំងមូលឱ្យវង្វេងចេញ វាត្រូវបោះទំលាក់ទៅផែនដីវិញ ព្រម**

**ទាំងពួកទេវតារបស់វាផង** ។

**នោះខ្ញុំឮសំឡេង១យ៉ាងខ្លាំង នៅលើមេឃថា ឥឡូវនេះ សេចក្ដីសង្គ្រោះ ព្រះចេស្ដា និង រាជ្យរបស់ព្រះនៃយើងរាល់គ្នា ហើយអំណាចរបស់ព្រះគ្រីស្ទនៃទ្រង់ បានមកដល់ហើយ ដ្បិត អានោះដែលចោទប្រកាន់ពីពួកបងប្អូនយើងរាល់គ្នា ដែលចេះតែចោទពីគេនៅចំពោះព្រះ ទាំង យប់ទាំងថ្ងៃ វាត្រូវបោះទំលាក់ទៅហើយ** ។

នៅព្រះគម្ពីរអេសេគាល ២៨:១៦ បានថែងតទៅទៀតថា: **ដ្បិតដោយសារការជួញ ប្រែដំបរិបូររបស់ឯង នោះគេបានបំពេញឯងដោយសេចក្ដីច្រឡោត ហើយឯងបានធ្វើបាប ហេតុ នោះអញបានបោះចោលឯងចេញពីភ្នំនៃព្រះ ទុកដូចជារបស់អាប់ឱនទៅវិញ ឱចេរ៉ូប៊ីនដែលគ្រប បាំងអើយ អញបានបំផ្លាញឯងចេញពីកណ្ដាលថ្មភ្លឺចាំងនោះទៅ ។**

អារក្សលុស៊ីហ្វើរ និងពួកទេវតារបស់វា ត្រូវបានបណ្ដេញចេញពីស្ថានសួគ៌ហើយ ។

**លទ្ធផលនៃសង្គ្រាម**

ទេវតាមួយភាគបីនៅក្រោមការគ្រប់គ្រងរបស់អារក្សលុស៊ីហ្វើរ ត្រូវបានទម្លាក់ចុះជា មួយនឹងវាហើយ ។ រីឯទេវតាដទៃទៀតនៅក្រោមការគ្រប់គ្រងរបស់ទេវតាមីកែល និងទេវតា កាព្រីយ៉ែល បាននៅតែស្មោះត្រង់ចំពោះព្រះដដែល ។

➪ *ពួកទេវតាមួយភាគបីត្រូវបានទម្លាក់ចុះ*

ព្រះគម្ពីរវិវរណៈ ១២:៤ក ថែងថា: **កន្ទុយវាក៏ទាញផ្កាយនៅលើមេឃ១ភាគក្នុង៣ គ្រវាត់ចោលទៅផែនដី ។**

អារក្សលុស៊ីហ្វើរ ព្រមទាំង "ពួកទេវតារបស់វា" ត្រូវបានទម្លាក់ចុះទៅដល់ភពផែនដី ។

ព្រះគម្ពីរវិវរណៈ ១២:៩ ថែងថា: **នោះនាគធំត្រូវបោះទំលាក់ទៅ គឺជាពស់ពីបុរាណ ដែលឈ្មោះហៅថា អារក្ស ហើយសាតាំងផង ដែលបាននាំលោកិយទាំងមូលឱ្យវង្វេងចេញ វា ត្រូវបោះទំលាក់ទៅផែនដីវិញ ព្រមទាំងពួកទេវតារបស់វាផង ។**

➪ *ការប្ដូរឈ្មោះ*

ឈ្មោះរបស់លុស៊ីហ្វើរបានត្រូវប្ដូរ ។ មុខងាររបស់វាដែលត្រូវបានដាក់ឈ្មោះថាជាកូន នៃផ្កាយព្រឹក នោះត្រូវប្ដូរទៅជា:

➪ *នាគ*

➪ *ពស់*

➪ *វិញ្ញាណអាក្រក់*

➪ *សាតាំង*

ពួកទេវតាដែលនៅក្រោមអំណាចអារក្សលុស៊ីហ្វើរ គឺជាអស់អ្នកដែលចូលរួមបះបោរជា មួយ គឺត្រូវបានរៀបចំជារចនាសម្ព័ន្ធ តាមថ្នាក់ អំណាច ខ្នាត និងតាមអំណាចគ្រប់គ្រង ប៉ុន្តែ

ឈ្មោះរបស់ពួកវាត្រូវបានប្តូរទៅតាមធម្មជាតិ ដែលធ្លាក់ចុះនោះឯង ។ ពួកវាឥឡូវនេះត្រូវបានហៅថា ជាពួកអារក្ស ពួកខ្មោច និងពួកវិញ្ញាណអាក្រក់វិញ ។

⇨ *ការប្តូរលក្ខណធម្មជាតិ*

ការប្តូរលក្ខណធម្មជាតិរបស់សាតាំង ដែលវាពីដើមជា:

⇨ *ផ្កាយព្រឹក*

⇨ *កូននៃពន្លឺ*

⇨ *ជាអ្នកដឹកនាំសរសើរតម្កើង និងថ្វាយបង្គំ*

⇨ *ជាកងការពារ និងជាអ្នកការពារបល្ល័ង្ករបស់ព្រះ*

ឥឡូវនេះវាបានក្លាយមកជា:

⇨ *ពុករលួយ*

⇨ *បន្ទុះបង្អាប់*

⇨ *គ្មានចំណែកនៅនគរស្ថានសួគ៌*

វាបានបាត់បង់នូវ:

⇨ *ភាពស្រស់ត្រកាលរបស់វា*

⇨ *មុខងារដ៏ខ្ពស់របស់វានៅនគរព្រះ*

លក្ខណធម្មជាតិរបស់វាបានក្លាយមកជា:

⇨ *សេចក្តីងងឹត*

⇨ *អាក្រក់*

⇨ *វិញ្ញាណអាក្រក់*

⇨ *ពេញដោយការស្អប់*

នេះគឺជាលទ្ធផលទាំងអស់ដែលវាបានធ្វើបាប ដោយមានសេចក្តីអំនួត និងការបះបោរ ។

## សំណួររំឭកសារឡើងវិញ

១- ចូរពិពណ៌នានូវមុខងារ និងតួនាទីពិតប្រាកដរបស់លុស៊ីហ្វើរ ។

២- ចូរពិពណ៌នាពីការបះបោររបស់វា ដែលនាំឱ្យមានការធ្លាក់ចុះ ព្រមទាំងបានទទួលនូវលទ្ធផលដោយសារអំពើបាបរបស់វា ។

៣- តើអ្នកណាជាខ្មាំងសត្រូវពិតប្រាកដរបស់អ្នកជឿ នៅសម័យសព្វថ្ងៃនេះ?

# មេរៀនទី២
# អំណាចនៅផែនដី

## ផែនដីត្រូវបានបង្កើតឡើង

**ដោយសារព្រះ**

នៅក្នុងព្រះគម្ពីរលោកុប្បត្តិបានប្រាប់យើងថា ព្រះទ្រង់បានបង្កើតផែនដី ។

ព្រះគម្ពីរលោកុប្បត្តិ ១:១ ចែងថា: **កាលដើមដំបូងឡើយ ព្រះបានបង្កើតផ្ទៃមេឃ និងផែនដី** ។

➪ *ដើម្បីឱ្យមនុស្សនៅ*

តាមព្រះគម្ពីរអេសាយបានចែងថា ផែនដីមិនមែនបង្កើតឡើងឱ្យនៅទទេឡើយ គឺត្រូវបានរៀបចំឱ្យមានមនុស្សនៅវិញ ។

ព្រះគម្ពីរអេសាយ ៤៥:១៨ ចែងថា: **ដ្បិតព្រះយេហូវ៉ាដែលបានបង្កើតផ្ទៃមេឃ ជាព្រះដែលទ្រង់សូនធ្វើហើយប្រតិស្ឋានផែនដី ក៏តាំងឡើង មិនមែនបង្កើតមកឱ្យនៅទទេទេ គឺបានជប់សូនបង្កើតឱ្យជាទីអាស្រ័យនៅ ទ្រង់មានបន្ទូលដូច្នេះថា គឺអញនេះជាយេហូវ៉ា ឥតមានព្រះឯណាទៀតឡើយ ។**

➪ *ផែនដីបានខូច*

ទោះជាយ៉ាងណាក៏ដោយ តាមព្រះគម្ពីរលោកុប្បត្តិ ១:២ បានពណ៌នាថា ផែនដីបានខូចនៅទទេ ហើយងងឹត ។ ការពណ៌នានេះ គឺបានន័យថាទីកន្លែងមិនទាន់បានរៀបចំរួចនៅឡើយ សម្រាប់ឱ្យមនុស្សនៅនោះទេ ។ នៅព្រះគម្ពីរហេព្រើរ ពាក្យដែលបានបកប្រែទៅជាភាសាអង់គ្លេស "ជា" គួរតែត្រូវបានបកប្រែឱ្យបានត្រឹមត្រូវថា "ត្រឡប់ជា" វិញ ។

ព្រះគម្ពីរលោកុប្បត្តិ ១:២ ចែងថា: **ឯផែនដីបានខូច ហើយនៅទទេ មានសុទ្ធតែងងឹតនៅគ្របលើជំរៅទឹក ហើយព្រះវិញ្ញាណនៃព្រះក៏រេរានៅពីលើទឹក ។**

នៅក្នុងព្រះគម្ពីរយេរេមា យើងបានឃើញពាក្យជាភាសាហេព្រើរដូចគ្នា ដែលបានប្រើក្នុងការបកប្រែនេះដែរ ។

ព្រះគម្ពីរយេរេមា ៤:២៣-២៥ ចែងថា: **ខ្ញុំបានពិចារណាមើលផែនដី ឃើញថាខូច ហើយនៅទទេ រួចមើលទៅលើមេឃ នោះក៏ឥតមានពន្លឺដែរ ខ្ញុំក្រឡេកមើលទៅភ្នំធំ ឃើញថាញ័រទាំងអស់ ហើយភ្នំតូចទាំងប៉ុន្មានក៏កក្រើករញ្ជួយ ខ្ញុំក៏ពិចារណាមើលឃើញថា គ្មានមនុស្សណាទៀតសោះ អស់ទាំងសត្វហើរលើអាកាសបានហើរទៅបាត់ហើយ** ។

➪ *បានត្រឡប់ជាងងឹត ហើយនៅទទេ*

លោកហោរាយេរេមាបានពន្យល់ថា សេចក្ដីជំនុំជម្រះរបស់ព្រះ បានវិលត្រឡប់មកជាគ្រប់លក្ខណ៍នៅផែនដី ជាកន្លែងដែលត្រូវបានស្ថាបនាឡើងវិញ ។

ព្រះគម្ពីរយេរេមា ៤:២៣ ចែងថា: **ខ្ញុំបានពិចារណាមើលផែនដី ឃើញថាខូច ហើយនៅទទេ រួចមើលទៅលើមេឃ នោះក៏ឥតមានពន្លឺដែរ** ។

លោកហោរាយេរេមា បានបន្តពណ៌នានូវសេចក្តីជំនុំជម្រះរបស់ព្រះ ដែលនៅផែនដី ។

ព្រះគម្ពីរយេរេមា ៤:២៦-២៧ ចែងថា: **រួចខ្ញុំក៏មើលទៅឃើញដីដុះដាល បានត្រឡប់ជាវាលស្ងាត់ ហើយអស់ទាំងទីក្រុងក៏ត្រូវរលំចុះ នៅចំពោះព្រះយេហូវ៉ា ហើយចំពោះសេចក្តីខ្ញាល់ដ៏សហ័សរបស់ទ្រង់** ។

**ដ្បិតព្រះយេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា ស្រុកទាំងមូលនឹងត្រូវខូចបង់ ប៉ុន្តែអញមិនបំផ្លាញអស់រលីងទេ** ។

⇨ *សាតាំងបានមកផែនដី*

វាជាការមានលទ្ធភាព ដែលសាតាំងត្រូវបានទម្លាក់ចុះមកផែនដី នៅចន្លោះព្រះគម្ពីរលោកុប្បត្តិ ១:១ និងលោកុប្បត្តិ ១:២ (សូមមើលការពន្យល់នៅទំព័របន្ទាប់)

ចូរសាកល្បងគិតមើលពីសាតាំង ពេលដែលវាត្រូវបានទម្លាក់ចុះមកផែនដីនេះ ។ វាត្រូវបានលើកតម្កើងឱ្យមានមុខងារដ៏ខ្ពស់នៅឯស្ថានសួគ៌ ។ វាបានទទួលនូវសម្រស់ស្រស់ត្រកាលដែលមិនគួរនឹងពណ៌នាបាន ។ វាគឺជាពន្លឺសិរីល្អរបស់ព្រះ ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការបះបោររបស់វា វារិតតែបានសម្រេចចិត្តបន្តហើយបន្តទៀត ។ វាបានសម្រេចចិត្តថា នឹងគ្រប់គ្រងនគរស្ថានសួគ៌ ។

កាលពីដើម នៅស្ថានសួគ៌មានសមរភូមិមួយ ។ វានិងពពួកទេវតាដែលតាមវា ត្រូវបានបណ្តេញមកផែនដី ។ គ្រប់កន្លែងដែលសាតាំងបានឃើញ វាតែងតែចងចាំនូវព្រះដ៏ជាអ្នកបង្កើតគ្រប់របស់ទាំងអស់ គឺជាអ្នកដែលវាបានកោតខ្លាចយ៉ាងខ្លាំងរហូតមកដល់សព្វថ្ងៃនេះ ។ វាបានចងចាំនូវគ្រប់រឿងរ៉ាវទាំងអស់ ដែលវាបានចុះចាញ់ដោយការបះបោររបស់វា ។

ពេលខ្លះសាតាំង គឺជាម្នាក់ដែលមកដើម្បីនឹងលួច សម្លាប់ ហើយបំផ្លាញនៅលើផែនដីនេះ ។ មានរឿងតែមួយទេដែលសាតាំងបានធ្វើច្បាប់ ឱ្យទៅជាអសារឥតការ ឱ្យនៅទំនេរ ព្រមទាំងនៅក្នុងភាពងងឹត ។

អារក្សលុស៊ីហ្វើរបានសម្រេចចិត្តចង់គ្រប់គ្រងលើចក្រវាលទាំងមូល ។ ឥឡូវនេះវាកំពុងតែបានត្រឡប់ទៅជាតូច ងងឹត និងនៅក្នុងភពដែលទទេ ។

## ព្រះទ្រង់បានកែតែផែនដីឡើងវិញ

នៅក្នុងព្រះគម្ពីរលោកុប្បត្តិ ១:២ ដែលយើងបានអានឃើញថា ព្រះវិញ្ញាណនៃព្រះ ក៏រេរានៅពីលើទឹក ។ លោកុប្បត្តិ ១:៣ សម្តែងថា ព្រះទ្រង់មានបន្ទូលថា "ចូរឱ្យមានពន្លឺឡើង" សាតាំងបានស្គាល់សម្លេងនោះ!

វាបានយល់ជ្រួតជ្រាបថា មានភាពអស់កល្បជានិច្ចតាំងពីដើមមក ។ ចូរគិតមើល ថាតើវាមានការភ័យស្លន់ស្លោប៉ុណ្ណា ពេលដែលវាបានឮសម្លេងរបស់ព្រះ ។ សូម្បីតែនៅលើផែនដីនេះ វាមិនអាចលាក់ខ្លួនពីព្រះបានឡើយ រីឯព្រះក៏ទ្រង់មិនចង់ទុកវាឱ្យនៅឯកោដែរ ។

តើគួរឱ្យភ័យស្លុតយ៉ាងណាទៅ ដែលសាតាំងត្រូវតែបានទទួល ពេលដែលវាបានឃើញព្រះទ្រង់កំពុងតែកែផែនដីឱ្យបានស្អាតល្អឡើងវិញ នៅប្រាំថ្ងៃបន្ទាប់ទៀត ។

*"បន្ទាប់មកព្រះទ្រង់មានបន្ទូល"*

ផែនដីត្រូវបង្កើតឡើងវិញតាមរយៈការមានព្រះបន្ទូល ។ វាជាការសំខាន់ដើម្បីឱ្យបានយល់ថា ព្រះទ្រង់មានបន្ទូលទៅកាន់របស់ដែលមានហើយ ឱ្យត្រូវបំផ្លាញទៅវិញបាន ។

ព្រះគម្ពីរលោកុប្បត្តិ ១:៣ ចែងថា: **ព្រះទ្រង់មានបន្ទូលថា "ចូរឱ្យមានពន្លឺឡើង" ហើយពន្លឺក៏មានឡើង ។**

ខ.៦ **បន្ទាប់មកព្រះទ្រង់មានបន្ទូលថា ចូរឱ្យមានប្រឡោះនៅកណ្តាលទឹក ដើម្បីញែកទឹកចេញពីគ្នា ។**

ខ.៩ **បន្ទាប់មក ព្រះទ្រង់មានបន្ទូលថា ចូរឱ្យទឹកនៅក្រោមមេឃប្រមូលគ្នានៅកន្លែងតែ ១ ហើឱ្យមានទីគោកដុះលេចឡើង នោះក៏មានដូច្នោះ ។**

ខ.១១ **រួចព្រះទ្រង់មានបន្ទូលថា ចូរឱ្យដីដុះតិណជាតិឡើង គឺជាពួកស្មៅដែលមានគ្រាប់ និងរុក្ខជាតិមានផ្លែតាមពូជ ដែលមានគ្រាប់នៅក្នុងផ្លែនោះនៅផែនដី នោះក៏មានដូច្នោះ ។**

ខ.១៤ **បន្ទាប់មក ព្រះទ្រង់មានបន្ទូលថា ចូរឱ្យមានពន្លឺនៅនាផ្ទៃមេឃ ដើម្បីនឹងញែកថ្ងៃចេញពីយប់ សំរាប់ទុកជាទីសំគាល់នៃរដូវ ថ្ងៃ និងឆ្នាំ ។**

ខ.២០ **បន្ទាប់មក ព្រះទ្រង់មានបន្ទូលថា ចូរឱ្យមានមច្ឆជាតិរវើកនៅក្នុងទឹកជាបរិបូរ និងបក្សីជាតិហើរលើដីនៅនាអាកាស ។**

ខ.២៤ **បន្ទាប់មក ព្រះទ្រង់មានបន្ទូលថា ចូរឱ្យមានចតុប្បាទជាតិកើតមកនៅដីគោកតាមពូជ គឺជាសត្វស្រុក សត្វលូនវារ និងសត្វព្រៃនៅផែនដីតាមពូជ នោះក៏មានដូច្នោះ ។**

ខ.២៦ **ទ្រង់មានបន្ទូលថា ចូរយើងធ្វើមនុស្សឱ្យដូចជារូបយើង ឱ្យមានភាពដូចជាយើង ហើយឱ្យមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាស និងសត្វជើង៤ដែលនៅលើផែនដីទាំងមូល ព្រមទាំងសត្វលូនវារដែលវារនៅផែនដីផង ។**

ខ.២៩ **ទ្រង់មានបន្ទូលថា មើល អញឱ្យគ្រប់ទាំងតិណជាតិមានគ្រាប់ពូជដែលដុះនៅផែនដី និងគ្រប់ទាំងរុក្ខជាតិទាំងឡាយដែលកើតផ្លែមានគ្រាប់ពូជ ទុកជាអាហារដល់ឯង ។**

**ប្រតិកម្មរបស់សាតាំង**

គ្រប់របស់ទាំងអស់ដែលត្រូវបានបំផ្លាញនៅផែនដីឱ្យខូច នោះព្រះទ្រង់បានកែឱ្យល្អគ្រប់លក្ខណ៍ឡើងវិញ។ តើព្រះទ្រង់មានផែនការយ៉ាងដូចម្តេច? ហេតុអ្វីបានជាព្រះទ្រង់ចាប់អារម្មណ៍នៅភពផែនដីនេះម្ល៉េះ?

ចូរគិតមើលពីសាតាំងដែលវាបានពោលដោយភាពកំណាចរបស់វាថា "ហេតុអ្វី" បានជាព្រះទ្រង់មិនទុកយើងឱ្យនៅតែឯង? ទ្រង់មានសកលលោកទាំងមូលជារបស់ទ្រង់ហើយ រីឯភពដ៏តូចមួយនេះ គួរតែជារបស់យើងវិញ" ។

ការភ័យស្លន់ស្លោ និងការស្អប់ខ្ពើម គឺត្រូវតែមាននៅក្នុងកណ្តាប់ដៃសាតាំង ក្នុងពេលទាំងប្រាំថ្ងៃនោះ ពីព្រោះសម្លេងរបស់ព្រះបានឮទៅដល់វា ។ ពេលដែលព្រះទ្រង់មានបន្ទូល ផែនដីក៏ត្រូវបានកែជាថ្មីឡើង ឱ្យបានល្អដូចដើមវិញ ។ ទំហំនៃការស្អប់របស់សាតាំងចំពោះព្រះ គឺរឹតតែខ្លាំងឡើងៗ ពីមួយថ្ងៃទៅមួយថ្ងៃ ។

កំណត់ចំណាំៈ អ្នកប្រាជ្ញព្រះគម្ពីរមិនបានឯកភាពទៅនឹងព្រឹត្តិការណ៍នៃការច្បាំងដណ្តើមយក ដែលទាក់ទងទៅនឹងការធ្លាក់ចុះរបស់សាតាំង ព្រមទាំងការបង្កើតមនុស្សមកនោះទេ ។ សម្ភារៈនៃមេរៀននេះ គឺផ្តោតទៅលើ "ទ្រឹស្តីដែលមានការខ្វះចន្លោះ" ដែលបង្រៀនថាមាន "ការខ្វះចន្លោះ" រវាងខ.១ និងខ.២ នៃព្រះគម្ពីរលោកុប្បត្តិជំពូកដំបូង ។ ទ្រឹស្តីនេះបានបង្រៀនថាសាតាំងត្រូវបានទម្លាក់ចុះមកផែនដី បន្ទាប់ពីការបះបោររបស់វាមក ផែនដីបានត្រឡប់ទៅជាខូចនៅទទេ ហើយមានសុទ្ធតែងងឹត នេះត្រូវបានពណ៌នានៅក្នុងខ.២ ។

ការបង្រៀនដទៃទៀត ដែលបញ្ជាក់ពីការបះបោររបស់សាតាំង និងមានការធ្លាក់ចុះទៅជាជម្លោះ បន្ទាប់មកទៀត មនុស្សយើងក៏ត្រូវបានបង្កើតឡើង ។ អ្នកប្រាជ្ញទាំងអស់ក៏មិនឯកភាពផងដែរ អំពីពេលវេលានៃការបណ្តេញសាតាំងចេញពីស្ថានសួគ៌មកផែនដី ។

វាមិនមែនជាការសំខាន់ចំពោះការឯកភាពជាមួយនឹងព្រឹត្តិការណ៍ នៃការច្បាំងដណ្តើមយក ដែលបានពណ៌នានៅក្នុងមេរៀននេះនោះទេ គឺជាការដើម្បីធ្វើឱ្យយល់ពីមនុស្សដែលត្រូវបានបង្កើតមក ឱ្យមានរូបភាពរបស់ព្រះនោះវិញ គឺត្រូវបានប្រទានពរឱ្យមានអំណាច និងអំណាចគ្រប់គ្រងលើផែនដីនេះ ។ វាក៏ជាការសំខាន់ផងដែរ ដែលឱ្យយល់ថា នេះគឺជាហេតុផលដែលសាតាំងស្អប់មនុស្សជាតិដល់ម្លេះ ។

## អំណាចបានផ្តល់ឱ្យមនុស្សជាតិ

### ការបង្កើតនៅក្នុងរូបភាពរបស់ព្រះ

បន្ទាប់ពីព្រះទ្រង់បានបង្កើតផែនដីម្តងទៀត ទ្រង់ក៏បានបង្កើតមនុស្សប្រុសស្រី ឱ្យមានរូបភាពដូចជាព្រះអង្គ ។ បន្ទាប់មកទៀត ទ្រង់បានប្រទានពរឱ្យគេមានអំណាចលើគ្រប់ទាំងអស់ដែលមានជីវិតនៅលើផែនដី ។

➪ *ឱ្យពួកគេមានអំណាច*

នៅក្នុងព្រះគម្ពីរលោកុប្បត្តិជំពូក១ បានប្រាប់យើងថា មនុស្សជាតិត្រូវបានបង្កើតឡើងនៅក្នុងរូបភាពរបស់ព្រះ រីឯព្រះគម្ពីរលោកុប្បត្តិជំពូក៥វិញ គឺបានប្រាប់យើងនូវរឿងដដែលនេះម្តងទៀត ។

ព្រះគម្ពីរលោកុប្បត្តិ ១:២៦ ចែងថា: **ទ្រង់មានបន្ទូលថា ចូរយើងធ្វើមនុស្សឱ្យដូចជារូបយើង ឱ្យមានភាពដូចជាយើង ហើយឱ្យមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាស និងសត្វជើង៤ដែលនៅលើផែនដីទាំងមូល ព្រមទាំងសត្វលូនវារដែលវារនៅផែនដីផង ។**

រីឯព្រះគម្ពីរលោកុប្បត្តិ ៩:៦ ក៏បានចែងថា: **អ្នកណាដែលកំចាយឈាមរបស់មនុស្ស នោះឈាមអ្នកនោះឯងនឹងត្រូវខ្ចាយដោយសារមនុស្សដែរ ដ្បិតព្រះទ្រង់បានបង្កើតមនុស្សឱ្យដូចជារូបអង្គទ្រង់** ។

ការដឹងថាមនុស្សប្រុសស្រី ដែលបានបង្កើតមកនៅក្នុងរូបភាពរបស់ព្រះ នោះគឺជារឿងសំខាន់មួយ ដែលយើងបានយល់នូវគោលបំណងរបស់ព្រះ ពីព្រោះរូបភាពរបស់ព្រះ គឺជាតួអង្គដ៏មានអំណាច ។

ដូចជាព្រះគម្ពីរលោកុប្បត្តិ ១:២៧ ចែងថា: **ទ្រង់ក៏បង្កើតមនុស្សឱ្យដូចរូបអង្គទ្រង់ គឺបានបង្កើតគេឱ្យចំនឹងរូបអង្គទ្រង់នោះឯង ក៏បង្កើតគេឡើងជាប្រុសជាស្រី** ។

### ការប្រទានជីវិតរបស់ព្រះ

ព្រះទ្រង់បានសូនរូបកាយរបស់មនុស្សពីធូលីដី ដោយព្រះហស្តរបស់ទ្រង់ រួចបន្ទាប់មកទ្រង់ក៏បានផ្លុំខ្យល់ជីវិតបញ្ចូលទៅក្នុងគេ គឺជាខ្យល់ជីវិតរបស់ព្រះ ។ ព្រះទ្រង់បានផ្លុំខ្យល់ជីវិតចូលទៅក្នុងមនុស្សជាតិ គឺជាខ្យល់ធម្មជាតិរបស់ព្រះសុទ្ធសាត ។

ទ្រង់បានប្រទានជីវិតរបស់ទ្រង់ដល់យើង ។ ជីវិតរបស់ព្រះបាននៅក្នុងយើងហើយ ។

ព្រះគម្ពីរលោកុប្បត្តិ ២:៧ **ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់យកធូលីដីមកសូនធ្វើជាមនុស្ស ទ្រង់ផ្លុំខ្យល់ដង្ហើមជីវិតបញ្ចូលទៅក្នុងរន្ធច្រមុះ នោះក៏ត្រឡប់ជាមានព្រលឹងរស់ឡើង** ។

### មានអំណាចលើសាតាំង

បន្ទាប់ពីសង្គ្រាមនៅស្ថានសួគ៌មក សាតាំងត្រូវបានបណ្តេញចេញមកផែនដី ។ តើលោកអ្នកអាចគិតមើលនូវភាពកំណាចរបស់វា ពេលដែលវាបានឃើញព្រះទ្រង់បង្កើតមនុស្សជាតិមក ហើយទ្រង់បានផ្លុំខ្យល់ជីវិតរបស់ព្រះបញ្ចូលទៅក្នុងគាត់ ហើយបន្ទាប់មកទ្រង់បានប្រទាននូវការកើតជាថ្មី ព្រមទាំងប្រទានអំណាចឱ្យបានគ្រប់គ្រងលើរបស់ដែលមានជីវិតទាំងឡាយ នៅលើផែនដីនេះ?

សាតាំងមានជីវិតរស់នៅលើផែនដី ។ អំណាចត្រូវបានប្រទានមកមនុស្ស រួមបញ្ចូលទាំងអំណាចគ្រប់គ្រងលើសាតាំង និងពួកអ្នកដែលតាមវាផងដែរ ។

### អំណាចត្រូវបានប្រទានមកអ្នកទាំងពីរ

ព្រះទ្រង់បានជប់សូននាងអេវ៉ា រួមទាំងលោកអ័ដាម ពួកគេបានទទួលអំណាច និងអំណាចគ្រប់គ្រងលើគ្រប់របស់ទាំងអស់ នៅលើផែនដី ។

នៅក្នុងព្រះគម្ពីរលោកុប្បត្តិជំពូកទី២ យើងមានរឿងរ៉ាវពីការបង្កើតនាងអេវ៉ាមក ។

ព្រះគម្ពីរលោកុប្បត្តិ ២:២១-២៤ ចែងថា: **នោះព្រះយេហូវ៉ាដ៏ជាព្រះ ទ្រង់ធ្វើឱ្យអ័ដាមដេកលក់ស៊ុបទៅ រួចទ្រង់យកឆ្អឹងជំនីគាត១ ហើយបិទថ្ពិតសាច់ទៅវិញ រីឯឆ្អឹងដែលព្រះយេហូវ៉ាដ៏ជាព្រះបានយកពីអ័ដាមមក នោះទ្រង់ជប់ឱ្យកើតឡើងជាមនុស្សស្រី ក៏នាំទៅឯអ័ដាម អ័ដាមក៏ថា នេះហើយជាឆ្អឹងពីឆ្អឹងអញ ជាសាច់ពីសាច់អញ នឹងត្រូវហៅថា "ស្ត្រី" ពីព្រោះបានយកចេញពីបុរសមក ដោយហេតុនោះ បានជាមនុស្សប្រុសនឹងលាចេញពីឪពុកម្តាយខ្លួន ទៅនៅជាប់នឹងប្រពន្ធវិញ ហើយអ្នកទាំង២នោះនឹងត្រឡប់ជាសាច់តែ១សុទ្ធ ។**

⇨ *មិនមែនចំពោះតែលោកអ័ដាមទេ*

ចាប់តាំងពីមនុស្សជាតិត្រូវបានបង្កើតមក ព្រះទ្រង់មានបន្ទូលថា "ចូរឱ្យពួកគេមានអំណាច" ទ្រង់មិនមែនមានបន្ទូលថា "ចូរឱ្យឯងមានអំណាច" នោះទេ ។

ព្រះគម្ពីរលោកុប្បត្តិ ១:២៦-២៨ ចែងថា: **ទ្រង់ក៏មានបន្ទូលថា ចូរយើងធ្វើមនុស្សឱ្យដូចជារូបយើង ឱ្យមានភាពដូចយើង ហើយឱ្យមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាស និងសត្វជើងបួនដែលនៅលើផែនដីទាំងមូល ព្រមទាំងសត្វលូនវារដែលវារនៅផែនដីផង ទ្រង់ក៏បង្កើតមនុស្សឱ្យដូចរូបអង្គទ្រង់ គឺបានបង្កើតគេឱ្យចំនឹងរូបអង្គទ្រង់នោះឯង ក៏បង្កើតគេឡើងជាប្រុសជាស្រី ទ្រង់ប្រទានពរដល់គេ ហើយមានបន្ទូលថា ចូរបង្កើតកូនឱ្យចម្រើនជាច្រើនឡើង ឱ្យមានពេញពាសលើផែនដីចុះ ត្រូវបង្ក្រាបផែនដី ហើយមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាស និងជីវិតផងទាំងឡាយដែលកម្រើកនៅផែនដីផង ។**

រីឯមនុស្សប្រុសមិនបានហាត់ប្រើការគ្រប់គ្រងទៅលើមនុស្សស្រីទេ ឬក៏មនុស្សស្រីមិនបានហាត់ប្រើការគ្រប់គ្រងទៅលើមនុស្សប្រុសដែរ តែពួកគេបែរជាជ្រើសរើសយកបំណងខាងសាច់ឈាមវិញ គឺពួកគេបានដើររួមគ្នាដើម្បីគ្រប់គ្រង និងប្រើអំណាចនៅលើផែនដីនេះវិញ ។

ពួកគេទាំងអស់គ្នាត្រូវបានប្រទានអំណាចគ្រប់គ្រងទៅលើ:

⇨ *ត្រីនៅក្នុងសមុទ្រ*

⇨ *សត្វហើរលើអាកាស*

⇨ *សត្វលូនវារ*

⇨ *គ្រប់អំណាចនៅផែនដី*

⇨ *គ្រប់របស់មានជីវិតទាំងអស់*

⇨ *មិនមែនលើមនុស្សដទៃទៀត*

មនុស្សមិនមែនមានអំណាចលើអ្នកដើរតាមរបស់គេនោះទេ គេត្រូវបានប្រទានអំណាចមក ដើម្បីគ្រប់គ្រងលើស្នាព្រះហស្តរបស់ព្រះ ដែលនៅលើផែនដី ព្រមទាំងគ្រប់គ្រងលើសាតាំង និងពួកវិញ្ញាណអាក្រក់របស់វា ។

ឥឡូវនេះ ព្រះទ្រង់បានមានអំណាចពេញលេញ និងអំណាចគ្រប់គ្រងលើសកលលោកទាំងមូល លើកលែងតែភពផែនដីប៉ុណ្ណោះ ។ ឥឡូវនេះព្រះទ្រង់បានប្រទានអំណាចរបស់ព្រះអង្គ

ទៅដល់អ្នកដែលព្រះអង្គទ្រង់បានបង្កើតជាថ្មីមកឱ្យដូចជាព្រះអង្គ ដែលហៅថាមនុស្សប្រុស និងមនុស្សស្រី ។

**មនុស្សត្រូវបានប្រទានឱ្យមានឆន្ទៈសេរី**

⇨ *ឆន្ទៈ*

ព្រះទ្រង់បានប្រទានដល់លោកអ័ដាមនូវឆន្ទៈដោយសេរី ។ គាត់មានអំណាចគ្រប់គ្រាន់ដើម្បីជ្រើសរើសរវាងការស្តាប់បង្គាប់ និងការមិនស្តាប់បង្គាប់ដល់ព្រះ ។ មនុស្សជាតិត្រូវបានប្រទានឱ្យមានឆន្ទៈ មានការជ្រើសរើស និងមានឆន្ទៈសេរី ។

ឆន្ទៈរបស់មនុស្សត្រូវតែបានទទួលការសាកល្បងនៅក្នុងសួនច្បារ រវាងការស្តាប់បង្គាប់ និងការមិនស្តាប់បង្គាប់ រវាងការទទួលទានផ្លែឈើដឹងខុសត្រូវ ឬក៏មិនទទួលទានវា ។

មនុស្សជាតិនៅតែមានឆន្ទៈសេរីដដែល ។

ព្រះគម្ពីរលោកុប្បត្តិ ២:១៦-១៧ ចែងថា: **ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់ទៅអ័ដាមថា ឯងនឹងស៊ីផ្លែឈើទាំងអស់ក្នុងសួនច្បារនេះបានតាមចិត្ត តែឯត្រង់ដើមឈើដឹងខុសត្រូវ នោះមិនត្រូវឱ្យឯងស៊ីផលឡើយ ដ្បិតនៅថ្ងៃណាដែលឯងស៊ី នោះនឹងត្រូវស្លាប់ជាមិនខាន ។**

**សាតាំងស្អប់មនុស្សជាតិ**

សាតាំងបានស្អប់លោកអ័ដាម និងនាងអេវ៉ា ពីព្រោះពួកគេត្រូវបានបង្កើតជារូបភាពរបស់ព្រះ នៅពេលដែលព្រះទ្រង់បានបង្កើតពួកគេភ្លាម ពួកគេត្រូវប្រទានគ្រប់ទាំងអំណាច ដែលវាមានពីដើម ដូច្នេះវាចង់ដណ្តើមយកវិញដោយអំណាច ។

⇨ *ពួកគេមើលទៅដូចជាព្រះ*

⇨ *ពួកគេនិយាយដូចជាព្រះ*

⇨ *ពួកគេដើរដូចជាព្រះ*

ពួកគេបានត្រូវប្រទាននូវអំណាចគ្រប់គ្រងលើគ្រប់របស់ទាំងអស់លើផែនដី និងលើទាំងសាតាំងផងដែរ ។ ទាំងគ្រប់គ្រងលើរបស់ទាំងអស់ ដែលវាធ្លាប់មានអំណាចគ្រប់គ្រងលើទៅទៀត ព្រមទាំងគ្រប់គ្រងលើរបស់ទាំងអស់ ដែលនៅ"នគររបស់វា"ទៅទៀត ។

**ការភ័យខ្លាចដ៏ធំសម្បើមរបស់សាតាំង**

សាតាំងដឹងស្គាល់នូវអំណាចរបស់យើង។ វាស្គាល់នូវអ្វីដែលព្រះទ្រង់មានព្រះបន្ទូល និងអ្វីដែលទ្រង់បានធ្វើសម្រេចហើយ ។

វាជាការសំខាន់ដ៏ក្រៃលែងចំពោះវា ដែលយើងមិនបានទាំងដឹងស្គាល់នូវអំណាចរបស់យើងផង ព្រមទាំងមិនបានរាវរក និងចាប់ផ្តើមដើរនៅក្នុងអំណាច និងអំណាចគ្រប់គ្រង ដែលព្រះទ្រង់បានប្រទានមកយើងថែមទៀតផង ។ សាតាំងមានហេតុផលនឹងខ្លាច ទាំងមនុស្សប្រុស និងមនុស្សស្រី ដែលដើរនៅក្នុងអំណាចរបស់គេដែលបានប្រទានមកពីព្រះ ។

**"អញនឹង" របស់សាតាំង**

ចូរចងចាំនូវបំណង១របស់សាតាំង ដែលបានផ្ដល់មកនៅក្នុងព្រះគម្ពីរអេសាយ ។

ព្រះគម្ពីរអេសាយ ១៤:១៣-១៥ ចែងថា: **ឯង**(សាតាំង) **បានគិតក្នុងចិត្តថា:**

**អញនឹងឡើងទៅឯស្ថានសួគ៌**

**អញនឹងដំកើងបល្ល័ង្កអញ ឱ្យខ្ពស់ជាងអស់ទាំងផ្កាយរបស់ព្រះ**

**ហើយអញនឹងអង្គុយលើភ្នំជា ទីប្រជុំជំនុំ នៅទីបំផុតនៃទិសខាងជើង**

**អញនឹងឡើងទៅផុតទីខ្ពស់នៃពពក**

**អញនឹងលើកខ្លួនឱ្យបានដូចជាព្រះដ៏ខ្ពស់បំផុត**

**តែឯងបានត្រូវទំលាក់ចុះដល់ស្ថានឃុំព្រលឹងមនុស្សស្លាប់វិញ គឺដល់ទីជំរៅនៃជង្ហុកធំ** ។

**គ្រប់ការទាំងអស់ត្រូវបានប្រទានមកមនុស្ស**

គ្រប់ការទាំងអស់ សាតាំងមានបំណងចង់បាននៅក្នុងការបះបោររបស់វា តែព្រះទ្រង់បានបង្កើតមនុស្សឱ្យបាននៅវិញ ។

⇨ សាតាំងមានវាចាថា "អញនឹងឡើងទៅឯស្ថានសួគ៌" ។

មនុស្សជាតិត្រូវបានបង្កើតមកឱ្យមានការប្រកបទាក់ទងជាមួយនឹងព្រះ ។ យើងក៏ត្រូវបានបង្កើតមកឱ្យមានការដើរ ការនិយាយជាមួយនឹងព្រះនៅសកលលោកនេះដែរ! យើងត្រូវបានបង្កើតឡើងដើម្បីសោយរាជ្យជាមួយនឹងព្រះអង្គដែរ ។

ព្រះគម្ពីរវិវរណៈ ២០:៦ ចែងថា: **មានពរហើយ ក៏បរិសុទ្ធផង អស់អ្នកណាដែលមានចំណែក ក្នុងខណៈរស់ឡើងវិញជាន់មុនដំបូងនេះ សេចក្ដីស្លាប់ទី២គ្មានអំណាចលើអ្នកទាំងនោះឡើយ អ្នកទាំងនោះនឹងធ្វើជាពួកសង្ឃនៃព្រះ និងព្រះគ្រីស្ទ ហើយនិងសោយរាជ្យជាមួយនឹងទ្រង់អស់១ពាន់ឆ្នាំ** ។

⇨ សាតាំងបាននិយាយថា "អញនឹងតម្កើងបល្ល័ង្កអញ ឱ្យខ្ពស់ជាងអស់ទាំងផ្កាយរបស់ព្រះ" ។

ផ្កាយរបស់ព្រះបញ្ជូនទៅឱ្យពួកទេវតាទាំងឡាយ ។ សាតាំងបានសម្រេចចិត្តធ្វើជាអ្នកខ្ពស់ជាងពួកទេវតាទាំងឡាយ ដែលសំខាន់ៗទៅទៀត ។

លោកសាវកប៉ុលបានសរសេរថា ថ្ងៃមួយយើងនឹងបានជំនុំជម្រះពួកទេវតា ។

ព្រះគម្ពីរ ១កូរិនថូស ៦:២-៣ បានចែងថា: **តើមិនដឹងថា ពួកបរិសុទ្ធនឹងជំនុំជំរះលោកិយដែរទេឬ ដូច្នេះ បើអ្នករាល់គ្នានឹងជំនុំជំរះលោកិយបាន នោះតើមិនគួរនឹងជំនុំជំរះការតូចបំផុតនេះបានដែរទេឬអី តើមិនដឹងថា យើងរាល់គ្នានឹងជំនុំជំរះ ដល់ទាំងពួកទេវតាផងទេឬអី ដូច្នេះ ចំណង់បើការនៅជីវិតនេះ តើលើសជាងអំបាលម៉ានទៅទៀត ។**

⇨ សាតាំងបាននិយាយថា "ហើយអញនឹងអង្គុយលើភ្នំជាទីប្រជុំជំនុំ នៅទីបំផុតនៃទិសខាងជើង" ។

យើងនឹងត្រូវបានអង្គុយនៅនគរស្ថានសួគ៌ នៅកន្លែងព្រះយេស៊ូវ ។

ព្រះគម្ពីរអេភេសូរ ២:៦ ចែងថា: **ហើយទ្រង់បានប្រោសឱ្យយើងរស់ឡើងវិញ ក៏ឱ្យយើងអង្គុយជាមួយនឹងព្រះគ្រីស្ទ នៅស្ថានដ៏ខ្ពស់ដែរ ។**

⇨ សាតាំងបាននិយាយថា "អញនឹងឡើងទៅផុតទីខ្ពស់នៃពពក" ។

យើងនឹងជួបព្រះយេស៊ូវនៅក្នុងពពក នាអាកាស ។

ព្រះគម្ពីរថែស្សាឡូនិច ៤:១៦-១៧ ចែងថា: **ព្រោះព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថានសួគ៌មកដោយស្រែកបង្គាប់១ព្រះឱស ទាំងមានឮសំឡេងមហាទេវតា និងត្រែរបស់ព្រះផង នោះពួកស្លាប់ក្នុងព្រះគ្រីស្ទនឹងរស់ឡើងវិញជាមុនបង្អស់ រួចយើងរាល់គ្នាដែលកំពុងតែរស់នៅ ក៏នឹងបានលើកឡើង ទៅក្នុពពកជាមួយគ្នាទាំងអស់ ដើម្បីឱ្យបានជួបជុំនឹងព្រះអម្ចាស់នៅនាអាកាស យ៉ាងនោះ យើងនឹងនៅជាមួយនឹងព្រះអម្ចាស់ជាដរាបទៅ ។**

⇨ សាតាំងបាននិយាយថា "អញនឹងលើកខ្លួនឱ្យបានដូចជាព្រះដ៏ខ្ពស់បំផុត" ។

មនុស្សត្រូវបានបង្កើតឡើងនៅក្នុងរូបភាពរបស់ព្រះ ។ តើលោកអ្នកនៅតែឆ្ងល់ថា ហេតុអ្វីបានជាសាតាំងស្អប់មនុស្សជាតិឬទេ?

មនុស្សយើងត្រូវបានបង្កើតមកឱ្យបានទៅជា:

⇨ *មើលទៅដូចជាព្រះ*

⇨ *និយាយដូចជាព្រះ*

⇨ *ដើរដូចជាព្រះ*

⇨ *បានគ្រប់គ្រងត្រួតត្រាជាមួយនឹងព្រះ*

សាតាំងបានទទួលនូវការអាម៉ាសមុខ ដែលយើងត្រូវបានទទួលនូវអ្វីៗទាំងអស់ មកពីវាបានព្យាយាមធ្វើការបះបោរនោះឯង ។

## សំណួររំឭកសារឡើងវិញ

១- ចូរធ្វើការពន្យល់ដោយពាក្យពេចន៍លោកអ្នកផ្ទាល់ ផែនដីដើម ការធ្លាក់ចុះរបស់សាតាំង ព្រមទាំងលទ្ធផលនៃការជំនុំជម្រះផែនដី ។

២- ចូរពណ៌នារបៀបដែលព្រះទ្រង់បានដាក់មុខងារ ទៅក្នុងអំណាច និងអំណាចគ្រប់គ្រង នៅពេលដែលទ្រង់បានបង្កើតផែនដីមក ។

៣- ចូរធ្វើការពន្យល់ថា មូលហេតុអ្វីបានជាសាតាំងស្អប់លោកអ្នក ។ តើលោកអ្នកបានធ្វើអ្វីខ្លះ ដែលធ្វើឱ្យវាមានការស្អប់យ៉ាងដូច្នោះ?

# មេរៀនទី៣

# ផែនការរបស់សាតាំងគឺជាការបោកប្រាស់

សាតាំងបានឃើញថាលោកអ័ដាម និងនាងអេវ៉ា ព្រមទាំងមនុស្សជាតិទាំងអស់ បានត្រូវប្រទានឱ្យមានជីវិត និងលក្ខណៈធម្មជាតិដូចជាព្រះ ។ ដូច្នេះហើយ បានជាសាតាំងត្រូវបានទទួលការភ័យខ្លាចដល់មនុស្សជាតិនោះ ដែលឥឡូវនេះ មនុស្សមានអំណាចគ្រប់គ្រងរបស់ទាំងអស់នៅលើផែនដីនេះ ។

មនុស្សមើលទៅដូចជាព្រះ គាត់មានសកម្មភាពដូចជាព្រះ ។ រីឯសាតាំងបានស្អប់ដល់ព្រះ អញ្ចឹងហើយ វាក៏បែរត្រឡប់មកទាស់នឹងមនុស្ស ។ វាធ្វើមិនឱ្យមនុស្សបានទទួលជោគជ័យឡើយ ។ ដូច្នេះ សាតាំងបានបង្កើតឡើងនូវផែនការផ្ទាល់របស់វា ។

## ផែនការរបស់សាតាំង

### ការបោកប្រាស់

សាតាំងបានបោកបញ្ឆោតពួកទេវតាដែលនៅស្ថានសួគ៌ ហើយមានមួយភាគបី បានមកតាមការបះបោររបស់វា ។ វាមានការពិសោធន៍នៅក្នុងការបោកប្រាស់នេះ ។

ព្រះទ្រង់បានប្រទានដល់មនុស្សឱ្យមានបំណងចិត្តដោយសេរី គេអាចជ្រើសរើសយកការស្តាប់បង្គាប់ ឬការមិនស្តាប់បង្គាប់បាន ។ ដោយមានសេរីភាពនៃការជ្រើសរើសយ៉ាងដូច្នោះ គាត់ក៏ត្រូវបានទទួលទោសដោយការមិនស្តាប់បង្គាប់នោះឯង ។

ព្រះគម្ពីរលោកុប្បត្តិ ២:១៧ ចែងថា: **តែឯត្រង់ដើមឈើដឹងខុសត្រូវ នោះមិនត្រូវឱ្យឯងស៊ីផលឡើយ ដ្បិតនៅថ្ងៃណាដែលឯងស៊ី នោះនឹងត្រូវស្លាប់ជាមិនខាន** ។

⇨ *ការសម្ងំលាក់ខ្លួន និងសួរទៅព្រះ*

សាតាំងបានជ្រើសរើសយកការសម្ងំលាក់ខ្លួនធ្វើជាពស់ ដើម្បីឱ្យវាអាចចូលទៅក្នុងសួនច្បារបាន ។ វាគ្មានសិទ្ធិនឹងនៅក្នុងសួនច្បារនោះទេ ហើយលោកអ័ដាមច្បាស់ជានឹងបណ្តេញវាចេញពីសួននោះហើយ ប្រសិនបើសាតាំងចូលមកដោយមិនបានប្រើល្បិចសម្ងំលាក់ខ្លួនទេនោះ ។

ព្រះគម្ពីរលោកុប្បត្តិ ៣:១ក ចែងថា: **ឯពស់ជាសត្វចេះឧបាយកលលើសជាងអស់ទាំងសត្វព្រៃ ដែលព្រះយេហូវ៉ាដ៏ជាព្រះទ្រង់បានបង្កើតវាមក** ។

"ចេះឧបាយកល" មានន័យថា ឆ្លាត ឬវាងវៃ ។

សាតាំងបាននៅក្នុងរូបរាងកាយរបស់សត្វពស់ ពេលដែលវាបាននិយាយទៅកាន់នាងអេវ៉ា វិញ្ញាណអាក្រក់នោះ វានៅតែមានរូបរាងកាយរហូតមកដល់សព្វថ្ងៃនេះ វិញ្ញាណនោះ គឺបានសម្ងំលាក់របស់ពួកវា ដែលបានគ្រប់ដណ្តប់ទៅលើវិញ្ញាណអាក្រក់ផ្សេងៗទៀត ដែលពួកវាចង់ធ្វើកិច្ចការអ្វីមួយឱ្យបានសម្រេច ។

ព្រះគម្ពីរលោកុប្បត្តិ ៣:១ខ ចែងថា: **វានិយាយទៅកាន់ស្ត្រីថា តើព្រះមានបន្ទូលហាមមិនឱ្យអ្នកបរិភោគផ្លែឈើណានៅក្នុងសួនច្បារមែនឬ** ។

សាតាំងបានសួរនូវអ្វីដែលព្រះទ្រង់បានមានព្រះបន្ទូល ហើយនៅពេលជាមួយគ្នានោះ ព្រះទ្រង់បានបណ្តេញចេញដោយសារទោសនៃអំពើបាបដែរ ។

⇨ *ចែករំលែកនឹងព្រះ*

ចូរចំណាំថា សាតាំងចង់ចែករំលែកនូវព្រះបន្ទូលរបស់ព្រះជាពីរចំណែក ដោយមធ្យោបាយបោកប្រាស់របស់វា ។

ព្រះគម្ពីរលោកុប្បត្តិ ៣:២-៣ ចែងថា: **ស្ត្រីឆ្លើយតបថា យើងបរិភោគអស់ទាំងផ្លែឈើនៅក្នុងសួនច្បារបាន តែត្រង់ដើមឈើ១ដែលនៅកណ្តាលសួនច្បារនោះ ព្រះទ្រង់មានបន្ទូលថា កុំឱ្យបរិភោគផ្លែនោះឡើយ ដែលទាំងកុំឱ្យពាល់ប៉ះផង ក្រែងលោស្លាប់ ។**

នាងអេវ៉ាបានបន្ថែមពាក្យថា "កុំឱ្យពាល់ប៉ះ"ទៅលើព្រះបន្ទូលរបស់ព្រះ ដែលទ្រង់មានបន្ទូលពិតប្រាកដ ប៉ុន្តែនាងនៅតែចងចាំនូវបំរាមរបស់ព្រះដដែល ។

⇨ *ជីវិតរបស់សាតាំង*

ខ.៤ "**អ្នកមិនស្លាប់ជាពិតមែនទេ**" ។

សាតាំងបានបញ្ជាក់នូវអ្វីដែលព្រះទ្រង់មានបន្ទូល តែនាងអេវ៉ានៅតែបន្តស្តាប់ ។ បន្ទាប់មកសាតាំងបានសន្យាថាមិនអីទេចំពោះអំពើបាបនោះ ។

⇨ *អ្នកនឹងបានដូចជាព្រះ*

ខ.៥ "**ដ្បិតព្រះទ្រង់ជ្រាបថា នៅថ្ងៃណាដែលអ្នកបរិភោគ នោះភ្នែកអ្នកនឹងបានភ្លឺឡើង ហើយអ្នកនឹងបានដូចជាព្រះដែរ ព្រមទាំងដឹងការខុសត្រូវផង**" ។

សាតាំងបាននិយាយទៅកាន់នាងអេវ៉ា និងលោកអ័ដាមថា "នោះភ្នែកអ្នកនឹងបានភ្លឺឡើង ហើយអ្នកនឹងបានដូចជាព្រះដែរ" ។ ពួកគេបានដូចជាព្រះរួចទៅហើយ តែសាតាំងបានបញ្ឆោតពួកគេឱ្យចង់បានតទៅទៀត ។

## លោកអ័ដាម និងនាងអេវ៉ាបានធ្វើបាប

### អ្នកទាំងពីរបានធ្វើបាប

យើងឃើញរូបភាពនាងអេវ៉ានៅជាមួយនឹងសាតាំងជាច្រើនពេល វាបានសម្ភំពួននឹងសត្វពស់ ហើយបានមកឯនាង នោះគឺជារឿងដែលព្រះគម្ពីរបានចែងមក ។ នៅក្នុងខ.៦ យើងបានអានថា "ព្រមទាំងចែកឱ្យប្តីដែរ គាត់ក៏បរិភោគតាម" ។

ពួកគេបានឈប់ធ្វើតាមព្រះបន្ទូលរបស់ព្រះ និងសម្រេចចិត្តធ្វើតាមបំណងចិត្តរបស់គេវិញ គឺពួកគេបានស្តាប់តាមសាតាំង ដោយបានស៊ីផ្លែឈើដឹងខុសត្រូវនោះ ។

ខ.៦ **កាលស្ត្រីបានឃើញថា ផ្លែឈើនោះបរិភោគបាន ក៏ជាទីគាប់ដល់ភ្នែក ហើយជាដើមដែលល្អមគួរនឹងចង់បាន ដើម្បីឱ្យបានប្រាជ្ញា នោះនាងក៏យកផ្លែមកបរិភោគ ព្រមទាំងចែកឱ្យដល់ប្តីដែរ គាត់ក៏បរិភោគតាម** ។

ពេលដែលលោកអ័ដាមនិងនាងអេវ៉ា លែងស្តាប់បង្គាប់ព្រះ ព្រមទាំងបានបរិភោគផ្លែឈើនោះមក សញ្ញាតិជាព្រះក៏លែងនៅជាមួយពួកគេទៀតឡើយ ។ ពួកគេធ្លាប់បានទទួលនូវសំលៀកបំពាក់ ដែលមានពេញដោយពន្លឺសិរីល្អរបស់ព្រះ តែឥឡូវនេះ ពួកគេបាននៅជាអាក្រាតវិញ ។

ការប្រើដើមឈើដឹងខុសត្រូវ សាតាំងបានបញ្ឆោតលោកអ័ដាម និងនាងអេវ៉ា ឱ្យជាប់មានទោស និងធ្វើឱ្យពួកគេបានចុះចាញ់ ។

សាតាំងមិនដែលផ្លាស់ប្តូរឡើយ ល្បិចកលរបស់វានៅតែដដែល ។

**ពួកគេត្រូវបានបណ្តេញចេញ**

➪ *គេបានចុះចាញ់*

➪ *គេនៅជាអាក្រាត*

សាតាំងបានបោកបញ្ឆោតពួកគេ ហើយមនុស្សជាតិក៏ត្រូវបានដកចេញនូវការគ្រប់គ្រងរបស់ពួកគេ ទាំងផ្នែកគ្រប់គ្រង និងអំណាចអស់រលីង ។

ព្រះគម្ពីរលោកុប្បត្តិ ៣:៧ ចែងថា: **នោះស្រាប់តែផ្នែករបស់អ្នកទាំង២បានភ្លឺឡើង ហើយគេដឹងថាខ្លួននៅជាអាក្រាត ក៏យកស្លឹកល្វាមកក្លាស់ធ្វើជាប្រដាប់បាំង** ។

➪ *ពួកគេខ្លាច*

➪ *ពួកគេបានលាក់ខ្លួន*

សាតាំងបានធ្វើឱ្យលោកអ័ដាមនិងនាងអេវ៉ាទទួលការបរាជ័យ ។ ឥឡូវនេះ មនុស្សដែលបានកើតមកពីដីបានត្រូវបានក្រាបចុះ និងលាក់ខ្លួននៅពីក្រោយគម្ពុតព្រៃទៅវិញ ។

ព្រះគម្ពីរលោកុប្បត្តិ ៣:១០ ចែងថា: **គាត់ទូលឆ្លើយថា ទូលបង្គំបានឮសំឡេងទ្រង់នៅក្នុងសួនច្បារ ក៏រត់ទៅពួន ដោយនឹកភ័យខ្លាច ពីព្រោះនៅខ្លួនទទេ** ។

➪ *ពួកគេនៅក្នុងរូបភាពរបស់ព្រះដដែល*

វាជាការសំខាន់ដើម្បីឱ្យយល់ថា សូម្បីតែបន្ទាប់ពីលោកអ័ដាម និងនាងអេវ៉ាបានធ្វើបាបក៏ដោយ ពួកគេនៅតែបានត្រូវបង្កើតឱ្យមានរូបភាពរបស់ព្រះដដែល ។ ប៉ុន្តែ ពួកគេក៏មិនអាចមានជីវិតរបស់ព្រះ នៅក្នុងគេបានយូរអង្វែងដែរ ។ ពួកគេបានស្លាប់ខាងវិញ្ញាណហើយ ។

ព្រះគម្ពីរលោកុប្បត្តិ ៩:១-២,៦ ចែងថា: **ព្រះទ្រង់ក៏ប្រទានពរដល់លោកណូអេ និងកូនគាត់ ព្រមទាំងមានបន្ទូលថា ចូរបង្កើតកូនឱ្យចំរើនជាច្រើនឡើង ឱ្យបាននៅពេញពាសលើផែនដីចុះ ឯគ្រប់ទាំងសត្វនៅផែនដី សត្វហើរលើអាកាស សត្វលូនវារនៅដី និងត្រីក្នុងសមុទ្រទាំងប៉ុន្មាន នឹងកោតខ្លាច ហើយស្ញប់ស្ញែងដល់ឯងរាល់គ្នា អញប្រគល់វាមកក្នុងអំណាចឯងហើយ អ្នកណាដែលកំចាយឈាមរបស់មនុស្ស នោះឈាមអ្នកនោះឯងនឹងត្រូវខ្ចាយដោយសារមនុស្សដែរ ដ្បិតព្រះទ្រង់បានបង្កើតមនុស្សឱ្យដូចជារូបអង្គទ្រង់** ។

មនុស្សនៅតែបានទៅជា:

➪ *បង្កើតផលផ្លែ*

➪ *បង្កើនពូជពង្ស*

➪ *បង្ក្រប់ផែនដី*

➪ *បង្ក្រាបផែនដី*

➪ *មានអំណាច និងការគ្រប់គ្រង*

ឥឡូវនេះគេនឹងត្រូវបានទទួលការឈឺចាប់ ដោយបែកញើសពេញថ្ងាស គ្រប់ជីវិតទាំងអស់ នឹងរស់នៅដោយភ័យខ្លាចចំពោះមនុស្សជាតិ ។

**រំឭកសារឡើងវិញ**

ព្រះទ្រង់បានបង្កើតលោកអ័ដាម និងនាងអេវ៉ាមក គឺដើម្បីឱ្យបានគ្រប់គ្រងលើផែនដីនេះ។ ទោះជាយ៉ាងណាក៏ដោយ ពេលដែលមនុស្សចាប់ផ្ដើមមិនស្ដាប់បង្គាប់ព្រះ ព្រមទាំងប្រព្រឹត្តផ្ទុយពីបំណងព្រះហឫទ័យរបស់ព្រះមក មនុស្សនោះក៏ត្រូវបានស្លាប់ខាងវិញ្ញាណដែរ ។ មនុស្សត្រូវបានគេប្លន់យកអំណាច និងអំណាចគ្រប់គ្រងដែលព្រះទ្រង់បានប្រទានឱ្យគេ ។

**បំណងព្រះហឫទ័យរបស់ព្រះ គឺសម្រាប់មនុស្សប្រុស-ស្រី ឱ្យពួកគេមានអំណាច និងអំណាចគ្រប់គ្រង ។**

**រីឯបំណងចិត្តរបស់សាតាំងចំពោះមនុស្សជាតិវិញ គឺដើម្បីឱ្យពួកគេបះបោរប្រឆាំងនឹងព្រះ ។**

**លោកអ័ដាម និងនាងអេវ៉ាបានជ្រើសរើសដើម្បីធ្វើការផ្សេងៗ ...**

**ពួកគេមានឆន្ទៈនឹងអនុវត្ត . . .**

**ពួកគេបានរៀបចំឆន្ទៈរបស់គេទៅជាមួយនឹងសាតាំង ។**

**សាតាំងបានលួចមុខងារចេញពីលោកអ័ដាមគឺ:**

**ជាអ្នកគ្រប់គ្រងលោកិយនេះ**

**ជាព្រះអម្ចាស់នៃលោកិយនេះ**

## បន្ទាប់ពីមនុស្សបានធ្វើបាប

**បណ្ដាសាដែលបានមក**

➪ *ចំពោះសត្វពស់*

ចាប់តាំងពីសត្វពស់ បានអនុញ្ញាតឱ្យសាតាំងប្រើរូបកាយរបស់វាមក បណ្ដាសាក៏បានចូលមកក្នុងពួកសត្វពស់ទាំងអស់ផងដែរ ។

ព្រះគម្ពីរលោកុប្បត្តិ ៣:១៤ ចែងថា: **រួចព្រះយេហូវ៉ាដ៏ជាព្រះទ្រង់មានបន្ទូលទៅពស់ថា ដោយព្រោះឯងបានធ្វើដូច្នេះ នោះនៅក្នុងអស់ទាំងពួកសត្វស្រុក សត្វព្រៃ ឯងជាសត្វត្រូវបណ្ដាសាហើយ គឺឯងត្រូវលូនតែនឹងពោះ ហើយត្រូវស៊ីធូលីដីអស់១ជីវិត ។**

➪ *ចំពោះស្ត្រី*

ចំពោះបណ្តាសាដែលមានមកលើស្ត្រីមានពីរផ្នែក ។ នាងត្រូវបង្កើតកូនដោយឈឺចាប់ ហើយបុរសនឹងគ្រប់គ្រងលើនាង ។

ព្រះគម្ពីរលោកុប្បត្តិ ៣:១៦ ចែងថា: **ទ្រង់ក៏មានបន្ទូលទៅស្ត្រីវិញថា អញនឹងចំរើនឱ្យឯងមានសេចក្តីព្រួយលំបាកជាច្រើនឡើង ក្នុងវេលាដែលមានផ្ទៃពោះ ឯងនឹងបង្កើតកូនដោយឈឺចាប់ ចិត្តឯងនឹងប្រាថ្នាខាងឯប្តី ហើយប្តីនឹងត្រួតត្រាលើឯង** ។

ពេលដែលនាងទទួលព្រះយេស៊ូវ ធ្វើជាព្រះអង្គសង្គ្រោះរបស់នាង នោះនាងនឹងបានមកវិញ នូវភាពដែលទ្រង់បានបង្កើតមក ។ ព្រះយេស៊ូវទ្រង់បានត្រឡប់មកជាបណ្តាសា ជំនួសនាងហើយ ។

ព្រះគម្ពីរលោកុប្បត្តិ ៣:១៣ ចែងថា: **រួចព្រះយេហូវ៉ាដ៏ជាព្រះទ្រង់មានបន្ទូលសួរទៅស្ត្រីថា ឯងបានធ្វើដូច្នេះ នាងទូលឆ្លើយថា ពស់វាមកល្បួងបញ្ឆោតខ្ញុំម្ចាស់ ហើយខ្ញុំម្ចាស់បានទទួលទាន** ។

➪ *ចំពោះបុរស*

បណ្តាសាចំពោះបុរស គឺគាត់នឹងត្រូវខំប្រឹងគាស់កាយដី ដោយឈឺចាប់ ទើបបានទទួលអាហារមកបរិភោគ ។

ព្រះគម្ពីរលោកុប្បត្តិ ៣:១៧ ចែងថា: **ដីនឹងដុះជាបន្លាហើយនិងអញ្ចាញឱ្យឯង ឯងនឹងស៊ីអស់ទាំងតិណជាតិដែលដុះនៅស្រែចំការ** ។

➪ *ចំពោះផែនដី*

ផែនដីក៏ត្រូវបណ្តាសាដែរ ។

ខ.១៨-១៩ **ដីនឹងដុះជាបន្លា ហើយនិងអញ្ចាញឱ្យឯង ឯងនឹងស៊ីអស់ទាំងតិណជាតិដែលដុះនៅស្រែចំការ ឯងនឹងបានអាហារស៊ីដោយការបែកញើស ដរាបដល់ឯងត្រឡប់ទៅដីវិញពីព្រោះអញបានយកឯងពីដីមក ដ្បិតឯងជាធូលីដី ក៏ត្រូវត្រឡប់ទៅជាធូលីដីវិញ** ។

➪ *ចំពោះសាតាំង*

នៅពេលដ៏មមាញឹកនោះ សាតាំងក៏បានឆក់ឱកាសយកជ័យដ៏ធំ មកលើមនុស្សផងដែរ ព្រះទ្រង់ក៏បានដាក់បណ្តាសាទៅលើវា ។

ព្រះគម្ពីរលោកុប្បត្តិ ៣:១៥ ចែងថា: **អញនឹងធ្វើឱ្យឯងហើយនិងស្ត្រី គឺទាំងពូជឯងនិងពូជនាងមានសេចក្តីខ្មាំងនឹងគ្នា ពូជនាងនឹងកិនក្បាលឯង ហើយឯងនឹងចឹកកែងជើងគេ ។**

ព្រះទ្រង់មានបន្ទូលទៅកាន់សាតាំង ដែលនៅខាងក្នុងពស់ ហើយប្រាប់វាថា ពូជរបស់ស្ត្រីនឹងជាន់ក្បាលរបស់វា ។

**សេចក្តីសន្យាពីការសង្គ្រោះ!**

បណ្ដាសាដែលបានដាក់មកលើសាតាំង ក៏ជាសេចក្ដីសន្យាលើកទីមួយ នៃព្រះមេស៊ីដែលត្រូវយាងមកផែនដីដែរ ។ "គ្រាប់ពូជ" គឺជាព្រះយេស៊ូវដែលត្រូវមកកើតនឹងស្ត្រី ។

សាតាំងត្រូវតែនៅក្រោមព្រះបាទារបស់ព្រះយេស៊ូវ ។ ក្បាលរបស់វាត្រូវបានកម្ទេច និងជាន់ឈ្លី ។

**រូបមន្តទៅអនាគត**

នៅក្នុងរឿងរ៉ាវនៃការធ្លាក់ចុះរបស់មនុស្ស មានជាច្រើនប្រភេទ ឬជាច្រើនរូបមន្តទៅអនាគត ។

⇨ *ស្លឹកល្វា*

ស្លឹកល្វាដែលលោកអ័ដាម និងនាងអេវ៉ាយកមកប៉ឹងរុំខ្លួនប្រាណ នោះគឺជារូបមន្តនៃការខំប្រឹងប្រែងរបស់មនុស្ស ដើម្បីបិទបាំងនូវអំពើបាបផ្ទាល់របស់គេតែប៉ុណ្ណោះ ។ គេធ្វើរូបមន្តជារបៀបសាសនា ដើម្បីបង្ហាញតាមរយៈមនុស្ស ។

⇨ *ឈាមសត្វពាហន:*

ការបង្ហូរឈាមពីដំបូងត្រូវបានសម្រេចដោយព្រះទ្រង់បានបិទបាំងឱ្យលោកអ័ដាម និងនាងអេវ៉ា ។ នេះគឺជាសញ្ញា ជាប្រភេទរបស់ព្រះយេស៊ូវ ដែលទ្រង់បានបង្ហូរព្រះលោហិត ដើម្បីទទួលទណ្ឌកម្មលាងកំហុស សម្រាប់គ្រប់ទាំងអំពើបាបរបស់លោកិយទាំងមូល ។

**ផែនការរបស់ព្រះ**

ចំណុចនៃសេចក្ដីងងឹតនៅក្នុងប្រវត្តិរបស់មនុស្សជាតិ ព្រះទ្រង់បានរៀបចំផែនការដើម្បីជួយសង្គ្រោះ ។

ព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រារបស់ព្រះ ទ្រង់បានប្រទានជីវិតរបស់ទ្រង់ជំនួសយើង តាមបំណងព្រះហឫទ័យ ។

ដោយការសុគតរបស់ទ្រង់ បានធ្វើឱ្យសាតាំងត្រូវទទួលបរាជ័យ សាតាំងបានប្រកួតនឹងព្រះយេស៊ូវនៅលើភ្នំ ប៉ុន្តែព្រះយេស៊ូវបានជាន់ក្បាលវាជាប់ ។ អំណាចរបស់សាតាំងត្រូវបានជាន់ពន្លិច និងត្រូវបានរៀបចំឱ្យមនុស្ស តាមផែនការដ៏ត្រឹមត្រូវរបស់ព្រះ ។

**ផែនការរបស់សាតាំង**

**ការបោកប្រាស់របស់សាតាំង**

សាតាំងមិនដែលបញ្ឈប់នូវការស្អប់ និងការភ័យដល់មនុស្សប្រុស-ស្រី ដែលត្រូវបានបង្កើតមកឱ្យមានលក្ខណៈ សកម្មភាពដូចជាព្រះនោះទេ ។ ផែនការបោកប្រាស់របស់វា មិនដែលបញ្ឈប់បានឡើយ ។ តាមរយៈការសង្គ្រោះ ការដឹកនាំខាងវិញ្ញាណ ការផ្ដល់នូវអាយុកាល ត្រូវបានទទួលការប្លន់ដោយអំណាចរបស់ពួកវា ។ ពួកវាបានត្រឡប់មកជាម្ចាស់នៃសេចក្ដីងងឹត ។

**កិច្ចការរបស់សាតាំង**

សាតាំងបានរៀបចំកម្លាំងរបស់វា ចូលទៅក្នុងផែនការចម្បាំងយ៉ាងពេញលេញ ។ ម្ចាស់

នៃសេចក្ដីងងឹតនេះ បានធ្វើការទៅតាមជនជាតិនីមួយៗ ទាំងបុរស ទាំងស្ត្រី ទាំងក្មេង ដើម្បីដាក់គេចូលទៅក្នុងចំណង ។ គោលបំណងរបស់វា គឺលួច សម្លាប់ និងបំផ្លាញ ។

ព្រះទ្រង់បានរៀបចំច្បាប់សម្រាប់មនុស្សជាតិ ដើម្បីឱ្យពួកគេចេះអត់ទោសបាប និងដើរនៅក្នុងការរួបរួមដោយមានព្រះអង្គ ។ ប៉ុន្តែ ជាងបួនពាន់ឆ្នាំមកនេះ សាតាំងបានរស់នៅដោយមានអំណាចគ្រប់គ្រងលើផែនដី ពីព្រោះតែការមិនស្ដាប់បង្គាប់របស់មនុស្សជាតិ ។

## សំណួររំឭកសារឡើងវិញ

១- ចូរពន្យល់នូវមូលហេតុដែលសាតាំងមានកំហឹងដ៏ខ្លាំងក្លា ចំពោះស្នាព្រះហស្តរបស់ព្រះ ដែលទ្រង់បានហៅមនុស្សប្រុស-ស្រីមក ។

២- ចូរពណ៌នានូវការធ្វើបាប និងការធ្លាក់ចុះរបស់មនុស្ស ។

៣- តើសេចក្ដីសន្យានៃការប្រោសលោះរបស់ព្រះ បានបើកសម្ដែងមកនៅក្នុងព្រះគម្ពីរលោកុប្បត្តិ ៣:១៥ យ៉ាងដូចម្ដេចខ្លះ?

# មេរៀនទី៤
# ពេលដែលព្រះយេស៊ូវយាងមកគឺជាផែនការរបស់ព្រះ

**អ័ដាមទីមួយ_អ័ដាមទីពីរ**

**ព្រះទ្រង់ចាត់ព្រះរាជបុត្រាទ្រង់**

ពេលដែលលោកអ័ដាម និងនាងអេវ៉ាបានធ្វើបាបពីដំបូង ព្រះទ្រង់បានសន្យាថា នឹងបញ្ជូនព្រះរាជបុត្រាទ្រង់មកធ្វើជាពូជរបស់ស្ត្រី ឱ្យបានជាន់ក្បាលរបស់សាតាំង ( លប ៣:១៥ ) ។ លោកសាវកប៉ុលបានប្រាប់យើងពីព្រឹត្តិការណ៍នេះ ព្រមទាំងដំណាលប្រាប់នូវសេចក្តីសន្យាដំបូងរបស់អ្នកប្រោសលោះផងដែរ ។

ព្រះគម្ពីរលោកុប្បត្តិ ៤:៤-៥ ចែងថា: **ហើយអេបិលក៏ធ្វើដូចគ្នា គឺគាត់យកកូនជាដំបូង ១ពីហ្វូងសត្វមកថ្វាយ ព្រមទាំងខ្លាញ់វាផង រួចព្រះយេហូវ៉ាទ្រង់សព្វព្រះហឫទ័យចំពោះអេបិល និងដង្វាយរបស់គាត់ តែមិនសព្វព្រះហឫទ័យចំពោះដង្វាយរបស់កាអ៊ីនទេ នោះកាអ៊ីនក៏ក្តៅក្រហាយ ហើយឡើងទឹកមុខក្រញូវ** ។

ការប្រកបទាក់ទងរបស់មនុស្សចំពោះព្រះ ព្រមទាំងអំណាចរបស់គាត់ ត្រូវបានកែជាថ្មីឡើងវិញ ដោយយញ្ញបូជាជំនួសដែលព្រះយេស៊ូវទ្រង់បានសុគតនៅលើឈើឆ្កាង ។

ការប្រោសលោះឱ្យរួចពីបាប ពីទោស និងពីបណ្តាសាក្រឹត្យវិន័យ មនុស្សត្រូវបានកើតជាថ្មីនៅក្នុងគ្រួសាររបស់ព្រះ ។ គាត់បានកើតជាថ្មី និងបានទទួលព្រះវិញ្ញាណរបស់ព្រះនៅក្នុងខ្លួនវិញ ។

**លោកអ័ដាមបាននាំអំពើបាបចូលមក**

អំពើបាបបានចូលមកក្នុងលោកិយនេះ ដោយសារការមិនស្តាប់បង្គាប់របស់លោកអ័ដាម

ព្រះគម្ពីររ៉ូម ៥:១២ ចែងថា: **ដូច្នេះ ដែលបាបបានចូលមកក្នុងលោកិយ ដោយសារមនុស្សតែម្នាក់ ហើយក៏មានសេចក្តីស្លាប់ចូលមកដែរ ដោយសារអំពើបាបនោះយ៉ាងណា នោះសេចក្តីស្លាប់បានឆ្លងរាលដាល ដល់មនុស្សគ្រប់គ្នាយ៉ាងនោះដែរ ដ្បិតគ្រប់គ្នាបានធ្វើបាបហើយ ។**

**ព្រះយេស៊ូវទ្រង់បាននាំមក**

⇨ *សេចក្តីសុចរិត*

តាមរយៈការស្តាប់បង្គាប់របស់មនុស្សតែម្នាក់ គឺជាព្រះយេស៊ូវ ធ្វើឱ្យមនុស្សជាច្រើនបានត្រឡប់ជាសុចរិតពេញលេញ ។

ខ.១៩ **ដ្បិតដូចជាមនុស្សជាច្រើន បានត្រឡប់ជាមានបាប ដោយសារមនុស្សតែម្នាក់មិនបានស្តាប់បង្គាប់ជាយ៉ាងណា នោះមនុស្សជាច្រើន ក៏បានត្រឡប់ទៅជាសុចរិតដោយសារម្នាក់បានស្តាប់បង្គាប់វិញយ៉ាងនោះដែរ ។**

➪ *ដំណឹងល្អ*

បន្ទាប់ពីលោកអ័ដាម និងនាងអេវ៉ាបានធ្វើបាបមក ពេលដែលពួកគេបានដឹងថា ព្រះទ្រង់បានយាងចូលមក ពួកគេបានលាក់ខ្លួននៅពីក្រោយគម្ពតព្រៃ ។ ឥឡូវនេះ ព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ ទ្រង់កំពុងតែយាងមក ហើយទេវតានៃព្រះបាននិយាយថា "កុំខ្លាចអី! នេះជាដំណឹងល្អសម្រាប់លោកអ្នកហើយ" ។

ព្រះគម្ពីរលូកា ២:១០-១១ ចែងថា: **តែទេវតាប្រាប់ថា កុំខ្លាចអី មើល ខ្ញុំមកប្រាប់ដំណឹងល្អដល់អ្នករាល់គ្នា ពីសេចក្តីអំណរយ៉ាងអស្ចារ្យ ដែលសំរាប់បណ្តាជនទាំងអស់គ្នា ដ្បិតនៅថ្ងៃនេះ មានព្រះអង្គសង្គ្រោះ១អង្គ ប្រសូតដល់អ្នករាល់គ្នានៅក្រុងហ្លួងដាវីឌ គឺជាព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់ ។**

➪ *សេចក្តីសុខសាន្តមកដល់មនុស្ស*

ទេវតាមួយរូបបានថ្លែងព្រះរាជសារមកដល់ហោរា នៅក្រុងបេថ្លេហិម ស្រុកភ្នំនៅយប់នោះ ហើយសេចក្តីអំណរដ៏ធំនៅឯស្ថានសួគ៌ ក៏មានពេញជាអនេកអនន្តរ៍ដែរ ។

ខ.១៣-១៤ **នោះស្រាប់តែមានពួកពលបរិវារកកកុញពីស្ថានសួគ៌ មកនៅជាមួយនឹងទេវតានោះ ក៏ពោលសរសើរដល់ព្រះថា សួស្តីដល់ព្រះនៅស្ថានដ៏ខ្ពស់បំផុត ហើយសេចក្តីសុខសាន្តនៅផែនដី នៅកណ្តាលមនុស្ស ដែលជាទីគាប់ព្រះហឫទ័យដល់ទ្រង់ ។**

តើគួរឱ្យអស្ចារ្យអ្វីម្ល៉េះហ្ន៎ ដែលដែលសេចក្តីសន្យាបានប្រទានមកយ៉ាងដូច្នេះ គឺដែលព្រះគ្រីស្ទទ្រង់បានកើតមក! "សេចក្តីសុខសាន្តនៅផែនដី នៅកណ្តាលមនុស្ស" ។

> **គ្មានអ្វីនឹងថ្លាថ្លែងសេចក្តីអំណរដែលបានទុកនៅលើផែនដីទាំងមូលនេះឡើយ ។**
> **ពួកទេវតាមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង**
> **ពួកគេបានផ្ទុះសំណើចដោយបានឃើញពួកអ្នកគង្វាល**
> **កំពុងតែច្រៀងសរសើរ ។**
> **សូម្បីតែហ្វូងតារាទាំងឡាយក៏បានប្រកាសពីកំណើតរបស់ព្រះអង្គដែរ**

## ព្រះយេស៊ូវទ្រង់បានបំពេញព្រះរាជកិច្ចជាមនុស្សនៅផែនដីនេះ

តើព្រះយេស៊ូវទ្រង់បានចម្រើនអំណាចចេស្តាជាព្រះ ពេលដែលទ្រង់គង់នៅផែនដីនេះ ឬក៏ទ្រង់បានចម្រើនអំណាចចេស្តាជាមនុស្ស ដែលទ្រង់បានប្រទានឱ្យដោយព្រះវិញ្ញាណបរិសុទ្ធ?

**ព្រះយេស៊ូវគឺជាលោកអ័ដាមចុងក្រោយ**

លោកសាវកប៉ុលបានបញ្ជាក់ថា ព្រះយេស៊ូវជាលោកអ័ដាមចុងក្រោយ ។

ព្រះគម្ពីរ ១កូរិនថូស ១៥:៤៥ ចែងថា: **ដូចជាសេចក្ដីដែលចែងទុក ពីលោកអ័ដាម ដែលជាមនុស្សមុនដំបូងថា "បានត្រឡប់ជាមានព្រលឹងរស់" តែលោកអ័ដាមក្រោយបង្អស់ ជាវិញ្ញាណដ៏ប្រោសឱ្យរស់វិញ** ។

ព្រះយេស៊ូវគឺជាលោកអ័ដាមចុងក្រោយ ទ្រង់បានយាង និងបំពេញព្រះរាជកិច្ច ដោយអំណាចនៅផែនដីនេះ ព្រោះតែទ្រង់បានបង្កើតលោកអ័ដាមទីមួយមក ដើម្បីបំពេញបំណងព្រះហឫទ័យរបស់ព្រះអង្គ ។

វាជាការសំខាន់បំផុត ដើម្បីឱ្យយើងអាចយល់នូវរឿងនេះ ពីព្រោះវា មិនត្រឹមតែបានសម្រេចតាមក្រឹត្យវិន័យប៉ុណ្ណោះទេ គឺជាលោកអ័ដាមចុងក្រោយ ដែលទ្រង់បានធ្វើឱ្យយើងរួចពីបន្ទុកក្រឹត្យវិន័យ ។ ទាល់តែទ្រង់យាងមកកើតជាមនុស្សជាតិ ទើបទ្រង់អាចត្រឡប់មកជាព្រះអង្គសង្គ្រោះរបស់យើងបាន ។ វាជាការចាំបាច់ដែលទ្រង់បានធ្វើឱ្យអារក្សចុះចាញ់ គឺទ្រង់បានត្រឡប់មកជាមនុស្ស ដើម្បីយកអំណាចដែលសាតាំងបានប្លន់យកពីលោកអ័ដាមដំបូងនោះ មកឱ្យដល់មនុស្សវិញ ។

តាំងតែពីព្រះយេស៊ូវទ្រង់បាននៅជាមនុស្សដែលគ្រប់លក្ខណ៍ គឺជាលោកអ័ដាមមុនដំបូងនោះ ទ្រង់បានប្រទានអំណាចដល់លោកអ័ដាមនោះរួចទៅហើយ ។ ពេលដែលព្រះវិញ្ញាណបរិសុទ្ធបានយាងមកសណ្ឋិតលើទ្រង់ នោះទ្រង់ក៏មានអំណាចរបស់ព្រះនៅជាមួយនឹងទ្រង់ដែរ ។

**ព្រះយេស៊ូវទ្រង់បានទទួលបុណ្យជ្រមុជទឹក**

⇨ *ព្រះវិញ្ញាណបរិសុទ្ធយាងមកសណ្ឋិតលើទ្រង់*

លោកយ៉ូហានបាប់ទិស្ទបានឃើញព្រះវិញ្ញាណនៃព្រះ យាងមកសណ្ឋិតលើព្រះយេស៊ូវ ហើយព្រឹត្តិការណ៍នេះ គឺជាការសំខាន់បំផុតដែលបានកត់ត្រាទុកនៅក្នុងព្រះគម្ពីរដំណឹងល្អទាំងបួន (ម៉ាកុស ១:១០ លូកា ៣:២២ យ៉ូហាន ១:៣២) ។

ព្រះគម្ពីរម៉ាថាយ ៣:១៦ ចែងថា: **កាលព្រះយេស៊ូវទទួលបុណ្យជ្រមុជហើយ នោះទ្រង់យាងឡើងពីទឹកភ្លាម ស្រាប់តែមេឃក៏របើកឡើង ឱ្យទ្រង់ឃើញព្រះវិញ្ញាណនៃព្រះ យាងចុះមកដូចជាសត្វព្រាប ក៏សណ្ឋិតលើទ្រង់** ។

⇨ *ការអស្ចារ្យបានបើកសម្ដែង*

ព្រះយេស៊ូវទ្រង់មិនបានសម្ដែងការអស្ចារ្យ ពីឆ្នាំដំបូងនៃជីវិតរបស់ទ្រង់នោះទេ ប៉ុន្តែពេលដែលទ្រង់បានចាប់ផ្ដើមព្រះរាជកិច្ចជាសាធារណៈ នោះព្រះវិញ្ញាណបរិសុទ្ធបានយាងមកសណ្ឋិតលើទ្រង់ ។ បន្ទាប់មក ព្រះយេស៊ូវទ្រង់បានចាប់ផ្ដើមធ្វើការដោយព្រះវិញ្ញាណបរិសុទ្ធ ។

អំណាចរបស់ព្រះបានចាប់ផ្ដើមជាមួយនឹងព្រះវិញ្ញាណរបស់ព្រះ ធ្វើឱ្យអំណាចទាំងពីរនេះបានទទួលជោគជ័យ!

**ព្រះយេស៊ូវទ្រង់បានបោះបង់សេចក្ដីសុចរិតជាព្រះ**

⇨ *ទ្រង់បានក្លាយមកជាទទេ*

លោកសាវកប៉ុលបានផ្តល់ឱ្យយើងនូវគំនិត ដែលមាននៅក្នុងព្រះគ្រិស្ទ នៅពេលដែលទ្រង់បានយាងមកផែនដីនេះ ។ លោកបានសរសេរថា . . .

ព្រះគម្ពីរភីលីព ២:៥-៨ ចែងថា: **ត្រូវតែមានគំនិត គិតដូចព្រះគ្រីស្ទយេស៊ូវវិញ ដែលទោះបើទ្រង់មានរូបអង្គជាព្រះក៏ដោយ គង់តែមិនបានរាប់សេចក្តីដែលស្មើនឹងព្រះនោះ ទុកជាសេចក្តីដែលគួរកាន់ខ្ជាប់ឡើយ គឺទ្រង់បានលះបង់ព្រះអង្គទ្រង់ មកយករូបភាពជាបាវបំរើវិញ ព្រមទាំងប្រសូតមកមានរូបជាមនុស្សផង ហើយដែលឃើញទ្រង់មានភាពជាមនុស្សដូច្នោះ នោះក៏បន្ទាបព្រះអង្គទ្រង់ ទាំងចុះចូលស្តាប់បង្គាប់ រហូតដល់ទីមរណៈ គឺទ្រង់ទទួលសុគតជាប់លើឈើឆ្កាងផង ។**

ព្រះយេស៊ូវទ្រង់មានបំណង:

- ⇨ *លះបង់កិត្តិស័ព្ទ*
- ⇨ *យករូបភាពជាបាវបម្រើ*
- ⇨ *មកជាមនុស្ស*
- ⇨ *បន្ទាបអង្គទ្រង់*
- ⇨ *ស្តាប់បង្គាប់រហូតដល់មរណា*

ព្រះយេស៊ូវទ្រង់មានសញ្ជាតិជាព្រះ ថ្វីដ្បិតតែទ្រង់មានភាពស្មើនឹងព្រះក៏ដោយ ក៏ទ្រង់មិនបានប្រៀបអង្គទ្រង់ស្មើនឹងព្រះដែរ គឺទ្រង់បានចាប់យកមុខងារទ្រង់នៅលើផែនដី និងធ្វើជាមនុស្សវិញ ។ ទ្រង់បានចាប់យកតួនាទីជាបាវបម្រើ និងលក្ខណៈភាពជាមនុស្សវិញ ។ ទ្រង់ក៏បានបន្ទាបអង្គទ្រង់ និងចុះចូលរហូតដល់មរណា ។ ទ្រង់បានយាងមកផែនដីនេះ ដើម្បីមកកើតជាមនុស្ស ហើយអំណាចដែលទ្រង់មាននៅផែនដីនេះ គឺបានមកពីព្រះវិញ្ញាណបរិសុទ្ធ ។

**ហេតុអ្វីបានជារឿងនេះជាការសំខាន់?**

លោកអ័ដាមជាមនុស្សដំបូង ដែលមិនបានស្តាប់បង្គប់ដល់ព្រះ ហើយបានប្រគល់អំណាចរបស់គាត់ឱ្យទៅសាតាំងទៀតផង ។ ព្រះយេស៊ូវជាលោកអ័ដាមចុងក្រោយ ទ្រង់បានធ្វើគ្រប់ការទាំងអស់នៅលើផែនដីជាមនុស្ស ដែលបានទទួលអំណាចពីព្រះវិញ្ញាណរបស់ព្រះមក ទ្រង់ជាមនុស្សគ្រប់លក្ខណៈ ដែលបានធ្វើការនៅលើផែនដីនេះ ដូចជាលោកអ័ដាមដែលត្រូវបានបង្កើតមកឱ្យមានការងារយ៉ាងដូច្នោះដែរ ។

## ទ្រង់ជាកូនមនុស្ស

ពេលដែលព្រះយេស៊ូវទ្រង់បានគង់នៅផែនដីនេះ អំណាចដែលទ្រង់បានប្រើគឺជាអំណាចនៃកូនមនុស្ស ។ នៅក្នុងព្រះគម្ពីរយ៉ូហាន បានជ្រើសយកពាក្យ "ព្រះរាជបុត្រានៃព្រះ" មកជា "កូនមនុស្ស" វិញ ។

ព្រះគម្ពីរយ៉ូហាន ៥:២៥-២៧ ចែងថា: **ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នា ជាប្រាកដថានឹងមានពេលវេលាមក ក៏មកដល់ហើយ ដែលមនុស្សស្លាប់នឹងឮសម្លេងព្រះរាជបុត្រានៃព្រះ**

**ហើយអស់អ្នកណាដែលឮនឹងបានរស់វិញ ពីព្រោះដែលព្រះវរបិតាមានជីវិតក្នុងព្រះអង្គទ្រង់យ៉ាងណា នោះទ្រង់ក៏បានប្រទានឱ្យ ព្រះរាជបុត្រាមានជីវិត ក្នុងព្រះអង្គទ្រង់យ៉ាងនោះដែរ ហើយបានប្រទានអំណាចមកទ្រង់ ឱ្យជំនុំ ជម្រះផង ពីព្រោះទ្រង់ជាកូនមនុស្ស ។**

សេចក្តីស្លាប់នឹងឮសម្លេងព្រះរាជបុត្រានៃព្រះ ។ នៅខាងក្រៅផែនដីនេះ ព្រះយេស៊ូវទ្រង់បានបំពេញជាចំណែកនៃព្រះត្រៃឯក ។

នៅផែនដីនេះ ព្រះយេស៊ូវទ្រង់បានដើរដោយអំណាច ពីព្រោះទ្រង់ជាកូនមនុស្ស ។ មនុស្សត្រូវបានបង្កើតឡើង ឱ្យបានដើរដោយអំណាច និងអំណាចគ្រប់គ្រង ។ ភាពមនុស្សជាតិរបស់ព្រះយេស៊ូវ គឺជាអ្នកដែលមានអំណាច ។ បានជាទ្រង់មានអំណាចយ៉ាងដូច្នោះ ពីព្រោះព្រះយេស៊ូវទ្រង់គឺជាកូនមនុស្ស ជាលោកអ័ដាមចុងក្រោយ មិនមែនដោយព្រោះទ្រង់ជាព្រះរាជបុត្រានៃព្រះនោះទេ ។

**ប្រសិនបើព្រះយេស៊ូវធ្វើបាន យើងក៏អាចធ្វើបានដែរ**

ព្រះយេស៊ូវទ្រង់បានធ្វើកិច្ចការរបស់មនុស្ស ដូចជាមនុស្សដែលព្រះទ្រង់បានបង្កើតមកឱ្យបានធ្វើនៅផែនដីយ៉ាងដូច្នោះដែរ ។ ទ្រង់បានធ្វើការដោយអំណាចចេស្តាព្រះវិញ្ញាណបរិសុទ្ធ ។ គឺមិនមែននៅក្នុងអំណាច**ព្រះរាជបុត្រានៃព្រះ**នោះទេ !

នេះគឺជាការសំខាន់បំផុតសម្រាប់យើង ។ ប្រសិនបើព្រះយេស៊ូវទ្រង់បំពេញព្រះរាជកិច្ចជាមនុស្សនៅផែនដីនេះ ដូច្នេះយើងក៏អាចធ្វើគ្រប់ការទាំងអស់ដូចជាទ្រង់បានធ្វើដែរ ។ យើងក៏មានអំណាចចេស្តា និងសេចក្តីសុចរិតគ្រប់អស់ ដែលព្រះយេស៊ូវទ្រង់មាន ពេលដែលទ្រង់បានគង់នៅផែនដី**ជាមនុស្ស**នោះដែរ ។

## ទ្រង់បានប្រឈមមុខនឹងសេចក្តីល្បួងដូចមនុស្សយើងដែរ

**ទ្រង់ទទួលសេចក្តីល្បួងដូចជាយើងទទួលដែរ**

ព្រះទ្រង់បានប្រទានដល់លោកអ័ដាម និងនាងអេវ៉ានូវបំណងចិត្ត ការជ្រើសរើស និងឆន្ទៈដោយសេរី ។ ព្រះយេស៊ូវក៏មានឆន្ទៈដូចគ្នានេះដែរ ។

ដើម្បីឱ្យបានក្លាយជាលោកអ័ដាមចុងក្រោយដ៏ពេញលេញនោះ ព្រះយេស៊ូវទ្រង់បានទទួលនូវការរងទុក្ខ និងត្រូវសេចក្តីល្បួងផងដែរ ។

**លោកអ័ដាម និងនាងអេវ៉ា បានត្រូវទទួលសេចក្តីល្បួងក្នុងលក្ខណៈបីយ៉ាងៈ**

⇨ **ផ្នែករូបរាងកាយ** *-នាងអេវ៉ាបានឃើញផ្លែឈើដែលជាចំណីអាហារល្អ ។*

⇨ **ផ្នែកព្រលឹង** *-សាតាំងបានសន្យាជាមួយនាងថា នឹងមានប្រាជ្ញា ដឹងខុសត្រូវ ។*

⇨ **ផ្នែកវិញ្ញាណ** *-ចុងក្រោយវាបានសន្យានឹងនាងថា នឹងបានដូចជាព្រះ ។*

ព្រះយេស៊ូវក៏ត្រូវបានទទួលសេចក្តីល្បួងដូចលក្ខណៈនេះដែរ ។

**សេចក្តីល្បួងទី១ -រូបកាយ**

ព្រះយេស៊ូវទ្រង់បានគង់នៅវាលរហោស្ថានអស់៤០ថ្ងៃ ។ សាតាំងបានមកល្បួង នៅក្នុង

ពេលដែលរូបកាយខ្សោយ វាមកល្បួងព្រះយេស៊ូវដោយឱ្យព្រះអង្គប្រើអំណាចចេស្តា ជាព្រះរាជបុត្រានៃព្រះ ដើម្បីឱ្យព្រះអង្គចម្អែតអង្គទ្រង់ជាមនុស្សភាព ។ ប៉ុន្តែព្រះយេស៊ូវទ្រង់បានផ្ទុកផ្តាក់ការទាំងអស់ទៅលើព្រះ ដោយពេលដែលទ្រង់បានយាងមកផែនដីនេះ គឺដើម្បីបំពេញព្រះរាជកិច្ចរបស់ព្រះអង្គជាកូនមនុស្ស ។

➪ *សេចក្តីត្រូវការចម្អែតកាយរបស់មនុស្ស*

ព្រះគម្ពីរម៉ាថាយ ៤:១-៣ ចែងថា: **នោះព្រះវិញ្ញាណក៏នាំព្រះយេស៊ូវ ទៅឯទីរហោស្ថាន ដើម្បីឱ្យត្រូវអារក្សល្បួង កាលទ្រង់បានតម៤០ថ្ងៃ៤០យប់ហើយ ក្រោយមកទ្រង់ឃ្លាន រួចមេល្បួងក៏មកទូលទ្រង់ថា បើអ្នកជាព្រះរាជបុត្រានៃព្រះមែន ចូរបង្គាប់ថ្មទាំងនេះឱ្យត្រឡប់ជានំបុ័ងទៅ ។**

ពេលដែលមេល្បួងបានចូលមកឯទ្រង់ វានិយាយថា "បើអ្នកជាព្រះរាជបុត្រានៃព្រះមែន ចូរអ្នកប្រើសិទ្ធិរបស់អ្នកជាព្រះទៅ ។ ប្រសិនបើអ្នកជាព្រះរាជបុត្រានៃព្រះមែន ចូរអ្នកបញ្ជាទៅថ្មនេះ ឱ្យត្រឡប់ជានំបុ័ងទៅ" ។

ប្រសិនបើព្រះយេស៊ូវទ្រង់បានធ្វើថ្មឱ្យត្រឡប់ទៅជានំបុ័ងមែន ទ្រង់នឹងមិនអាចបំពេញព្រះរាជកិច្ចជាមនុស្សបានឡើយ ។ ទ្រង់គួរតែបានប្រើអំណាចទ្រង់ជាព្រះ ។ ប្រសិនបើទ្រង់បានធ្វើយ៉ាងដូច្នោះ នោះសាតាំងនឹងធ្វើឱ្យព្រះអង្គត្រូវបរាជ័យ ទាំងលោកអ័ដាមទីមួយ និងលោកអ័ដាមទី២ជាមិនខាន ។

➪ *ព្រះយេស៊ូវទ្រង់បានឆ្លើយ*

ព្រះយេស៊ូវទ្រង់បានឆ្លើយទៅសាតាំង ដោយយកព្រះបន្ទូលរបស់ព្រះមកថា:

"**មនុស្សមិនមែនរស់ដោយសារតែនំបុ័ងប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូលដែលចេញពីព្រះឱស្ឋព្រះមកដែរ**" (ម៉ាថាយ ៤:៤) ។

ចូរចាំថា ព្រះយេស៊ូវទ្រង់ប្រកាសដោយអង្គទ្រង់ថា ទ្រង់ជាមនុស្ស ។

ខ.៥ **នោះអារក្សក៏នាំទ្រង់ទៅឯក្រុងបរិសុទ្ធ ដាក់លើកំពូលព្រះវិហារ** . . . ។

**សេចក្តីល្បួងទី២ -ព្រលឹង**

សេចក្តីល្បួងទីពីរ គឺផ្នែកខាងវិញ្ញាណ សាតាំងបានល្បួងព្រះយេស៊ូវ ដោយឱ្យហេតុផលផ្ទុយពីបំណងព្រះហឫទ័យរបស់ព្រះ ចំពោះការរស់នៅ និងអារម្មណ៍របស់ទ្រង់ ។

➪ *ការបញ្ជាក់ដោយខ្លួនឯង*

ខ.៦ **ទូលថា បើអ្នកជាព្រះរាជបុត្រានៃព្រះមែន ចូរទំលាក់ខ្លួនទៅក្រោមចុះ ដ្បិតមានសេចក្តីចែងទុកមកថា "ទ្រង់នឹងបង្គាប់ពួកទេវតានៃទ្រង់ ពីដំណើរអ្នក ទេវតានឹងទ្រអ្នកដោយដៃ ក្រែងលោជើងអ្នកទង្គិចនឹងថ្ម" ។**

នេះគឺជាសេចក្តីល្បួងបន្តទៅទៀត ។ "ប្រសិនបើអ្នកជាព្រះរាជបុត្រានៃព្រះមែន. . ." សាតាំងបានដឹងថា ទ្រង់ជាព្រះរាជបុត្រានៃព្រះមែន ។ ជីវិតរបស់ព្រះយេស៊ូវនៅផែនដីនេះ គឺត្រូវ

បានរស់នៅជាកូនមនុស្ស ជាលោកអ័ដាមចុងក្រោយ ។

⇨ *ព្រះយេស៊ូវទ្រង់បានឆ្លើយ*

ព្រះយេស៊ូវទ្រង់បានធ្វើសាតាំងបរាជ័យ ដោយទ្រង់ប្រើព្រះបន្ទូលត្រូវតាព្រះបន្ទូលរបស់ព្រះ ។ ព្រះយេស៊ូវទ្រង់ជ្រាបច្បាស់ថា ទ្រង់ជាព្រះអម្ចាស់ ហើយសាតាំងក៏ដឹងដែរ ។

ខ.៧ **ព្រះយេស៊ូវមានបន្ទូលទៅវាថា មានសេចក្តីចែងទុកដូច្នេះទៀត "កុំឱ្យឯងល្បងព្រះអម្ចាស់ជាព្រះនៃឯងឡើយ" ។**

**សេចក្តីល្បងទី៣ -វិញ្ញាណ**

នៅក្នុងសេចក្តីល្បងទី៣នេះ សាតាំងបានផ្តល់ឱ្យព្រះយេស៊ូវនូវនគរទាំងអស់ ដែលនៅលើផែនដីនេះ ។ រឿងនោះមិនមែនជាហេតុផល ដែលព្រះយេស៊ូវទ្រង់បានយាងមកផែនដីនេះទេឬ? រឿងនេះ តើព្រះអង្គយាងមក មិនមែនដើម្បីដណ្តើមយកផែនដីពីសាតាំងត្រឡប់ទៅវិញទេឬអី?

⇨ *ធ្វើជាព្រះរបស់លោកិយនេះ*

ព្រះគម្ពីរម៉ាថាយ ៤:៨-៩ ចែងថា: **មួយទៀត អារក្សបាននាំទ្រង់ទៅលើកំពូលភ្នំយ៉ាងខ្ពស់ ក៏បង្ហាញអស់ទាំងនគរក្នុងលោកិយ និងសិរីលំអរបស់នគរទាំងនោះថ្វាយទ្រង់ទត រួចទូលថា បើសិនជាអ្នកក្រាបថ្វាយបង្គំខ្ញុំ នោះខ្ញុំនឹងឱ្យរបស់ទាំងនេះដល់អ្នក** ។

សាតាំងមានអំណាចអាចប្រគល់នគរទាំងនេះឱ្យទៅព្រះយេស៊ូវ ។ សាតាំងបានប្រើល្បិចកលប្លន់យកអំណាចពីលោកអ័ដាម បន្ទាប់មកវាបានធ្វើជាអ្នកគ្រប់គ្រងផែនដីនេះ ។ ប៉ុន្តែព្រះយេស៊ូវទ្រង់មិនបានចាប់អារម្មណ៍ នឹងទទួលយកផែនដីនេះពីសាតាំងវិញដោយវិធីនេះទេ បើធ្វើយ៉ាងដូច្នោះមានន័យថា ទ្រង់មិនបានស្តាប់បង្គាប់ព្រះវរបិតាទេ ។

⇨ *ព្រះយេស៊ូវទ្រង់បានឆ្លើយ*

ព្រះយេស៊ូវទ្រង់មិនបានជជែកវែកញែកអ្វីជាមួយនឹងសាតាំងទេ។ ទ្រង់ក៏មិនបានឈ្លោះជាមួយនឹងវាដែលជាអ្នកគ្រប់គ្រងលោកិយនេះនោះដែរ។ ព្រះយេស៊ូវទ្រង់បានមានបន្ទូលទៅកាន់វាឱ្យចាកចេញវិញ ។ ទ្រង់បានមានបន្ទូលដោយព្រះបន្ទូលនៃព្រះម្តងទៀត ។

ព្រះគម្ពីរម៉ាថាយ ៤:១០ ចែងបន្តទៀតថា: **នោះព្រះយេស៊ូវមានបន្ទូលតបថា នែសាតាំង ចូរឯងថយចេញពីអញទៅ ដ្បិតមានសេចក្តីចែងទុកមកថា "ឯងត្រូវថ្វាយបង្គំដល់ព្រះអម្ចាស់ជាព្រះនៃឯង ហើយត្រូវគោរពដល់ទ្រង់តែមួយព្រះអង្គប៉ុណ្ណោះ" ។**

**រំឭកសារឡើងវិញ**

ប្រសិនបើព្រះយេស៊ូវទ្រង់ធ្វើសកម្មភាពជាព្រះរាជបុត្រានៃព្រះ ពេលដែលសាតាំងបានល្បងព្រះអង្គឱ្យធ្វើនោះ ទ្រង់ច្បាស់ជាត្រូវបោះបង់នូវសេចក្តីសុចរិតរបស់ព្រះអង្គជាកូនមនុស្សហើយ ។ ទ្រង់គួរគប្បីត្រូវបានផ្ទុកផ្តាក់ ឱ្យបានជាអ្នកជំនួសដ៏គ្រប់លក្ខណ៍ ដើម្បីធ្វើជាអ្នកប្រោសលោះរបស់មនុស្សជាតិ ។

សាតាំងបានឱ្យដល់ព្រះយេស៊ូវនូវការដ៏លំបាក ដែលព្រះអង្គទ្រង់យាងមកផែនដី ដើម្បីយកជ័យជម្នះត្រឡប់ទៅវិញ គឺយកសិទ្ធិគ្រប់គ្រងផែនដីនេះ ។ វាគួរតែប្បីតែបាន "ងាយស្រួល" យ៉ាងដូច្នោះ ដើម្បីធ្វើការនោះតាមមធ្យោបាយរបស់សាតាំង ដោយទ្រង់មិនចាំបាច់ត្រូវសុគតនៅលើឈើឆ្កាង ។ ព្រះយេស៊ូវទ្រង់បានជ្រាបថា បើគ្មានការបង្ហូរឈាមរបស់ព្រះអង្គទេ នោះនឹងគ្មានការលោះបាបបានឡើយ ។

សូម្បីតែព្រះយេស៊ូវទ្រង់បានសុគតលើឈើឆ្កាងក៏ដោយ ក៏សាតាំងនៅតែចំអកឱ្យព្រះយេស៊ូវ តាមរយៈមនុស្ស ជាមួយនឹងពាក្យសម្ដីដូចគ្នានេះដែរ ។

ព្រះគម្ពីរម៉ាថាយ ២៧:៤០ ចែងថា: **ឯងដែលបំផ្លាញព្រះវិហារ ហើយសង់ឡើងវិញក្នុងរវាង៣ថ្ងៃអើយ ចូរជួយសង្គ្រោះខ្លួនចុះ បើឯងជាព្រះរាជបុត្រានៃព្រះមែន នោះឱ្យចុះពីឈើឆ្កាងមក ។**

ជានិច្ចកាល សាតាំងតែងឱ្យការដ៏លំបាកដល់យើង ដែលព្រះទ្រង់បានសន្យាថា នឹងប្រទានឱ្យយើងហើយ ។ គ្រប់ទាំងអស់យើងត្រូវតែធ្វើទៅតាមសេចក្ដីសន្យា ចំពោះចំណុចខ្លះៗដែរ ។ គំរូដែលនាំឱ្យយើងមានជ័យជម្នះទៅលើយុទ្ធសាស្ត្ររបស់វា គឺត្រូវចេះនិយាយតាមព្រះបន្ទូលព្រះ ។

## ព្រះយេស៊ូវទ្រង់ជាគំរូរបស់យើងក្នុងការតស៊ូនឹងសេចក្ដីល្បួង

### ព្រះយេសុទ្រង់យល់នូវសេចក្ដីល្បួង

រឿងរ៉ាវរបស់ព្រះយេស៊ូវពីសេចក្ដីល្បួង គឺបានរៀបរាប់នៅក្នុងព្រះគម្ពីរម៉ាថាយ ដែលយើងត្រូវ បានទទួលព្រះពរ ឱ្យបានរៀននូវរបៀបដែលសាតាំងត្រូវតែធ្វើឱ្យយើងទទួលការបរាជ័យ នៅក្នុងមេរៀននេះ ។ រីឯយើងរាល់គ្នាក៏មានការជ្រើសរើសដោយសេរីដែរ យើងក៏បានត្រូវល្បួងផងដែរ តែព្រះយេស៊ូវទ្រង់បានដើរដោយមានជ័យជម្នះ ដូច្នេះយើងក៏អាចទទួលបាននូវជ័យជម្នះដូចជាទ្រង់ដែរ ។

លោកសាវកប៉ុលបានសម្ដែងថា ព្រះយេស៊ូវទ្រង់បានរងទុក្ខដោយត្រូវល្បួង ទ្រង់ក៏មានលទ្ធភាព ដើម្បីជួយដល់អស់អ្នកណា ដែលត្រូវសេចកក្ដីល្បួងផងដែរ ។

ព្រះគម្ពីរហេព្រើរ ២:១៨ ចែងថា: **ដ្បិតដែលទ្រង់បានរងទុក្ខលំបាក ទាំងត្រូវសេចក្ដីល្បួងនោះ ទ្រង់ក៏អាចនឹងជួយដល់អស់អ្នក ដែលត្រូវសេចក្ដីល្បួងបានដែរ** ។

### ព្រះយេស៊ូវទ្រង់ត្រូវសចក្ដីល្បួងដូចជាយើងដែរ

យើងក៏អាចពិសោធនូវសេចក្ដីជឿជាក់ដ៏ខ្លាំងផងដែរ ដោយដឹងថា ព្រះយេស៊ូវទ្រង់បានត្រូវល្បួង នៅត្រង់ចំណុចដែលយើងមានផងដែរ ។ ពេលដែលព្រះយេស៊ូវទ្រង់មិនបានចុះចាញ់ចំពោះសេចក្ដីល្បួងនោះ យើងក៏អាចទៅឯព្រះបាន ដោយភាពអស្ចារ្យរបស់ទ្រង់ ដែលជួយយើងឱ្យរួចពីសេចក្ដីល្បួងបាន ។

ព្រះគម្ពីរហេព្រើរ ៤:១៤-១៦ ចែងថាៈ **ដូច្នេះ ដែលមានសំដេចសង្ឃយ៉ាងធំ១អង្គ ដែលទ្រង់បានយាងកាត់អស់ទាំងជាន់ស្ថានសួគ៌ គឺព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ នោះត្រូវតែឱ្យយើងមានចិត្តដាច់ស្រឡះនឹងជឿតាមចុះ ដ្បិតសម្តេចសង្ឃនៃយើង ទ្រង់មិនមែននឹងមិនអាចនឹងអាណិតអាសូរ ដល់សេចក្តីកំសោយរបស់យើងរាល់គ្នានោះទេ ព្រោះទ្រង់បានត្រូវសេចក្តីល្បួងគ្រប់យ៉ាង ដូចជាយើងរាល់គ្នាដែរ តែឥតធ្វើបាបឡើយ ដូច្នេះ ត្រូវឱ្យយើងរាល់គ្នា មកដល់បល្ល័ង្កនៃព្រះគុណដោយក្លាហាន ដើម្បីនឹងទទួលសេចក្តីមេត្តា ហើយរកបានព្រះគុណសំរាប់នឹងជួយដល់ពេលត្រូវការចុះ ។**

**គ្រប់សេចក្តីល្បួងទាំងអស់គឺជាធម្មតា**

យុទ្ធសាស្ត្រមួយរបស់សាតាំងក្នុងបណ្តាយុទ្ធសាស្ត្រជាច្រើន វាធ្វើឱ្យយើងហាក់ដូចជាទទួលអារម្មណ៏ថា ជាសេចក្តីល្បួងផ្សេងទៀតដែលលំបាកជាងការរងទុក្ខមុនៗទៅទៀត ។ ប៉ុន្តែគ្រប់សេចក្តីល្បួងទាំងអស់គឺជាធម្មតាទេ ហើយព្រះទ្រង់តែងតែប្រទានឱ្យយើងអាចគេចរួច និងឈរនៅមាំមួនជានិច្ច ។

ព្រះគម្ពីរ ១កូរិនថូស ១០:១៣ ចែងថាៈ **ដ្បិតគ្មានសេចក្តីល្បួងណាកើតដល់អ្នករាល់គ្នាក្រៅពីសេចក្តីល្បួង ដែលត្រូវខាងមនុស្សលោកទេ រីឯព្រះទ្រង់ក៏ស្មោះត្រង់ដែរ ទ្រង់មិនឱ្យកើតមានសេចក្តីល្បួងហួសកំឡាំងអ្នករាល់គ្នាឡើយ គឺនៅវេលាណាដែលត្រូវល្បួង នោះទ្រង់ក៏រៀបផ្លូវឱ្យចៀសរួច ដើម្បីឱ្យអ្នករាល់គ្នាអាចនឹងទ្រាំបាន ។**

**ដើរតាមគំរូព្រះយេស៊ូវ**

ព្រះយេស៊ូវទ្រង់ជាគំរូរបស់យើង ទ្រង់បានឆ្លើយទៅសាតាំងដោយប្រើព្រះបន្ទូលរបស់ព្រះ ដូច្នេះយើងក៏ត្រូវតែធ្វើយ៉ាងដូច្នោះដែរ ។

ពេលដែលសាតាំងបានមកឯព្រះយេស៊ូវ ទ្រង់មិនបានៈ

- ⇨ *ឈ្លោះជាមួយសាតាំង*
- ⇨ *រកហេតុផលជាមួយសាតាំង*
- ⇨ *ធ្វើតាមមធ្យោបាយរបស់សាតាំង*

ព្រះយេស៊ូវទ្រង់បានយកសេចក្តីចែងតាមព្រះបន្ទូលព្រះ ។

ព្រះគម្ពីរម៉ាថាយ ៤:៤ ចែងថាៈ **ដ្បិតមានសេចក្តីចែងទុកមកថា "មនុស្សមិនមែនរស់ដោយសារតែនំប៉័ងប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋព្រះមកដែរ" ។**

នេះគឺជារបៀបដែលសាតាំងបានធ្វើការផ្ចាញ់ផ្ចាល ។ ព្រះបន្ទូលរបស់ព្រះត្រូវតែហូរចេញពីមាត់របស់យើង។

ពេលដែលជំងឺរោគាព្យាយាមចង់ចូលមកក្នុងរូបរាង្គកាយរបស់យើង យើងអាចនិយាយថា "មានសេចក្តីចែងទុកមកដូច្នេះ ដោយនូវអំណាចរបស់ទ្រង់ ខ្ញុំត្រូវបានជា" ។

នៅពេលដែលភាពខ្វះខាត បានព្យាយាមចូលមកទាស់ទទឹងនឹងផ្នែកថវិការបស់យើង យើងអាចនិយាយថា "ព្រះរបស់ខ្ញុំនឹងផ្គត់ផ្គង់គ្រប់ទាំងសេចក្ដីត្រូវការទាំងអស់របស់ខ្ញុំ " ។

ពេលដែលសាតាំងព្យាយាមដឹកនាំកូនរបស់យើង យើងអាចនិយាយថា "មានសេចក្ដីចែងទុកមកដូច្នេះ កូនរបស់ខ្ញុំ នឹងត្រូវបានទទួលការបង្រៀនមកពីព្រះអម្ចាស់" ។

| |
|---|
| **ការនិយាយដោះសា-មិនមែនជាបញ្ហាទេ ។** |
| **ការនិយាយជាចម្លើយ-មិនមែនជាសេចក្ដីត្រូវការទេ ។** |
| **ការនិយាយ និងជឿលើព្រះបន្ទូលព្រះ** |
| **សាតាំងនឹងបានទទួលនូវៈ** |
| **ការបូកសរុប** |
| **យ៉ាងពេញលេញ** |
| **យ៉ាងពេញចិត្ត** |
| **ការបរាជ័យ** |
| **ចុះលោកអ្នក តើនឹងត្រូវបានទទួលជោគជ័យយ៉ាងណាហ្ន៎!** |

**<u>សំណួររំឭកសារឡើងវិញ</u>**

១- ហេតុអ្វីបានជាការសំខាន់លោកអ្នកត្រូវតែដឹងថា ព្រះយេស៊ូវទ្រង់បានបោះបង់សិទ្ធិជាព្រះ និងមករស់នៅបំពេញព្រះរាជកិច្ចជាមនុស្សនៅលើ ផែនដីនេះវិញ?

២- តើលោកអ្នកអាចឱ្យជាឧទាហរណ៍ដូចម្ដេចខ្លះ ដែលព្រះយេស៊ូវទ្រង់បានបំពេញព្រះរាជកិច្ចនៅក្នុងអំណាចរបស់មនុស្ស ពេលដែលទ្រង់បានគង់នៅលើផែនដី?

៣- ចូររកមើលគំរូរបស់ព្រះយេស៊ូវដូចតទៅនេះ តើលោកអ្នកអាចធ្វើឱ្យសាតាំង ឬវិញ្ញាណរបស់វាត្រូវបរាជ័យ ពេលដែលពួកវាព្យាយាមល្បួងលោកអ្នកឱ្យចេញពីការស្ដាប់បង្គាប់ដល់ព្រះ ?

# មេរៀនទី ៥

# ព្រះយេស៊ូវទ្រង់បានបំពេញព្រះរាជកិច្ចដោយអំណាច

## ផែនការរបស់ព្រះសម្រាប់អ្នកជឿទាំងអស់

### ព្រះយេស៊ូវទ្រង់ជាមនុស្ស

ព្រះយេស៊ូវទ្រង់បានបំពេញព្រះរាជកិច្ចនៅលើផែនដីនេះជាមនុស្ស ។ ទ្រង់មិនបានប្រើសិទ្ធិអំណាចរបស់ទ្រង់ជាព្រះឡើយ ។ ទ្រង់បានទទួលរងនូវសេចក្តីល្បួងដូចជាមនុស្សយើងដែរ ។ ទ្រង់បានឈ្នះលើសាតាំង ដូចជាមនុស្សយើងបានឈ្នះដែរ ។

ព្រះយេស៊ូវគឺជាមនុស្ស ដែលមានអំណាចនៅលើផែនដីនេះ ។ អំណាចរបស់ទ្រង់ គឺដោយសារទ្រង់ជាកូនមនុស្ស ជាលោកអ័ដាមទី២ មិនមែនដោយសារទ្រង់ជាព្រះរាជបុត្រានៃព្រះនោះទេ ។

ព្រះយេស៊ូវទ្រង់បានយាងមកជាលោកអ័ដាមទី២ ដើម្បីដំរេចគ្រប់ទាំងអស់ ដែលព្រះទ្រង់បានបង្កើតលោកអ័ដាមទី១ឱ្យមានមក ។ ការសម្រេចនូវផែនការរបស់ព្រះ គឺសម្រាប់លោកអ័ដាមទី១ ដែលព្រះយេស៊ូវទ្រង់បានដើរនៅក្នុងអំណាច និងអំណាចគ្រប់គ្រងនៅផែនដីនេះ ។

វាជាការសំខាន់ដើម្បីឱ្យយល់នូវអំណាចនៅទីកន្លែងដែលព្រះយេស៊ូវទ្រង់បានយាងទៅ ។ ប្រសិនបើអំណាចនេះ ជាអំណាចដែលព្រះទ្រង់បានបង្កើតមក បានប្រទានមកមនុស្សលោក អញ្ចឹងយើងក៏អាចដើរនៅក្នុងអំណាច ដូចជាបានប្រោសលោះដល់មនុស្សប្រុសស្រីសម័យសព្វថ្ងៃនេះដែរ ។

ព្រះគម្ពីរលូកា ១០:១៩ ចែងថា: **មើល ខ្ញុំឱ្យអ្នករាល់គ្នាមានអំណាច នឹងដើរជាន់ទាំងពស់ និងខ្យាដំរី ហើយលើគ្រប់ទាំងឥទ្ធិឫទ្ធិរបស់ខ្មាំងសត្រូវផង គ្មានអ្វីនឹងធ្វើទុក្ខអ្នករាល់គ្នាឡើយ ។**

លុះត្រាណាតែបានកើតជាថ្មីនៅក្នុងព្រះយេស៊ូវគ្រីស្ទ ទើបអាចឱ្យយើងបានត្រឡប់មកជាមនុស្សប្រុសស្រី ដែលយើងត្រូវបានបង្កើតនៅក្នុងផែនការរបស់ព្រះ ។ លុះត្រាណាយើងបានអាននូវដំណឹងល្អ ព្រមទាំងបានឃើញព្រះយេស៊ូវ ដែលកំពុងដើរជាមនុស្សគ្រប់លក្ខណ៍ ដែលអាចឱ្យយើងយល់នូវជំហានរបស់ព្រះសម្រាប់ជីវិតរស់នៅ និងការដើរដោយអំណាច ព្រមទាំងអំណាចគ្រប់គ្រងរបស់យើង ជារៀងរាល់ថ្ងៃ ។

### ព្រះគម្ពីរលូកាប្រាប់យើងពីអំណាចរបស់ព្រះយេស៊ូវ

### ព្រះរាជសារទី១

⇨ *នៅក្នុងអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ*

ពេលដែលព្រះយេស៊ូវទ្រង់បានទទួលជ្រមុជទឹកនៅទន្លេយ័រដាន់ នោះព្រះវិញ្ញាណបរិសុទ្ធយាងមកសណ្ឋិតលើព្រះអង្គ ដើម្បីប្រទានអំណាចដល់ព្រះអង្គសម្រាប់ព្រះរាជកិច្ចនៅផែនដីនេះ ។ ក្រោយមកទ្រង់ត្រូវបាននាំទៅវាលរហោស្ថាន ជាកន្លែងដែលទ្រង់បានទទួលជ័យជម្នះ

លើសាតាំង ព្រមទាំងសេចក្ដីល្បួងរបស់ព្រះអង្គ ដោយទ្រង់បានប្រើព្រះបន្ទូលរបស់ព្រះ ។ ទ្រង់មានការបើកសម្ដែងដោយអំណាចរបស់ទ្រង់ នៅលើផែនដីជាមនុស្សជាតិ ដែលព្រះវិញ្ញាណបរិសុទ្ធទ្រង់បានប្រទានឱ្យមក ទ្រង់បានត្រៀមរួចជាស្រេច សម្រាប់ព្រះរាជកិច្ចរបស់ទ្រង់ ឱ្យបានដំណើរការ ។

ទ្រង់បានចាប់ផ្ដើមព្រះរាជកិច្ចរបស់ទ្រង់នៅស្រុកកាលីឡេ ទ្រង់បានទទួលការចាក់ប្រេងតាំងដោយព្រះវិញ្ញាណបរិសុទ្ធ ព្រមទាំងទ្រង់មានបន្ទូលដោយអំណាច ។

ព្រះគម្ពីរលូកា ៤:១៤-១៥,១៨-២១ ចែងថា: **ឯព្រះយេស៊ូវទ្រង់វិលទៅស្រុកកាលីឡេវិញទាំងមានព្រះចេស្ដានៃព្រះវិញ្ញាណមកសណ្ឋិតលើទ្រង់ នោះមានឮល្បីពីទ្រង់សុសសាយទូទៅក្នុងស្រុកជុំវិញ ទ្រង់បង្រៀនក្នុងសាលាប្រជុំរបស់គេ ហើយគេក៏សរសើរដំកើងទ្រង់ទាំងអស់គ្នា... "ព្រះវិញ្ញាណព្រះអម្ចាស់សណ្ឋិតលើខ្ញុំ ពីព្រោះទ្រង់បានចាក់ប្រេងតាំងខ្ញុំ ឱ្យផ្សាយដំណឹងល្អដល់មនុស្សទ័លក្រ ទ្រង់បានចាត់ខ្ញុំឱ្យមក ដើម្បីនឹងប្រោសមនុស្សដែលមានចិត្តសង្រេង ហើយប្រកាសប្រាប់ពីសេចក្ដី ប្រោសលោះដល់ពួក ឈ្លើយ និងសេចក្ដីភ្លឺឡើងវិញដល់មនុស្សខ្វាក់ ហើយឱ្យដោះមនុស្សដែលត្រូវគេជិះជាន់ឱ្យរួច ព្រមទាំងប្រកាសប្រាប់ពីឆ្នាំដែលព្រះអម្ចាស់កំណត់ទុក" កាលទ្រង់បានបិទគម្ពីរ ប្រគល់ដល់អ្នករក្សាសាលាវិញហើយ នោះទ្រង់ក៏គង់ចុះ ឯពួកអ្នកដែលនៅក្នុងសាលា គេក៏សំឡឹងមើលទ្រង់ ទ្រង់ចាប់តាំងមានបន្ទូលទៅគេថា នៅថ្ងៃនេះបទគម្ពីរនេះបានសំរេចនៅត្រចៀកអ្នករាល់គ្នាហើយ ។**

( ព្រះយេស៊ូវទ្រង់បានអានព្រះគម្ពីរអេសាយ ៦១:១-២) ។

**ព្រះរាជសារទី២**

បន្ទាប់ពីព្រះយេស៊ូវទ្រង់មានបន្ទូលនៅស្រុកណាសារ៉ែតមក ទ្រង់បានមានបន្ទូលនៅស្រុកកាណានទៀត ។ មានមនុស្សជាច្រើនបានឆ្ងល់នឹងអំណាចរបស់ទ្រង់ ។

⇨ *ទ្រង់មានអំណាច*

ព្រះគម្ពីរលូកា ៤:៣១-៣២ ចែងថា: **ទ្រង់យាងចុះទៅដល់កាពើណិម ជាទីក្រុងស្រុកកាលីឡេ ក៏តែងតែបង្រៀនគេរាល់ថ្ងៃឈប់សំរាក គេក៏នឹកផ្ញើកពីសេចក្ដីដែលទ្រង់បង្រៀនណាស់ ពីព្រោះទ្រង់មានបន្ទូលដោយអំណាច ។**

⇨ *វិញ្ញាណអាក្រក់ត្រូវបានបណ្ដេញចេញ*

ខ.៣៣-៣៥ **រីឯនៅក្នុងសាលានោះ មានមនុស្សម្នាក់ ដែលមានវិញ្ញាណអារក្សអសោចិចូល វាស្រែកឡើងជាខ្លាំងថា ហ៊ឺះនែ ព្រះយេស៊ូវពីស្រុកណាសារ៉ែតអើយ តើយើងហើយនិងទ្រង់មានហេតុអ្វីនឹងគ្នា តើទ្រង់មកបំផ្លាញយើងឬអី ខ្ញុំស្គាល់ជាក់ហើយ ទ្រង់ជាព្រះអង្គបរិសុទ្ធនៃព្រះ ព្រះយេស៊ូវក៏កំហែងទៅវាថា ចូរស្ងៀមចុះ ហើយចេញពីមនុស្សនេះទៅ លុះអារក្សបានផ្ដួលអ្នកនោះទៅកណ្ដាលពួកគេ នោះក៏ចេញទៅឥតមានធ្វើឱ្យឈឺអ្វីឡើយ ។**

ព្រះយេស៊ូវទ្រង់បានបញ្ជាទៅវិញ្ញាណអារក្សអសោចិ៍ឱ្យចេញទៅ ហើយដោយព្រោះតែវាស្គាល់អំណាចរបស់ព្រះយេស៊ូវ វាក៏ចេញទៅ ។

⇨ *អំណាច និងចេស្តា*

ខ.៣៦ **គ្រប់គ្នាក៏នឹកស្ញើចក្នុងចិត្ត ទាំងសួរគ្នាថា តើពាក្យបែបយ៉ាងណានេះ ដែលលោកបង្គាប់ដល់វិញ្ញាណអពសចិ៍ ដោយអំណាចនិងឫទ្ធិបាន ហើយវាក៏ចេញទៅដូច្នេះ ។**

**<u>អំណាចព្រះយេស៊ូវលើវិញ្ញាណអសោចិ៍ ជំងឺ ដើមឈើ ព្យុះ</u>**

លោកម៉ាកុសក៏បានសរសេរផងដែរ អំពីព្រះរាជកិច្ចរបស់ព្រះយេស៊ូវនៅស្រុកកាពើណិម ហើយបណ្ដាជនក៏ឆ្ងល់ចំពោះអំណាចរបស់ទ្រង់ នៅគ្រប់កន្លែងដែលទ្រង់បានបំពេញព្រះរាជកិច្ច ។ លោកម៉ាកុសក៏បានប្រាប់យើងអំពីវិញ្ញាណដទៃទៀត ដែលត្រូវបានបណ្ដេញចេញផងដែរ ព្រមទាំងមនុស្សមានជំងឺក៏ត្រូវបានប្រោសឱ្យជាដែរ ។

**អំណាចលើវិញ្ញាណអសោចិ៍**

ព្រះយេស៊ូវទ្រង់មានអំណាចលើវិញ្ញាណអសោចិ៍ ។

ខ.៤០-៤១ **ដល់ពេលថ្ងៃលិច អស់អ្នកដែលមានបងប្អូនឈឺជំងឺផ្សេងៗ គេនាំអ្នកទាំងនោះមកឯទ្រង់ ហើយទ្រង់ប្រោសគេគ្រប់គ្នាឱ្យបានជា ដោយដាក់ព្រះហស្តលើ ក៏មានអារក្សចេញពីមនុស្សជាច្រើនដែរ វាស្រែកឡើងថា ទ្រង់ជាព្រះរាជបុត្រានៃព្រះ តែទ្រង់បន្ទោស ហាមមិនឱ្យវានិយាយសោះ ពីព្រោះវាដឹងថា ទ្រង់ជាព្រះគ្រីស្ទពិត ។**

**អំណាចលើជំងឺរោគា**

ព្រះយេស៊ូវមានអំណាចលើជំងឺរោគា ។

ព្រះគម្ពីរម៉ាកុស ១:៤០-៤១ **គ្រានោះ មានមនុស្សឃ្លង់ម្នាក់ មកឯព្រះយេស៊ូវ លុតជង្គង់ទូលអង្វរថា បើទ្រង់សព្វព្រះហឫទ័យ ទ្រង់អាចនឹងប្រោសឱ្យទូលបង្គំជាស្អាតបាន ដូច្នេះទ្រង់មានព្រះហឫទ័យក្តួលអាណិត ក៏លូកព្រះហស្តទៅពាល់គាត់ ដោយបន្ទូលថា ខ្ញុំចង់ដែរឱ្យជាស្អាតទៅ ។**

**អំណាចលើរូបរាង្គកាយមនុស្ស**

ព្រះយេស៊ូវទ្រង់មានបន្ទូលទៅបុរសដែលស្វិតដៃថា "ចូរលាតដៃអ្នកទៅ" ។

ព្រះគម្ពីរម៉ាកុស ៣:១-៣ ចែងថា: **ទ្រង់យាងចូលទៅសាលាប្រជុំម្តងទៀត នៅទីនោះមានមនុស្សស្វិតដៃម្ខាង គេក៏ចាំមើលទ្រង់ ក្រែងនឹងប្រោសឱ្យគាត់ជានៅថ្ងៃឈប់សំរាក ដើម្បីឱ្យបានរឿងចោទប្រកាន់ទ្រង់ ទ្រង់មានបន្ទូលទៅមនុស្សស្វិតដៃថា ចូរអ្នកក្រោកឡើង ឈរនៅកណ្តាលនុ៎ះទៅ ។**

ព្រះយេស៊ូវទ្រង់បានស្គាល់បុរសនោះ ទ្រង់សព្វព្រះហឫទ័យនឹងប្រោសគាត់ឱ្យជា ទ្រង់ក៏មានបន្ទូលថា "ចូរដើរទៅ" ។

ខ.៤-៥ **រួចទ្រង់សួរគេថា នៅថ្ងៃឈប់សំរាក តើបើកឱ្យធ្វើការល្អ ឬឱ្យធ្វើការអាក្រក់**

**ឱ្យសង្គ្រោះជីវិត ឬឱ្យសំលាប់បង់ ប៉ុន្តែគេនៅតែស្ងៀម នោះទ្រង់ងាកទតទៅគេទាំងឆ្អាន់ក្នាញ់ ដោយមានព្រះហឫទ័យព្រួយ ព្រោះចិត្តគេរឹងរូស ក៏មានបន្ទូលទៅមនុស្សនោះថា ចូរអ្នកលាតដៃទៅ អ្នកនោះក៏លាត ហើយដៃគាត់បានជាដូចម្ខាង ។**

ដោយនូវអំណាច ព្រះយេស៊ូវទ្រង់បានមានបន្ទូលដោយពាក្យសម្តី បុរសនោះក៏លាតដៃរបស់គាត់ ហើយក៏បានជា ។

**អំណាចលើស្នាព្រះហស្ត**

➪ *បណ្តាសាចំពោះដើមល្វា*

ព្រះយេស៊ូវទ្រង់មានអំណាចលើដើមល្វា ។

ព្រះគម្ពីរម៉ាថាយ ២១:១៩ ចែងថា: **ទ្រង់ទតឃើញដើមល្វា១តាមផ្លូវ ក៏យាងទៅដល់ ឃើញមានតែស្លឹកទទេ នោះទ្រង់មានបន្ទូលថា កុំឱ្យឯងមានផ្លែទៀតឡើយ ស្រាប់តែដើមល្វានោះក្រៀមទៅ ។**

**អំណាចលើវត្ថុធម្មជាតិ**

➪ *បញ្ឈប់ខ្យល់ព្យុះ*

ព្រះយេស៊ូវទ្រង់បានមានបន្ទូលទៅខ្យល់ និងសមុទ្រដោយអំណាច ពួកវាក៏ស្តាប់បង្គាប់ទ្រង់ ។

ព្រះគម្ពីរម៉ាកុស ៤:៣៥-៣៨ ចែងថា: **លុះពេលល្ងាចថ្ងៃនោះឯង ទ្រង់មានបន្ទូលទៅពួកសិស្សថា ចូរយើងឆ្លងទៅត្រើយម្ខាង កាលឱ្យហ្វូងមនុស្សទៅវិញហើយ នោះពួកសិស្សក៏ទទួលទ្រង់តាមភាពដដែលទៅក្នុងទូក ហើយមានទូកតូច១ខ្លះទៀតទៅជាមួយដែរ នោះកើតមានខ្យល់ព្យុះជាខ្លាំង ហើយរលកបោកចូលក្នុងទូក ដល់ម្លេះបានជាទូកពេញហើយ តែទ្រង់ផ្ទំលក់លើខ្នើយ នៅកន្សៃទូក ពួកសិស្សដាស់ទ្រង់ឡើង ទូលថា លោកគ្រូអើយ យើងវិនាសហើយ លោកមិនរវល់ទេឬអី ។**

ព្រះយេស៊ូវទ្រង់បានកំហែងទៅខ្យល់ ហើយមានបន្ទូលទៅសមុទ្រ ។

ខ.៣៩-៤០ **កាលតើនឡើង ទ្រង់កំហែងខ្យល់ ក៏បង្គាប់ទៅសមុទ្រថា ចូរស្ងៀមទៅ ហើយឈប់ចុះ នោះខ្យល់ក៏ស្ងប់ ហើយស្ងាត់ឈឹងសូន្យទាំងអស់ទៅ រួចទ្រង់មានបន្ទូលថា ហេតុអ្វីបានជាអ្នករាល់គ្នាភ័យដល់ម្លេះ ម្តេចក៏គ្មានសេចក្តីជំនឿ ។**

ព្រះបន្ទូលរបស់ព្រះយេស៊ូវគឺ "ហេតុអ្វីបានជាអ្នករាល់គ្នាភ័យយ៉ាងចូច្នេះ? អ្នករាល់ក៏អាចបញ្ឈប់ខ្យល់ព្យុះបានដែរ ។ តើសេចក្តីជំនឿរបស់អ្នករាល់គ្នានៅឯណា?" ។

ខ.៤១ **នោះគេមានសេចក្តីស្ញែងខ្លាចជាខ្លាំង ទាំងសួរគ្នាទៅវិញទៅមកថា ដូច្នេះ តើលោកនេះជាអ្វី បានជាខ្យល់ និងសមុទ្រក៏ស្តាប់បង្គាប់លោកដូច្នេះ ។**

**ព្រះយេស៊ូវទ្រង់ជាគំរូរបស់យើង**

ព្រះយេស៊ូវទ្រង់ជាគំរូរបស់យើង ដូច្នេះយើងគួរតប្បីដើរ និងបំពេញការងារដោយ

អំណាចផងដែរ ។ ទ្រង់ធ្វើការនៅលើផែនដីនេះ ជាលោកអ័ដាមទីចុងក្រោយ គឺទុកជាគំរូ ជារបៀបដល់យើង ទ្រង់បានប្រោសលោះ និងកែមនុស្សជាតិឡើងវិញ ដើម្បីឱ្យបានបំពេញការងាររបស់ព្រះយេស៊ូវនៅលើផែនដីសព្វថ្ងៃនេះ ។ យើងត្រូវតែរស់នៅ និងបំពេញការងារដោយកម្លាំងអំណាចដូចដែលព្រះយេស៊ូវទ្រង់បានធ្វើទុកជាគំរូស្រាប់ ។

ព្រះគម្ពីរយ៉ូហាន ១៤:១២ ចែងថា: **ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកណាដែលជឿដល់ខ្ញុំ នោះនឹងធ្វើការដែលខ្ញុំធ្វើដែរ ក៏នឹងធ្វើការធំជាងការទាំងនោះទៅទៀត ពីព្រោះខ្ញុំទៅឯព្រះវរបិតា ។**

**ព្រះយេស៊ូវទ្រង់បានកំហែងទៅជំងឺគ្រុន**

ព្រះយេស៊ូវទ្រង់បានមានបន្ទូលដោយអំណាច ពេលដែលទ្រង់បានកំហែងទៅជំងឺគ្រុន នៅក្នុងរូបរាងកាយម្តាយក្មេករបស់លោកពេត្រុស ។

ព្រះគម្ពីរលូកា ៤:៣៨-៣៩ ចែងថា: **រួចទ្រង់ក្រោកឡើង យាងចេញពីសាលា ចូលទៅក្នុងផ្ទះស៊ីម៉ូន រីឯម្តាយក្មេកស៊ីម៉ូន នាងកំពុងគ្រុនជាខ្លាំង ហើយគេសូមអង្វរទ្រង់ឱ្យនាង ទ្រង់ក៏ឈរឈ្ងោកទៅនាង ទាំងកំហែងដល់គ្រុន នោះគ្រុនក៏បាត់ទៅ រួចនាងក្រោកឡើងភ្លាម បំរើដល់ទាំងអស់គ្នា ។**

**ការរស់ឡើងវិញរបស់លោកឡាសារ**

ព្រះយេស៊ូវទ្រង់មានបន្ទូលដោយកម្លាំង និងដោយបង្គំ ជាសម្លេងព្រះអម្ចាស់ ទៅកាន់ផ្នូររបស់លោកឡាសារ ។

ព្រះគម្ពីរយ៉ូហាន ១១:៤៣ ចែងថា: **កាលទ្រង់មានបន្ទូលដូច្នេះហើយ ក៏បន្លឺវាចាថា ឡាសារអើយ ចូរចេញមក ។**

**ការធ្វើការងាររបស់ព្រះយេស៊ូវ**

គ្រប់ទីកន្លែងដែលព្រះយេស៊ូវទ្រង់បានយាងទៅ ទ្រង់បានបំពេញព្រះរាជកិច្ចដោយមានភាពរឹងប៉ឹង ដែលទ្រង់បានធ្វើការដោយអំណាចនៃកូនមនុស្ស ។ ពេលដែលទ្រង់បានបញ្ចេញអំណាច គឺជាអំណាចរបស់ព្រះវិញ្ញាណបរិសុទ្ធ ទ្រង់បានប្រោសអ្នកជំងឺឱ្យជា បណ្តេញវិញ្ញាណអសោចិ៍ឱ្យចេញទៅ ព្រមទាំងប្រោសមនុស្សស្លាប់ឱ្យរស់ឡើងវិញ ។ ទ្រង់បានធ្វើការទាំងនេះ ទុកជាគំរូសម្រាប់អ្នកជឿទាំងឡាយ ទាំងនៅសម័យព្រះគម្ពីរ និងសម័យយើងសព្វថ្ងៃនេះ ។

ព្រះយេស៊ូវទ្រង់មានបន្ទូលទៅកាន់ពួកសិស្ស ដើម្បីឱ្យបំពេញការងារ ដែលមានអំណាច និងធ្វើការងារផ្សេងៗទៀត ដូចជាព្រះយេស៊ូវទ្រង់បានធ្វើទុកជាគំរូហើយស្រាប់ ។

ព្រះគម្ពីរម៉ាថាយ ១០:៨ ចែងថា: **ចូរប្រោសមនុស្សជំងឺឱ្យជា មនុស្សស្លាប់ឱ្យរស់ឡើងវិញ មនុស្សឃ្លង់ឱ្យជាស្អាត ហើយដេញអារក្សចេញផង អ្នករាល់គ្នាបានទទួលទទេ ត្រូវឱ្យទទេដែរ ។**

ពួកសិស្សអាចធ្វើការរបស់ព្រះយេស៊ូវបាន ពីព្រោះទ្រង់បានអំណាចដល់ពួកគេ ដូចជាអំណាចទ្រង់បានធ្វើ កាលទ្រង់បានគង់នៅលើផែនដីនេះដែរ ។

ព្រះគម្ពីរលូកា ១០:១៩ ចែងថា: **មើល ខ្ញុំឱ្យអ្នករាល់គ្នាមានអំណាច នឹងដើរជាន់ទាំងពស់ និងខ្យាដំរី ហើយលើគ្រប់ទាំងឥទ្ធិឫទ្ធិរបស់ខ្មាំងសត្រូវផង គ្មានអ្វីនឹងធ្វើទុក្ខអ្នករាល់គ្នាឡើយ ។**

**មានកម្លាំងមានអំណាច**

ព្រះរាជកិច្ចរបស់ព្រះយេស៊ូវបានទុកជាគំរូដល់ភាពរឹងប៉ឹង និងភាពមានអំណាច ជំនួសឱ្យការភ័យខ្លាច និងភាពអៀនខ្មាស ។

ព្រះគម្ពីរ ២ធីម៉ូថេ ១:៧ ចែងថា: **ដ្បិតព្រះទ្រង់មិនបានប្រទានឱ្យយើងមានវិញ្ញាណដែលតែងតែខ្លាចឡើយ គឺឱ្យមានវិញ្ញាណដ៏មានអំណាច សេចក្ដីស្រឡាញ់ និងប្រាជ្ញានឹងធឹងវិញ ។**

ព្រះយេស៊ូវទ្រង់បានផ្សាយដំណឹងល្អដោយក្លាហាន បណ្ដេញវិញ្ញាណអាក្រក់ និងដាក់ព្រះហស្តលើមនុស្សឈឺ ព្រមទាំងមើលគេឱ្យបានជា ពេលដែលទ្រង់បានបំពេញព្រះរាជកិច្ចដោយអំណាច ។ ព្រះយេស៊ូវទ្រង់ជាគំរូរបស់យើង ទ្រង់បានទុកនូវព្រះបន្ទូលទាំងនេះដល់យើង ។

ព្រះគម្ពីរម៉ាកុស ១៦:១៥-១៨ ចែងថា: **ទ្រង់ផ្ដាំគេថា ចូរអ្នករាល់គ្នាទៅពេញសព្វក្នុងលោកិយទាំងមូល ហើយផ្សាយដំណឹងល្អទូទៅដល់គ្រប់មនុស្សទាំងអស់ចុះ អ្នកណាដែលជឿហើយទទួលបុណ្យជ្រមុជទឹក នោះនឹងបានសង្គ្រោះ តែអ្នកណាដែលមិនព្រមជឿ នោះនឹងត្រូវទោសវិញ ទីសំគាល់ទាំងនេះនឹងជាប់តាមអស់អ្នកដែលជឿ គឺថា គេនឹងដេញអារក្សដោយនូវឈ្មោះខ្ញុំ ហើយនិងចេះនិយាយភាសាថ្មី និងចាប់កាន់ពស់បាន ឬបើគេផឹកអ្វីពុល នោះមិនធ្វើឱ្យអន្តរាយទេ ហើយគេនឹងដាក់ដៃលើមនុស្សជំងឺឱ្យបានជាផង ។**

ពេលដែលយើងដើរតាមគំរូរបស់ព្រះយេស៊ូវ ជាលោកអ័ដាមចុងក្រោយ យើងនឹងរកឃើញនូវការស្ដាប់បង្គាប់តាមព្រះបន្ទូលរបស់ព្រះយេស៊ូវ ដែលជាអ្នកបង្កើតលោកអ័ដាមទី១មកហើយ ។ យើងនឹងរកឃើញនូវការគ្រប់គ្រង ព្រមទាំងការផ្ដល់អំណាចគ្រប់គ្រងលើផែនដីនេះ និងរបស់សារពើ រួមទាំងភាពមានជំងឺ ចំណង ភាពទ័លក្រ ព្រមទាំងសេចក្ដីស្លាប់ ។ ម្យ៉ាងទៀត យើងនឹងធ្វើនូវអ្វី ដែលព្រះទ្រង់បានបង្កើតយើងមកឱ្យធ្វើ ។

**ភាពចុះរន្ទត់របស់សាតាំង**

ពេលដែលព្រះយេស៊ូវទ្រង់បានបំពេញព្រះរាជកិច្ចនៅផែនដីនេះ សាតាំងត្រូវតែបានមើលដោយភាពរន្ធត់ ។ ពេលនេះព្រះយេស៊ូវកំពុងបំពេញព្រះរាជកិច្ចជាមនុស្ស ទ្រង់កំពុងដើរដោយអំណាចមានបន្ទូល និងបំពេញព្រះរាជកិច្ចដោយអំណាច ដែលទ្រង់បានធ្វើយ៉ាងដូច្នោះ គឺបានបំផ្លាញការងាររបស់សាតាំង ។

ព្រះគម្ពីរ ១យ៉ូហាន ៣:៨ខ ចែងថា: **ដោយហេតុនោះបានជាព្រះរាជបុត្រានៃព្រះបាន លេចមក គឺដើម្បីនឹងបំផ្លាញការងាររបស់អារក្សចេញ ។**

ពេលដែលយើងដើរតាមគំរូរបស់ព្រះយេស៊ូវសព្វថ្ងៃនេះ យើងក៏នឹងរស់នៅ និងប្រកប ការងារនៅក្នុងអំណាច ដែលបានប្រទានមកពីព្រះ ។ យើងក៏នឹងបំផ្លាញការងាររបស់វិញ្ញាណ អាក្រក់ដែរ ។

**សំណួររំឭកសារឡើងវិញ**

១- តាមព្រះគម្ពីរយ៉ូហាន ៥:២៥-២៧ តើព្រះយេស៊ូវទ្រង់បានបំពេញព្រះរាជកិច្ចដោយអំណាចជាកូនព្រះ ឬក៏ដោយអំណាចជាកូនមនុស្ស?

២- ចូរឱ្យនូវគំរូរបស់ព្រះយេស៊ូវ ដែលទ្រង់បានដើរដោយអំណាចលើវត្ថុធម្មជាតិ លើអ្នកជំងឺ និងលើជំងឺរោគា ព្រមទាំងលើវិញ្ញាណអសោចិ៍ ។

៣- តើប្រតិកម្មរបស់ហ្វូងមនុស្សដូចម្ដេចខ្លះ ចំពោះព្រះយេស៊ូវដែលទ្រង់បានប្រើអំណាចចេស្ដាលើផែនដីនេះ?

៤- តើសព្វថ្ងៃនេះមនុស្សអាចមានប្រតិកម្មដូចម្ដេចខ្លះ ពេលដែលលោកអ្នកដើរដោយអំណាចនៅលើផែនដីនេះ?

# មេរៀនទី ៦

# ពីឈើឆ្កាងទៅដល់បល្ល័ង្ករាជ្យ

## ការសុគតរបស់ព្រះយេស៊ូវ

នគររបស់សាតាំងត្រូវបានបំផ្លាញហើយ សាតាំងបានដឹងថាព្រះយេស៊ូវត្រូវតែបានគេធ្វើគុត ។ ការឆបោកបានធ្វើជាមួយនឹងពួកទេវតា ។ វាបាធ្វើការប្រឆាំងនឹងលោកអ័ដាម និងនាងអេវ៉ា ប៉ុន្តែវាមិនបានធ្វើការប្រឆាំងនឹងព្រះយេស៊ូវទេ ។

ម្យ៉ាងទៀត ទោះជាយ៉ាងណាក៏ដោយ សាតាំងក៏បានប្រើល្បិចកលដែរ ។ វាឆបោកដល់ពួកអ្នកដឹកនាំសាសនា ឱ្យបានធ្វើគុតដល់ព្រះយេស៊ូវដែរ ។ វាបានចូលក្នុងខ្លួនរបស់យូដាស ដើម្បីឱ្យបាននាំគេមកចាប់ទ្រង់ ដូចជាវាបានចូលទៅក្នុងខ្លួនរបស់សត្វពស់ ដើម្បីឱ្យបានល្បួងលោកអ័ដាម និងនាងអេវ៉ាដូច្នោះដែរ ។

សាតាំងបានស្អប់ព្រះយេស៊ូវយ៉ាងខ្លាំង មិនមែនត្រឹមតែចង់ធ្វើគុតទ្រង់តែប៉ុណ្ណោះទេ គឺវាចង់ធ្វើទារុណ្ណកម្មដល់ទ្រង់ទៀតផង ។ គ្រប់ទាំងគោលការណ៍ អំណាច ច្បាប់នៃសេចក្តីងងឹត ព្រមទាំងវិញ្ញាណបញ្ឆោះរបស់សាតាំង គឺចង់តែបានសម្រេចតាមផែនការរបស់វា ។ ពួកវាត្រូវតែរៀបចំដើម្បីឱ្យបានទទួលនូវជ័យជម្នះដ៏ធំឆាប់រហ័សបំផុត ព្រមទាំងវាចង់ឱ្យមានឈ្មោះបោះសម្លេង ពេលដែលវារៀបចំការបំផ្លាញរបស់វាចូលមក ។

**ព្រះយេស៊ូវទ្រង់ត្រូវបានគេចាប់ចង គេវាយដំ និងជាប់លើឈើឆ្កាង** ។

## មេបោកប្រាសដ៏ធំបានធ្វើការបោកប្រាស់

សាតាំងគឺជាមេបោកប្រាស់ដ៏ធំ វាបានធ្វើការបោកប្រាស់ ។ ក្នុងការស្អប់ខ្ពើមដ៏ងងឹតងងល់របស់វា នោះមិនពិតប្រាកដទេ គឺវាគ្រាន់តែបានបណ្តាលឱ្យមនុស្សចង់ស្លាប់តែប៉ុណ្ណោះ តែចំណែកសេចក្តីស្លាប់ និងការរស់ឡើងវិញជាខាងក្រោយនោះ បានធ្វើឱ្យវាចុះចាញ់តែម្យ៉ាងគត់ ហើយមនុស្សជាតិបែរជាទទួលការប្រោសលោះ នូវអំពើបាបរបស់ពួកគេទៅវិញ ។

**ព្រះយេស៊ូវទ្រង់បានបងលថ្លៃជំនួសអំពើបាបរបស់យើង ដោយទ្រង់សុគតនៅលើឈើឆ្កាង** ។

ទ្រង់បានលោះគ្រប់ទាំងអំពើបាបរបស់យើង ទាំងអ្នកជំងឺ ទាំងជំងឺរោគា ព្រមទាំងបានសុខចិត្តរងទុក្ខលំបាកជំនួសយើង ។ អំពើបាបរបស់លោកិយទាំងមូល ត្រូវបានព្រះយេស៊ូវបំផ្លាញដោយអំណាចរបស់ព្រះដែលគង់នៅក្នុងទ្រង់ ។ លោកិយទាំងមូលបានកក្រើករំពើក នៅក្នុងកំឡុងពេលសង្គ្រាមដ៏ធំខាង ឯវិញ្ញាណកើតឡើង ។ ព្រះយេស៊ូវទ្រង់បានធ្វើឱ្យសាតាំង ព្រមទាំងវិញ្ញាណរបស់វាបានខកចិត្ត ។ សាតាំងបានយកមនុស្សដាក់នៅក្រោមអំណាចរបស់វា តាំងពីនៅជំនាន់លោកអ័ដាមដំបូងមកម្ល៉េះ ។ រីឯព្រះយេស៊ូវវិញ ទ្រង់បានយកកូនសោរនៃអំណាចនេះចេញពីវិញ្ញាណអាក្រក់នោះ ។

## តើមានអ្វីកើតឡើងនៅលើផែនដី?

មានសង្គ្រាមកើតឡើងចំនួនបីថ្ងៃ ។ ព្រះយេស៊ូវទ្រង់បានមានបន្ទូលថា លោកយ៉ូណាស បាននៅក្នុងពោះត្រីបាឡែន ចំនួនបីថ្ងៃបីយប់ រីឯទ្រង់ក៏បាននៅក្នុងកណ្ដាលផែនដីចំនួនបីយប់បីថ្ងៃដែរ ។

ព្រះគម្ពីរម៉ាថាយ ១២:៤០ ចែងថា: **ដ្បិតដែលលោកយ៉ូណាសបាននៅក្នុងពោះត្រីធំអស់៣ថ្ងៃ៣យប់យ៉ាងណា កូនមនុស្សក៏នឹងនៅក្នុងផ្ទៃផែនដី៣ថ្ងៃ៣យប់យ៉ាងនោះដែរ** ។

⇨ *វាំងននបានរហែកជាពីរ*

⇨ *មានកក្រើកដី*

⇨ *ថ្មប្រេះដាច់ពីគ្នា*

⇨ *ផ្នូរខ្មោចក៏របើកឡើង*

មនុស្សមិនត្រូវបានបែរចេញពីព្រះយូរប៉ុន្មានទេ ។ វាំងននដែលនៅក្នុងព្រះវិហារ នៅទីបរិសុទ្ធបំផុតនោះ ត្រូវរហែកជាពីរ ។ រីឯផែនដីក៏បានញ័រកក្រើកយ៉ាងខ្លាំង ពេលដែលព្រះយេស៊ូវទ្រង់បានដោះចំណងនៃសេចក្ដីស្លាប់នៅកណ្ដាលផ្ទៃផែនដីចេញ ។

ព្រះគម្ពីរម៉ាថាយ ២៧:៥០-៥៣ ចែងថា: **កាលព្រះយេស៊ូវទ្រង់បានស្រែកជាខ្លាំងម្ដងទៀត នោះទ្រង់ប្រគល់វិញ្ញាណទ្រង់ទៅវិញ គ្រានោះ វាំងននក្នុងព្រះវិហារក៏រហែកជា២ភាគ ចាប់តាំងពីលើចុះទៅដល់ក្រោម ក៏មានកក្រើកដី ហើយថ្មប្រេះដាច់ពីគ្នា អស់ទាំងផ្នូរខ្មោចក៏របើកឡើង ឯខ្មោចពួកអ្នកបរិសុទ្ធ ដែលដេកលក់ទៅហើយ បានរស់ឡើងវិញជាច្រើន ទាំងចេញពីផ្នូរ ក្នុងពេលក្រោយដែលទ្រង់មានព្រះជន្មរស់ឡើងវិញ ហើយចូលទៅក្នុងទីក្រុងបរិសុទ្ធ លេចមកឱ្យមនុស្សជាច្រើនឃើញដែរ ។**

## តើមានការអ្វីកើតឡើងចំពោះវិញ្ញាណនៅលោកិយខាងមុខ?

សង្គ្រាមដែលមានព្រះយេស៊ូវដ៏ជាអ្នកជំនួសរបស់យើងចូលរួមជាមួយសាតាំង ព្រមទាំងវិញ្ញាណបម្រើរបស់វា នឹងត្រូវវិនាសជាមិនខាន ។

ពេលដែលព្រះយេស៊ូវទ្រង់បានគេបោះដែកគោលនៅលើឈើឆ្កាង សាតាំងបានកោះហៅអស់ពួកវិញ្ញាណរបស់វាមកប្រជុំ ដើម្បីធ្វើបន្ទាល់ទាស់នឹងព្រះយេស៊ូវនៅក្នុងព្រឹត្តិការណ៍នោះ ។ រឿងនេះក៏ជាការសំខាន់ផងដែរចំពោះពួកវាដែលត្រូវទទួលការបាត់បង់ ។ ពេលដែលព្រះយេស៊ូវទ្រង់បានសុគតនៅលើឈើឆ្កាង សាតាំង និងវិញ្ញាណរបស់វា បានត្រូវតែប្រុងប្រៀបក្នុងការសប្បាយរីករាយដ៏កាចសាហាវ ដោយគិតថា ពួកវានឹងបានទទួលជ័យជម្នះនៅក្នុងពេលនោះហើយ ។

រឿងនោះនៅមិនទាន់គ្រប់គ្រាន់ទេសម្រាប់សាតាំង ដើម្បីឃើញព្រះកាយសុគតនៅលើឈើឆ្កាងរបស់ព្រះយេស៊ូវនោះទេ ។ នៅក្នុងកំហឹងដ៏ងងឹតងងល់ សាតាំងបានស្រែកថា "សូមទ្រង់កុំបណ្ដេញយើងឱ្យទៅក្នុងជង្ហុកធំនោះអី!" សាតាំងព្រមទាំងពួកវិញ្ញាណរបស់វា កំពុងតែបានឋិត

នៅក្នុងការល្ងង់ខ្លៅ ដែលពួកវាបានចាប់ផ្តើមសប្បាយរីករាយ តែពិធីដែលត្រូវចូលទៅឯទ្វារនៃស្ថានឃុំព្រលឹងមនុស្សស្លាប់ ត្រូវបិតនៅខាងក្រោយព្រះយេស៊ូវវិញ ។

ព្រះយេស៊ូវទ្រង់បានផ្ទុកនូវអំពើបាបដ៏គួរឱ្យស្អប់ខ្ពើមរបស់មនុស្សជាតិទាំងអស់ ដោយទ្រង់បានរងទុក្ខ ចុកចាប់នៅក្នុងជង្ហុកដ៏ធំ ដើម្បីបានជួយរំដោះយើងឱ្យបានរួចផុតពីស្ថានវេទនាទាំងនោះវិញ ។ ទ្រង់បានបញ្ឈប់ និងរំដោះគ្រប់ទាំងអំពើបាបទាំងអស់របស់យើង ដែលបានផ្ទុកនៅក្នុងយើង ។ ទ្រង់បានកប់អំពើបាបទាំងអស់របស់យើង ដើម្បីឱ្យយើងលែងនឹកចាំវាតទៅទៀត ។

ព្រះគម្ពីរទំនុកដំកើង ១០៣:១២ ចែងថា: **ឯទិសខាងកើតនៅឆ្ងាយពីទិសខាងលិចយ៉ាងណា ទ្រង់បានដកយកអស់ទាំងការល្មើសនៃនៃយើង ឱ្យឃ្លាតឆ្ងាយពីយើងយ៉ាងនោះដែរ ។**

**ការទាយទុកជាមុនដោយស្តេចដាវីឌ**

➪ *ទំនាយពីឈ្នួលនៃអំពើបាប*

➪ *ទំនាយពីការជំនុំជម្រះនៃអំពើបាប*

ស្តេចដាវីឌបានពណ៌នានូវអ្វីដែលបានកើតឡើងចំពោះព្រះយេស៊ូវ បន្ទាប់ពីការសុគតរបស់ទ្រង់ ។ ការផ្ទុកនូវអំពើបាបរបស់យើង ទ្រង់បានជួយយើងពេលដែលសាតាំងបានចាប់ផ្តើមធ្វើផែនការ នោះទ្រង់បានបញ្ចប់ដោយបានបំផ្លាញនូវគម្រោងផែនការនោះ ។ ទ្រង់បានយាងចុះទៅដល់ស្ថានឃុំព្រលឹងមនុស្សស្លាប់ ។ អស់អ្នកដែលបានស្លាប់ដោយមិនបានជឿ នោះនឹងត្រូវបានរងទុក្ខ និងត្រូវជាប់ជំនុំជម្រះ ។

ព្រះយេស៊ូវទ្រង់បានយាងចុះទៅដល់ស្ថានឃុំព្រលឹងមនុស្សស្លាប់ (ស្ថាននរក) ទ្រង់បានទទួលជាប់ទោស និងជាប់ជំនុំជម្រះជំនួសអំពើបាបរបស់យើងរាល់គ្នា ។

ព្រះគម្ពីរទំនុកដំកើង ៨៨:៣-៧ ចែងថា: **ដ្បិតព្រលឹងនៃទូលបង្គំមានពេញដោយសេចក្តីវេទនា ជីវិតនៃទូលបង្គំក៏កាន់តែជិតស្ថានឃុំព្រលឹងមនុស្សស្លាប់ គេរាប់ទូលបង្គំជាមួយនឹងពួកអ្នកដែលកំពុងតែចុះទៅក្នុងរណ្តៅ ទូលបង្គំក៏ដូចជាមនុស្សដែលគ្មានកំឡាំង ត្រូវបោះចោលនៅកណ្តាលពួកមនុស្សស្លាប់ហើយ ដូចជាអ្នក១ដែលត្រូវគេកាប់សំឡាប់ ដែលដេកនៅក្នុងផ្នូរ ជាអ្នកដែលទ្រង់មិននឹកចាំទៀតសោះ ហើយត្រូវកាត់ចេញពីព្រះហស្តទ្រង់ទៅ ទ្រង់បានផ្តេកទូលបង្គំនៅក្នុងរណ្តៅជ្រៅបំផុត គឺក្នុងទីងងឹតនៅទីជំរៅ សេចក្តីក្រោធរបស់ទ្រង់កំពុងតែសង្កត់លើទូលបង្គំជាធ្ងន់ ទ្រង់បានធ្វើទុក្ខទូលបង្គំ ដោយអស់ទាំងរលកទ្រង់ ។**

ស្តេចដាវីឌក៏បានទាយពីការរស់ឡើងវិញរបស់ព្រះយេស៊ូវផងដែរ ។

ព្រះគម្ពីរទំនុកដំកើង ១៦:១០ ចែងថា: **ដ្បិតទ្រង់មិនទុកឱ្យព្រលឹងទូលបង្គំ នៅក្នុងស្ថានឃុំព្រលឹងមនុស្សស្លាប់ទេ ក៏មិនព្រមឱ្យអ្នកបរិសុទ្ធរបស់ទ្រង់ឃើញសេចក្តីពុករលួយដែរ ។**

**ទំនាយដោយលោកហោរាអេសាយ**

លោកហោរាអេសាយក៏បានទាយពីសេចក្តីសុគត និងសេចក្តីរស់ឡើងវិញរបស់ព្រះយេស៊ូវដែរ ។

ព្រះគម្ពីរអេសាយ ៥៣:៨-១២ ចែងថា: **ទ្រង់ត្រូវដកចេញពីអំណាចការពារ ហើយពីសេចក្តីយុត្តិធម៌ ឯសម័យជំនាន់ទ្រង់ តើអ្នកណារំពឹងគិតឃើញថា ទ្រង់ត្រូវកាត់ចេញពីស្ថានរបស់មនុស្សរស់នេះ ហើយត្រូវវាយ ដោយព្រោះអំពើរំលងរបស់ជនជាតិខ្ញុំនោះ ហើយក្នុងកាលដែលទ្រង់សុគត នោះគេក៏បញ្ចុះសពទ្រង់នៅជាមួយនឹងពួកអាក្រក់ ហើយនៅក្នុងផ្នូររបស់អ្នកមានម្នាក់ ទោះបើទ្រង់មិនដែលធ្វើអំពើទុច្ចរិតណាមួយក៏ដោយ ក៏មិនដែលមានការបញ្ឆោតនៅក្នុងព្រះឱស្ឋទ្រង់ឡើយផង ។**

**ទោះបើយ៉ាងនោះ គង់តែព្រះយេហូវ៉ាបានសព្វព្រះហឫទ័យនឹងវាយទ្រង់ឱ្យជាំ ហើយឱ្យឈឺចាប់កាលណាព្រះជន្មទ្រង់បានត្រូវថ្វាយទុកជាយញ្ញបូជាលោះបាបហើយ នោះទ្រង់បានឃើញពូជពង្សរបស់ទ្រង់ ហើយនិងចំរើនព្រះជន្មទ្រង់ឱ្យយឺនយូរតទៅ ឯបំណងព្រះហឫទ័យនៃព្រះយេហូវ៉ា នោះនឹងចំរើនឡើងដោយសារព្រះហស្តទ្រង់ ទ្រង់នឹងឃើញផលនៃការដែលព្រលឹងទ្រង់រងវេទនា នោះនឹងបានស្កប់ស្កល់ផង អ្នកដ៏សុចរិត គឺជាអ្នកបំរើរបស់អញ ទ្រង់នឹងធ្វើឱ្យមនុស្សជាច្រើនបានសុចរិត ដោយគេស្គាល់ដល់ទ្រង់ ហើយទ្រង់នឹងទទួលរងទោសចំពោះអំពើទុច្ចរិតរបស់គេ ។**

**កូនចៀមនៃព្រះ**

⇨ *ទំនាយពីអំពើបាបនៃមនុស្សជាច្រើន*

⇨ *ការជួយសុំទោសឱ្យដល់អ្នកប្រព្រឹត្តរំលង*

**ហេតុនោះអញនឹងឱ្យទ្រង់មានចំណែកជាមួយនឹងពួកអ្នកធំ ហើយទ្រង់នឹងចែករបឹបជាមួយនឹងពួកអ្នកដ៏ខ្លាំងពូកែ ពីព្រោះទ្រង់បានច្រួចព្រលឹងចេញរហូតដល់ស្លាប់ គេបានរាប់ទ្រង់ជាអ្នកទទឹងច្បាប់ ប៉ុន្តែ ទ្រង់បានទទួលរងទោសនៃអំពើបាបរបស់មនុស្សជាច្រើន ហើយបានអង្វរជំនួសមនុស្សដែលទទឹងច្បាប់វិញ ។**

នៅលើឈើឆ្កាង ព្រះយេស៊ូវទ្រង់បានធ្វើសម្រេចនូវមុខងារជាយញ្ញបូជា ជាកូនចៀមដែលដោះបាបនៅព្រះគម្ពីរសញ្ញាចាស់ ។

ព្រះគម្ពីរយ៉ូហាន ១:២៩ ចែងថា: **លុះស្អែកឡើង យ៉ូហានឃើញព្រះយេស៊ូវ ដែលទ្រង់កំពុងតែយាងមកឯគាត់ នោះក៏ពោលថា នុ៎ះន៏ កូនចៀមនៃព្រះ ដែលដោះបាបមនុស្សលោក ។**

**អ្នករងទុក្ខជំនួសអ្នកឯទៀត**

ពេលដែលព្រះយេស៊ូវទ្រង់បានទម្លុះទម្លាយនូវអំពើបាបរបស់យើង ទៅដល់ជម្រៅនៃផែនដី ទ្រង់បានធ្វើសម្រេចនូវរូបភាពនៃមុខងារដោយការរងទុក្ខជំនួសអ្នកឯទៀត នោះទ្រង់បានយកអំពើបាបចេញពីមនុស្សបាន ។

ព្រះគម្ពីរលេវីវិន័យ ១៦:១០,២១-២២ ចែងថា: **តែឯពពែដែលចាប់ឆ្នោតត្រូវសម្រាប់បំបរបង់ទៅ នោះត្រូវយកមកដាក់ទាំងរស់ នៅចំពោះព្រះយេហូវ៉ា ដើម្បីឱ្យបានធួននឹងបាប រួចចាត់គេឱ្យនាំយកទៅលែងឯទីរហោស្ថាន ។**

**រួចដាក់ដៃទាំង២នៅលើក្បាលពពែនោះ លន់តួពីអស់ទាំងសេចក្ដីទុច្ចរិត និងអស់ទាំងសេចក្ដីរំលងរបស់ពួកកូនចៅអ៊ីស្រាអែល ពីលើពពែនោះ គឺអំពើបាបរបស់គេទាំងអស់ ត្រូវដាក់ទាំងអស់លើក្បាលពពែនោះ រួចប្រគល់ដល់មនុស្សម្នាក់ ដែលប្រុងជាស្រេចដើម្បីដឹកវាទៅឯទីរហោស្ថាន ឯពពែនោះត្រូវផ្ទុកអស់ទាំងសេចក្ដីទុច្ចរិតរបស់គេ លើខ្លួនចេញទៅឯទីដីបង់ស្ងួតស្ងាត់ រួចអ្នកនោះត្រូវលែងវានៅទីរហោស្ថាននោះ ។**

## ព្រះយេស៊ូវមិនអាចត្រូវបានឃុំទុកទេ

ពេលដែលព្រះយេស៊ូវទ្រង់បានរំដោះអំពើបាបរបស់យើង ដោយទ្រង់បានចូលទៅដល់ជង្ហុកដ៏ធំ នោះអំណាចរបស់ព្រះបានមកសណ្ឋិតលើទ្រង់ ។

ព្រះគម្ពីរកិច្ចការ ២:២៧ ចែងថា: **ដ្បិតទ្រង់នឹងមិនទុកព្រលឹងទូលបង្គំ ឱ្យជាប់នៅក្នុងស្ថានឃុំព្រលឹងមនុស្សស្លាប់ទេ ក៏មិនឱ្យអ្នកបរិសុទ្ធរបស់ទ្រង់ឃើញសេចក្ដីពុករលួយដែរ ។**

ទ្វារស្ថាននរក (ស្ថានឃុំព្រលឹងមនុស្សស្លាប់) មិនអាចទាស់ទទឹងយកឈ្នះលើព្រះយេស៊ូវបានទេ ។ ការចោះទម្លុះទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់ ទ្រង់បានដណ្ដើមយកកូនសោរនៃសេចក្ដីស្លាប់ ហើយស្ថានឃុំព្រលឹងមនុស្សស្លាប់ និងផ្លូវនៃសេចក្ដីស្លាប់ ត្រូវឆ្លងផុតពីកណ្ដាប់ដៃរបស់សាតាំងហើយ ។

## វិញ្ញាណអាក្រក់ និងវិញ្ញាណអសោចិ៍ បានទទួលការបរាជ័យ

ប្រវត្តិចម្បាំងពីបុរាណ និងការចុះចាញ់របស់ពួកខ្មាំងសត្រូវ បានផ្ដល់នូវគំហើញពិសេសនៅក្នុងខសំខាន់៧ ដូចតទៅ:

ព្រះគម្ពីរកូល៉ុស ២:១៥ ចែងថា: **ទ្រង់បានទាំងទំលាក់ងារពីពួកគ្រប់គ្រង និងពួកមានអំណាច ទាំងដាក់ពួកទាំងនោះនៅកណ្ដាលជំនុំឱ្យគេមើល ហើយដឹកនាំគេទៅ ដោយមានជ័យជំនះ ដោយសារឈើឆ្កាងនោះឯង ។**

ពេលដែលយើងបានសិក្សាមុនពេលដែលយើងមានចេស្ដា និងមានអំណាច គឺយោងទៅលើការរៀបចំរបស់វិញ្ញាណសាតាំង ។

នៅក្នុងសម័យបុរាណ ពេលដែលទាហានបានចុះចាញ់ចំពោះខ្មាំងសត្រូវរបស់ពួកគេ គេបានដកហូតយកអាវុធពីពួកគេ ដោះយកសំលៀកបំពាក់របស់ពួកគេ ចងពួកគេដាក់ជាប់នឹងច្រវ៉ាក់បន្តគ្នា ព្រមទាំងបណ្ដើរអាក្រោសដល់ពួកគេ យកពួកគេធ្វើជាខ្ញុំកញ្ជះដាច់ថ្លៃ ឱ្យពួកគេធ្វើជាជនចាញ់សង្គ្រាមជាដើម ។

ព្រះយេស៊ូវអង្គទ្រង់បានដកហូតយកអាវុធពីសាតាំង ព្រមទាំងពីគ្រប់វិញ្ញាណអសោចិ៍ទាំងអស់ផង ។ ទ្រង់ក៏ដកយកអាវុធចេញពីពួកវា ទ្រង់ក៏បានដោះសំលៀកបំពាក់របស់ពួកវាចេញផងដែរ ។ ទ្រង់ក៏បានបង្ហាញឱ្យឃើញលក្ខណៈរបស់វាជាសាធារណៈដែរ ។

អស់អ្នកដែលឃើញថាថ្ងៃជិតមកដល់ហើយ ពេលដែលព្រះយេស៊ូវទ្រង់ត្រូវគេព្យួរទាំងអាក្រាតផង ទ្រង់ត្រូវអាក្រាត និងអាម៉ាស់នៅលើឈើឆ្កាង ដូចជាឥឡូវនេះយើងក៏ត្រូវបានទទួលការអាម៉ាសខ្មាស ដោយរបៀបនេះដែរ ។

**សាតាំងបានធ្វើឱ្យលោកអ័ដាម និងនាងអេវ៉ាបានចុះចាញ់**

⇨ *បានទុកឱ្យពួកគេនៅជាអាក្រាត*

⇨ *បានដោះនូវអំណាចពួកគេចេញ*

**សាតាំងបានគិតថា វាបានធ្វើឱ្យព្រះយេស៊ូវត្រូវបរាជ័យ**

⇨ *ហើយបានដោះសំលៀកបំពាក់ទ្រង់ចេញ ឱ្យទ្រង់នៅជាអាក្រាត*

⇨ *ព្យួរទ្រង់នៅលើឈើឆ្កាង*

**ទោះជាយ៉ាងណា ព្រះយេស៊ូវទ្រង់នៅតែធ្វើឱ្យសាតាំង និងវិញ្ញាណរបស់វាចុះចាញ់ដដែល**

⇨ *ទុកពួកវាឱ្យនៅជាអាក្រាត*

⇨ *យកអំណាចពីពួកវាចេញ អស់កល្បជានិច្ច!*

**សេចក្តីរស់ឡើងវិញ**

ទ្រង់បានបង់ថ្លៃឈ្នួលនៃអំពើបាបដោយការសុគតរបស់ទ្រង់នៅលើឈើឆ្កាង ព្រមទាំងរំដោះអំពើបាបរបស់យើងដោយទ្រង់បានចូលទៅដល់ជង្ហុកធំ ព្រះយេស៊ូវទ្រង់បានយកកូនសោរនៃសេចក្តីស្លាប់ ក៏បានដកយកស្ថានឃុំព្រលឹងមនុស្សស្លាប់ចេញពីកណ្តាប់ដៃរបស់សាតាំងផងដែរ ។

ទ្រង់បានធ្វើឱ្យសាតាំងចុះចាញ់ ព្រមទាំងបំបាក់បំបែកអំណាចលើសេចក្តីស្លាប់របស់វាផ្នូរនៃសេចក្តី ឈើចុកចាប់មិនអាចឃុំព្រះកាយព្រះយេស៊ូវបានឡើយ ។ ព្រះយេស៊ូវទ្រង់បានរស់ពីសុគតឡើងវិញ ទ្រង់បានទទួលជោគជ័យដោយអំណាចចេស្តា ។ សាតាំងនិងគ្រប់ទាំងវិញ្ញាណអសោចិ៍ បានត្រូវបរាជ័យហើយ !

ព្រះគម្ពីរអេភេសូរ ១:១៩-២១ ចែងថា: **ហើយថា ព្រះចេស្តាដ៏ខ្លាំងលើសលន់របស់ទ្រង់ ដល់យើងរាល់គ្នា ដែលជឿជាយ៉ាងណាដែរ តាមដែលកំឡាំងទ្រង់ដ៏មានឫទ្ធិបានពូកែនឹងធ្វើជាព្រះចេស្តាដែល ទ្រង់បានសំដែងចេញ ដោយប្រោសព្រះគ្រីស្ទ ឱ្យមានព្រះជន្មរស់ពីស្លាប់ឡើងវិញ ព្រមទាំងតាំងឱ្យគង់ខាងស្តាំទ្រង់នៅស្ថានដ៏ខ្ពស់ ឱ្យខ្ពស់ជាងអស់ទាំងពួកគ្រប់គ្រង ពួកមានអំណាច មានឫទ្ធិបារមី និងពួកមេទាំងប៉ុន្មាន ហើយគ្រប់ទាំងឈ្មោះដែលបានតាំងឡើងដែរ មិនមែនតែក្នុងបច្ចុប្បន្ននេះតែប៉ុណ្ណោះ គឺទៅក្នុងអនាគតខាងមុខទៀតផង ។**

ព្រះយេស៊ូវទ្រង់បានតម្កើងឡើង ដោយមានជ័យជម្នះយកមកឯនគរស្ថានសួគ៌វិញ ហើយទ្រង់ក៏បាននាំពួកខ្មាំងសត្រូវ មកទទួលការហ៊ោកហ៊ីនរបស់ទ្រង់ ។

ព្រះគម្ពីរអេភេសូរ ៤:៨-១០ ចែងថា: **បានជាទ្រង់មានបន្ទូលថា "ដែលបានយាងឡើងទៅស្ថានខ្ពស់ នោះទ្រង់បានចាប់ពួកឈ្លើយនាំទៅជាឈ្លើយ ហើយបានប្រទានអំណោយទានដល់មនុស្ស" តែដែលថាទ្រង់យាងឡើងទៅនោះ តើមានន័យដូចម្តេច បើមិនមែនថា ទ្រង់បានយាងចុះទៅដល់ស្ថានទាបក្រោមដីជាមុនប៉ុណ្ណោះ ឯព្រះដែលយាងចុះទៅនោះ គឺជាព្រះដដែល ដែលបានយាងឡើងផុតអស់ទាំងជាន់នៅស្ថានសួគ៌ ដើម្បីឱ្យទ្រង់បានគង់នៅពេញគ្រប់ទាំងអស់ ។**

ពេលដែលព្រះយេស៊ូវទ្រង់បាននាំពួកឈ្លើយឱ្យទៅជាឈ្លើយនោះ យើងក៏បានរូបភាពព្រះយេស៊ូវទុកជាមេបញ្ជាការអ្នកដឹកនាំផ្នែកសញ្ជ័យ ដើម្បីធ្វើឱ្យពួកខ្មាំងសត្រូវត្រូវបរាជ័យ នៅក្នុងព្យុះហយាត្រា ព្រោះទ្រង់បានទម្លាក់ងារ បានដោះសំលៀកបំពាក់ បានដាក់ច្រវ៉ាក់ ព្រមទាំងបានធ្វើឱ្យពួកវាអាម៉ាសមុខនៅកណ្តាលវាល ដែលបានវំពូកនៅចំពោះមុខពួកទេវតាទាំងអស់ដែលនៅឯស្ថានសួគ៌ផង ។ សាតាំងព្រមទាំងពួកវិញ្ញាណទាំងអស់ ត្រូវបានទទួលការបរាជ័យពីគ្រប់ការទាំងអស់ ព្រមទាំងភាពអាម៉ាសមុខដែលវាបានទទួលជាសាធារណៈ ។

ពេលដែលព្រះយេស៊ូវទ្រង់យកបាននូវកូនសោរនៃអំណាចចេញពីសាតាំងហើយ ទ្រង់បានដាក់កូនសោរនៃអំណាចដែលលោកអ័ដាមមិនបានស្តាប់បង្គាប់ ហើយបានចុះចូលជាមួយសាតាំងនោះ ទៅឱ្យគាត់វិញ ។ ពេលដែលព្រះយេស៊ូវទ្រង់បានត្រូវនៅជាអាក្រាតនោះ កូនសោរនៃអំណាចទាំងនោះ បាននៅក្នុងដៃរបស់សាតាំងនៅឡើយទេ ទាល់តែទ្រង់បានទម្លាក់ងារពីសាតាំងមក អំណាចរបស់វាដែលបានគ្រប់គ្រងលើមនុស្សជាតិ និងលើផែនដីនោះ ត្រូវបានធ្លាក់មកលើដៃយើងវិញ ។ ព្រះយេស៊ូវទ្រង់បានផ្ចាញ់សាតាំង និងគ្រប់អស់ទាំងវិញ្ញាណរបស់វា ដោយអង្គទ្រង់ផ្ទាល់ ។

## បានទទួលដោយអំណរ

ពិតប្រាកដហើយ គ្មានពាក្យនឹងពណ៌នានូវសេចក្តីអំណរនៃអ្នកនៅស្ថានសួគ៌ នៅពេលដែលព្រះ រាជបុត្រានៃព្រះ ទ្រង់បានយាងត្រឡប់មកស្ថានសួគ៌វិញដើម្បីមកទទួលយកសិទ្ធិនោះទេ ។

តើគួរឱ្យមនុស្សអាចពណ៌នានូវជ័យជម្នះ ដែលយកបានមកវិញដោយរបៀបណាហ្ន៎ !

ស្តេចដាវីឌបានទូន្មានដល់យើង ដោយពណ៌នាអំពីពេលវេលានេះ ។

ព្រះគម្ពីរទំនុកដំកើង ២៤:៧-១០ ចែងថា: **ឱទ្វារទាំងឡាយអើយ ចូរងើបក្បាលឡើង ឱទ្វារដ៏នៅអស់កល្បជានិច្ចអើយ ចូរនៅជាចំហចុះ នោះមហាក្សត្រដ៏មានសិរីល្អ ទ្រង់នឹងយាងចូលមក តើមហាក្សត្រដ៏មានសិរីល្អនេះជាអ្នកណា គឺព្រះយេហូវ៉ាដ៏មានព្រះចេស្តា និងឥទ្ធិឫទ្ធិ ជាព្រះយេហូវ៉ាដ៏មានឥទ្ធិឫទ្ធិក្នុងចំបាំង ឱទ្វារទាំងឡាយអើយ ចូរងើបក្បាលឡើង ឱទ្វារដ៏នៅអស់កល្បជានិច្ចអើយ ចូរនៅជាចំហចុះ នោះមហាក្សត្រដ៏មានសិរីល្អ ទ្រង់នឹងយាងចូលមក តើ**

**មហាក្សត្រដ៏មានសិរីល្អនេះជាអ្នកណា គឺព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់ជាមហាក្សត្រដ៏មានសិរីល្អនោះឯង ។**

**ការប្រកាសពីជ័យជម្នះ**

លោកសាវ័កយ៉ូហានបានផ្ដល់ជូននូវព្រះបន្ទូលរបស់ព្រះយេស៊ូវដល់យើង នៅពេលដែលទ្រង់បានប្រកាសពីជ័យជម្នះរបស់ទ្រង់ថាៈ

**ជាព្រះដ៏រស់នៅ អញបានស្លាប់ តែមើល អញរស់នៅអស់កល្បជានិច្ចរៀងរាបតទៅវិញ អញក៏មានកូនសោរនៃសេចក្ដីស្លាប់ និងស្ថានឃុំព្រលឹងមនុស្សស្លាប់ដែរ** (វិវរណៈ ១:១៨) ។

**ព្រះយេស៊ូវទ្រង់មានកូនសោរ !**

ព្រះយេស៊ូវទ្រង់បានយាងចូលស្ថានសួគ៌ ដោយបន្លឺឧទានថា "ឱព្រះវរបិតាអើយ ទូលបង្គំមានកូនសោរហើយ! សាតាំងត្រូវបរាជ័យ ហើយមើល ទូលបង្គំមានកូនសោរ!" ។

ព្រះយេស៊ូវទ្រង់មានកូនសោរនៅក្នុងព្រះហស្ដរបស់ទ្រង់ហើយ គឺជាកូនសោរដែលទ្រង់បានយកពីសាតាំងត្រឡប់មកវិញ ដែលវាបានលួចពីលោកអ័ដាម និងនាងអេវ៉ានៅក្នុងសួនច្បារអេដែន ។

**សារៈសំខាន់របស់កូនសោរ**

ព្រះយេស៊ូវទ្រង់បានយកកូនសោរចេញពីសាតាំងវិញហើយ ប៉ុន្ដែ ទ្រង់មិនមែនជាអ្នកថែរក្សាពួកវានោះទេ គឺទ្រង់បានប្រទានពួកវាមកក្នុងដៃរបស់មនុស្សជាតិវិញ ។

នៅក្នុងការបើកសម្ដែងដំបូងដល់ពួកជំនុំ ព្រះយេស៊ូវទ្រង់មានបន្ទូលទៅពួកសិស្សថា ទ្រង់បានប្រគល់កូនសោរនៃនគរស្ថានសួគ៌ទៅពួកគេហើយ ។

ព្រះគម្ពីរម៉ាថាយ ១៦:១៩ ចែងថាៈ **ខ្ញុំនឹងឱ្យកូនសោរនៃនគរស្ថានសួគ៌ដល់អ្នក បើអ្នកនឹងទុកអ្វីៗនៅផែនដី នោះនឹងត្រូវចងទុកនៅលើស្ថានសួគ៌ដែរ ហើយបើអ្នកនឹងស្រាយអ្វីៗនៅផែនដី នោះនឹងត្រូវស្រាយនៅស្ថានសួគ៌ដែរ ។**

នៅក្នុងព្រះគម្ពីរអេសាយ មានការធានាដទៃទៀតចំពោះកូនសោរនេះដែរ ។

ព្រះគម្ពីរអេសាយ ២២:២២ ចែងថាៈ **អញនឹងយកកូនសោរនៃវង្សដាវីឌ ដាក់លើស្មាគាត់ នោះគាត់នឹងបើកឥតមានអ្នកណាបិទបានឡើយ ក៏នឹងបិទទៅ ឥតមានអ្នកណាបើកបានដែរ ។**

នៅសម័យពីអតីតកាល កូនសោរនោះមានទំហំធំណាស់ ធ្ងន់ហើយជារបស់លំអទៀតផង ។ មានបុរសអ្នកមានម្នាក់បានលីពួកវានៅលើស្មា ដោយសារតែវាធ្ងន់ពេក ប៉ុន្ដែវាធ្វើឱ្យរឹតតែមានបន្ទុកចំពោះភាពស្រស់ត្រកាលរបស់គេទៅវិញ ។ មានឈ្នួលបម្រើពីរទៅបីនាក់ដែលតាមបុរសអ្នកមាននោះ ដើម្បីលីកូនសោរលើស្មារបស់ពួកគេជានិច្ច ។ រឿងនេះគឺបង្ហាញពីភាពជាអ្នកមាន ។

ពេលដែលលោកហោរាអេសាយបានទាយទំនាយពីការយាងមករបស់ព្រះមែស៊ី គាត់បានផ្តល់នូវទីសម្គាល់នៃកូនសោរ ដែលបានត្រូវលីនៅលើស្មា ។

ព្រះគម្ពីរអេសាយ ៩:៦ក ចែងថា: **ដ្បិតមានបុត្រ១កើតដល់យើង ព្រះទ្រង់ប្រទានបុត្រា១មកយើងហើយ ឯការគ្រប់គ្រងនឹងនៅលើស្មារបស់បុត្រនោះ ។**

កូនសោរគឺជារដ្ឋបាល និងអំណាច ដែលនៅក្នុងព្រះហស្តព្រះយេស៊ូវ! ព្រះយេស៊ូវទ្រង់បានយកកូនសោរទាំងនោះ ឱ្យទៅពួកគេ គឺជាពួកជំនុំរបស់ទ្រង់ ។

**អំណាចនៅលើផែនដីនេះ**
**ត្រូវបានកែឡើងសារជាថ្មី**
**ឱ្យទៅមនុស្សជាតិហើយ!**

## <u>សំណួររំឭកសារឡើងវិញ</u>

១- បន្ទាប់ពីការសុគតនៅលើឈើឆ្កាងរបស់ទ្រង់មក តើព្រះយេស៊ូវទ្រង់បានយកអំពើបាបទាំងអស់ ព្រមទាំងវិសមធម៌របស់យើងទៅឯណា?

២- តើព្រះបន្ទូលដែលចែងថា ព្រះយេស៊ូវទ្រង់បានបំផ្លាញគោលការណ៍ និងអំណាច ព្រមទាំងដាក់ពួកវាឱ្យស្ថិតនៅក្នុងភាពអាម៉ាស នោះមានន័យយ៉ាងដូចម្តេច?

៣- តើអ្វីទៅជាតំណាងឱ្យកូនសោរ ដែលព្រះយេស៊ូវទ្រង់បានសម្តែងនៅក្នុងព្រះគម្ពីរវិវរណៈ ១:១៨?

# មេរៀនទី ៧
# អំណាចបានកែជាថ្មីឡើងវិញឱ្យដល់មនុស្សជាតិ

## ព្រះរាជកិច្ចរបស់ព្រះយេស៊ូវបានសម្រេចហើយ !

ព្រះរាជកិច្ចរបស់ព្រះយេស៊ូវដែលទ្រង់បានបំពេញនោះ គឺត្រូវបានចប់ហើយ !

ពេលដែលព្រះទ្រង់បានបង្កើតលោកអ័ដាម និងនាងអេវ៉ាមក ទ្រង់បានប្រទានអំណាចដល់ពួកគេ ឱ្យបានគ្រប់គ្រងលើផែនដីនេះ ។ ដោយពួកគេបានធ្វើបាប ទើបពួកគេបានបាត់បង់នូវអំណាច ហើយអំណាចនោះត្រូវបានប្រគល់ឱ្យទៅសាតាំង ។ បន្ទាប់មក ព្រះយេស៊ូវទ្រង់បានធ្វើជាមនុស្សគ្រប់លក្ខណវិញ គឺជាលោកអ័ដាមចុងក្រោយ ទ្រង់បានដើរនៅលើផែនដីនេះ ជាលក្ខណៈមនុស្សធម្មតា ដែលព្រះទ្រង់បានបង្កើតមកឱ្យមាននៅ ។ ព្រះយេស៊ូវទ្រង់បានផ្ទុកនូវអំពើបាបរបស់មនុស្សជាតិ ដោយអង្គទ្រង់ ដោយទ្រង់បានសុគតនៅលើឈើឆ្កាង បង់ថ្លៃអំពើបាបនោះ ។

ទ្រង់បានរងទុក្ខសុគតសម្រាប់មនុស្សជាតិទាំងអស់ ។ ទ្រង់បានរំដោះអំពើបាបទាំងនោះ ដោយទ្រង់បានយាងចុះទៅដល់ជង្ហុកធំ ហើយក្រោយមកអំណាចចេស្តារបស់ព្រះបានមកឯព្រះយេស៊ូវ ។ ទ្រង់បានធ្វើឱ្យសាតាំង និងពួកវិញ្ញាណរបស់វាត្រូវបរាជ័យ នៅទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់ ។ ព្រះយេស៊ូវទ្រង់បានយកកូនសោរនៃអំណាចត្រឡប់មកវិញ ។

ព្រះយេស៊ូវទ្រង់បានយករបស់គ្រប់យ៉ាងពីសាតាំងមកវិញ ដែលវាបានលួចយកពីមនុស្សជាតិទៅ ។ គ្រប់របស់ទាំងអស់ដែលព្រះទ្រង់បានបង្កើតមក រួមទាំងលោកអ័ដាម និងនាងអេវ៉ា ត្រូវបានទាមទារយកមកប្រគល់ឱ្យមនុស្សជាតិវិញ ដោយអង្គព្រះយេស៊ូវ ។

ពេលដែលព្រះយេស៊ូវទ្រង់បានមានបន្ទូលជាដំបូងទៅដល់ពួកជំនុំ ថាទ្រង់ត្រូវតែសង់ពួកជំនុំឡើង គឺទ្រង់មានបន្ទូលដូច្នេះថា: ...**ខ្ញុំនឹងតាំងពួកជំនុំខ្ញុំនៅលើថ្មដានេះ ហើយទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់ នឹងមិនដែលឈ្នះពួកជំនុំឡើយ ខ្ញុំនឹងឱ្យកូនសោរនៃនគរស្ថានសួគ៌ដល់អ្នក បើអ្នកនឹងចងអ្វីៗនៅផែនដី នោះនឹងត្រូវចងទុកនៅលើស្ថានសួគ៌ដែរ ហើយបើអ្នកនឹងស្រាយអ្វីៗនៅផែនដី នោះនឹងត្រូវស្រាយនៅស្ថានសួគ៌ដែរ** ( ម៉ាថាយ ១៦:១៨ខ-១៩) ។

## ព្រះយេស៊ូវទ្រង់គង់នៅក្នុងនគរស្ថានសួគ៌

អ្នកសរសេរព្រះគម្ពីរហេព្រើរបានផ្ដល់ឱ្យយើងនូវមុខងារព្រះយេស៊ូវសព្វថ្ងៃនេះថា:

**តែទ្រង់វិញ ក្រោយដែលទ្រង់បានថ្វាយយញ្ញបូជាតែ១ ដោយព្រោះបាប នោះទ្រង់បានគង់ខាងស្តាំព្រះ នៅជារៀងរាបដរាបទៅ ទាំងចាំទំរាំដល់បានដាក់ពួកខ្មាំងសត្រូវ ឱ្យធ្វើជាកំណល់កល់ព្រះបាទទ្រង់** ( ហេព្រើរ ១០:១២-១៣) ។

ព្រះយេស៊ូវទ្រង់បានគង់នៅខាងស្តាំដៃនៃព្រះវរបិតា ។

ស្ដេចដាវីឌក៏បានទាយទុកជាមុនផងដែរ នូវកន្លែងដែលព្រះយេស៊ូវគង់នៅ ។

ព្រះគម្ពីរទំនុកដំកើង ១១០:១ ចែងថា: **ព្រះយេហូវ៉ាទ្រង់មានបន្ទូលដល់ព្រះអម្ចាស់នៃទូលបង្គំថា ចូរឱ្យឯងអង្គុយនៅខាងស្តាំអញ ទាល់តែអញដាក់ពួកខ្មាំងសត្រូវឯង ឱ្យធ្វើជាកំណល់កល់ជើងឯង ។**

ស្តេចដាវីឌបានទាយទំនាយថា ព្រះយេស៊ូវនឹងត្រូវបានអង្គុយនៅខាងស្តាំនៃព្រះវរបិតា។

## ព្រះយេស៊ូវកំពុងរង់ចាំ

ទាំងស្តេចដាវីឌ និងអ្នកសរសេរព្រះគម្ពីរហេព្រើរ បានប្រាប់យើងថាព្រះយេស៊ូវកំពុងតែធ្វើការ ច្រើនជាងអង្គុយនៅខាងស្តាំនៃព្រះវរបិតា ។ ព្រះយេស៊ូវកំពុងតែរង់ចាំ ទាល់តែខ្មាំងសត្រូវរបស់ព្រះអង្គ បានដាក់នៅក្រោមបាទរបស់ទ្រង់ ។

តើអ្នកណាមានបំណងចង់ធ្វើឱ្យខ្មាំងសត្រូវរបស់ទ្រង់ បាននៅក្រោមព្រះបាទរបស់ទ្រង់?

ព្រះយេស៊ូវទ្រង់កំពុងរង់ចាំ សម្រាប់ការប្រោសលោះរបស់ព្រះអម្ចាស់ ដើម្បីរកឱ្យឃើញនូវអំណាចដែលត្រូវបានកែជាថ្មីរបស់ពួកគេ ព្រមទាំងបានបង្ហាញថា សាតាំងដែលជាខ្មាំងសត្រូវច្បាស់ជាត្រូវទទួលបរាជ័យជាមិនខាន ។ ព្រះរាជកិច្ចរបស់ព្រះយេស៊ូវត្រូវបានសម្រេច ! ទ្រង់កំពុងតែរង់ចាំ ទាល់តែខ្មាំងសត្រូវរបស់ព្រះអង្គ បានដាក់នៅក្រោមព្រះបាទរបស់ទ្រង់ ។ វាជាកិច្ចការរបស់អ្នកជឿទាំងឡាយ ដែលត្រូវតែដាក់សាតាំងទៅនៅកន្លែងរបស់វាវិញ ។ អ្នកជឿទាំងឡាយត្រូវតែដាក់សាតាំង និងវិញ្ញាណអសោចិ៍របស់វា នៅពីក្រោមព្រះបាទព្រះយេស៊ូវ ។

ព្រះយេស៊ូវទ្រង់បានធ្វើសម្រេចគ្រប់កិច្ចការទាំងអស់ ទ្រង់ក៏បានសន្មតិថាបានធ្វើចប់ហើយ ។ ឥឡូវនេះ អ្នកដែលត្រូវទទួលខុសត្រូវ គឺសម្រាប់យើងរាល់គ្នាហើយ ។ យើងរាល់គ្នាជារូបកាយរបស់ព្រះអង្គនៅផែនដីនេះ ។ យើងគឺជាដៃជាជើងជាប្រអប់ជើងរបស់ព្រះអង្គ ។ យើងគឺជាអ្នកដែលត្រូវតែគ្រប់គ្រងលើភពផែនដីរបស់យើង នៅពេលសព្វថ្ងៃនេះ ។

## សេចក្តីអធិស្ឋានរបស់លោកសាវកប៉ុល

លោកសាវកប៉ុលបានអធិស្ឋាននូវរឿងសំខាន់មួយ គឺជាសេចក្តីអធិស្ឋានដ៏ពេញដោយអំណាចសម្រាប់ពួកបរិសុទ្ធទាំងអស់។ សេចក្តីអធិស្ឋានរបស់គាត់បានគ្របដណ្តប់លើមុខងាររបស់ព្រះយេស៊ូវ ដែលកំពុងតែគង់នៅខាងស្តាំដៃនៃព្រះវរបិតា គឺជាមុខងារជាអំណាច ព្រមទាំងការទទួលខុសត្រូវរបស់យើងរាល់គ្នា ។

ព្រះគម្ពីរអេភេសូរ ១:១៨-២៣ ចែងថា: **ដើម្បីឱ្យភ្នែកចិត្តអ្នករាល់គ្នាបានភ្លឺឡើងប្រយោជន៍ឱ្យបានដឹងថា ដែលទ្រង់ហៅអ្នករាល់គ្នា នោះមានសេចក្តីសង្ឃឹមជាយ៉ាណា ហើយថាសិរីល្អដ៏ប្រសើរក្រៃ លែងនៃមរតកទ្រង់ ក្នុងពួកបរិសុទ្ធជាយ៉ាណាផង ហើយថា ព្រះចេស្តាដ៏ខ្លាំងលើសលន់របស់ទ្រង់ ដល់យើងរាល់គ្នាដែលជឿជាយ៉ាងណាដែរ តាមដែលកំឡាំងទ្រង់ដ៏មានឫទ្ធីបានពូកែនឹងធ្វើ នោះព្រះចេស្តាដែលទ្រង់បានសំដែងចេញ ដោយប្រោសព្រះគ្រីស្ទ ឱ្យមានព្រះជន្មរស់ពីស្លាប់ឡើងវិញ ព្រមទាំងតាំងឱ្យគង់ខាងស្តាំទ្រង់ នៅស្ថានដ៏ខ្ពស់ ឱ្យខ្ពស់អស់ជាងទាំងពួកគ្រប់គ្រង ពួកមានអំណាច មានឫទ្ធិបារមី និងពួកមេទាំងប៉ុន្មាន ហើយគ្រប់ទាំងឈ្មោះដែលបាន**

**តាំងឡើងដែរ មិនមែនតែក្នុងបច្ចុប្បន្ននេះតែប៉ុណ្ណោះ គឺទៅក្នុងអនាគតខាងមុខទៀតផង ហើយទ្រង់បានបង្ក្រាបគ្រប់ទាំងអស់ នៅក្រោមព្រះបាទនៃព្រះរាជបុត្រា ទាំងប្រទានទ្រង់មកធ្វើជាសិរសាលើគ្រប់ទាំងអស់ដល់ពួកជំនុំ ដែលជារូបកាយទ្រង់ គឺជាសេចក្តីពោរពេញរបស់ព្រះអង្គ ដែលបំពេញគ្រប់ទាំងអស់ ក្នុងទាំងអស់ ។**

**មុខងាររបស់ព្រះយេស៊ូវ**

**តាមរយៈលោកសាវកប៉ុលៈ**

- *ព្រះយេស៊ូវទ្រង់មានព្រះជន្មរស់ពីសុគតឡើងវិញ*
- *ទ្រង់បានគង់ខាងស្តាំដៃនៅឯនគរស្ថានសួគ៌ដ៏បំផុត*
- *ឱ្យខ្ពស់អស់ជាងទាំងពួកគ្រប់គ្រង ពួកមានអំណាច មានឫទ្ធិបារមី និងពួកមេទាំងប៉ុន្មាន*
- *ខ្ពស់លើសអស់ទាំងអ្វីដែលបានប្រទានឱ្យផង*
- *គ្រប់ទាំងអស់បាននៅក្រោមព្រះបាទទ្រង់*
- *ត្រូវបានតែងតាំងឱ្យបានជាប្រមុខលើទាំងអស់*

ព្រះយេស៊ូវទ្រង់ខ្ពស់លើសអស់ទាំងអំណាចនៃវិញ្ញាណអសោចិ៍ ។ ព្រះយេស៊ូវទ្រង់ខ្ពស់លើសអស់ទាំងអ្វីដែលបានប្រទានមក ឬក៏លើសអស់ទាំងអ្វីដែលនឹងត្រូវបានប្រទានមកទៅមុខទៀត ។ គ្រប់ទាំងអស់ត្រូវតែបាននៅក្រោមព្រះបាទព្រះយេស៊ូវ ។

**កត្តានៃអំណាច**

មានកត្តានៃអំណាចពីរយ៉ាង អំណាចមួយនៅគ្រាសញ្ញាចាស់ អំណាចមួយទៀតនៅគ្រាសញ្ញាថ្មី ។

កត្តានៃអំណាចនៅគ្រាសញ្ញាចាស់ គឺនៅផ្នែកមួយនៃសមុទ្រក្រហម ។

រីឯកត្តានៃអំណាចនៅគ្រាសញ្ញាថ្មី គឺស្ថិតនៅហើយនៅតែស្ថិតនៅ គឺជាអំណាចនៃសេចក្តីរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ។

លោកសាវកប៉ុលបានសរសេរថាៈ

**តាមដែលកំឡាំងទ្រង់ដ៏មានឫទ្ធិបានពូកែនឹងធ្វើ នោះព្រះចេស្តាដែលទ្រង់បានសំដែងចេញ ដោយប្រោសព្រះគ្រីស្ទ ឱ្យមានព្រះជន្មរស់ពីស្លាប់ឡើងវិញ** (អេភេសូរ ១:១៩ខ-២០ក) ។

**មុខងាររបស់ពួកអ្នកជឿ**

លោកសាវកប៉ុលបានអធិស្ឋានថា អ្នកជឿទាំងឡាយគួរតប្បីធ្វើជាពន្លឺ ធ្វើឱ្យគេដឹងថាៈ

- *សេចក្តីសង្ឃឹមពីការត្រាស់ហៅរបស់ទ្រង់*
- *ជាអ្នកមានសិរីល្អនៃមរតកទ្រង់*
- *ភាពធំឧត្តមដែលហួសលើសនៃអំណាចចេស្តាទ្រង់*

➪ *យើងរាល់គ្នាជារូបកាយរបស់ទ្រង់*

➪ *យើងរាល់គ្នាជាគ្រប់ទាំងអស់របស់ទ្រង់*

យើងរាល់គ្នាត្រូវតែជាអ្នកមានសិរីល្អនៃមរតកទ្រង់ ព្រមទាំងអំណាចដ៏ធំឥតឧបមារបស់ទ្រង់សម្រាប់យើងដែលជាអ្នកជឿ ។ យើងត្រូវតែបំពេញការងារនៅក្នុងអំណាចដ៏ធំ ដូចជាព្រះយេស៊ូវទ្រង់បានរស់ពីស្លាប់ឡើងវិញ ។

## **ភាពពោរពេញរបស់ទ្រង់**

លោកសាវកប៉ុលបានអធិស្ឋានសម្រាប់ "ពួកជំនុំដែលជារូបកាយរបស់ទ្រង់ ឱ្យមានភាពពោរពេញរបស់ទ្រង់ ដែលបំពេញគ្រប់ទាំងអស់លើគ្រប់ទាំងអស់" ។

ប្រសិនបើយើងជាពួកជំនុំរបស់ទ្រង់ កំពុងតែបានបំពេញនៅកន្លែងទំនេរ ឬកន្លែងដែលខ្វះចន្លោះដែលនៅក្នុងព្រះរាជបុត្រានៃព្រះ តើដល់ពេលណាទើបបានត្រូវបំពេញនៅកន្លែងដែលខ្វះនោះ? ប្រហែលជាកន្លែងដែលខ្វះនេះត្រូវតែវិលត្រឡប់ទៅឯថ្ងៃរបស់លុស៊ីហ្វើរវិញ ដែលបានទទួលការចាក់ប្រេងតាំងជា ទេវតាចេរូប៊ីនឡើងជាអ្នកគ្របបាំង ហើយដែត្រូវបានបណ្តេញចេញពីស្ថានសួគ៌ រួមទាំងទាំងទេវតាដែលតាមវា ក្នុងការបះបោររបស់វានោះទេដឹង?

ព្រះគម្ពីរអេសេគាល ២៨:១៤ ចែងថា: **ឯងជាចេរូប៊ីនដែលបានចាក់ប្រេងតាំងឡើងជាអ្នកគ្របបាំង គឺអញបានតាំងឯងឡើង ឱ្យឯងបាននៅលើភ្នំបរិសុទ្ធរបស់ព្រះ ឯងក៏បានដើរទៅមកនៅកណ្តាលថ្មភ្លឺចាំង ។**

### **អ្នកដឹកនាំទេវតា**

មានអ្នកដឹកនាំបីនាក់ ក្នុងចំណោមអ្នកបម្រើព្រះទាំងអស់ គឺមានអ្នកដឹកនាំទេវតាចំនួនបីនាក់ បានលេចឡើងជាងគេ ។ ពួកគេទាំងនោះគឺ ទេវតាមីកែល ទេវតាលុស៊ីហ្វើរ និងទេវតាកាព្រីយ៉ែល ។

➪ *មួយភាគបី*

ពេលដែលទេវតាលុស៊ីហ្វើរបានធ្វើការទាស់ទទឹងនឹងព្រះ វាបាននិយាយទៅ "ពួកទេវតារបស់វា" ថា យើងត្រូវបានបណ្តេញចេញទាំងអស់គ្នា ។

ព្រះគម្ពីរវិវរណៈ ១២:៧-៩ ចែងថា: **នោះមានចំបាំងនៅលើមេឃ គឺមីកែល និងពួកទេវតារបស់លោកច្បាំងនឹងនាគ ហើយនាគ និងទេវតាវា ក៏ច្បាំងនឹងលោកដែរ តែមិនបានឈ្នះទេ ក៏មិនឃើញមានកន្លែងណាឱ្យវា នៅលើមេឃទៀតផង នោះនាគធំ ត្រូវបោះទំលាក់ទៅ គឺជាពស់ពីបុរាណ ដែលឈ្មោះហៅថា អារក្ស ហើយសាតាំងផង ដែលបាននាំលោកិយទាំងមូលឱ្យវង្វេងចេញ វាត្រូវបោះទំលាក់ទៅផែនដីវិញ ព្រមទាំងពួកទេវតារបស់វាផង ។**

ពួកទេវតាដែលត្រូវបានពណ៌នា គឺជាពួកទេវតារបស់សាតាំង ហើយដែលត្រូវបានបណ្តេញចេញចុះមកផែនដីជាមួយវានោះ គឺមានចំនួនមួយភាគបីនៃពួកទេវតាដែលនៅស្ថានសួគ៌ទាំងអស់ ។

ព្រះគម្ពីរវិវរណៈ ១២:៤ក ចែងថា: **កន្ទុយវាក៏ទាញផ្កាយនៅលើមេឃ១ភាគក្នុង៣ ត្រវាត់ចោលទៅផែនដី ។**

➪ *ទេវតាមីកែល*

ទេវតាមីកែលគឺជាទេវតាតែមួយគត់ ដែលត្រូវបានផ្តល់ឱ្យធ្វើជាមហាទេវតា ។

ព្រះគម្ពីរយូដាស ខ.៩ក ចែងថា: **រីឯមីកែល ជាមហាទេវតា ។**

គឺជាទេវតាមីកែល និង"ពួកទេវតារបស់លោក" ដែលជាពួកទេវតាចម្បាំង ដែលបាន ប្រឆាំងនឹងសាតាំង "នាគ និងពួកទេវតារបស់វា" ។

ព្រះគម្ពីរវិវរណៈ ១២:៧ ចែងថា: **នោះមានចំបាំងនៅលើមេឃ គឺមីកែល និងពួក ទេវតារបស់លោកច្បាំងនឹងនាគ ហើយនាគនិងទេវតាវា ក៏ច្បាំងនឹងលោកដែរ ។**

ប្រហែលជាមហាទេវតាមីកែល និងពួកទេវតាមួយភាគបី ដែលនៅក្រោមបញ្ជារបស់ លោក បានរៀបចំការងារឱ្យព្រះដ៏ជាព្រះវរបិតា ។

➪ *ទេវតាកាព្រីយ៉ែល*

ប្រហែលជាទេវតាកាព្រីយ៉ែល ដែលតែងតែលេចមុខ គឺជាទេវតាអ្នកនាំសារ ក៏មាន ទេវតាមួយភាគក្នុងបី នៅក្រោមបញ្ជារបស់លោកដែរ គឺជាអ្នករៀបចំការងារឱ្យព្រះដ៏ជាព្រះ វិញ្ញាណបរិសុទ្ធ ។

លោកបានលេចមុខឱ្យលោកសាការីបានឃើញ ដើម្បីផ្តល់ព្រះរាជសារឱ្យគាត់ ដែល ប្រពន្ធរបស់គាត់ឈ្មោះអេលីសាបិត ដែលត្រូវបង្កើតកូនប្រុសមួយឱ្យគាត់ ដែលត្រូវ"បានសម្រេច ដោយព្រះវិញ្ញាណបរិសុទ្ធ សូម្បីតែមកពីសត្វស្លាបក៏ដោយ" ។

ព្រះគម្ពីរលូកា ១:១៩ ចែងថា: **ទេវតាឆ្លើយតបនឹងលោកថា ខ្ញុំនេះឈ្មោះកាព្រីយ៉ែល ដែលឈរនៅចំពោះព្រះ ទ្រង់បានចាត់ខ្ញុំឱ្យមកនិយាយនឹងលោក ហើយប្រកាសប្រាប់ដំណឹងល្អ នេះ ។**

ទេវតាកាព្រីយ៉ែលក៏បានលេចមកឱ្យស្ត្រីព្រហ្មចារីយ៍ឈ្មោះនាងម៉ារាបានឃើញដែរ ។

ព្រះគម្ពីរលូកា ១:៣០-៣១,៣៥ ចែងថា: **តែទេវតានិយាយថា កុំខ្លាចអី ម៉ារាអើយ ដ្បិតព្រះបានប្រោសមេត្តាដល់នាងហើយ មើលនាងនឹងមានគភ៌ប្រសូតបានបុត្រា១ ដែលនាងត្រូវ ថ្វាយព្រះនាមថា "យេស៊ូវ"**

នាងម៉ារាបានសួរទៅទេវតាថា "តើការនេះនឹងកើតបានដូចម្តេច បើខ្ញុំមិនដែលទាំង ស្គាល់ប្រុសណាផងនោះ"

**ទេវតាក៏ឆ្លើយថា ព្រះវិញ្ញាណបរិសុទ្ធនឹងយាងមកសណ្ឋិតលើនាង ហើយព្រះចេស្តានៃ ព្រះដ៏ខ្ពស់បំផុត នឹងមកគ្របបាំងនាងដោយស្រមោល ហេតុដូច្នេះបុត្របរិសុទ្ធដែលនឹងប្រសូត មកនោះ ត្រូវហៅថាជាព្រះរាជបុត្រានៃព្រះ ។**

ទេវតាកាព្រីយ៉ែលបានបើកសម្តែងនូវការងាររបស់ព្រះវិញ្ញាណបរិសុទ្ធ ។

➪ *ទេវតាលុស៊ីហ្វើរ*

អញ្ចឹងតើវាអាចកើតឡើងបានឬទេថា ទេវតាលុស៊ីហ្វើរ និងពួកទេវតារបស់គាត់ គឺជាអ្នករៀបចំការងារឱ្យដល់ព្រះរាជបុត្រានៃព្រះ?

ទេវតាលុស៊ីហ្វើរបានរៀបចំការងារជាទេវតាចេរូប៊ីនជាអ្នកគ្របបាំង ហើយគាត់ក៏ត្រូវបានពណ៌នាជាទេវតាចេរូប៊ីន ដែលគ្របបាំងនៅកន្លែងម្ខាងរបស់ព្រះមែស៊ី ។ គាត់ជាអ្នកមានសិទ្ធិអង្គុយនៅចំហៀងម្ខាងបល្ល័ង្ករបស់ព្រះ ។ ពេលដែលយើងឃើញនូវការគ្របបាំង គឺជាការងារសរសើរតម្កើង និងការងារថ្វាយបង្គំ ។

ពេលដែលទេវតាលុស៊ីហ្វើរ ព្រមទាំងពួកទេវតារបស់គាត់ទាំងអស់ បានធ្វើការទាស់ទទឹងភ្លាមៗ ក៏បានត្រូវទទួលការបណ្ដេញចេញពីស្ថានសួគ៌ភ្លាមៗផងដែរ នោះតើកន្លែងទទេនេះនឹងត្រូវបានយ៉ាងដូចម្ដេចវិញ?

តើព្រះដ៏ជាព្រះវរបិតាទ្រង់បានសុំទៅទេវតាមីកែល និងទេវតាកាព្រីយ៉ែលឱ្យរំលែកពួកទេវតារបស់ពួកគេខ្លះ ឱ្យបំពេញកន្លែងដែលខ្វះ ដើម្បីធ្វើការឱ្យព្រះរាជបុត្រាឬ? យើងមិនបានកត់ទុកនូវព្រឹត្តិការណ៍ដែលបានកើតឡើងនោះទេ ។

តើវាអាចកើតឡើងបានទេ ដែលថា ព្រះទ្រង់មានផែនការបានប្រសើរជាងនេះ នៅពេលដែលទ្រង់បានបង្កើតមនុស្សជាតិមក នៅក្នុងរូបភាពរបស់ព្រះអង្គ ដើម្បីឱ្យបានថ្វាយបង្គំដល់ទ្រង់ ឱ្យបានអង្គុយជាមួយនឹងទ្រង់ នៅឯនគរស្ថានសួគ៌ ឱ្យបាននៅកន្លែងរបស់ទ្រង់ ព្រមទាំងបានគ្រប់គ្រង និងសោយរាជ្យជាមួយនឹងទ្រង់ដរាបដល់អស់កល្បជានិច្ច?

**កន្លែងទំនេរត្រូវបានបំពេញ**

មនុស្សប្រុសស្រីត្រូវបានបង្កើតមក ឱ្យមានរូបភាពរបស់ព្រះ ត្រូវបានបំពេញ និងបានសម្រេចដូចជាព្រះអាទិករ ដែលទ្រង់បានបង្កើតគេមកតែមួយដង ទាំងបានផ្លុំខ្យល់ជីវិតទៅឱ្យពួកគេក្នុងមួយរំពេចនោះ ទ្រង់ក៏បានបង្កើតគេសារជាថ្មី ដើម្បីឱ្យគេបានទទួលសេចក្ដីសង្គ្រោះ តែមួយពព្រិចភ្នែកយ៉ាងនោះដែរ ។

ទ្រង់បំពេញនូវភាពខ្វះខាតនៅក្នុងជីវិតរបស់យើងដោយព្រះអង្គទ្រង់ ។ ឥឡូវនេះ រូបកាយរបស់ទ្រង់ត្រូវបំពេញនូវភាពខ្វះខាតនៅក្នុងទ្រង់ ដោយការថ្វាយរបស់ពួកគេផ្ទាល់ដល់ទ្រង់ គឺជាការបំពេញកិច្ចការសរសើរតម្កើង និងការថ្វាយបង្គំនោះឯង ។

កាលដើមដំបូង មានតែការងារមួយប៉ុណ្ណោះ ហើយការងារនោះគឺជាការសរសើរតម្កើង និងការថ្វាយបង្គំ ។ ពេលការនោះត្រូវបានបញ្ឈប់ហើយ មានការងារដទៃជាច្រើនទៀត បានត្រឡប់មកជាមានការចាំបាច់ ដូចជាការងារប្រោសឱ្យជា ការងារជួយរំដោះ ការងារផ្សះផ្សា ការងារកែជាថ្មីឡើងវិញ និងការងារផ្សេងៗទៀត ។

តើវាអាចកើតឡើងបានឬទេ ចំពោះការងារសរសើរតម្កើង និងការងារថ្វាយបង្គំ ត្រូវបានកែជាថ្មីឡើងវិញឱ្យទៅពួកជំនុំ ហើយការងារដទៃក្រៅពីការទាំងនេះ នឹងគ្មានការចាំបាច់យូរអង្វែងនៅក្នុងរូបកាយរបស់ព្រះគ្រីស្ទ ដែលពួកគេមានសព្វថ្ងៃនេះ?

ពេលដែលយើងចំណាយពេលបំពេញការងារសរសើរតម្កើង និងថ្វាយបង្គំព្រះ យើងនឹងរុករកឱ្យឃើញថា មានកម្រិតនៃសេចក្តីត្រូវការសម្រាប់ការប្រោសឱ្យជា ឬការរំដោះ ឬក៏ការងារដទៃទៀត ដែលនៅក្នុងជីវិតរបស់យើង ។

យើងគឺជាអ្នកមានសារៈសំខាន់ចំពោះព្រះ! យើងត្រូវតែបានបំពេញដល់ព្រះអង្គ យើងត្រូវបានបំពេញការងារចំពោះទ្រង់ ក្នុងការសរសើរ និងការថ្វាយបង្គំ ។ ដោយការធ្វើយ៉ាងដូច្នោះនោះយើងគឺជារូបកាយរបស់ទ្រង់ យើងបានត្រឡប់មកជា "ភាពពោរពេញរបស់ទ្រង់ ដែលបានបំពេញលើទាំងអស់ ក្នុងគ្រប់ទាំងអស់" ។

ព្រះគម្ពីរអេភេសូរ ១:២២-២៣ ចែងថាៈ **ហើយទ្រង់បានបង្ក្រាបគ្រប់ទាំងអស់ នៅក្រោមព្រះបាទនៃព្រះរាជបុត្រា ទាំងប្រទានទ្រង់មកធ្វើជាសិរសាលើគ្រប់ទាំងអស់ ដល់ពួកជំនុំ ដែលជារូបកាយទ្រង់ គឺជាសេចក្តីពោរពេញរបស់ព្រះអង្គ ដែលបំពេញគ្រប់ទាំងអស់ ក្នុងទាំងអស់ ។**

ពេលដែលយើងសរសើរតម្កើង និងថ្វាយបង្គំដល់ព្រះ យើងមិនត្រឹមតែបានបំពេញនូវមុខងារនៃទេវតាលុស៊ីហ្វើរ និងទេវតារបស់គាត់ប៉ុណ្ណោះទេ គឺយើងកំពុងតែសម្តែងសេចក្តីពិតដែលពួកគេត្រូវបរាជ័យ និងគ្មានកន្លែងនៅឯនគរស្ថានសួគ៌ទៀតផង ។ យើងកំពុងតែធ្វើឱ្យពួកវាត្រូវចុះចាញ់ ព្រមទាំងបានដាក់ពួកវានៅពីក្រោមបាទជើងរបស់យើង ។ ពេលដែលយើងរាំនៅចំពោះព្រះអម្ចាស់ នោះយើងកំពុងតែជាន់សង្កត់សាតាំងឱ្យបរាជ័យ ដោយជើងរបស់យើងបានបញ្ចេញសកម្មភាពយ៉ាងខ្លាំងក្លា ។

**កំណត់ចំណាំៈ** សម្រាប់ការសិក្សាពីការសរសើរតម្កើង និងការថ្វាយបង្គំ ឱ្យបានដល់ទីជម្រៅនោះ យើងត្រូវតែអានពីក្បួននៃការសរសើរតម្កើង និងការថ្វាយបង្គំ ដែលសរសេរដោយលោកអេ.អែល និងអ្នកស្រីចយ ហ្គីល ។

## តើការនេះមានន័យដូចម្តេចចំពោះយើង

ដោយការងាររបស់ព្រះយេស៊ូវនៅលើឈើឆ្កាង និងដោយព្រឹត្តិការណ៍ដែលមានជាបន្តបន្ទាប់ នោះសាតាំងបានត្រូវទទួលការបរាជ័យ! ទាំងពួកវិញ្ញាណអសោចិ៍ក៏បានត្រូវទទួលការបរាជ័យដែរ! ព្រះយេស៊ូវទ្រង់បានធ្វើឱ្យពួកវាត្រូវចុះចាញ់ ព្រមទាំងបានធ្វើឱ្យពួកវាគ្មានអ្វីទាំងអស់! ទ្រង់បានធ្វើឱ្យពួកវា ត្រូវបានទម្លាក់ចុះទៅក្នុង "ភាពសូន្យ" ។

⇨ *ហេតុអ្វីបានជាយើងត្រូវធ្វើឱ្យសាតាំងចុះចាញ់នៅពេលឥឡូវនេះ?*

⇨ *ហេតុអ្វីបានជាយើងត្រូវឱ្យសាតាំងយកផ្ទះ យកទីក្រុង យកជនជាតិយើងបាន?*

⇨ *ហេតុអ្វីបានជាយើងឱ្យវាដាក់ជំងឺមកលើយើងបាន?*

➪ *ហេតុអ្វីបានជាយើងត្រូវទទួលភាពក្រីក្រ?*

ចម្លើយគឺថា យើងត្រូវតែសិក្សាឱ្យយល់នូវអ្វី ដែលយើងត្រូវបានប្រទានឱ្យ បាននៅក្នុងព្រះយេស៊ូវគ្រីស្ទ ។ យើងត្រូវតែរុករកឱ្យឃើញនូវអំណាចដែលបានកែជាថ្មីឡើងវិញរបស់យើង ។

**យើងត្រូវបានរំដោះហើយ!**

ពេលដែលលោកសាវកប៉ុលបានសរសេរទៅកាន់ពួកអ្នកនៅក្រុងកូល៉ុស នោះបានចែងមកថា យើងបានត្រូវ:

➪ *រំដោះឱ្យរួច*

➪ *បានបកស្រាយ*

➪ *ប្រោសលោះ*

➪ *ទទួលការអត់ទោស*

ព្រះគម្ពីរកូល៉ុស ១:១៣-១៤ ចែងថា: **ទ្រង់បានប្រោសឱ្យយើងរួចពីអំណាចនៃសេចក្តីងងឹត ហើយផ្លាស់យើងមកក្នុងនគររបស់ព្រះរាជបុត្រាស្ងួនភ្ងានៃទ្រង់ យើងរាល់គ្នាមានសេចក្តីប្រោសលោះ ក្នុងព្រះរាជបុត្រានោះ គឺជាសេចក្តីផ្តាច់បាប ដោយសារព្រះលោហិតទ្រង់ ។**

**នគរស្ថានសួគ៌នៅទីនេះហើយ**

តើនគររបស់ព្រះរាជបុត្រាគឺជាអ្វី?

ពេលដែលព្រះយេស៊ូវ ទ្រង់បានបង្រៀនពួកសិស្សរបស់ទ្រង់ឱ្យអធិស្ឋាន ទ្រង់បានអធិស្ឋាននូវពាក្យទាំងនេះថា:

**សូមឱ្យរាជ្យទ្រង់បានមកដល់ សូមឱ្យបំណងព្រះហឫទ័យទ្រង់ បានសំរេចនៅផែនដីដូចជានៅស្ថានសួគ៌ដែរ** (ម៉ាថាយ ៦:១០) ។

នគរព្រះគឺមិនសំដៅលើរបស់ដែលនៅពេលអនាគតនោះឡើយ គឺចង់សំដៅយកនៅពេលឥឡូវនេះវិញ ។ យើងត្រូវបានរំដោះឱ្យរួចពីអំណាចគ្រប់គ្រងនៃសេចក្តីងងឹត ព្រមទាំងបាននាំចូលទៅក្នុងនគររបស់ព្រះរាជបុត្រា តាមរយៈការប្រោសលោះ និងការអត់ទោសនូវអំពើបាបរបស់យើងរាល់គ្នា ។

ដោយមានចំណេះនៃអំណាចការកែជាថ្មីឡើងវិញរបស់យើង នោះយើងបានត្រឡប់មកជាមនុស្សប្រុសស្រី ដែលមានពេញដោយកម្លាំង ដែលនឹងបានជាផ្នែកមួយមានសារៈសំខាន់ នៅក្នុងការចម្រុងចម្រើន នៅនគរស្ថានសួគ៌ក៏ដូចជានៅផែនដីនេះដែរ ។

ព្រះគម្ពីរម៉ាថាយ ១១:១២ ចែងថា: **តាំងតែពីគ្រាយ៉ូហាន-បាទិស្ទ ដរាបដល់គ្រាឥឡូវនេះ នោះមានគេខំប្រឹងចាប់បាននគរស្ថានសួគ៌ ហើយគឺជាពួកខំប្រឹងពិតដែលចាប់បានផង ។**

លោកសាវកប៉ុលក៏បានបន្តដោយពណ៌នានូវការអស្ចារ្យរបស់ព្រះយេស៊ូវថា:

**ដែលទ្រង់ជារូបអង្គនៃព្រះដ៏មើលមិនឃើញ ជាបងច្បងនៃគ្រប់ទាំងអស់ ដែលព្រះបានបង្កើតមក ដ្បិតគឺទ្រង់ហើយដែលបង្កើតគ្រប់ទាំងអស់ ទាំងរបស់នៅស្ថានសួគ៌ និងនៅផែនដី**

**ទាំងរបស់ដែលមើលឃើញ ហើយដែលមើលមិនឃើញផង ទោះបើជារាជ្យ ឬអំណាចជាព្រះអម្ចាស់ ឬអំណាចគ្រប់គ្រង ឬអំណាចណាក៏ដោយ នោះសុទ្ធកើតមកដោយសារទ្រង់ ហើយសំរាប់ទ្រង់ទាំងអស់ផង ទ្រង់គង់នៅមុនទាំងអស់ ហើយរបស់ទាំងអស់ក៏នៅស្ថិតស្ថេរ ទ្រង់ជាសិរសារបស់រូបកាយ គឺជាពួកជំនុំទ្រង់ជាដើម ក៏បានរស់ពីស្លាប់ឡើងវិញមុនគេបង្អស់ ដើម្បីឱ្យទ្រង់បានជាប្រធានក្នុងគ្រប់ទាំងអស់** ( កូល៉ុស ១:១៥-១៨) ។

## ព្រះយេស៊ូវទ្រង់ជាសិរសារបស់យើង

**ព្រះយេស៊ូវៈ**

- *ជារូបភាពរបស់ព្រះ*
- *អ្នកបង្កើតគ្រប់របស់ទាំងអស់*
- *ទ្រង់នៅមុនមានរបស់អ្វីទាំងអស់*
- *ទ្រទ្រង់គ្រប់របស់ទាំងអស់*
- *ទ្រង់ជាសិរសារបស់រូបកាយ គឺជាពួកជំនុំ*
- *ទ្រង់ជាដើម ជាបងច្បងក្នុងចំណោមអ្នកដែលត្រូវស្លាប់ ។*

ព្រះយេស៊ូវទ្រង់ជាសិរសារបស់យើង ។ យើងជារូបកាយរបស់ទ្រង់ ។ រូបកាយរបស់ទ្រង់ គឺត្រូវបានបង្កើតឡើងពីពួកអ្នកជឿទាំងអស់ ។ យើងរាល់គ្នាត្រូវបានទទួលការពណិនា ជារូបកាយរបស់ទ្រង់ ដែលត្រូវបានសង្គ្រោះឱ្យរួចពីអំណាចគ្រប់គ្រងរបស់សាតាំងរួចហើយ ព្រមទាំងបានវិលបែរត្រឡប់ទៅរកនគរថ្មី ដែលនឹងបានសោយរាជ្យ មានអំណាចគ្រប់គ្រងជាមួយនឹងព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ ។ យើងរាល់គ្នាត្រូវទទួលការពណិនា ជាអ្នកទទួលការប្រោសលោះ ព្រមទាំងត្រូវបានទទួលការអត់ទោស ជាបរិបូរពីគ្រប់អំពើបាបទាំងអស់ ។

ព្រះយេស៊ូវទ្រង់ជាសិរសារបស់រូបកាយ ទ្រង់គង់នៅក្នុងនគរស្ថានសួគ៌ ។ ព្រះកាយរបស់ទ្រង់បានសម្រាកនៅផែនដី រួមទាំងព្រះបាទរបស់ទ្រងផង ។ រីឯនៅលើផែនដី មនុស្សត្រូវតែបំពេញទៅតាមមុខងារដ៏ពេញដោយអំណាចគ្រប់គ្រងរបស់ខ្លួននោះឱ្យបាន ។ អំណាចនោះ គឺនៅទីនេះហើយ យើងរាល់គ្នាត្រូវតែមានកម្លាំងចម្រើនឡើងខាងឯនគរព្រះ ដោយខំប្រឹងប្រែងទប់ទល់សង្គ្រាមខាងឯវិញ្ញាណ ។

## ទីតាំងរបស់សាតាំង

### នៅក្រោមព្រះបាទាព្រះយេស៊ូវ

ព្រះទ្រង់បានដាក់សាតាំងឱ្យនៅក្រោមព្រះបាទាព្រះយេស៊ូវ ព្រមទាំងបានតាំងព្រះយេស៊ូវ ឱ្យធ្វើជាសិរសាលើគ្រប់ទាំងអស់ ដោយយកព្រះទ័យទុកដាក់ចំពោះពួកជំនុំ ។

ព្រះគម្ពីរអេភេសូរ ១:២២ ចែងថាៈ **ហើយទ្រង់បានបង្ក្រាបគ្រប់ទាំងអស់ នៅក្រោមព្រះបាទនៃព្រះរាជបុត្រា ទាំងប្រទានទ្រង់មកធ្វើជាសិរសាលើគ្រប់ទាំងអស់ ដល់ពួកជំនុំ ។**

**នៅក្រោមបាទជើងរបស់យើង**

ព្រះគម្ពីររ៉ូម ១៦:២០ក ចែងថា: **ឯព្រះនៃសេចក្តីសុខសាន្ត នៅបន្តិចទៀតទ្រង់នឹងកិនអារក្សសាតាំង នៅក្រោមជើងអ្នករាល់គ្នាហើយ ។**

ដើម្បីឱ្យបាននៅក្រោមជើងអ្នកណាម្នាក់ នោះគឺជារូបភាពដែលបានសរុបនូវការឈ្នះពីការចុះចាញ់ និងការចុះចូល ។ វាជារូបភាពនៃអំណាច និងអំណាចគ្រប់គ្រងដ៏ពេញលេញ ។

ព្រះគម្ពីរលោកុប្បត្តិ ៣:១៥ ចែងថា: **អញនឹងធ្វើឱ្យឯងហើយនិងស្ត្រី គឺទាំងពូជឯងនិងពូជនាង មានសេចក្តីខ្មាំងនឹងគ្នា ពូជនាងនឹងកិនក្បាលឯង ហើយឯងនឹងចឹកកែងជើងគេ ។**

**នៅក្រោមអំណាចរបស់យើង**

សាតាំងនៅក្រោមព្រះបាទាព្រះយេស៊ូវ ពីព្រោះព្រះយេស៊ូវទ្រង់ធ្វើឱ្យវាបរាជ័យពិតប្រាកដ ព្រមទាំងបណ្តេញវា និងវិញ្ញាណរបស់វាទាំងអស់ពីលើមក ។ សាតាំង និងពួកវិញ្ញាណរបស់វា ឥឡូវនេះត្រូវបានដាក់ឱ្យនៅក្រោមបាទជើងរបស់យើង ដែលយើងបានរុករកឃើញនូវអំណាចនៃការកែជាថ្មីឡើងវិញ ព្រមទាំងឱ្យបានប្រើអំណាចនៅលើផែនដីនេះ ។

**ការជាន់ឈ្លីពីលើ**

លោកសាវកលូកាបានឱ្យរូបភាពនៃទីតាំងរបស់សាតាំងយ៉ាងច្បាស់លាស់ដល់យើង។ វាត្រូវតែបានទទួលការជាន់ឱ្យនៅពីក្រោមបាទជើងរបស់យើង ។ យើងក៏បានជាន់វា ធ្វើឱ្យវាគ្មានមធ្យោបាយណាធ្វើឱ្យយើងមានការចុកចាប់បានឡើយ ។

ព្រះគម្ពីរលូកា ១០:១៩ ចែងថា: **មើល ខ្ញុំឱ្យអ្នករាល់គ្នាមានអំណាច នឹងដើរជាន់ទាំងពស់ និងខ្យាដំរី ហើយលើគ្រប់អស់ទាំងឥទ្ធិឫទ្ធិរបស់ខ្មាំងសត្រូវផង គ្មានអ្វីនឹងធ្វើទុក្ខអ្នករាល់គ្នាឡើយ ។**

មនុស្សជាតិកំពុងតែត្រូវបានជួយសង្គ្រោះឱ្យរួច ត្រូវបាននាំចូល ត្រូវបានរំដោះ ត្រូវបានអត់ទោស ព្រមទាំងត្រូវបានកែជាថ្មីឡើងវិញដ៏ពេញលេញ ដើម្បីឱ្យបានរូបភាពរបស់ព្រះនៅលើផែនដី ដែលឥឡូវនេះ បានជាន់សាតាំងឱ្យនៅពីក្រោមបាទជើងរបស់គេ ព្រមទាំងសម្តែងថា គេបានធ្វើឱ្យខ្មាំងសត្រូវចុះចាញ់ ។

កាលលោកហោរាអេសាយបានពណ៌នានូវទីបញ្ចប់របស់សាតាំង វាត្រូវបានបញ្ជូនឱ្យទៅនៅក្រោមបាទជើងរបស់អ្នកជាន់ ។

ព្រះគម្ពីរអេសាយ ១៤:១៨-២០ ចែងថា: **ឯសពនៃអស់ទាំងស្តេចរបស់សាសន៍ទាំងប៉ុន្មាន សុទ្ធតែដេកនៅក្នុងទីរុងរឿងនាម៉ុងរបស់គេរៀងខ្លួន តែឯងបានត្រូវបោះចោលចេញឆ្ងាយពីម៉ុងឯងទៅ ដូចជាមែកដែលគួរខ្ពើមវិញ គឺដូចជាអាវរបស់មនុស្សដែលត្រូវគេសំឡាប់ ជាអ្នកដែលត្រូវគេចាក់ទំលុះដោយដាវ ហើយក៏ចុះទៅដល់ថ្មនៅក្នុងរណ្តៅ ដូចជាខ្មោចដែលគេជាន់ឈ្លីដោយជើង ឯងនឹងមិនបានមូលទៅជាមួយនឹងគេនៅក្នុងផ្នូរទេ ពីព្រោះឯងបានបំផ្លាញស្រុករបស់ឯង ហើយបានសំឡាប់ប្រជាជនរបស់ឯងផង ឯពូជនៃមនុស្សអាក្រក់ នឹងឥតមានអ្នកណាចេញ**

ឈ្មោះគេ នៅអស់កល្បជានិច្ច ។



ពេលដែលព្រះយេស៊ូវទ្រង់បានយាងឡើងទៅឯព្រះវរបិតារបស់ទ្រង់វិញ ទ្រង់បានគង់នៅខាងស្តាំរបស់ទ្រង់ គឺជាកូនមនុស្ស ហើយដែលទ្រង់បានចាប់យកនូវសិទ្ធិទាំងអស់របស់ទ្រង់ដោយអង្គឯង ជាព្រះរាជបុត្រានៃព្រះ ។

**សិទ្ធិរបស់មនុស្សនៅលើផែនដី**

ទ្រង់មិនបានអនុវត្តអំណាចជាព្រះនៅលើផែនដីយូរអង្វែងទេ ពីព្រោះនៅទីនេះទ្រង់បានប្រទានអំណាចគ្រប់គ្រងទាំងអស់ដល់មនុស្សហើយ ។

មនុស្សត្រូវតែដាក់សាតាំងឱ្យនៅពីក្រោមបាទជើងរបស់គេនៅលើផែនដី ដែលគេត្រូវបានបង្កើតមកឱ្យគ្រប់គ្រងត្រួតត្រា ។

លោកហោរាអេសាយបានផ្តល់នូវការអស្ចារ្យ១ដល់យើង ដោយទំនាយពីការលើកទឹកចិត្តៈ

- *ដោយសេចក្តីសុចរិត លោកអ្នកនឹងត្រូវបានតាំងនៅ*
- *ភាពថប់បារម្ភនឹងនៅឆ្ងាយពីលោកអ្នក*
- *លោកអ្នកគ្មានសេចក្តីភ័យខ្លាចសោះឡើយ*
- *ភាពភ័យខ្លាចនឹងមិនមកជិតលោកអ្នកឡើយ*
- *ប្រសិនបើមានអ្នកណាមួយមកប្រយុទ្ធនឹងអ្នក គេនឹងត្រូវចុះចូលចំពោះអ្នក*
- *គ្មានអាវុធយុទ្ធភណ្ឌណាមកទាស់ប្រឆាំងនឹងលោកអ្នក លោកអ្នកនឹងបានចម្រើនឡើង*
- *លោកអ្នកនឹងបដិសេធគ្រប់ទាំងអណ្តាតដែលមកប្រឆាំងនឹងលោកអ្នក*

ព្រះគម្ពីរអេសាយ ៥៤:១៤-១៧ ចែងថាៈ **ឯងនឹងបានតាំងមាំមួន នៅដោយសេចក្តីសុចរិត ហើយនិងនៅឆ្ងាយពីការសង្កត់សង្កិន ដ្បិតឯងនឹងមិនខ្លាចអ្វីសោះ ក៏នឹងនៅឆ្ងាយពីសេចក្តីស្ញែងខ្លាចដែរ ពីព្រោះសេចក្តីនោះនឹងមិនមកជិតឯងឡើយ មើល នឹងមានគេលើកគ្នាឡើង តែនោះមិនមែនមកពីអញទេ ឯអ្នកណាដែលលើកគ្នាទាស់នឹងឯង គេនឹងដួលចុះដោយព្រោះឯង មើល អញបានបង្កើតទាំងជាងដែក ដែលសប់ភ្លើងធ្វើគ្រឿងសស្ត្រាវុធសំរាប់ជាការរបស់ខ្លួន ហើយក៏បានបង្កើតមេបំផ្លាញទុកសំរាប់នឹងបំផ្លាញផង ។**

មរដករបស់យើង គឺជារបស់ដែលជាកម្មសិទ្ធិដល់យើងដោយកំណើតសុចរិត ។

លោកហោរាអេសាយបានទាយថា

**នេះគឺជាមរដកនៃអ្នកបម្រើរបស់ព្រះអម្ចាស់ !**

## សំណួររំឭកសារឡើងវិញ

១- ប្រសិនបើគ្រប់របស់ទាំងអស់នៅក្រោមព្រះបាទរបស់ព្រះយេស៊ូវ ហេតុអ្វីបានជាអំណាចវិញ្ញាណអាក្រក់ និងវិញ្ញាណអសោចិ៍ នៅតែបន្តធ្វើការអាក្រក់នៅលើផែនដីនេះបាន ?

២- ហេតុអ្វីបានជាព្រះទ្រង់អនុញ្ញាតឱ្យសាតាំងនៅតែបន្តវិញ្ញាណអាក្រក់របស់វានៅលើផែនដី បន្ទាប់ពីព្រះយេស៊ូវបានធ្វើឱ្យវាបរាជ័យ ដោយការសុគតរបស់ទ្រង់នៅលើឈើឆ្កាង និងការរស់ពីសុគតឡើងវិញរបស់ទ្រង់ ?

៣- តើការផ្លាស់ប្រែគឺជាការចាំបាច់នៅក្នុងជីវិតលោកអ្នកយ៉ាងដូចម្ដេច ប្រសិនបើលោកអ្នកដើរនៅក្នុងអំណាចដែលត្រូវបានកែជាថ្មីឡើងវិញ ដើម្បីសម្ដែងថា សាតាំងគឺជាខ្មាំងសត្រូវដែលចុះចាញ់ម្នាក់ ?

# មេរៀនទី ៨
# យុទ្ធសាស្ត្ររបស់សាតាំងនៅពេលបច្ចុប្បន្ននេះ

## តើមានហេតុការណ៍អ្វីកើតឡើង?

២០០០ឆ្នាំក្រោយមក សាតាំងបានក្លែងនូវអំណាចនោះ ។

| |
|---|
| ២០០០ឆ្នាំក្រោយមក យើងរាល់គ្នាគឺជាៈ |
| មនុស្សដែលរស់នៅដោយមិនស្គាល់ព្រះនាមព្រះយេស៊ូវ |
| មនុស្សរស់នៅក្នុងភាពក្រីក្រ |
| មនុស្សរស់នៅក្នុងអំពើបាប |
| មនុស្សរស់នៅក្នុងភាពបរាជ័យ |
| មនុស្សទទួលនូវភាពឯកោ |
| មនុស្សនិងកូនចៅរបស់គេរស់នៅក្នុងភាពល្ងៀន |
| មនុស្សថ្វាយបង្គំដោយងងឹតងងល់ |
| ហេតុអ្វីបានជាសាតាំងនៅតែធ្វើសកម្មភាពដូចជាព្រះនៃលោកិយនេះ? |
| វាបានត្រូវទទួលបរាជ័យដោយព្រះយេស៊ូវ ព្រមទាំងនាំឱ្យវាបាត់បង់នូវអំណាច |
| ព្រះយេស៊ូវទ្រង់បានសម្រេចនូវផ្នែកនៃការរំដោះដល់យើង! |
| តើយើងបានសម្រេចអ្វីខ្លះ នូវអំណាចចេស្តា អំណាចគ្រប់គ្រង និងអំណាច? |

## យុទ្ធសាស្ត្ររបស់សាតាំង

**ដើម្បីលួច សម្លាប់ ហើយបំផ្លាញ**

តាមអាយុកាលទាំងអស់នេះ បំណងរបស់សាតាំងមិនដែលផ្លាស់ប្តូរឡើយ ។

ព្រះគម្ពីរយ៉ូហាន ១០:១០ក **ឯចោរវាមកប្រយោជន៍តែនឹងលួច សំឡាប់ ហើយបំផ្លាញ ប៉ុណ្ណោះ ។**

វិញ្ញាណអាក្រក់ស្អប់យើងខ្លាំងណាស់ ដែលវាបានផ្តល់ឱ្យយើងនូវរបៀបតាមរយៈយស ស័ក្តិរបស់ទាហ៊ានខាងវិញ្ញាណ ដើម្បីលួច សម្លាប់ ហើយបំផ្លាញ! កិច្ចការរបស់វា គឺបានចេញមកប្លន់យើងនូវការចាំបាច់សម្រាប់ជីវិត និងការងាររបស់យើង ។ វាបានមកសម្លាប់យើង តាមរយៈវិញ្ញាណផ្នែកគុណវិបត្តិ ឃាតករ និងអំពើអត្តឃាត ។ ឧបដ្ឋិវហេតុប្រកបដោយគ្រោះថ្នាក់ត្រូវបានមានមកលើជីវិតរបស់យើង ។ វិញ្ញាណអាក្រក់បានចេញមកដោយការសម្រេចរបស់វា "អ្វីក៏ដោយពួកវាបានចាប់យក ពួកវាត្រូវតែមកបំផ្លាញ" ។

ប្រសិនបើវិញ្ញាណអសោចិ៍គ្មានលទ្ធភាពសម្លាប់យើងទេ ប្រហែលជាពួកវាអាចរាយការណ៍ថា ពួកវាបានពន្យឺតយើង ឬបញ្ឈប់យើងពីការសម្រេចនូវកិច្ចការដែលព្រះប្រគល់ឱ្យយើងធ្វើ ។

## ការកំណត់វិញ្ញាណនៃគុណវិបត្តិ

សាតាំងព្យាយាមនឹងលួចសុខភាពរបស់យើង ដោយប្រើអំណាចនៃវិញ្ញាណអសោចិ៍ ។

ព្រះគម្ពីរលូកា ១៣:១១-១៣ ចែងថា: **កាលព្រះយេស៊ូវ ទ្រង់កំពុងតែបង្រៀនក្នុងសាលាប្រជុំ១ នៅថ្ងៃឈប់សំរាក នោះឃើញមានស្ត្រីម្នាក់ ដែលអារក្សធ្វើឱ្យពិការ អស់១៨ឆ្នាំមកហើយ មានខ្នងកោង ងើបត្រង់ពុំបានសោះ លុះទ្រង់បានឃើញគាត់ ក៏មានបន្ទូលហៅគាត់មក ប្រាប់ថា នាងអើយ នាងបានរួចពីជរាពិការហើយ រួចទ្រង់ដាក់ព្រះហស្តលើគាត់ នោះគាត់ក៏ងើបត្រង់ឡើងជា១រំពេច ហើយពោលពណ៌នាសរសើរដល់ព្រះ ។**

ព្រះគម្ពីរយ៉ូហាន ៥:៥ ចែងថា: **នៅទីនោះ មានមនុស្សម្នាក់ដែលឈឺ៣៨ឆ្នាំមកហើយ ។**

## ដើម្បីគាបសង្កត់ ធ្វើឱ្យឆ្ងល់ បៀតបៀន

លោកសាវកប៉ុលពណ៌នាពីការប្រយុទ្ធរបស់សាតាំង លើការរស់នៅ និងការធ្វើការងាររបស់វា ។ វាជាការលើកទឹកចិត្តឱ្យឃើញថា គ្រប់ទាំងការខិតខំព្យាយាមរបស់សាតាំង បានធ្វើឱ្យការងាររបស់លោកសាវកប៉ុលបានធ្លាក់ចុះ បានបញ្ឈប់ក្នុងការបម្រើព្រះអម្ចាស់ ។

ព្រះគម្ពីរ២កូរិនថូស ៤:៨-៩ ចែងថា: **ដែលយើងខ្ញុំត្រូវគេសង្កត់សង្កិនគ្រប់ជំពូក តែមិនទ័លផ្លូវឡើយ មានសេចក្តីវិលវល់ តែមិនទ័លគំនិតទេ មានគេធ្វើទុក្ខ តែមិនមែនត្រូវចោលនៅម្នាក់ឯងទេ ត្រូវគេវាយដួលស្តូក តែមិនស្លាប់ទេ ។**

សាតាំងធ្វើឱ្យមានការរាំងស្ទះគ្រប់ការទាំងអស់ ដែលល្អ ហើយត្រឹមត្រូវនៅក្នុងជីវិតរបស់យើង:

- ⇨ *គូអាពាហ៍ពិពាហ៍*
- ⇨ *កូនចៅ*
- ⇨ *ក្រុមគ្រួសារ*
- ⇨ *មិត្តភ័ក្តិ*
- ⇨ *ការងារ*
- ⇨ *សុខភាព*
- ⇨ *សេចក្តីអំណរ*
- ⇨ *សុខសន្តិភាព*

# ការការពាររបស់យើង

## ស្គាល់យុទ្ធសាស្ត្ររបស់ខ្មាំងសត្រូវ

មនុស្សត្រូវវិនាសដោយខ្វះចំណេះចេះដឹង ។ ប្រសិនបើពួកគេមានបំណងបញ្ឈប់សាតាំងពីគោលបំណងលួច សម្លាប់ ហើយបំផ្លាញរបស់វានោះ ពួកគេត្រូវតែស្គាល់ខ្មាំងសត្រូវ និងយុទ្ធសាស្ត្ររបស់វា គឺ:

➪ *សាតាំងនាំមកនូវសេចក្តីស្លាប់ - ព្រះទ្រង់នាំមកនូវជីវិត ។*

➪ *សាតាំងនាំមកនូវការស្អប់ខ្ពើម - ព្រះទ្រង់នាំមកនូវសេចក្តីស្រឡាញ់ ។*

**ព្រះយេស៊ូវ**

➪ *ទ្រង់បំផ្លាញសេចក្តីស្លាប់*

ព្រះយេស៊ូវទ្រង់បានបំផ្លាញសេចក្តីស្លាប់ និងនាំមកនូវជីវិត ព្រមទាំងសីលធម៌ល្អ ។

ព្រះគម្ពីរ ២ធីម៉ូថេ ១:១០ ចែងថា: **តែឥឡូវនេះ ទើបនឹងសំដែងមក ដោយដំណើរព្រះយេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះនៃយើង ទ្រង់លេចមក ដែលទ្រង់បានបំផ្លាញ សេចក្តីស្លាប់ ហើយបានយកជីវិត និងសេចក្តីមិនចេះស្លាប់ មកដាក់នៅពន្លឺ ដោយសារដំណឹង ល្អវិញ** ។

➪ *ទ្រង់បំផ្លាញអំណាចវិញ្ញាណអាក្រក់*

ព្រះយេស៊ូវទ្រង់បានបំផ្លាញវិញ្ញាណអាក្រក់ ព្រមទាំងប្រទានឱ្យយើងរួចពីការភ័យខ្លាចចំពោះសេចក្តីស្លាប់ ។

ព្រះគម្ពីរហេព្រើរ ២:១៤-១៥ ចែងថា: **ដូច្នេះ ដែលកូនចៅបានប្រកបដោយសាច់ឈាមព្រមគ្នា នោះទ្រង់ក៏ទទួលចំណែកជាសាច់ឈាមដូច្នោះដែរ ដើម្បីឱ្យទ្រង់បានបំផ្លាញអានោះ ដែលមានអំណាចលើសេចក្តីស្លាប់ គឺជាអារក្ស ដោយទ្រង់សុគត ហើយឱ្យបានប្រោសដល់ពួកអ្នកនោះ ដែលជាប់ជាបាវបំរើគ្រប់១ជីវិត ដោយខ្លាចស្លាប់ ឱ្យបានរួចចេញវិញ ។**

➪ *ទ្រង់រំដោះយើងឱ្យរួចពីទាសភាព*

សាតាំងគ្មានសិទ្ធិនឹងគ្រប់គ្រងយើងឱ្យនៅជាទាសភាពរបស់វាបានឡើយ ។ ដោយសេចក្តីជំនឿជឿលើព្រះយេស៊ូវគ្រីស្ទ យើងរាល់គ្នាបានត្រូវរំដោះឱ្យរួចផុតពីចំណង នៃទាសភាពរបស់សាតាំង និងនគររបស់វានោះ ។

ពេលដែលសាតាំង ឬពួកវិញ្ញាណរបស់វា បានមកលួច សម្លាប់ ហើយបំផ្លាញនោះ ពួកវានៅមិនអាចរកឃើញនូវភាពងាយស្រួលនឹងធ្វើទុក្ខ ភាពគ្មានការទំនុកបម្រុង ឬក៏គ្មានការការពារដែលនៅក្នុងយើងនោះទេ ។ ជំនួសនូវការនេះ តាមរយៈចំណេះដឹងពីព្រះបន្ទូលនៃព្រះ យើងត្រូវតែបានរកឃើញនូវការគ្របបាំងដោយព្រះលោហិតព្រះយេស៊ូវ ។ យើងត្រូវតែឈរឱ្យនឹង ដោយមានខែលនៃសេចក្តីជំនឿរបស់យើង ។ យើងត្រូវតែនិយាយពីព្រះបន្ទូលព្រះដោយមានកម្លាំង និងឥតភ័យខ្លាច ដែលមាននៅក្នុងព្រះគម្ពីរហោរាអេសាយ ។

ព្រះគម្ពីរអេសាយ ៥៤:១៧ក ចែងថា: **ឯគ្រឿងសស្ត្រាវុធណាដែលគេធ្វើឡើង នោះគ្មានណាមួយនឹងអាចទាស់នឹងឯងបានឡើយ ។**

**អត្ថិភាពកំពូលរបស់សាតាំង ~ ប្លន់យើងចេញពីព្រះបន្ទូលនៃព្រះ**

**សម្រួចធាររបស់លោកអ្នក**

ប្រសិនបើយើងមិនមានព្រះបន្ទូលនៅក្នុងគំនិត និងវិញ្ញាណរបស់យើងទេ នោះយើងនឹងមិនអាចធ្វើឱ្យសាតាំង និងពួកអ្នកដើរតាមវាត្រូវបរាជ័យដោយសារព្រះបន្ទូលឡើយ ។ ព្រះយេ-

ស៊ូវទ្រង់ចង់ឱ្យយើងមានអាវុធ ដើម្បីការពារគ្រប់ទាំងដំណើរនៅក្នុងជីវិតរបស់យើង ។ ប្រសិនបើយើងមិនមានវាទេ យើងបានត្រូវសាតាំងលួចទៅហើយ ។

យើងត្រូវតែស្គាល់អស់អ្នកដែលនៅក្នុងព្រះគ្រីស្ទ ដើម្បីបញ្ជាក់ថា យើងបានទទួលជ័យជម្នះក្នុងសង្គ្រាមរួចហើយ !

**ការប្រៀបធៀបពីកសិករ – ការបើកសម្តែងនូវជ័យជម្នះ**

**ការប្រៀបធៀប**

ម៉ាកុស ៤:៣-៨ ចែងថា:

**ចូរស្តាប់ចុះ មើល មានអ្នកព្រោះពូជម្នាក់ចេញទៅព្រោះ ។**

**កំពុងដែលព្រោះ មានខ្លះធ្លាក់ចុះតាមផ្លូវ ហើយសត្វហើរលើអាកាសក៏មកចឹកស៊ី ។**

**ខ្លះទៀតធ្លាក់ទៅក្នុងកន្លែងថ្ម ដែលមិនសូវមានដីប៉ុន្មាន ហើយក៏ដុះឡើងភ្លាម ពីព្រោះគ្មានដីជ្រៅ ។**

**តែកាលថ្ងៃរះឡើង នោះក្រៀមខ្លោចទៅវិញ ពីព្រោះគ្មានឫស ។**

**ខ្លះទៀតធ្លាក់ទៅក្នុងដីបន្លា បន្លាក៏ដុះឡើងខ្ទប់ ហើយគ្រាប់នោះមិនកើតផលសោះ ។**

**តែខ្លះទៀតធ្លាក់ទៅក្នុងដីល្អ ក៏កើតផលចំរើនកាន់តែច្រើនឡើង គ្រាប់១បង្កើតបាន៣០ មួយបាន៦០ ហើយមួយបាន១រយ ។**

**ព្រះយេស៊ូវទ្រង់បានពន្យល់អំពីការប្រៀបធៀប**

ម៉ាកុស ៤:១៤-២០ ចែងថា:

**ឯអ្នកព្រោះពូជ គឺព្រោះព្រះបន្ទូល ។**
**ឯពួកអ្នកតាមផ្លូវ គឺជាកន្លែងដែលបានព្រោះព្រះបន្ទូលចុះ កាលគេឮ នោះអារក្សសាតាំងក៏មកលួចឆក់យកព្រះបន្ទូលដែលព្រោះក្នុងចិត្តគេទៅភ្លាម ។**
**ឯពួកអ្នកដែលទទួលពូជក្នុងកន្លែងថ្ម ក៏ដូចគ្នាដែរ កាលណាគេឮព្រះបន្ទូល នោះគេទទួលដោយអំណរ ។**
**តែគ្មានចាក់ឫសនៅក្នុងខ្លួនសោះ ហើយក៏ នៅជាប់តែបន្តិចទេ បើកាលណាកើតមានសេចក្តីទុក្ខលំបាក ឬសេចក្តីបៀតបៀនដោយព្រោះព្រះបន្ទូល នោះគេរវាតចិត្តចេញភ្លាម ។**
**ឯពួកអ្នកដែលទទួលពូជក្នុងបន្លា គឺអស់អ្នកដែលឮព្រះបន្ទូលហើយ ។**
**តែសេចក្តីខ្វល់ខ្វាយនៅជីវិតនេះ សេចក្តីឆបោករបស់ទ្រព្យសម្បត្តិ និងសេចក្តីប៉ងប្រាថ្នាខាងឯសេចក្តីផ្សេងៗឯទៀត ក៏ចូលមកខ្ទប់ព្រះបន្ទូលជិត រួចព្រះបន្ទូលមិនអាចនឹងបង្កើតផលបាន ។**
**ឯពួកអ្នកដែលទទួលពូជក្នុងដីល្អ គឺអស់អ្នកដែលបានឮព្រះបន្ទូល ហើយទទួល រួចបង្កើតផល ម្នាក់បាន៣០ ម្នាក់បាន៦០ ម្នាក់ទៀតបាន១រយ ។**

មានមនុស្សជាច្រើនបានយល់នូវឧបមាកថានេះ ដើម្បីបញ្ចូននូវគ្រាប់ពូជនៃសេចក្តីសង្គ្រោះ ដែលត្រូវបានឃើញនូវលទ្ធផលនៃការផ្សាយដំណឹងល្អផ្សេងៗគ្នា នេះហើយជាសេចក្តីពិត ។

ទោះជាយ៉ាងណាក៏ដោយ ព្រះយេស៊ូវទ្រង់មានបន្ទូលថា ទ្រង់កំពុងជជែកអំពីព្រះបន្ទូលរបស់ព្រះ ។ ព្រះយេស៊ូវទ្រង់បានបង្រៀនថា កាលណាយើងទទួលនូវការយល់ដឹងពីព្រះបន្ទូលនៃព្រះថ្មីៗមក រំពេចនោះសាតាំងនឹងមកលួចវាចេញពីយើង ។ ការនេះ ធ្វើឱ្យព្រះបន្ទូលរបស់ព្រះនឹងជ្រួតជ្រាបចូលមកនៅក្នុងជីវិតរបស់យើង ។

តើមានរយៈពេលប៉ុន្មាន ដែលលោកអ្នកឮមនុស្សនិយាយថា ព្រះអម្ចាស់ទ្រង់បានសាកល្បងលយើង បន្ទាប់ពីពេលវេលាឈប់ទៅ? បន្ទាប់ពីសន្និបាត ឬក៏សិក្ខាសិលាដ៏អស្ចារ្យមួយ គ្រប់ទាំងអស់ហាក់ដូចជា "ផ្នែកមួយត្រូវធ្លាក់ចុះ" ។ ព្រះយេស៊ូវទ្រង់មានបន្ទូលដូច្នេះ សាតាំងបានមកដើម្បីលួចព្រះបន្ទូល ។

**រឿងមួយក្នុងរឿងទាំងបី**

ពេលដែលព្រះបន្ទូលត្រូវបានរកឃើញមានបីចំណុចដែលអាចកើតឡើង:

⇨ *សាតាំងអាចលួចព្រះបន្ទូលចេញពីយើងភ្លាមៗ ប្រសិនបើយើងមានការធ្វេសប្រហែស នោះសាតាំងនឹងនាំទុក្ខព្រួយ និងសេចក្តីបៀតបៀនចូលមកដល់យើង ។*

⇨ *ត្រូវយកព្រះបន្ទូលមកដាក់នៅនឹងក បើមានសេចក្តីទុក្ខព្រួយនៅក្នុងជីវិតនេះ ការបោកបញ្ឆោតនូវទ្រព្យសម្បត្តិ ឬក៏ការសម្រេចចិត្តដែលពេញដោយអំពើបាប ។*

⇨ *ព្រះបន្ទូលអាចត្រូវបានធ្វើឱ្យប្រសគល់លូតលាស់ឡើង ។*

**ការទុក្ខព្រួយ/ ការបៀតបៀន**

ព្រះយេស៊ូវទ្រង់បានទូន្មានពួកគេថា ការទុក្ខព្រួយ និងការបៀតបៀននឹងត្រូវតែកើតឡើង សម្រាប់ជាប្រយោជន៍របស់ព្រះបន្ទូល ។

ព្រះគម្ពីរម៉ាកុស ៤:១៧ ចែងថា: **តែគ្មានចាក់ឫសនៅក្នុងខ្លួនសោះ ហើយក៏នៅជាប់តែបន្តិចទេ បើកាលណាកើតមានសេចក្តីទុក្ខលំបាក ឬសេចក្តីបៀតបៀនដោយព្រោះព្រះបន្ទូលនោះគេរវាតចិត្តចេញភ្លាម ។**

**សាតាំងមកភ្លាមៗ**

សាតាំងដឹងថា ប្រសិនបើការបើកសម្តែងនៃព្រះបន្ទូលព្រះ បានរំឭកនៅក្នុងចិត្តរបស់យើង តាមព្រះបន្ទូលដដែលនោះ វានឹងត្រូវចុះចាញ់ហើយ ។ ពេលដែលវាមានផែនការ និងយុទ្ធសាស្ត្រជាច្រើនដើម្បីផ្ចាល់យើង អាទិភាពកំពូលរបស់វា គឺតែងតែប្លន់យើងនូវការបើកសម្តែងព្រះបន្ទូលព្រះ ។ ព្រះយេស៊ូវមានបន្ទូល សាតាំងតែងតែមកពេលដែលពួកវាបានឮ ។

ព្រះគម្ពីរម៉ាកុស ៤:១៥ ចែងថា: **ឯពួកអ្នកតាមផ្លូវ គឺជាកន្លែងដែលបានព្រោះព្រះបន្ទូលចុះ កាលគេឮ នោះអារក្សសាតាំងក៏មកលួចឆក់យកព្រះបន្ទូល ដែលព្រោះក្នុងចិត្តគេទៅភ្លាម ។**

ពេលដែលព្រះយេស៊ូវទ្រង់បញ្ចប់ការបង្រៀន ទ្រង់និងពួកសិស្សបានចូលទៅក្នុងទូក ។ រំពេចនោះព្រះយេស៊ូវទ្រង់បានផ្ទុំនៅផ្នែកខាងក្រោយទូក ។ ពេលនោះសាតាំងបានមក ដោយនាំយកការទុក្ខព្រួយក្នុងជីវិតនេះមកដល់យើង ។

ព្រះគម្ពីរម៉ាកុស ៤:៣៥-៤១ ចែងថា: **លុះពេលល្ងាចថ្ងៃនោះឯង ទ្រង់មានបន្ទូលទៅពួកសិស្សថា ចូរយើងឆ្លងទៅត្រើយម្ខាង កាលបានឱ្យហ្វូងមនុស្សទៅវិញហើយ នោះពួកសិស្សក៏ទទួលទ្រង់តាមភាពដដែលទៅក្នុងទូក ហើយមានទូកតូចៗខ្លះទៀតទៅជាមួយដែរ នោះកើតមានខ្យល់ព្យុះជាខ្លាំង ហើយរលកបោកចូលទៅក្នុងទូក ដល់ម្ល៉េះបានជាទូកពេញហើយ តែទ្រង់ផ្ទំលក់លើខ្នើយ នៅកន្សៃទូក ពួកសិស្សដាស់ទ្រង់ឡើងទូលថា លោកគ្រូអើយ យើងវិនាសហើយ លោកមិនរវល់ទេឬអី កាលតើនឡើង ទ្រង់កំហែងខ្យល់ ក៏បង្គាប់ទៅសមុទ្រថា ចូរស្ងៀមទៅ ហើយឈប់ចុះ នោះខ្យល់ក៏ស្ងប់ ហើយស្ងាត់ឈឹងសូន្យទាំងអស់ទៅ រួចទ្រង់មានបន្ទូលថា ហេតុអ្វីបានជាអ្នករាល់គ្នាភ័យដល់ម្ល៉េះ ម្តេចក៏គ្មានសេចក្តីជំនឿ នោះគេមានសេចក្តីស្ញែងខ្លាចជាខ្លាំង ទាំងសួរគ្នាទៅវិញទៅមកថា ដូច្នេះ តើលោកនេះជាអ្វី បានជាខ្យល់ និងសមុទ្រក៏ស្តាប់បង្គាប់លោកដូច្នេះ ។**

ព្យុះដែលបានបក់មក គឺជាសេចក្តីទុក្ខព្រួយ ឬក៏ជាសេចក្តីបៀតបៀន ពេលព្រះយេស៊ូវទ្រង់មានបន្ទូល សាតាំងក៏បានឮព្រះបន្ទូលរបស់ទ្រង់ ។

ចូរចងចាំថា ប្រតិកម្មរបស់ពួកសិស្ស ពួកគេបានមើលស្រាល ។ "មានសេចក្តីបង្រៀនថា តើលោកអ្នកមិនខ្វល់ថា យើងត្រូវបានវិនាសទេឬអី?" ពួកគេត្រូវបានទទួលការអាក់អន់ចិត្ត ពីព្រោះព្រះយេស៊ូវទ្រង់កំពុងតែផ្ទុំលក់ ដោយមិនមានការភ័យខ្លាចដូចជាពួកគេ ហើយពួកគេបានបន្ទោសថា ទ្រង់មិនខ្វល់ពីពួកគេ ។

## យើងមានការជ្រើសរើស

ពេលដែលសាតាំងនាំសេចក្តីទុក្ខ និងសេចក្តីបៀតបៀន ប្រឆាំងទាស់នឹងយើងព្យាយាមប្លន់យកព្រះបន្ទូលព្រះចេញពីយើង នោះយើងមានការជ្រើសរើស ។ នោះអាចគិតថា យើងត្រូវអរគុណដល់ព្រះអម្ចាស់សម្រាប់ការទូន្មានដល់យើង ដើម្បីឱ្យយើងមិនត្រូវធ្លាក់ទៅក្នុងគម្រោងការណ៍របស់សាតាំង ហើយបន្ទាប់មកយើងស្តីបន្ទោសដល់វា ។ យើងអាចត្រឡប់មកជាអាក់អន់ចិត្ត បាត់បង់នៅសេចក្តីអំណរ ហើយដោយហេតុនោះបានជាយើងអនុញ្ញាតឱ្យសាតាំង ប្លន់នូវការបើកសម្តែងព្រះបន្ទូលព្រះពីយើង ដែលវាបានឃើញនៅក្នុងចិត្តរបស់យើង ។

តើសេចក្តីទុក្ខព្រួយ និងសេចក្តីបៀតបៀនបានមកដោយញឹកញាប់របៀបណា បានជាយើងចាប់ផ្តើមស្រែកបន្ទោសដល់ព្រះ ?

- ⇨ *គ្រូបង្រៀនថា តើលោកអ្នកមិនខ្វល់ថា យើងមានបំណងនឹងគិតគូរទេ ឬអី ?*
- ⇨ *ព្រះ តើលោកអ្នកមិនខ្វល់ពីកូនចៅរបស់ខ្ញុំដែលត្រូវបានគេចាប់ចងទេ ឬអី ?*
- ⇨ *ព្រះ តើលោកអ្នកមិនខ្វល់ថា ជំងឺបានមកប្រឆាំងនឹងជីវិតរបស់ខ្ញុំទេ ឬអី ?*

⇨ *ព្រះ តើលោកអ្នកមិនខ្វល់ថា ខ្ញុំមិនអាចបងថ្លៃបំណុលរបស់ខ្ញុំបានទេ ឬអី ?*

ពេលដែលយើងបើកឱ្យខ្លួនយើង មានការប្រមាថ និងការស្តីបន្ទោសដល់ព្រះសម្រាប់ព្យុះដែលមាននៅក្នុងជីវិតរបស់យើង ដែលយើងបើកឱកាសឱ្យសាតាំងយកគ្រាប់ពូជដំបូងនៃព្រះបន្ទូលរបស់ព្រះ ចេញពីយើង ។

**ការនិយាយដោយសេចក្តីជំនឿ**

សកម្មភាពស្របចំពោះសេចក្តីជំនឿគឺជាការចាំបាច់ ប្រសិនបើយើងមានបំណងថែរក្សាគ្រាប់ពូជនៃព្រះបន្ទូលនៅក្នុងចិត្តរបស់យើង ព្រមទាំងបានទទួលនៅចម្រូតដ៏ធំ ជា៣០ ជា៦០ ឬក៏១០០ដង ។

ព្រះគម្ពីរម៉ាកុស ៤:៤០ ចែងថា: **រួចទ្រង់មានបន្ទូលថា ហេតុអ្វីបានជាអ្នករាល់គ្នាភ័យដល់ម៉្លេះ ម្តេចក៏គ្មានសេចក្តីជំនឿ ។**

**ការនិយាយដោយអំណាច**

ជំនួសឱ្យការខកចិត្តបានកើតឡើង ពេលដែលព្យុះបានបោកបក់មកលើទូករបស់យើង នោះយើងត្រូវតែក្រោកឈរដោយមាំមួនទាស់នឹងវិញ្ញាណអាក្រក់ ហើយនិយាយពីព្រះបន្ទូលព្រះដោយសេចក្តីជំនឿ ។

ព្រះគម្ពីរម៉ាកុស ៤:៣៩ ចែងថា: **កាលតើនឡើង ទ្រង់កំហែងខ្យល់ ក៏បង្គាប់ទៅសមុទ្រថា ចូរស្ងៀមទៅ ហើយឈប់ចុះ នោះខ្យល់ក៏ស្ងប់ ហើយស្ងាត់ឈឹងស្ងួនទាំងអស់ទៅ ។**

**ដោយមានការប្រយ័ត្នប្រយែង**

ទោះបីសាតាំងជាខ្មាំងសត្រូវបានទទួលការបរាជ័យហើយក៏ដោយ ក៏វានៅតែធ្វើគ្រប់ការទាំងអស់ក្នុងការដើរជាមួយនឹងអំណាចដែលព្រះរបស់យើង ទ្រង់បានប្រទានពរមកដែរ ។ យើងត្រូវតែប្រុងប្រយ័ត្ន ចាំយាមជានិច្ច ដើម្បីឱ្យមានជ័យជម្នះគ្រប់ទាំងការប្រយុទ្ធប្រឆាំង នៅក្នុងជីវិតរបស់យើង ។

ព្រះគម្ពីរ១ពេត្រុស ៥:៨ ចែងថា: **ចូរឱ្យដឹងខ្លួន ហើយចាំយាមចុះ ព្រោះអារក្សដែលជាខ្មាំងសត្រូវរបស់អ្នករាល់គ្នា វាតែងដើរក្រវែល ទាំងគ្រហឹមដូចជាសិង្ហ ដើម្បីនឹងរកអ្នកណាដែលវានឹងត្របាក់លេបបាន ។**

**គ្រឿងសឹករបស់ព្រះ**

ដោយសារសេចក្តីជំនឿ យើងត្រូវតែពាក់គ្រឿងសឹករបស់ព្រះ ដើម្បីឱ្យយើងអាចឈរទាស់ជាមួយនឹងគម្រោងផែនការណ៍របស់វិញ្ញាណអាក្រក់បាន ។

ព្រះគម្ពីរអេភេសូរ ៦:១០-១១ ចែងថា: **ឯសេចក្តីឯទៀត បងប្អូនអើយ ចូរឱ្យមានកំឡាំងឡើងក្នុងព្រះអម្ចាស់ ដោយឫទ្ធិបារមីរបស់ព្រះចេស្តាទ្រង់ ចូរពាក់គ្រប់គ្រឿងសឹករបស់ព្រះ ដើម្បីអាចនឹងឈរមាំមួន ទាស់នឹងឧបាយកលទាំងអម្បាលម៉ានរបស់អារក្ស ។**

ពេលដែលយើងធ្វើការនេះ យើងនឹងឃើញដោយខ្លួនឯង ដោយការក្រោកឈរឡើងទាស់នឹងវិញ្ញាណអាក្រក់នៅកណ្តាលព្យុះនោះ ។

ព្រះគម្ពីរអេភេសូរ ៦:១៣ ចែងថា: **ហេតុនោះបានជាត្រូវឱ្យយកគ្រប់គ្រឿងសឹករបស់ព្រះ ដើម្បីឱ្យអ្នករាល់គ្នាអាចនឹងទប់ទល់ក្នុងថ្ងៃអាក្រក់បាន រួចកាលណាបានតតាំងសព្វគ្រប់ហើយ នោះឱ្យបាននៅតែឈរមាំមួនដដែល ។**

**អំណាចរបស់យើង**

ព្រះរាជកិច្ចរបស់ព្រះយេស៊ូវត្រូវបានបញ្ចប់! ទ្រង់បានធ្វើឱ្យវិញ្ញាណអាក្រក់ និងវិញ្ញាណអសោចិ៍របស់វាត្រូវបរាជ័យ ។

នៅលើផែនដី ទ្រង់បានបង្កើតមនុស្សប្រុសស្រីឱ្យដើរក្នុងអំណាច ។ ទ្រង់បានកែអំណាចរបស់យើងសារជាថ្មីឡើងវិញ ហើយឥឡូវនេះ យើងត្រូវតែងើបឡើងទាស់នឹងវិញ្ញាណអាក្រក់ ធ្វើឱ្យខ្មាំងសត្រូវចុះចាញ់ ។ យើងត្រូវតែមានកម្លាំង និងចម្រើននូវសិរីល្អរបស់ព្រះ នៅលើផែនដីនេះ ។

**សំណួររំឭកសារឡើងវិញ**

១- តាមព្រះគម្ពីរយ៉ូហាន ១០:១០ សាតាំងបានមកដើម្បីប្រយុទ្ធប្រឆាំងនឹងជីវិតរបស់យើង ដោយមានចំណុចជាចម្បងចំនួន៣យ៉ាង ។ តើមានអ្វីខ្លះ ?

២- តាមការប្រៀបធៀបទៅនឹងកសិករម្នាក់ តើអាទិភាពដ៏កំពូលរបស់សាតាំងដែលវាជាចោរ នោះយ៉ាងដូចម្ដេចខ្លះ ?

៣- ហេតុអ្វីបានជាការសំខាន់ដែលយើងបញ្ចេញសកម្មភាពដោយអំណាច ហើយមិនព្រមឱ្យសេចក្ដីក្រោធកើតឡើងដល់យើងបាន ពេលដែលយើងប្រឈមមុខនឹងសេចក្ដីទុក្ខព្រួយ ព្រមទាំងសេចក្ដីបៀតបៀន ?

# មេរៀនទី៩
# ពួកជំនុំ និងអំណាច

## តើពួកជំនុំគឺជាអ្វី

**ការបើកសម្តែងទីមួយ**

តាមរយៈព្រះគម្ពីរសញ្ញាចាស់ ការថ្វាយបង្គំ តែងតែធ្វើនៅកណ្តាលរោងឧបោសថ ព្រះវិហារ ឬក៏ទីតម្លើងត្រសាល ។ គ្មានពួកជំនុំដែលយើងបានស្គាល់រហូតមកដល់សព្វថ្ងៃនេះទេ ។

ពេលដែលព្រះយេស៊ូវទ្រង់បានសម្តែងជាដំបូងដល់ពួកជំនុំ ទ្រង់បានបើកសម្តែងនូវរឿងបីយ៉ាង ដែលមានលក្ខណៈជាមុខងារនៅខាងលើ គឺជាការសាងសងដោយព្រះយេស៊ូវ ។ ការទាំងនេះហើយដែលធ្វើឱ្យមានជ័យជន្នះលើខ្មាំងសត្រូវ ដែលបានទាស់ទទឹងនឹងទ្វារស្ថាននរក ។ វាមានអំណាចនឹងចង ហើយស្រាយ ។

ព្រះគម្ពីរម៉ាថាយ ១៦:១៣-១៨ ចែងថា: **កាលព្រះយេស៊ូវ បានយាងមកដល់ក្រវល់ក្រុងសេសារា-ភីលីពហើយ នោះទ្រង់មានបន្ទូលសាកសួរពួកសិស្សថា តើមនុស្សទាំងឡាយ គេថាកូនមនុស្សជាអ្នកណា ពួកសិស្សទូលឆ្លើយថា ខ្លះថាជាយ៉ូហាន-បាទីស្ទ ខ្លះទៀតថាជាអេលីយ៉ា ហើយខ្លះទៀតថាជាយេរេមា ឬហោរាណាមួយ ទ្រង់មានបន្ទូលសួរថា ចុះអ្នករាល់គ្នាវិញ តើថាខ្ញុំជាអ្នកណា ស៊ីម៉ូន-ពេត្រុសទូលឆ្លើយថា ទ្រង់ជាព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់ រួចព្រះយេស៊ូវមានបន្ទូលតបថា អ្នកស៊ីម៉ូន កូនយ៉ូណាសអើយ អ្នកមានពរ ដ្បិតមិនមែនជាសាច់ឈាម ដែលបានបើកសំដែងឱ្យអ្នករាល់គ្នាស្គាល់ទេ គឺព្រះវរបិតានៃខ្ញុំដែលគង់នៅស្ថានសួគ៌វិញ ខ្ញុំប្រាប់អ្នកថា អ្នកឈ្មោះពេត្រុស ខ្ញុំនឹងតាំងពួកជំនុំខ្ញុំនៅលើថ្មដានេះ ហើយទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់នឹងមិនដែលឈ្នះពួកជំនុំឡើយ ។**

**សេចក្តីពិតជាគ្រឹះ**

លោកសាវកពេត្រុសបានដឹងដោយការបើកសម្តែងពីព្រះ ដែលព្រះយេស៊ូវដ៏ជាព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ ។ ការនេះគឺជាសេចក្តីពិត ដែលពួកជំនុំត្រូវបានសង់ឡើង ។

**ការសង់ឡើងដោយព្រះយេស៊ូវ**

លក្ខណៈទី១ គឺជាពួកជំនុំដែលព្រះយេស៊ូវបានសង់ឡើង មិនមែនជាសំណង់អាគារដែលសង់ឡើងដោយសារដៃមនុស្សទេ ។

**ជ័យជម្នះលើទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់**

លក្ខណៈទី២ គឺជាទ្វារស្ថានឃុំព្រលឹងដែលមិនអាចយកឈ្នះពួកជំនុំបានឡើយ ។

នៅក្នុងព្រះគម្ពីរបានបរិយាយថា

**ខ្ញុំនឹងតាំងពួកជំនុំខ្ញុំនៅលើថ្មដានេះ ហើយទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់ (អំណាចនៃតំបន់ស្ថាននរក) នឹងមិនដែលឈ្នះពួកជំនុំឡើយ ឬនឹងគ្មានកម្លាំងណានឹងធ្វើឱ្យវិនាស ឬទាស់ទទឹងនឹងពួកជំនុំបានឡើយ ។**

### កូនសោរដើម្បីចង និងស្រាយ

ពួកជំនុំមានអំណាចដើម្បីចង និងស្រាយ ។

ព្រះគម្ពីរម៉ាថាយ ១៦:១៩ ចែងថា: **ខ្ញុំនឹងឱ្យកូនសោរនៃនគរស្ថានសួគ៌ដល់អ្នក បើអ្នកនឹងចងទុកអ្វីៗនៅផែនដី នោះនឹងត្រូវចងទុកនៅស្ថានសួគ៌ដែរ ហើយបើអ្នកនឹងស្រាយអ្វីៗនៅផែនដី នោះនឹងត្រូវស្រាយនៅស្ថានសួគ៌ដែរ ។**

មានការបីយ៉ាងដែលយើងត្រូវការរៀនអំពីពួកជំនុំ ចាប់ពីពេលដែលព្រះយេស៊ូវទ្រង់បានបើកសម្ដែងជាលើកដំបូង ។

- ⇨ ពួកជំនុំនឹងត្រូវបានសង់ដោយព្រះយេស៊ូវ ដោយការបើកសម្ដែងពីព្រះដ៏ជាព្រះវរបិតាថា ព្រះយេស៊ូវជាព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់ ។
- ⇨ ទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់នឹងមិនអាចទាស់ទទឹងនឹងពួកជំនុំបានឡើយ ។
- ⇨ ពួកជំនុំនឹងត្រូវបានផ្ដល់ឱ្យ នូវកូនសោរនៃនគរស្ថានសួគ៌ នឹងមានអំណាចអាចចង ហើយអាចស្រាយបាន ។

## កូនសោរដែលបានកែជាថ្មីឡើងវិញ

យើងរាល់គ្នាត្រូវបានរៀបចំឱ្យមានកូនសោរ ដែលផ្ដល់ឱ្យនូវអំណាចលើផែនដីនេះ ។ កូនសោរអាចចាក់ ឬក៏អាចបើកទ្វារដែលយើងបានឃើញ គឺជាគ្រប់គ្រងលើអង្គភាព ទោះជាបុគ្គល ជាគ្រួសារ ជាអង្គការ ជាទីក្រុង ជារដ្ឋ ឬក៏ជាជនជាតិក៏ដោយ ។

### កូនសោរដើម្បីគ្រប់គ្រង

ការទាំងនេះ គឺជាកូនសោរនៃអំណាចដែលព្រះទ្រង់បានប្រទានដល់គ្រប់មនុស្សជាតិ ពេលដែលទ្រង់បានបង្កើតមនុស្សប្រុសស្រី នៅក្នុងរូបភាពរបស់អង្គទ្រង់ផ្ទាល់ ។

ព្រះគម្ពីរលោកុប្បត្តិ ១:២៦ ចែងថា: **ទ្រង់ក៏មានបន្ទូលថា ចូរយើងធ្វើមនុស្សឱ្យដូចជារូបយើង ឱ្យមានភាពដូចជាយើង ហើយឱ្យមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាស និងសត្វជើងបួនដែលនៅផែនដីទាំងមូល ព្រមទាំងសត្វលូនវារដែលវារនៅផែនដីផង ។**

### ការលួចដោយសាតាំង

កូនសោរទាំងនេះ ត្រូវបានបម្រុងដោយព្រះ ដើម្បីឱ្យយើងបានប្រើប្រាស់សម្រាប់ការងារល្អនៅលើផែនដីនេះ ។ ទោះជាយ៉ាងណាក៏ដោយ ពេលដែលលោកអ័ដាម និងនាងអេវ៉ាបានធ្វើបាប ពួកគេបានប្រគល់កូនសោរឱ្យទៅសាតាំង ដែលបានមកលួច សម្លាប់ ហើយបំផ្លាញ ។

កូនសោរនៃអំណាចក្រោមការគ្រប់គ្រងរបស់សាតាំង បានត្រឡប់មកជាកូនសោរនៃសេចក្ដីស្លាប់ និងកូនសោរនៃទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់ ។

ព្រះគម្ពីរវិវរណៈ ១:១៨ ចែងថា: **ជាព្រះដ៏រស់នៅ អញបានស្លាប់ តែមើល អញរស់នៅអស់កល្បជានិច្ចរៀងរាបតទៅវិញ អញក៏មានកូនសោរនៃសេចក្ដីស្លាប់ និងស្ថានឃុំព្រលឹងមនុស្សស្លាប់ដែរ ។**

**ការទាមទារមកវិញដោយព្រះយេស៊ូវ**

ទាំងនេះគឺជាកូនសោរនៃអំណាច ដែលព្រះយេស៊ូវទ្រង់បានយកចេញពីវិញ្ញាណអាក្រក់ បន្ទាប់ពីទ្រង់បានរំដោះនូវអំពើបាបរបស់យើងរាល់គ្នាពីជង្ហុកជ្រៅ នៃស្ថានឃុំព្រលឹងមនុស្សស្លាប់មក ។ ពេលដែលព្រះយេស៊ូវទ្រង់បានយាងមកកម្ទេចទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់ ដោយដណ្តើមបាននូវជ័យជម្នះ គឺទ្រង់បានយកកូនសោរនៃអំណាចទាំងនេះចេញពីសាតាំង ។ សាតាំងគ្មានអំណាចណាមួយនៅលើផែនដីនេះ យូរអង្វែងតទៅទៀតឡើយ ។

**ទ្រង់បានកែមនុស្សជាតិជាថ្មីឡើងវិញ**

កូនសោរទាំងនេះ គឺជាអំណាចដែលព្រះយេស៊ូវទ្រង់បានកែមនុស្សជាតិជាថ្មីឡើងវិញ ឱ្យគេបានកើតជាថ្មី បន្ទាប់ពីការរស់ពីសុគតឡើងវិញ និងការហោះឡើងរបស់ទ្រង់ទៅឯព្រះវរបិតាវិញ ។ តាំងពីកូនសោរទាំងនេះត្រូវបានកែជាថ្មីឡើងវិញ ដើម្បីឱ្យពួកគេមានភាពជាម្ចាស់ដូចដើមឡើងវិញ នៅលើផែនដីនេះ នោះពួកគេមិនត្រូវបាត់បង់នូវកូនសោរនៃសេចក្តីស្លាប់ និងស្ថានឃុំព្រលឹងមនុស្សស្លាប់ឡើយ ។ ជំនួសឱ្យការនេះ ពួកគេបានដឹងថា គឺជាកូនសោរនៃនគរស្ថានសួគ៌ ។

**កូនសោរនៃនគរស្ថានសួគ៌**

ព្រះគម្ពីរម៉ាថាយ ១៦:១៩ចែងថា: **ខ្ញុំនឹងឱ្យកូនសោរនៃនគរស្ថានសួគ៌ដល់អ្នក បើអ្នកនឹងចងទុកអ្វីៗនៅផែនដី នោះនឹងត្រូវចងទុកនៅស្ថានសួគ៌ដែរ ហើយបើអ្នកនឹងស្រាយអ្វីៗនៅផែនដី នោះនឹងត្រូវស្រាយនៅស្ថានសួគ៌ដែរ ។**

ចំពោះកូនសោរទាំងនេះ យើងរាល់គ្នាអាចសម្រេចតាមបំណងព្រះហឫទ័យរបស់ព្រះ និងនគររបស់ព្រះនៅលើផែនដីនេះ ។

នេះគឺជាជ័យជម្នះសម្រាប់ការបង្រៀនរបស់ព្រះយេស៊ូវ ដែលទ្រង់បានបង្រៀនដល់ពួកសិស្សរបស់ទ្រង់ឱ្យអធិស្ឋាន ។

ព្រះគម្ពីរម៉ាថាយ ៦:៩-១០ ចែងថា: **ដូច្នេះ ចូរអធិស្ឋានបែបយ៉ាងនេះវិញថា ឱព្រះវរបិតានៃយើងខ្ញុំ ដែលគង់នៅស្ថានសួគ៌អើយ សូមឱ្យព្រះនាមទ្រង់បានបរិសុទ្ធ សូមឱ្យរាជ្យទ្រង់បានមកដល់ សូមឱ្យព្រះហឫទ័យទ្រង់បានសំរេចនៅផែនដី ដូចជានៅស្ថានសួគ៌ដែរ ។**

យើងជារូបកាយរបស់ព្រះគ្រីស្ទ ពេលដែលយើងប្រើនូវកូនសោរនៃអំណាច ដែលព្រះទ្រង់បានប្រទានមកយើង តាមបំណងព្រះហឫទ័យរបស់ព្រះ នោះយើងកំពុងតែសម្រេចនូវនគរស្ថានសួគ៌នៅលើផែនដីនេះ ។

## ទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់

**ពួកជំនុំស្ថាននៅលើការវាយលុក**

ពេលដែលព្រះយេស៊ូវទ្រង់បានបើកសម្តែងព្រះបន្ទូលជាលើកទីមួយ ទៅកាន់ពួកជំនុំ ទ្រង់បានចាប់ផ្តើមមានបន្ទូលភ្លាមៗថា ទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់នឹងមិនដែលឈ្នះពួកជំនុំឡើយ ។

ព្រះគម្ពីរម៉ាថាយ ១៦:១៨ខ ចែងថា: **ខ្ញុំនឹងតាំងពួកជំនុំខ្ញុំនៅលើថ្មដានេះ ហើយទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់នឹងមិនដែលឈ្នះពួកជំនុំឡើយ ។**

វាជាការសំខាន់ដើម្បីឱ្យយល់នូវអ្វីដែលព្រះយេស៊ូវទ្រង់ចង់មានបន្ទូល ពេលដែលទ្រង់មានបន្ទូលថា ទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់នឹងមិនដែលឈ្នះពួកជំនុំឡើយ ។

នៅក្នុងពេលរបស់យើង យើងគិតពីទ្វារដែលនៅក្នុងរបង ឬក៏ជញ្ជាំង ។ តាមរូបភាពនោះនៅក្នុងគំនិតរបស់យើង វាជាការលំបាកណាស់ដើម្បីបំភ្លឺឱ្យយល់ច្បាស់នៅក្នុងខគម្ពីរនេះ ។ យើងរាល់គ្នាស្ទើរតែទាំងអស់មិនដែលធ្លាប់បានពើបប្រយុទ្ធ ដោយទ្វារនោះបានឡើយ ។

**តើទ្វារទាំងនោះគឺអ្វីខ្លះ**

នៅក្នុងសម័យព្រះគម្ពីរ អភិបាល និងអ្នកជំនួញនៅតាមទីក្រុង បានទទួលការបង្គាប់បញ្ជានៅឯទ្វារទាំងនោះ ។ ដូច្នេះទ្វារទាំងឡាយនោះ ត្រូវបានបញ្ជាដោយទាហានប្រចាំកំផែងក្រុង ក៏បានបញ្ជូនទៅកាន់អភិបាលរដ្ឋ និងអភិបាលក្រុងថែមទៀតផង ។ ស្តេចសាឡូម៉ូនបានបញ្ជូនទៅកាន់ក្រុងនេះ នៅក្នុងសម័យនៃព្រះគម្ពីរសុភាសិតរបស់ទ្រង់ដែរ ។

ព្រះគម្ពីរសុភាសិត ៣១:២៣ ចែងថា: **កាលណាប្តីនាងទៅអង្គុយត្រង់ទ្វារក្រុង ក្នុងចំណោមនៃពួកចាស់ទុំក្នុងស្រុក នោះគេក៏ស្គាល់រាប់អានគាត់ដែរ ។**

**ដើម្បីគ្រប់គ្រងទ្វារ**

ពេលដែលព្រះទ្រង់បានប្រទានពរដល់លោកអ័ប្រាហាំ គាត់ត្រូវបានបញ្ជូនទៅគ្រប់គ្រងទ្វារនៃខ្មាំងសត្រូវរបស់គាត់ នោះគឺជាព្រះពរហើយ ។

ព្រះគម្ពីរលោកុប្បត្តិ ២២:១៧ ចែងថា: **នោះអញនឹងឱ្យពរដល់ឯង ហើយនិងចំរើនពូជឯងឱ្យមានគ្នាសន្ធឹកដូចផ្កាយនៅលើមេឃ ហើយដូចខ្សាច់នៅមាត់សមុទ្រ ពូជឯងនឹងបានគ្រប់គ្រងលើទ្វារក្រុងនៃពួកខ្មាំងសត្រូវ ។**

ព្រះពរបានផ្តល់មកឱ្យនាងរេបិកា ក៏ត្រូវបានផ្តល់នូវការគ្រប់គ្រងទ្វារនៃខ្មាំងសត្រូវទាំងនោះ ។

ព្រះគម្ពីរលោកុប្បត្តិ ២៤:៦០ ចែងថា: **គេក៏ឱ្យពរដល់រេបិកាដោយពាក្យថា ប្អូនយើងអើយ សូមឱ្យឯងបង្កើតបានទាំងពាន់ទាំងម៉ឺន ហើយឱ្យពូជឯងគ្រប់គ្រងលើទ្វារក្រុងនៃពួកអស់អ្នកដែលស្អប់គេចុះ ។**

ដើម្បីឱ្យបានគ្រប់គ្រងទ្វាររបស់ខ្មាំងសត្រូវ នោះមានន័យថា ចាប់យក ហើយគ្រប់គ្រងនូវរដ្ឋបាលទាំងមូល ។ សម័យសព្វថ្ងៃនេះ យើងត្រូវតែគ្រប់គ្រងនូវទ្វារនៃខ្មាំងសត្រូវរបស់យើងនៅក្នុងចំណែកខាងឯវិញ្ញាណ ។ តាមអំណាចគ្រប់គ្រង និងប្រយុទ្ធប្រឆាំងនឹងសង្គ្រាមខាងឯវិញ្ញាណយ៉ាងខ្លាំងក្លា គឺជាទ្វារដែលយើងយកបានមកដោយក័ងកម្លាំង ។

ស្តេចសាឡូម៉ូនមានបន្ទូលសេចក្តីទាំងនេះថា :

**មនុស្សអាក្រក់រមែងឱនចុះ នៅចំពោះមនុស្សល្អ ហើយមនុស្សដែលប្រព្រឹត្តអំពើអាក្រក់ ក៏ក្រាបចុះនៅមាត់ទ្វារនៃមនុស្សសុចរិតដែរ** (សុភាសិត ១៤:១៩) ។

មានរូបភាពជាច្រើនក្នុងការប្រយុទ្ធប្រឆាំងជាមួយនឹងវិញ្ញាណអាក្រក់ ដែលពួកវាបានគ្រប់គ្រងនៅក្នុងទ្វារនៃសេចក្ដីភ័យខ្លាចដ៏អន្ទះសារបស់វា ។ ទោះជាយ៉ាងណាក៏ដោយ ក៏ពួកជំនុំនឹងមិនដែលចាញ់នូវការរុករានរបស់សាតាំងឡើយ ។

យើងជាពួកជំនុំ យើងតែងជួបប្រទះនូវព្យុះនៃទ្វារស្ថានឃុំព្រលឹង ព្រមទាំងមានកម្លាំងគាំទ្រនៃនគរព្រះផងដែរ ។

## កូនសោរសម្រាប់បើកទ្វារនគរស្ថានសួគ៌

ពេលព្រះយេស៊ូវទ្រង់បើកសម្ដែងដល់ពួកជំនុំដំបូង ទ្រង់បានមានបន្ទូលថា "ខ្ញុំនឹងឱ្យកូនសោរដល់អ្នក" ។ រឿងនោះត្រូវតែបានកើតឡើងនៅពេលអនាគតខាងមុខ ។ ក្រោយមក បន្ទាប់ពីការសុគត និងការរស់ឡើងវិញរបស់ទ្រង់ ទ្រង់បានមានព្រះបន្ទូលទៅកាន់ព្រះវរបិតាថា "ទូលបង្គំមានកូនសោរ" ។ កូនសោរជាតំណាងឱ្យអំណាចដែលបានកែជាថ្មីឡើងវិញរបស់មនុស្ស ។ កូនសោរទាំងនេះហើយ ដែលព្រះយេស៊ូវទ្រង់បានដណ្ដើមយកពីសាតាំង ពេលដែលទ្រង់បានដកយកព្រះចេស្ដា និងអំណាចពីវាត្រឡប់ទៅវិញ ។

តើនគរស្ថានសួគ៌នេះគឺជាអ្វី ដែលយើងត្រូវចាប់យកកូនសោរនេះ ?

ព្រះយេស៊ូវ ទ្រង់ជាស្ដេចលើអស់ទាំងស្ដេច ទ្រង់បានសោយរាជ្យជាមួយនឹងព្រះវរបិតាលើសកលលោកទាំងមូល គឺដែលនគររបស់ផងទ្រង់ត្រូវបានសម្រេចហើយ នៅលើភពផែនដីនេះ ។

នគររបស់ព្រះនឹងត្រូវបានលូតលាស់ដោយបង្ខំ ដោយសារលោកិយដែលទ្រង់បានរំដោះមនុស្សប្រុសស្រីមក ដោយប្រើប្រាស់នូវកូនសោរអំណាចខាងឯវិញ្ញាណ ដែលត្រូវបានកែជាថ្មីឡើងរបស់ពួកគេ ។

ទាំងអស់នេះគឺជាកូនសោរ ដែលព្រះយេស៊ូវទ្រង់បានមានព្រះបន្ទូល ដូច្នេះ យើងត្រូវតែប្រើដើម្បីចងនិងស្រាយ ។ យើងមានអំណាចដើម្បីចងសាតាំង និងវិញ្ញាណអសោចិ៍របស់វា ហើយយើងក៏មានកូនសោរអំណាច ដើម្បីស្រាយនូវពួកឈ្លើយសឹកផងដែរ ។ ពេលដែលយើងទទួលជ័យជម្នះលើសមរភូមិនៅក្នុងនគរខាងឯវិញ្ញាណ វានឹងសម្ដែងចេញនៅក្នុងផ្នែកធម្មជាតិ ឬនគរខាងសាច់ឈាម ។

## គោលការណ៍នៃការចង និងការស្រាយ

ព្រះយេស៊ូវទ្រង់មានបន្ទូលថា ទ្រង់បានប្រទានកូនសោរនៃនគរស្ថានសួគ៌ឱ្យយើង ព្រមទាំងអ្វីដែលយើងបានចងនៅលើផែនដី ក៏ដូចជាចងនៅនគរស្ថានសួគ៌ដែរ ហើយបើយើងស្រាយអ្វីៗនៅផែនដី ក៏បានស្រាយនៅនគរស្ថានសួគ៌ដែរ ។

តើមានន័យយ៉ាងដូចម្ដេច ?

## ព្រះយេស៊ូវទ្រង់បានចងមនុស្សខ្លាំងពូកែ

ព្រះយេស៊ូវទ្រង់មានបន្ទូលអំពីការចងមនុស្សខ្លាំងពូកែ ។

ព្រះគម្ពីរម៉ាថាយ ១២:២៨-២៩ ចែងថា: **ប៉ុន្តែ បើសិនជាខ្ញុំដេញអារក្សដោយសារព្រះវិញ្ញាណនៃព្រះវិញ នោះឈ្មោះថា នគរព្រះបានមកដល់ហើយ ឬធ្វើដូចម្តេចឱ្យអ្នកណាចូលទៅក្នុងផ្ទះនៃមនុស្សខ្លាំងពូកែ នឹងប្លន់យកទ្រព្យសម្បត្តិរបស់គេបាន វៀរតែចងអ្នកខ្លាំងពូកែនោះជាមុនសិន នោះទើបនឹងប្លន់ផ្ទះរបស់គេបាន ។**

**តើអ្នកណាជាមនុស្សខ្លាំងពូកែ?**

មនុស្សខ្លាំងពូកែគឺជាសាតាំង ឬក៏វិញ្ញាណគ្រប់គ្រងដែលវាបានចាត់ចែងរដ្ឋបាលគ្រប់គ្រង ការរៀបចំ ឬក៏គ្រប់គ្រងលើជីវិតមនុស្ស ។

ព្រះយេស៊ូវទ្រង់បានយាងចូលទៅក្នុងផ្ទះរបស់មនុស្សខ្លាំងពូកែ ហើយបានចងមនុស្សខ្លាំងពូកែ (សាតាំង និងវិញ្ញាណគ្រប់គ្រងរបស់វា) ។

យើងចងសាតាំង ហើយបន្ទាប់មកចងវិញ្ញាណគ្រប់គ្រងរបស់វា ដោយការនិយាយដោយអំណាចថា:

⇨ "សាតាំង អញចងឯងដោយនូវព្រះនាមព្រះយេស៊ូវ!"

បន្ទាប់មកយើងត្រូវតែចងមនុស្សខ្លាំងពូកែ ដោយនិយាយយ៉ាងម៉ឺងមាត់ ទៅកាន់វិញ្ញាណគ្រប់គ្រងនោះថា:

⇨ "ឯងជាវិញ្ញាណអាក្រក់ដ៏ស្មោគគ្រោក អញចងឯង នៅក្នុងព្រះនាមព្រះយេស៊ូវ!"

**តើការចងនោះជាអ្វីទៅ?**

ការចងមានន័យថា កំណត់សាតាំង ឬវិញ្ញាណអាក្រក់ លើស្ថានការណ៍ពិសេស ដែលព្រះទ្រង់បានអនុញ្ញាតឱ្យយើងចូលទៅក្នុងសង្គ្រាមខាងវិញ្ញាណ ។

ឧទាហរណ៍: ពេលដែលយើងចងឆ្កែមួយក្បាលដោយច្រវាក់ ភ្ជាប់នឹងស្ទឹង ឆ្កែអាចទៅណាមកណាត្រឹមតែប្រវែងខ្សែច្រវាក់នោះប៉ុណ្ណោះ ។ វាត្រូវបានគេកំណត់ពីប្រវែងនៃច្រវាក់ នៅក្នុងតំបន់របស់វាតែប៉ុណ្ណោះ ។ យើងបានកំណត់ព្រំខណ្ឌរបស់វាតែប៉ុណ្ណោះ ។ នេះគឺជាអត្ថន័យនៃពាក្យចង ។

**បង្ខូចផ្ទះរបស់វា**

បន្ទាប់មក យើងត្រូវតែបង្ខូចផ្ទះរបស់វា ។ យើងធ្វើដូច្នេះដោយបញ្ជាវិញ្ញាណអាក្រក់ដែលនៅក្រោមអំណាចមនុស្សខ្លាំងពូកែនោះ ឱ្យទៅជា:

⇨ "ក្នុងព្រះនាមព្រះយេស៊ូវ ចូរឯងចេញទៅ!"

យើងអាចស្គាល់ពីអត្តសញ្ញាណរបស់វិញ្ញាណទាំងនេះ ដោយបំពេញអំណោយទាននៃការវាងវៃ និងអំណោយទាននៃចំណេះចេះស្ទាត់ ។ យើងក៏អាចស្គាល់នូវអត្តសញ្ញាណរបស់ពួកវាតាមមុខងារជាក់ស្តែងរបស់ពួកវា ។

មុខងារទាំងនេះគឺ:

⇨ ពួកវិញ្ញាណឯងឹត

⇨ ពួកវិញ្ញាណលាក់កម្បាំង

- ពួកវិញ្ញាណមិនស្អាត (ពោរពេញដោយសេចក្តីប៉ងប្រាថ្នា) ពួកវិញ្ញាណកំហូច
- ពួកវិញ្ញាណដែលមានអំណាច
- ពួកវិញ្ញាណដែលធ្វើឱ្យមានការរងទុក្ខ
- ពួកវិញ្ញាណអត្តឃាត

**បណ្តេញពួកវិញ្ញាណចេញ**

ដើម្បីបណ្តេញពួកវិញ្ញាណទាំង យើងត្រូវតែបង្ខូចផ្ទះរបស់មនុស្សខ្លាំង ។ ពេលដែលផ្ទះរបស់វាត្រូវបានបង្ខូចហើយ វាត្រឡប់ទៅជាតែលតោល ហើយយើងអាចបញ្ជាវាឱ្យចាកចេញនៅក្នុងព្រះនាមព្រះយេស៊ូវ ។

ព្រះគម្ពីរលូកា ១១:២១-២២ ចែងថា: **កាលណាមនុស្សខ្លាំងពូកែកាន់គ្រឿងអាវុធប្រុងប្រៀបនឹងការពារផ្ទះរបស់ខ្លួន នោះទ្រព្យសម្បត្តិក៏បានគង់វង់នៅ តែបើមានមនុស្សខ្លាំងជាង មកបង្ក្រាបឱ្យឈ្នះគាត់កាលណា នោះក៏ដណ្តើមយកអស់ទាំងគ្រឿងអាវុធ ដែលគាត់ទុកចិត្តនោះចេញ រួចប្លន់យករបឹបទៅចែកគ្នាវិញ ។**

ប្រះយេស៊ូវទ្រង់បានដកហូតនូវចេស្តា និងអំណាច ព្រមទាំងបានបង្ហាញពួកវាជាសារធារណៈរួចហើយ ។ ទ្រង់បានឡើងទៅលើកន្លែងពួកវា និងបានអង្គុយនៅខាងស្តាំនៃព្រះវរបិតា ។ នេះគឺជាសេចក្តីពិតដែលបានធ្វើជាស្រេចនៅឯនគរស្ថានសួគ៌ ។

**អំណាចរបស់អ្នកជឿ**

យើងជាអ្នកជឿ យើងត្រូវតែហាត់ប្រើអំណាច និងអំណាចគ្រប់គ្រងរបស់យើងនៅលើផែនដីនេះ ។ ឥឡូវនេះ យើងត្រូវតែធ្វើឱ្យរួចជាស្រេច និងប្រមូលកម្លាំងនៅលើផែនដី នូវអ្វីដែលយើងបានធ្វើរួចជាស្រេចនៅក្នុងការសម្រាក នៅលើលោកកសន្និវាសនេះ ហើយនិងសេចក្តីពិតដែលបានសម្រេចនៅឯនគរស្ថានសួគ៌ ។ នៅលើផែនដី យើងត្រូវតែចងសាតាំង និងវិញ្ញាណគ្រប់គ្រងរបស់វា ហើយស្រោយពួកឈ្លើយសឹកមកវិញ ។ យើងត្រូវតែកំណត់នូវព្រំខណ្ឌរបស់វា ។

ព្រះគម្ពីរម៉ាថាយ ១៦:១៩ខ ចែងថា: **បើអ្នកនឹងចងទុកអ្វីៗនៅផែនដី នោះនឹងត្រូវចងទុកនៅស្ថានសួគ៌ដែរ ហើយបើអ្នកនឹងស្រាយអ្វីៗនៅផែនដី នោះនឹងត្រូវស្រាយនៅស្ថានសួគ៌ដែរ ។**

ពេលដែលយើងធ្វើការនេះ យើងក៏ត្រូវតែដកហូតនូវចេស្តា និងអំណាច ព្រមទាំងធ្វើឱ្យពួកវាហាលមុខ ក្នុងជ័យជម្នះលើពួកវាដោយសារឈើឆ្កាង ។

**អំណាចរបស់សាតាំង**

---

**ការធ្វើឱ្យគ្មានអានុភាព**

ដោយការសុគត និងការរស់ឡើងវិញរបស់ទ្រង់ ព្រះយេស៊ូវទ្រង់បានធ្វើឱ្យសាតាំងគ្មានអានុភាព ។

ព្រះគម្ពីរហេព្រើរ ២:១៤ ចែងថា: **ដូច្នេះ ដែលកូនចៅបានប្រកបដោយសាច់ឈាមព្រមគ្នា នោះទ្រង់ក៏ទទួលចំណែកជាសាច់ឈាមដូច្នេះដែរ ដើម្បីឱ្យទ្រង់បានបំផ្លាញអានោះ ដែលមានអំណាចលើសេចក្តីស្លាប់ គឺជាអារក្ស ដោយទ្រង់សុគត ។**

### អ្នកចាប់ចងរបស់យើងមិនយូរអង្វែងទេ

យើងត្រូវតែជ្រើសរើសដោយសេរី ពីការភ័យខ្លាចនៃសេចក្តី និងការភ័យខ្លាចនូវការជាប់ចំណង ។

ព្រះគម្ពីរហេព្រើរ ២:១៥ ចែងថា: **ហើយឱ្យបានប្រោសដល់ពួកអ្នកនោះ ដែលជាប់ជាបាវបំរើគ្រប់១ជីវិត ដោយខ្លាចស្លាប់ ឱ្យបានរួចចេញវិញ ។**

ដោយការងាររបស់ព្រះយេស៊ូវ ដែលបានសម្រេចនៅក្នុងសេចក្តីស្លាប់ និងសេចក្តីរស់ឡើងវិញដោយមានជ័យជម្នះរបស់ទ្រង់ នោះទាំងបុរសទាំងស្ត្រីមិនត្រូវទទួលការចាប់ចង ឱ្យមានសេចក្តីភ័យខ្លាចចំពោះសេចក្តីស្លាប់ដ៏យូរអង្វែងឡើយ ។ ពេលដែលយើងរកឃើញនូវសេចក្តីពិតនេះឃើញ យើងត្រូវតែជ្រើសរើសដោយសេរី ហើយបានរំដោះចេញពីចំណង និងសេចក្តីភ័យខ្លាចដល់វិញ្ញាណអាក្រក់បានពេញលេញ ។

### ការងាររបស់វាត្រូវបានបំផ្លាញ

ហេតុអ្វីបានជាព្រះរាជបុត្រារបស់ព្រះទ្រង់បានបើកសម្តែង ?

⇨ ដើម្បីបំផ្លាញការងាររបស់សាតាំង!

⇨ ដើម្បីធ្វើឱ្យពួកវាហាលមុខជាសាធារណៈ!

ព្រះគម្ពីរ១យ៉ូហាន ៣:៨ ចែងថា: **តែអ្នកណាដែលប្រព្រឹត្តបាបវិញ នោះគឺមកពីអារក្សទេ ពីព្រោះអារក្សបានធ្វើបាប តាំងពីដើមរៀងមក ដោយហេតុនោះបានជាព្រះរាជបុត្រានៃព្រះបានលេចមក គឺដើម្បីនឹងបំផ្លាញការរបស់អារក្សចេញ ។**

ព្រះគម្ពីរកូល៉ុស ២:១៥ ចែងថា: **ទ្រង់បានទាំងទំលាក់ងារពីពួកគ្រប់គ្រង និងពួកមានអំណាច ទាំងដាក់ពួកទាំងនោះនៅកណ្តាលជំនុំឱ្យគេមើល ហើយដឹកនាំគេទៅ ដោយមានជ័យជំនះ ដោយសារឈើឆ្កាងនោះឯង ។**

## ពួកជំនុំដែលកំពុងដេកត្រូវភ្ញាក់ឡើងវិញ

ពេលដែលព្រះយេស៊ូវទ្រង់បានយាងមកផែនដីនេះ ដើម្បីបំផ្លាញការងាររបស់វិញ្ញាណអាក្រក់ ទ្រង់បានគង់នៅខាងអំណាចរបស់ទ្រង់ជាព្រះ ។ នៅលើផែនដី គឺជាលោកអ័ដាមចុងក្រោយ ទ្រង់បានដើរ និងបំពេញព្រះរាជកិច្ចដោយមានអំណាច ហើយនិងអំណាចគ្រប់គ្រង ។

ព្រះយេស៊ូវទ្រង់ធ្វើឱ្យសាតាំងត្រូវបានបរាជ័យរួចហើយ ។ ទ្រង់បាននាំពួកវាទៅកាន់ភាពសោះសូន្យ ព្រមទាំងធ្វើឱ្យពួកវាគ្មានអានុភាព ។ ព្រះយេស៊ូវទ្រង់បានធ្វើឱ្យសាតាំង ពីធំទៅ "ចំណុចសូន្យ" ។

ឥឡូវនេះ អំណាច និងអំណាចគ្រប់គ្រងនេះ គឺជាកូនសោរដែលត្រូវបានទទួលការកែជាថ្មីឡើង ដើម្បីរំដោះមនុស្សជាតិ តាមសេចក្ដីជំនឿរបស់ពួកគេ ហើយពួកជំនុំរបស់ទ្រង់ គឺជារូបកាយរបស់ទ្រង់នៅលើផែនដីនេះ ។

ពេលដែលខ្មាំងសត្រូវចុះចាញ់ សាតាំងអាចធ្វើការនៅលើផែនដីនេះ បានត្រឹមតែរឿងបន្តិចបន្តួចប៉ុណ្ណោះ គឺតាមតែយើងអនុញ្ញាតឱ្យវាធ្វើ ។ ដោយមានការបើកសម្ដែងពីព្រះបន្ទូលរបស់ព្រះនេះ យើងអាចងើបឡើង ហើយចងសាតាំង និងវិញ្ញាណគ្រប់គ្រងរបស់វាបាន ។ យើងអាចរុញច្រានទីមាំមួនរបស់សាតាំង ពេលដែលយើងចងមនុស្សខ្លាំងពូកែ និងបង្ខូចផ្ទះរបស់វា ហើយយើងបញ្ជាពួកវិញ្ញាណអសោចិ៍ឱ្យចេញទៅ នៅក្នុងព្រះនាមព្រះយេស៊ូវ ។

ព្រះគម្ពីរ២កូរិនថូស ១០:៤ ចែងថា: **ព្រោះគ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមរបស់យើងខ្ញុំ មិនមែនជារបស់ខាងសាច់ឈាមទេ គឺជាឥទ្ធិឫទ្ធិដែលមកពីព្រះ សំរាប់នឹងរំលំទីមាំមួនវិញ ។**

ពួកជំនុំដែលព្រះយេស៊ូវទ្រង់បានមានបន្ទូលថា ទ្រង់នឹងសង់នោះបានដេកលក់ទៅហើយ ។ ឥឡូវនេះ ពួកគេត្រូវបានភ្ញាក់ឡើងវិញ ដើម្បីបំពេញភារកិច្ចដោយនូវអំណាច ដែលព្រះទ្រង់បានប្រទានឱ្យ និងបានកម្ទេចចោលនូវទីមាំមួនរបស់សាតាំង ។

## សំណួររំឭកសារឡើងវិញ

១- តើព្រះយេស៊ូវទ្រង់ចង់មានបន្ទូលដូចម្ដេច ពេលដែលទ្រង់ព្រះបន្ទូលថា "ទ្វារស្ថាននៃឃុំព្រលឹងមនុស្សស្លាប់នឹងមិនអាចឈ្នះ "ពួកជំនុំឡើយ"?

២- ព្រះយេស៊ូវទ្រង់មានបន្ទូលថា យើងនឹងត្រូវចង ហើយយើងត្រូវស្រាយ ។ ចូរពិពណ៌នានូវផែនការ ដែលលោកអ្នកនាំចេញនូវវចនាសម្ព័ន្ធដ៏សំខាន់ មកអំពីព្រះយេស៊ូវ ។

៣- ការចងមនុស្សខ្លាំងពូកែ គឺជាការគ្រប់គ្រងលើទីមាំមួនរបស់សាតាំង ព្រះយេស៊ូវទ្រង់មានបន្ទូលថា គ្មានអ្នកណាម្នាក់ធ្វើឱ្យទំនិញរបស់វាខូចខាតឡើយ ។ តើអ្នកណាដែលត្រូវបានពណ៌នាជាមនុស្សខ្លាំងពូកែ? តើមានទម្រង់ការអ្វី ដែលធ្វើឱ្យទំនិញរបស់វាបានខូចខាត?

# មេរៀនទី១០
# កូនសោរនគរស្ថានសួគ៌

## ព្រះយេស៊ូវទ្រង់មានកូនសោរ

តើលោកអ្នកចងចាំឬទេ នូវព្រះបន្ទូលដ៏មានជ័យជម្នះដែលព្រះយេស៊ូវទ្រង់មានបន្ទូលមួយព្រះឱស្ឋ ពេលដែលទ្រង់បានយាងចុះពីនគរស្ថានសួគ៌មកវិញ?

ព្រះគម្ពីរវិវរណៈ ១:១៨ ចែងថា: **ជាព្រះដ៏រស់នៅ អញបានស្លាប់ តែមើល អញរស់នៅអស់កល្បជានិច្ចរៀងរាបតទៅវិញ អញក៏មានកូនសោរនៃសេចក្តីស្លាប់ និងស្ថានឃុំព្រលឹងមនុស្សស្លាប់ដែរ ។**

ព្រះយេស៊ូវទ្រង់បានយកកូនសោរស្ថាននរក និងកូនសោរនៃសេចក្តីស្លាប់ ពីសាតាំងចេញមកហើយ ។ ព្រះយេស៊ូវទ្រង់បានរំដោះនូវអំពើបាបរបស់យើងតែមួយដងជាសម្រេច ចេញពីជង្ហុកដ៏ធំ នៃស្ថានឃុំព្រលឹងមនុស្សស្លាប់មក វាគ្មានលទ្ធភាពឃាតព្រះអង្គទុកធ្វើជាឈ្លើយសឹកនោះ បានយូរអង្វែងឡើយ ។

ព្រះគម្ពីរកិច្ចការ ២:២៤ ចែងថា: **ប៉ុន្តែ ព្រះបានប្រោសទ្រង់ ឱ្យមានព្រះជន្មរស់ឡើងវិញ ដោយបានស្រាយចំណងនៃសេចក្តីស្លាប់ចេញ ពីព្រោះសេចក្តីស្លាប់ គ្មានអំណាចនឹងឃុំឃាំងទ្រង់ទុកបានឡើយ ។**

ព្រះយេស៊ូវទ្រង់បានធ្វើឱ្យសេចក្តីស្លាប់ត្រូវបរាជ័យហើយ !

ព្រះយេស៊ូវទ្រង់បានកែអំណាច អំណាចគ្រប់គ្រង ព្រមទាំងភាពជាស្តេចឱ្យដល់មនុស្សជាថ្មីឡើងវិញហើយ ។ ទ្រង់បានគេគ្រប់យ៉ាងដែលសាតាំងបានលួចយកទៅ មកប្រគល់ឱ្យយើងសារជាថ្មីវិញហើយ ។

យើងបានដឹងថា ព្រះទ្រង់សព្វព្រះហឫទ័យឱ្យយើងរស់នៅដោយមានអំណាចគ្រប់គ្រង ព្រមទាំងអំណាចលើសាតាំង ពីព្រោះទ្រង់បានធ្វើជាយញ្ញបូជា ចេញពីព្រះរាជបុត្រារបស់ទ្រង់ផ្ទាល់ ដើម្បីឱ្យគ្រប់ទាំងអស់ត្រូវបានកែជាថ្មីឡើងវិញ ដូចជាទ្រង់ដែលបានបង្កើតយើងមក ព្រមទាំងបានប្រទានពរដល់យើងនៅលើផែនដីនេះ ។

គ្រប់ទាំងអស់ដែលព្រះយេស៊ូវទ្រង់បានធ្វើនៅលើផែនដីនេះ ដោយជីវិតរបស់ទ្រង់ផ្ទាល់ដែលទ្រង់បានសុគត ព្រមទាំងរស់ពីសុគតឡើងវិញ គឺដើម្បីឱ្យយើងបានកែជាថ្មីតែម្តងជាសម្រេច ។ ទ្រង់បានធ្វើការនេះ ដើម្បីឱ្យយើងអាចដើរនៅក្នុងអំណាច និងជ័យជម្នះលើសាតាំងវិញ្ញាណអាក្រក់របស់វា ព្រមទាំងអ្វីៗទាំងអស់នៅលើផែនដីនេះ ។

## ព្រះលោហិតព្រះយេស៊ូវ_ទទួលជ័យជម្នះដោយមានកូនសោរនៃជ័យជម្នះ

ពេលដែលព្រះទ្រង់បានបង្កើតលោកអ័ដាមមក ទ្រង់បានផ្លុំខ្យល់ជីវិតបញ្ចូលទៅក្នុងគាត់ ។ ជីវិតនេះគឺមិនមែនត្រូវបានកំណត់ឱ្យញែកចេញពីរូបកាយរបស់លោកអ័ដាមនោះទេ ។ ព្រះទ្រង់បានដាក់ជីវិតរបស់ទ្រង់ បញ្ចូលទៅក្នុងឈាមរបស់លោកអ័ដាម ។ វាត្រូវបានបន្តឱ្យមានជីវិតរស់ទៅគ្រប់ផ្នែកទាំងអស់ នៃរូបកាយរបស់លោកអ័ដាម ។

លោកម៉ូសេបានសរសេរថា គ្រប់ទាំងជីវិតជាស្នាព្រះហស្តនៃព្រះ គឺស្ថិតនៅក្នុងឈាម ។

ព្រះគម្ពីរលេវីវិន័យ ១៧:១១ក ចែងថា: **ដ្បិតជីវិតនៃរូបសាច់ នោះនៅក្នុងឈាម ។**

**អំពើបាបរបស់លោកអ័ដាម -សេចក្ដីស្លាប់**

តាមរយៈអំពើបាប លោកអ័ដាមបានបាត់បង់ជីវិតរបស់ព្រះ ដែលនៅក្នុងឈាមរបស់គាត់ ។ ជីវិតនេះមិនត្រឹមតែត្រូវបានកែជាថ្មីឡើងវិញឱ្យដល់មនុស្សតែប៉ុណ្ណោះទេ គឺតាមរយៈផែនការនៃការប្រោសលោះរបស់ព្រះ ។ ដើម្បីឱ្យមនុស្សត្រូវបានកែជាថ្មីវិញ ឱ្យមានរូបភាពរបស់ព្រះ គេត្រូវកើតម្ដងទៀតដើម្បីឱ្យមានជីវិតរបស់ព្រះ នៅក្នុងឈាមរបស់គេវិញ ។

នៅក្នុងផែនការនៃការប្រោសលោះរបស់ព្រះ ព្រះរាជបុត្រារបស់ទ្រង់ព្រះនាមព្រះយេស៊ូវ ទ្រង់ត្រូវតែបង្ហូរព្រះលោហិតផ្ទាល់របស់ទ្រង់ ។

ព្រះគម្ពីរហេព្រើរ ៩:២២ ចែងថា: **ហើយតាមក្រិត្យវិន័យ សឹងតែគ្រប់របស់ទាំងអស់បានស្អាត ដោយសារឈាម បើគ្មានខ្ចាយឈាមទេ នោះគ្មានផ្លូវណាឱ្យបានរួចពីបាបឡើយ ។**

ប្រភពអំពើបាបដែលនាំឱ្យស្លាប់ ត្រូវតែទទួលការបង់ថ្លៃ ដោយអ្នកជំនួសដ៏គ្រប់លក្ខណ៍ដែលមិនបានបាត់បង់ជីវិតរបស់ព្រះទាល់តែសោះ ដើម្បីផ្ដល់ទៅក្នុងឈាមរបស់គេ ដែលអាចឆ្លងកាត់អំពើបាបបាន ។

ការចាប់ទំផ្ទៃជាមួយនឹងស្ត្រីព្រហ្មចារីយដោយព្រះវិញ្ញាណបរិសុទ្ធ នោះព្រះយេស៊ូវទ្រង់គ្មានឈាមនៃអំពើបាបរបស់លោកអ័ដាមឡើយ ។ ទ្រង់បានត្រឡប់មកជាអ្នកជំនួសដ៏គ្រប់លក្ខណ៍ដែលសម្រេចតាមការលះបង់ជីវិតរបស់ទ្រង់ ដោយទ្រង់បានបង្ហូរឈាមដែលគ្មានទោសផ្ទាល់របស់ព្រះអង្គមក ។

**ដោយសារព្រះលោហិតរបស់ទ្រង់**

**ធ្វើឱ្យយើងមាន**

⇨ ការអត់ទោសបាប

ការប្រោសលោះរបស់យើងគឺនៅក្នុងព្រះលោហិតរបស់ព្រះយេស៊ូវ ។

ព្រះគម្ពីរអេភេសូរ ១:៧ ចែងថា: **ហើយយើងបានសេចក្ដីប្រោសលោះនៅក្នុងព្រះរាជបុត្រានោះ ដោយសារព្រះលោហិតទ្រង់ គឺជាសេចក្ដីប្រោសឱ្យរួចពីទោស តាមព្រះគុណដ៏ធ្ងន់ក្រៃលែងនៃទ្រង់ ។**

ព្រះគម្ពីរ១ពេត្រុស ១:១៨-១៩ ចែងថា: **ដោយដឹងថា ទ្រង់បានលោះអ្នករាល់គ្នា ឱ្យរួចពីកិរិយាឥតប្រយោជន៍ ដែលបានតពីពួកឰយុកោមក នោះមិនមែនដោយរបស់ពុករលួយ ដូចជាប្រាក់ឬមាសនោះទេ គឺបានលោះដោយសារព្រះលោហិតដ៏វិសេសរបស់ព្រះគ្រីស្ទវិញ ទុកដូចជាឈាមនៃកូនចៀមឥតខ្ចោះ ឥតស្លាកស្នាម ។**

⇨ ទទួលបាននូវសេចក្ដីយុត្តិធម៌

⇨ ទទួលបាននូវសេចក្ដីសង្គ្រោះ

យើងត្រូវបានទទួលសេចក្ដីយុត្តិធម៌ និងសេចក្ដីយុត្តធម៌របស់ព្រះ គឺដើម្បីកែជីវិតរបស់

យើងជាថ្មីឡើងវិញ ដោយព្រះលោហិតរបស់ព្រះយេស៊ូវ ។

ព្រះគម្ពីររ៉ូម ៥:៨-៩ ចែងថា: **តែឯព្រះ ទ្រង់សំដែងសេចក្ដីស្រឡាញ់របស់ទ្រង់ ដល់យើងរាល់គ្នាឱ្យឃើញច្បាស់ ដោយព្រះគ្រីស្ទបានសុគតជំនួសយើងរាល់គ្នា នោះគឺក្នុងកាលដែលយើងនៅមានបាបនៅឡើយផង ដូច្នេះ ដែលបានរាប់ជាសុចរិត ដោយសារព្រះលោហិតទ្រង់នោះប្រាកដជាយើងនឹងបានរួចចេញពីសេចក្ដីក្រោធ ដោយសារទ្រង់ជាមិនខានលើសទៅទៀត ។**

សេចក្ដីយុត្តិធម៌គ្រប់លក្ខណ៍របស់ព្រះ ត្រូវបានចម្អែតយើង ហើយយើងបានទទួលសេចក្ដីសង្គ្រោះឱ្យរួចពីសេចក្ដីក្រោធរបស់ព្រះ ពេលដែលព្រះយេស៊ូវទ្រង់បានត្រឡប់មកជាអ្នកជំនួសរបស់យើង ព្រមទាំងបានរុញច្រាននូវជ្រោះនៃសេចក្ដីស្លាប់ ដោយការបង្ហូរព្រះលោហិតរបស់ទ្រង់នៅលើឈើឆ្កាង ។

មានតែការបង្ហូរព្រះលោហិតរបស់ព្រះយេស៊ូវតែប៉ុណ្ណោះ ដែលមានជីវិតរបស់ព្រះ ហើយអាចធ្វើឱ្យយើងមានជីវិតរបស់ព្រះ នៅក្នុងយើងសារជាថ្មីម្ដងទៀត ។

ព្រះគម្ពីរយ៉ូហាន ៦:៥៣ ចែងថា: **នោះព្រះយេស៊ូវមានបន្ទូលទៅគេថា ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើអ្នករាល់គ្នាមិនពិសាសាច់ ហើយមិនផឹកឈាមរបស់កូនមនុស្ស នោះអ្នករាល់គ្នាគ្មានជីវិតនៅក្នុងខ្លួនទេ ។**

⇨ ទទួលបាននូវការប្រកប

ព្រះលោហិតរបស់ព្រះយេស៊ូវ នឹងធ្វើឱ្យគ្រប់ទាំងអស់នៃអំពើបាបដែលមាននៅក្នុងជីវិតរបស់យើង ដើម្បីឱ្យយើងមានជីវិតរបស់ព្រះម្ដងទៀត ដោយការកែជាថ្មីឡើងវិញ ។

ព្រះគម្ពីរ១យ៉ូហាន ១:៧ ចែងថា: **តែបើយើងរាល់គ្នាដើរនៅក្នុងពន្លឺវិញ ដូចជាទ្រង់ក៏គង់ក្នុងពន្លឺដែរ នោះយើងមានសេចក្ដីប្រកបនឹងគ្នាទៅវិញទៅមក ហើយព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃទ្រង់ ក៏សំអាតយើងរាល់គ្នា ពីគ្រប់អំពើបាបទាំងអស់ ។**

⇨ ទទួលការប្រោសលោះ

ការប្រោសលោះ ព្រមទាំងការអត់ទោសនូវគ្រប់អស់ទាំងអំពើបាបរបស់យើង គឺតាមរយៈព្រះលោហិតរបស់ព្រះយេស៊ូវ ។

ព្រះគម្ពីរកូល៉ុស ១:១៣-១៤ ចែងថា: **ទ្រង់បានប្រោសឱ្យយើងរួចពីអំណាចនៃសេចក្ដីងងឹត ហើយផ្លាស់យើងមកក្នុងនគររបស់ព្រះរាជបុត្រាស្ងួនភ្ងានៃទ្រង់ យើងរាល់គ្នាមានសេចក្ដីប្រោសលោះក្នុងព្រះរាជបុត្រានោះ គឺជាសេចក្ដីផ្ដាច់បាប ដោយសារព្រះលោហិតទ្រង់ ។**

បើមិនបានទទួលនូវយញ្ញបូជានៃការប្រោសលោះ និងអំណោយទាននៃសេចក្ដីសង្គ្រោះរបស់ព្រះ តាមរយៈការបង្ហូរព្រះលោហិតរបស់ព្រះយេស៊ូវនោះទេ គ្មានមធ្យោបាយណាដើម្បីឱ្យមនុស្សត្រូវបានទទួលការអត់ទោស និងការកែជាថ្មីឡើងវិញបានឡើយ ។

ព្រះគម្ពីរហេព្រើរ ៩:២២ ចែងថា: **ហើយតាមក្រិត្យវិន័យ សឹងតែគ្រប់របស់ទាំងអស់បានស្អាត ដោយសារឈាម បើគ្មានខ្ចាយឈាមទេ នោះគ្មានផ្លូវណាឱ្យបានរួចពីបាបឡើយ ។**

ព្រះគម្ពីរហេព្រើរ ៩:១២ ចែងថា: **នោះទ្រង់បានយាងចូលទៅក្នុងទីបរិសុទ្ធ១ដងជាសំរេច ទាំងបានសេចក្តីប្រោសលោះផង នៅអស់កល្បជានិច្ច មិនមែនដោយយកឈាមពពែឈ្មោល ឬឈាមកូនគោទេ គឺដោយមកព្រះលោហិតនៃអង្គទ្រង់វិញ ។**

- ដោយគ្មានស្លាកស្នាម
- អាចបម្រើព្រះបាន

តាមរយៈព្រះលោហិតរបស់ព្រះយេស៊ូវ យើងត្រូវបានសម្អាត ដើម្បីឱ្យយើងអាចបម្រើព្រះបាន ។

ព្រះគម្ពីរហេព្រើរ ៩:១៤ ចែងថា: **ចំណង់បើព្រះលោហិតរបស់ព្រះគ្រីស្ទ ដែលទ្រង់បានថ្វាយព្រះអង្គទ្រង់ ឥតសៅហ្មង ដល់ព្រះ ដោយសារព្រះវិញ្ញាណដ៏គង់នៅអស់កល្បជានិច្ច នោះនឹងសំអាតទាំងបញ្ញាចិត្តអ្នករាល់គ្នា ពីអស់ទាំងការស្លាប់ផង ដើម្បីឱ្យបានបំរើព្រះដ៏មានព្រះជន្មរស់ តើជាជាងអម្បាលម៉ានទៅទៀត ។**

- យើងមានសេចក្តីជឿជាក់

ពេលដែលលោកអ័ដាមបានដើរនៅក្នុងការប្រកបប្រចាំថ្ងៃ នៅក្នុងវត្តមានរបស់ព្រះមុនពេលដែលគាត់បានធ្វើបាប ទោះបីជាតាមរយៈព្រះលោហិតរបស់ព្រះយេស៊ូវ មនុស្សដែលបានរួចផុតពីអំពើកំហុសទាំងអស់ ព្រមទាំងការផ្តន្ទាទោសអញ្ជឹងក៏ដោយ ក៏មនុស្សនេះអាចដើរដោយអង់អាចចូលទៅក្នុងព្រះវត្តមានរបស់ព្រះម្តងទៀតបានដែរ ។

ព្រះគម្ពីរហេព្រើរ ១០:១៩ ចែងថា: **ដូច្នេះ បងប្អូនអើយ ដែលយើងមានសេចក្តីក្លៀវក្លានឹងចូលទៅក្នុងទីបរិសុទ្ធ ដោយសារព្រះលោហិតនៃព្រះយេស៊ូវ ។**

- យើងមានសេចក្តីសុខសាន្ត

សេចក្តីសុខសាន្ត និងការចុះសម្រុង គឺអាចធ្វើបានតាមរយៈព្រះលោហិតរបស់ទ្រង់ខ្ញុំ ។

ព្រះគម្ពីរកូល៉ុស ១:១៩-២០ ចែងថា: **ដ្បិតព្រះបានសព្វព្រះហឫទ័យ ឱ្យគ្រប់ទាំងសេចក្តីពោរពេញបានស្ថិតស្ថេរនៅក្នុងទ្រង់ ហើយឱ្យបានផ្សះផ្សាគ្រប់ទាំងអស់ ឱ្យជានឹងអង្គទ្រង់ ដោយសារព្រះរាជបុត្រានោះ ទោះបើរបស់នៅស្ថានសួគ៌ ឬនៅផែនដីក្តី ទាំងតាំងស្ពានមេត្រី ដោយសារព្រះលោហិតនៃឈើឆ្កាងទ្រង់ ។**

- ការកែជាថ្មីឡើងវិញ ដើម្បីឱ្យបានសភាពដើម

គឺជាព្រះលោហិតរបស់ព្រះយេស៊ូវ ដែលអាចយកឈ្នះលើសាតាំងបាន ក្នុងការប្រោសលោះ និងការកែមនុស្សជាតិជាថ្មីឡើងវិញ ឱ្យបានជីវិតរបស់ព្រះតាមរយៈការកើតជាថ្មី ។

សាតាំងបានមកលួច សម្លាប់ ហើយបំផ្លាញមនុស្សដែលព្រះទ្រង់បានបង្កើតមក ឱ្យមានរូបដូចជាព្រះអង្គនៅលើផែនដីនេះ ។ តាមរយៈអំពើបាបមនុស្សបានបាត់បង់ជីវិតរបស់ព្រះ ។ មនុស្សត្រូវបានឥតទីពឹងនៅក្នុងការប្រកួតប្រឆាំងរបស់សាតាំង នៅក្នុងជីវិតរបស់គេ ។ ដោយសារផែនការនៃសេចក្តីប្រោសលោះរបស់ព្រះ តាមរយៈការបង្ហូរព្រះលោហិតនៃព្រះរាជបុត្រាផ្ទាល់របស់ព្រះអង្គ មនុស្សអាចត្រូវបានទទួលការកែប្រែជាថ្មីដ៏ពេញលេញឡើងវិញ ដើម្បីឱ្យការ

បង្កើតឡើងរបស់គេមានភាពដូចដើម ព្រមទាំងបានប្រកបទាក់ទងជាមួយនឹងព្រះឡើងវិញ ។ ដោយសារព្រះលោហិតរបស់ព្រះយេស៊ូវ មនុស្សដែលបានជាប់នៅក្នុងបាពបរាជ័យដែលអស់សង្ឃឹម អាចត្រូវបានត្រឡប់ជាមានជ័យជម្នះម្តងទៀត ។

➡ ការគ្របបាំងនៃការការពារ

សូម្បីតែសម្តេចសង្ឃនៅក្នុងព្រះគម្ពីរសញ្ញាណចាស់ ក៏បានយកឈាមកូនចៀមធ្វើជាយញ្ញបូជា ព្រមទាំងប្រួចឈាមនោះទៅលើទីសន្តោសប្រោសរបស់ព្រះ ដើម្បីឱ្យបានគ្របបាំង ឬក៏ផ្សះផ្សាសម្រាប់អំពើបាបរបស់មនុស្ស រហូតមកដល់សព្វថ្ងៃនេះ ដោយសេចក្តីជំនឿទៅលើឈាមនៃកូនចៀម ដែលបានត្រឡប់មកជាការគ្របបាំង ការការពារ សម្រាប់ការប្រោសលោះដល់មនុស្សជាតិ ។

➡ ជ័យជម្នះ

តាមរយៈព្រះលោហិររបស់ព្រះយេស៊ូវ យើងមានជ័យជម្នះ!

ពេលដែលយើងដើរនៅក្នុងការអត់ទោស ក្នុងការស្តាប់បង្គាប់ដល់ព្រះ ដោយសេចក្តីជំនឿ យើងអាចនិយាយដោយអង់អាចថា:

- ➡ "សាតាំង អញគ្របឯងដោយព្រះលោហិតព្រះយេស៊ូវ!"
- ➡ "ក្រុមគ្រួសាររបស់អញ ដែលមានខ្មោចចូល ត្រូវបានគ្របបាំងដោយព្រះលោហិតរបស់ព្រះយេស៊ូវ!"
- ➡ "សាតាំងដោយព្រះលោហិតរបស់ព្រះយេស៊ូវ ឯងត្រូវទទួលបរាជ័យហើយ!"
- ➡ "ដោយសារតែព្រះលោហិតរបស់ព្រះយេស៊ូវ ឯងមិនអាចប៉ះពាល់អញបានឡើយ!"
- ➡ "សាតាំងដោយព្រះលោហិតរបស់ព្រះយេស៊ូវ ឯងត្រូវទទួលបរាជ័យហើយ!"

សូម្បីតែព្រះយេស៊ូវដែលទ្រង់បានឈ្នះសាតាំង គឺដោយសារព្រះលោហិតរបស់ទ្រង់ យើងក៏អាចទទួលជ័យជម្នះ ដោយសារព្រះលោហិតរបស់ព្រះយេស៊ូវដែរ! ដោយសារការការពារនៃព្រះលោហិតរបស់ទ្រង់ គ្មានការរងរំពាត់ មកទាស់ទទឹងនឹងយើង ធ្វើឱ្យយើងអាចចម្រើនរុងរឿងបាន ។

ព្រះគម្ពីរវិវរណៈ ១២:១១ក ចែងថា: **គេបានឈ្នះវា ដោយសារឈាមនៃកូនចៀម ហើយដោយសារសេចក្តីបន្ទាល់របស់គេ ។**

សាតាំង ដោយសារព្រះលោហិតរបស់ព្រះយេស៊ូវ ឯងត្រូវបរាជ័យហើយ ។

កូនសោរនៃអំណាចរបស់ព្រះលោហិតព្រះយេស៊ូវ បានប្រទានពរមកឱ្យយើងម្នាក់ៗតាមរយៈព្រះលោហិតដែលធ្វើឱ្យយើងទទួលការប្រោសលោះ ។ ដោយមានកូនសោរនៃចេស្តារបស់ព្រះលោហិតទ្រង់ យើងត្រូវបានឈ្នះ ហើយសាតាំងនឹងត្រូវតែបរាជ័យជារៀងរហូតនៅក្នុងជីវិតរបស់យើង ។

**ដាវនៃព្រះវិញ្ញាណ**

នៅក្នុងព្រះគម្ពីរអេភេសូរ អាវុធរបស់ពួកយើងដែលមានជ័យជម្នះនៅក្នុងសមរភូមិ គឺត្រូវបានពណ៌នាថា "ដាវរបស់ព្រះវិញ្ញាណ គឺជាព្រះបន្ទូល" (៦:១៧)។ ដាវរបស់ព្រះ គឺពេលដែលយើងបាននិយាយចេញពីមាត់របស់យើង បានត្រឡប់ទៅជាដាវដែលមានអំណាចទាស់ទទឹងជាមួយនឹងសាតាំង ដោយវាមិនអាចការពារបាន ។ ពេលដែលយើងនិយាយព្រះបន្ទូលព្រះ ដោយមានអំណាច យើងនឹងឈ្នះសាតាំងនៅក្នុងជីវិតយើងបាន ។

ព្រះគម្ពីរវិវរណៈ ១២:១១ក ចែងថាៈ **គេបានឈ្នះវា ដោយសារឈាមនៃកូនចៀម ហើយដោយសារសេចក្ដីបន្ទាល់របស់គេ ។**

**ព្រះបន្ទូលក្នុងការធ្វើទីបន្ទាល់**

"ពាក្យបន្ទាល់របស់ពួកគេ" គេបកប្រែត្រឹមតែន័យត្រង់ៗថា "ព្រះបន្ទូលជាទីបន្ទាល់របស់គេ"។ ទីបន្ទាល់របស់យើងរាល់គ្នា គឺជាអ្វីដែលយើងបាននិយាយ ។ ពេលដែលយើងបញ្ឈប់ការនិយាយដោយមានបញ្ហា គំនិតរបស់យើង ឬការភ័យខ្លាចរបស់យើងកើតឡើង យើងនឹងចាប់ផ្ដើមនិយាយដោយរឹងប៉ឹង នូវអ្វីដែលព្រះបន្ទូលបានចែងអំពីស្ថានការណ៍របស់យើង បន្ទាប់មក យើងក៏នឹងត្រឡប់ជាបានទទួលជ័យជម្នះ ។

**ព្រះបន្ទូលនាំមកនូវជ័យជម្នះ**

ដើម្បីឱ្យមានព្រះបន្ទូលរបស់ព្រះនៅតែបន្តចេញពីមាត់របស់យើង យើងចាំបាច់ត្រូវតែអាន សិក្សា ព្រមទាំងពិចារណាលើព្រះបន្ទូលនោះ ។ បន្ទាប់មក វានឹងត្រឡប់ជាចាក់ឫសយ៉ាងជ្រៅដោយមានសេចក្ដីជំនឿមាំមួន នៅក្នុងជីវិតរបស់យើង ។

ព្រះគម្ពីរ១យ៉ូហាន ២:១៣-១៤ ចែងថាៈ **ឪពុករាល់គ្នាអើយ ខ្ញុំសរសេរផ្ញើមកអ្នករាល់គ្នា ពីព្រោះបានស្គាល់ព្រះ ដែលទ្រង់គង់នៅតាំងពីដើមរៀងមក កំឡោះរាល់គ្នាអើយ ខ្ញុំសរសេរផ្ញើមកអ្នករាល់គ្នា ពីព្រោះបានឈ្នះមេកំណាចហើយ ក្មេងរាល់គ្នាអើយ ខ្ញុំបានសរសេរផ្ញើមកអ្នករាល់គ្នា ពីព្រោះបានស្គាល់ព្រះវរបិតា ឪពុករាល់គ្នាអើយ ខ្ញុំបានសរសេរផ្ញើមកអ្នករាល់គ្នា ពីព្រោះបានស្គាល់ ដែលគង់នៅតាំងពីដើមរៀងមក កំឡោះរាល់គ្នាអើយ ខ្ញុំបានសរសេរផ្ញើមកអ្នករាល់គ្នា ពីព្រោះមានកំឡាំង ហើយព្រះបន្ទូលក៏ស្ថិតនៅក្នុងអ្នករាល់គ្នា អ្នករាល់គ្នាបានឈ្នះមេកំណាចហើយ ។**

បុរសក្មេងៗទាំងនេះ ត្រូវបាននិយាយដោយមានកម្លាំងអាចឈ្នះខ្មាំងសត្រូវបាន ដោយសារតែពួកគេមានព្រះបន្ទូល ដ៏មាំមួនរបស់ព្រះនៅក្នុងពួកគេ ។ ពេលដែលពួកគេនិយាយដោយរឹងប៉ឹង នូវព្រះបន្ទូលនោះចេញពីមាត់របស់គេ នៅក្នុងអំណាចដែលបានប្រទានមកពីព្រះ ព្រមទាំងអំណាចគ្រប់គ្រង ដែលពួកគេបានទទួលជ័យជម្នះលើអាកំណាចនោះ ។

ព្រះគម្ពីរអេភេសូរ ៦:១៧ ចែងថាៈ **ចូរយកសេចក្ដីសង្គ្រោះទុកជាមួកសឹក និងដាវរបស់ព្រះវិញ្ញាណដែរ គឺជាព្រះបន្ទូល ។**

ដាវនៃព្រះវិញ្ញាណ គឺជាព្រះបន្ទូលព្រះ ។

ព្រះគម្ពីរវិវរណៈ ១៩:១៣-១៦ ចែងថា: **ទ្រង់ក៏ទ្រង់ព្រះពស្ត្រជ្រលក់ដោយឈាម ហើយព្រះនាមទ្រង់ហៅថា "ព្រះបន្ទូលនៃព្រះ" អស់ទាំងពលបរិវារនៅស្ថានសួគ៌ ក៏ជិះសេះសដង្ហែទ្រង់ ទាំងស្លៀកពាក់សំពត់ទេស ហើយស្អាតផង មានដាវយ៉ាងមុតចេញពីព្រះឱសទ្រង់ ដើម្បីនឹងកាប់អស់ទាំងសាសន៍ ហើយទ្រង់នឹងឃ្វាលគេ ដោយដំបងដែក ទ្រង់ក៏ជាន់ក្នុងធុងឃ្នាបនៃស្រាទំពាំងបាយជូរ ជាសេចក្តីឃោរឃៅរបស់សេចក្តីខ្ញាល់នៃព្រះដ៏មានព្រះចេស្តាចំផុត ទ្រង់មានព្រះនាមកត់នៅព្រះពស្ត្រ ហើយនៅព្រឺឱ្យទ្រង់ថា "ស្តេចលើអស់ទាំងស្តេច ជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់" ។**

**និយាយដោយនូវព្រះបន្ទូល**

ព្រះយេស៊ូវទ្រង់មានបន្ទូលនូវគំរូដ៏ពិសេស១នៃសេចក្តីជំនឿ គឺជាមនុស្សដែលបានយល់នូវអំណាច ព្រមទាំងបានស្គាល់នូវរបៀបអនុវត្តិ ដោយការនិយាយនូវព្រះបន្ទូល ។

ព្រះគម្ពីរម៉ាថាយ ៨:៨-១០ ចែងថា: **តែមេទ័ពទូលប្រកែកថា ព្រះអម្ចាស់អើយ ទូលបង្គំមិនគួរនឹងទទួលទ្រង់នៅក្នុងផ្ទះទូលបង្គំទេ សូមទ្រង់គ្រាន់តែមានបន្ទូលមួយប្រះឱស្ឋមកប៉ុណ្ណោះ នោះបាវទូលបង្គំនឹងបានជាហើយ ដ្បិតទូលបង្គំជាមនុស្សនៅក្រោមបង្គាប់គេដែរ ហើយមានទាហាននៅក្រោមឱវាទទូលបង្គំ បើទូលបង្គំប្រាប់ទៅម្នាក់ថា ទៅ នោះវាក៏ទៅ ប្រាប់ទៅម្នាក់ថា មក វាក៏មក ហើយប្រាប់ទៅបាវថា ធ្វើការនេះ នោះវាក៏ធ្វើតាម កាលព្រះយេស៊ូវបានឮពាក្យនោះហើយ ទ្រង់មានសេចក្តីអស្ចារ្យក្នុងព្រះហឫទ័យ រួចមានបន្ទូលទៅពួកអ្នកដែលតាមទ្រង់ថា ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា ខ្ញុំមិនដែលឃើញសេចក្តីជំនឿជាខ្លាំងដល់ម្ល៉េះទេ ទោះទាំងនៅក្នុងសាសន៍អ៊ីស្រាអែលផង ។**

**ព្រះបន្ទូលបានបញ្ជាក់**

ព្រះបន្ទូលព្រះនឹងត្រូវបានបញ្ជាក់ដោយទីសម្គាល់ និងការអស្ចារ្យ ។

ព្រះគម្ពីរម៉ាកុស ១៦:១៩-២០ ចែងថា: **ដូច្នេះ ក្រោយដែលព្រះអម្ចាស់បានមានបន្ទូលនឹងគេរួចហើយ នោះព្រះវរបិតាបានទទួលទ្រង់ឡើងទៅស្ថានសួគ៌វិញ ឱ្យគង់នៅខាងស្តាំឯពួកសិស្ស គេចេញទៅប្រកាសប្រាប់នៅសព្វគ្រប់អន្លើ ដោយមានព្រះអម្ចាស់ធ្វើការជាមួយទាំងបញ្ជាក់ព្រះបន្ទូល ដោយទីសំគាល់ដែលកើតមកតាមក្រោយផង ។**

**ព្រះបន្ទូលគឺជាព្រះបន្ទូល**

គ្រប់ព្រះនាមរបស់ព្រះយេស៊ូវ គឺជាព្រះបន្ទូលនៃព្រះ ។

ព្រះគម្ពីរវិវរណៈ ១៩:១៣ ចែងថា: **ទ្រង់ក៏ទ្រង់ព្រះពស្ត្រជ្រលក់ដោយឈាម ហើយព្រះនាមទ្រង់ហៅថា "ព្រះបន្ទូលនៃព្រះ" ។**

ព្រះគម្ពីរយ៉ូហាន ១:១ ចែងថា: **កាលដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះ ។**

**ព្រះបន្ទូលមិនដែលវិលមកវិញដោយឥតកើតផលឡើយ**

ព្រះទ្រង់មានបន្ទូលដោយអំណាចនៃព្រះបន្ទូលរបស់ទ្រង់ តាមរយៈហោរាអេសាយ ។

ព្រះគម្ពីរអេសាយ ៥៥:១១ ចែងថា: **នោះពាក្យអញ ដែលចេញពីមាត់អញទៅ ក៏មិនដែលវិលមកឯអញវិញ ដោយឥតកើតផលយ៉ាងដូច្នោះដែរ គឺនឹងធ្វើសំរេចតាមសេចក្ដីបំណងប្រាថ្នានៅក្នុងចិត្តអញ ហើយនិងចំរើនកើនឡើង ក្នុងការអ្វី ដែលអញចាត់ទៅធ្វើនោះ ។**

ព្រះទ្រង់មានបន្ទូលដោយអំណាចនៃការប្រោសឱ្យជា ដោយព្រះបន្ទូលរបស់ទ្រង់ តាមរយៈស្តេចដាវីឌ ។

ព្រះគម្ពីរទំនុកដំកើង ១០៧:២០ ចែងថា: **ទ្រង់ចាត់ព្រះបន្ទូលទៅប្រោសគេឱ្យជា ក៏ដោះឱ្យគេរួចពីសេចក្ដីវិនាស ។**

ព្រះបន្ទូលដែលយើងបាននិយាយដោយមានអំណាច គឺសង្កត់ធ្ងន់ទៅលើការបង្ហើយការទាំងឡាយ ដោយគាប់ព្រះហឫទ័យព្រះ ។ ព្រះបន្ទូលព្រះសន្យាឱ្យយើង ថានឹងនឹងឱ្យបានបង្កើតផល ។

**ព្រះបន្ទូលបានបង្កើត**

ព្រះបន្ទូលមានអំណាចនឹងបង្កើត ។

ព្រះគម្ពីរហេព្រើរ ១១:៣ ចែងថា: **យើងរាល់គ្នាក៏យល់ដោយសារសេចក្ដីជំនឿនោះថា លោកិយបានកើតមក ដោយសារព្រះបន្ទូលនៃព្រះ បានជារបស់ដែលមើលឃើញទាំងប៉ុន្មាន នោះមិនមែនកើតអំពីរបស់ដែលមើលឃើញទេ ។**

**ព្រះបន្ទូលមានអំណាច**

ព្រះយេស៊ូវទ្រង់មានបន្ទូលដោយអំណាច ។

ព្រះគម្ពីរលូកា ៤:៣៦ ចែងថា: **គ្រប់គ្នាក៏នឹកស្ញើចក្នុងចិត្ត ទាំងសួរគ្នាថា តើពាក្យបែបយ៉ាងណានេះ ដែលលោកបង្គាប់ដល់វិញ្ញាណអសោចិ៍ ដោយអំណាចនិងឫទ្ធិបាន ហើយវាក៏ចេញទៅដូច្នេះ ។**

**ព្រះបន្ទូលចូល -ព្រះបន្ទូលចេញ**

វាជាការល្អដើម្បីឱ្យស្គាល់ដឹងនូវព្រះបន្ទូល ប៉ុន្តែ ទាល់តែយើងបានជួបនូវសភាពការណ៍ដែលព្រះបន្ទូលព្រះត្រូវបាននិយាយចេញពីមាត់របស់យើង យើងនឹងមិនមានជ័យជម្នះទេឬ !

ព្រះយេស៊ូវទ្រង់មានបន្ទូលដោយអំណាច និងមានចេស្តា ។

ប្រភេទនៃសេចក្ដីជំនឿលើព្រះ:

⇨ ជឿលើព្រះបន្ទូល

⇨ និយាយពីព្រះបន្ទូល

⇨ មើលឃើញនូវការអស្ចារ្យតាមព្រះបន្ទូលដែលបានសម្រេចជោគជ័យ

កូនសោរនៃព្រះបន្ទូលរបស់ព្រះ មិនដែលធ្លាក់ចុះឡើយ ពេលដែលយើងនូវតែបន្តការនិយាយដោយមានអំណាច និងអំណាចគ្រប់គ្រង ។

យើងត្រូវខិតខំធ្វើការតាមលំដាប់លំដោយ នៅក្នុងអំណាចគ្រប់គ្រងលើផែនដី តាមការដែលព្រះទ្រង់បានបង្កើតយើងមក នោះព្រះយេស៊ូវទ្រង់បានប្រទានឱ្យយើង នូវពួកជំនុំរបស់ទ្រង់ កូនសោរនៃអំណាចសម្រាប់ឱ្យយើងធ្វើសង្គ្រាមខាងឯវិញ្ញាណ បានទទួលជ័យជម្នះ ។ ពេលដែលយើងរកឃើញនូវកូនសោរទាំងនេះ ព្រមទាំងឃើញនូវរបៀបនៃការប្រើប្រាស់ពួកវា យើងនឹងរកឃើញដោយខ្លួនឯង ក្នុងការរស់នៅដែលមានជ័យជម្នះលើការតស៊ូនៃជីវិតរបស់យើង ។ យើងនឹងរកឃើញដោយខ្លួនឯង នូវអ្វីដែលព្រះយេស៊ូវបានប្រកាសឱ្យយើងធ្វើរួចហើយថា:

**យើងវិសេសជាងអ្នកដែលមានជ័យជម្នះ ។**

**យើងឈ្នះនៅក្នុងព្រះនាមរបស់ទ្រង់ ។**

## សំណួររំឭកសារឡើងវិញ

១- ចូរពន្យល់ តើហេតុអ្វីបានជាព្រះលោហិតរបស់ព្រះយេស៊ូវ សង្កត់ធ្ងន់ទៅលើជ័យជម្នះក្នុងការប្រយុទ្ធនឹងពួកវិញ្ញាណអាក្រក់ ឬក៏ពួកវិញ្ញាណអសោចិ៍ ។

២- ចូរឱ្យឧទាហរណ៍នូវការនិយាយព្រះបន្ទូលព្រះដោយរបៀបណា ដែលផ្តល់ឱ្យលោកអ្នកបានទទួលជ័យជម្នះ នៅក្នុងជីវិតលោកអ្នកផ្ទាល់ ។

៣- តើព្រះបន្ទូលថែងយ៉ាងដូចម្តេច ដែលធ្វើឱ្យលោកអ្នកមានបំណងចងចាំ ដើម្បីប្រើធ្វើជាអាវុធ នៅក្នុងសមរភូមិខាងឯវិញ្ញាណរបស់លោកអ្នក?

# មេរៀនទី១១

## ព្រះនាមព្រះយេស៊ូវ

**ព្រះនាមព្រះយេស៊ូវ គឺជាកូនសោរដែលឈ្នះសម្រាប់ជ័យជម្នះរបស់យើង**

ពេលដែលយើងប្រើព្រះនាមព្រះយេស៊ូវ នោះយើងកំពុងតែនិយាយដោយនូវអំណាចព្រះយេស៊ូវ ។ ពេលដែលយើងនិយាយក្នុងព្រះនាមនោះ វាមានប្រសិទ្ធិភាពដូចជាព្រះយេស៊ូវកំពុងតែគង់នៅក្នុងការនិយាយទៅកាន់សភាពការណ៍នោះដែរ ។ ទ្រង់បានប្រទានសិទ្ធិអំណាច ឱ្យយើងប្រើព្រះនាមព្រះអង្គ ។

**ទីសម្គាល់តាមជំនឿដោយនូវព្រះនាមទ្រង់**

ទីសម្គាល់ត្រូវតែតាមជាប់ដល់អស់អ្នកណា ដែលជឿលើព្រះនាមព្រះយេស៊ូវ ។

ព្រះគម្ពីរម៉ាកុស ១៦:១៥-១៨ ចែងថា: **ទ្រង់ផ្តាំគេថា ចូរអ្នករាល់គ្នាទៅពេញសព្វក្នុងលោកិយទាំងមូល ហើយផ្សាយដំណឹងល្អទូទៅដល់គ្រប់មនុស្សទាំងអស់ចុះ អ្នកណាដែលជឿ ហើយទទួលបុណ្យជ្រមុជទឹក នោះនឹងបានសង្គ្រោះ តែអ្នកណាដែលមិនព្រមជឿ នោះនឹងត្រូវទោសវិញ ទីសំគាល់ទាំងនេះនឹងជាប់តាមអស់អ្នកដែលជឿ គឺថា គេនឹងដេញអារក្សដោយនូវឈ្មោះខ្ញុំ ហើយនិងចេះនិយាយភាសាថ្មី និងចាប់កាន់ពស់បាន ឬបើគេផឹកអ្វីពុល នោះមិនធ្វើឱ្យអន្តរាយទេ ហើយគេនឹងដាក់ដៃលើមនុស្សជំងឺឱ្យបានជាផង ។**

នៅក្នុងព្រះគម្ពីរសញ្ញាថ្មីជាភាសាក្រិកដើម ដែលបានសរសេរចែងមកនោះ គឺមិនបានដាក់វណ្ណយុត្តិទេ ។ វណ្ណយុត្តិដែលមានប្រើនៅក្នុងព្រះគម្ពីររបស់យើង គឺត្រូវបានពួកអ្នកបកប្រែបន្ថែមទៅតាមការនឹកឃើញរបស់គេតែប៉ុណ្ណោះ ។

ចូរអានព្រះគម្ពីរម៉ាកុស ១៦:១៧:

**ទីសំគាល់ទាំងនេះនឹងជាប់តាមអស់អ្នកដែលជឿ គឺថា គេនឹងដេញអារក្សដោយនូវឈ្មោះខ្ញុំ ហើយនិងចេះនិយាយភាសាថ្មី** ។

តាមព្រះបន្ទូលនេះ គឺជាការបកប្រែតាមន័យត្រង់ៗតែប៉ុណ្ណោះ

**ទីសំគាល់ទាំងនេះនឹងជាប់តាមអស់អ្នកដែលជឿ គឺថា គេនឹងដេញអារក្សដោយនូវឈ្មោះខ្ញុំ ហើយនិងចេះនិយាយភាសាថ្មី** ។

ព្រះយេស៊ូវទ្រង់មានបន្ទូលថា វាជាការសំខាន់ណាស់ដែលយើងជឿលើព្រះនាមព្រះអង្គ គឺយើងត្រូវតែយល់នូវអំណាចដែលជារបស់យើង នៅក្នុងព្រះនាមព្រះយេស៊ូវ ។ យើងត្រូវតែសម្តែងនូវអំណាចនោះដោយក្លាហាន ដោយជំនឿ ពេលដែលយើងប្រើព្រះនាមព្រះយេស៊ូវនោះ ។

ពេលដែលយើងនិយាយដោយក្លាហាន ព្រមទាំងបញ្ចេញសកម្មភាពនៃសេចក្តីជំនឿរបស់យើង នៅក្នុងព្រះនាមព្រះយេស៊ូវនោះ យើងនឹងអាចបណ្តេញពួកវិញ្ញាណអសោចិ៍បាន ។ យើងអាចអធិស្ឋានដាក់ដៃលើអ្នកជំងឺឱ្យជាបាន ។

**សិទ្ធិភ័យខ្លាច**

មុនពេលព្រះរាជកិច្ចរបស់ព្រះយេស៊ូវនៅលើឈើឆ្កាងត្រូវបានបញ្ចប់ គ្មានអ្នកណាម្នាក់ហ៊ាននិយាយពីព្រះនាមរបស់ព្រះបានឡើយ ។ ពួកគេត្រូវបានពិចារណាពីភាពបរិសុទ្ធ ដើម្បីនិយាយពីគ្រប់រឿងរ៉ាវទាំងអស់នេះដែរ តែពួកគេត្រូវបានត្រឹមតែរាប់បញ្ចូលទៅក្នុងកន្លែងបរិសុទ្ធបំផុត ព្រមទាំងដឹងថា ត្រូវតែប្រគល់ទៅឱ្យសម្ដេចសង្ឃតែប៉ុណ្ណោះ ។

ពេលដែលព្រះយេស៊ូវទ្រង់បានប្រទានសិទ្ធិដល់ពួកអ្នកជឿ ឱ្យប្រើព្រះនាមព្រះអង្គនោះក៏មានឯកសិទ្ធិនៃការភ័យខ្លាច ព្រមទាំងមិនដែលត្រូវបានគេយកមកបំភ្លឺឡើយ ។

**ការបញ្ចេញនូវអំណាចរបស់ព្រះយេស៊ូវ**

ដោយសារព្រះយេស៊ូវទ្រង់ជាព្រះរាជបុត្រានៃព្រះ:

⇨ ទ្រង់មានគ្រប់ទាំងអំណាចនៅនគរស្ថានសួគ៌

ដោយសារព្រះយេស៊ូវទ្រង់ជាកូនមនុស្ស:

⇨ ទ្រង់មានគ្រប់ទាំងអំណាចនៅលើផែនដី

ព្រះគម្ពីរម៉ាថាយ ២៨:១៨ ចែងថា: **ឯព្រះយេស៊ូវ ទ្រង់យាងមកមានបន្ទូលនឹងគេថា គ្រប់ទាំងអំណាចបានប្រគល់មកខ្ញុំនៅស្ថានសួគ៌ ហើយលើផែនដីផង ។**

ពេលដែលយើងប្រើព្រះនាមព្រះយេស៊ូវ អំណាចដ៏លើសលប់ ព្រមទាំងអំណាចចេស្ដាត្រូវបានសម្ដែងឡើង ដូចជាយើងកំពុងតែឈរនៅកន្លែងរបស់ទ្រង់ ព្រមទាំងប្រើអំណាចរបស់ទ្រង់យ៉ាងដូច្នោះដែរ ។

**អំណាចនៃស្នាក្ដី**

ពេលដែលព្រះយេស៊ូវទ្រង់បានប្រទានសិទ្ធិត្រឹមត្រូវតាមច្បាប់ដល់យើង ឱ្យប្រើព្រះនាមព្រះអង្គ នោះទ្រង់បានរៀបកន្លែងឱ្យយើងគ្រប់គ្រង តាមច្បាប់នៃសេចក្ដីពិតដ៏ខ្ពង់ខ្ពស់របស់ទ្រង់ ។ នៅក្នុងទម្រង់សិទ្ធិត្រឹមត្រូវតាមច្បាប់ ដែលទ្រង់បានប្រទានអំណាចនៃស្នាក្ដីឱ្យដល់យើងប្រើព្រះនាមព្រះអង្គ ។

នៅក្នុងប្រព័ន្ធជំនុំជម្រះរបស់យើង អំណាចស្នាក្ដីគឺជាកំណត់ហេតុត្រឹមត្រូវតាមច្បាប់ដែលផ្ដល់ឱ្យមនុស្សនូវសិទ្ធិ ព្រមទាំងឯកសិទ្ធិ ដើម្បីប្រើឈ្មោះអ្នកដទៃទៀត ។ ពេលដែលមនុស្សបានត្រូវគេទទួលការទុកចិត្ត ចុះហត្ថលេខាពីកិច្ចសន្យាជំនួសមនុស្សម្នាក់ទៀត ព្រមទាំងបានចម្លងនូវអំណាចស្នាក្ដីទៅលើកិច្ចសន្យានោះ គឺដូចគ្នានឹងមនុស្សម្នាក់ដែលបានចុះហត្ថលេខាលើកិច្ចសន្យានោះដែរ ។

**ការស្ដាប់ឮព្រះសូរសៀងពីព្រះ**

ពេលដែលព្រះយេស៊ូវបានកំពុងបំពេញព្រះរាជកិច្ចនៅលើផែនដីនេះ ទ្រង់បានបញ្ចេញសកម្មភាពជំនួសព្រះវរបិតារបស់ទ្រង់ ។

ព្រះគម្ពីរយ៉ូហាន ៥:១៩ ចែងថា: **ដូច្នេះ ព្រះយេស៊ូវ ទ្រង់មានបន្ទូលឆ្លើយទៅគេថា ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា ព្រះរាជបុត្រាពុំអាចនឹងធ្វើការអ្វី ដោយព្រះអង្គទ្រង់**

**បានទេ ធ្វើបានតែការអ្វីដែលឃើញព្រះវរបិតាធ្វើ ដ្បិតការអ្វីដែលព្រះវរបិតាធ្វើ នោះព្រះរាជបុត្រាក៏ធ្វើដូច្នោះដែរ ។**

ពេលដែលយើងបានបំពេញការងារលើផែនដីឥឡូវនេះ យើងក៏ត្រូវតែបញ្ចេញសកម្មភាពជំនួសឱ្យព្រះរាជបុត្រាដែរ ។ យើងមិនត្រូវប្រើព្រះនាមរបស់ព្រះយេស៊ូវ ដើម្បីបំពេញគោលបំណងផ្ទាល់ខ្លួនរបស់យើងឡើយ ត្រូវតែយកការស្តាប់ឮពីព្រះជាទីមួយ ។

**ការប្រើព្រះនាមជាអសារឥតការ**

ការព្យាយាមប្រើព្រះនាមព្រះយេស៊ូវ ដើម្បីបំពេញតាមការសម្រេចចិត្តផ្ទាល់របស់យើង មិនព្រមធ្វើតាមបំណងព្រះហឫទ័យព្រះជាមុន បានន័យថាប្រើព្រះនាមរបស់ទ្រង់ជាអសារឥតការ ។

ព្រះគម្ពីរចោទិយកថា ៥:១១ ចែងថា: **កុំឱ្យចេញព្រះនាមព្រះយេហូវ៉ា ជាព្រះនៃឯងជាអសារឥតការឡើយ ដ្បិតព្រះយេហូវ៉ាទ្រង់នឹងមិនរាប់ជាឥតទោស ដល់អ្នកណាដែលចេញព្រះនាមទ្រង់ជាអសារឥតការនោះទេ ។**

**ព្រះនាមខ្ពស់លើសអស់ទាំងនាមផង**

ព្រះនាមព្រះយេស៊ូវ គឺជានាមខ្ពស់លើគ្រប់អស់ទាំងនាម ។

ព្រះគម្ពីរភីលីព ២:៥-១១ ចែងថា: **ត្រូវតែមានគំនិតគិតដូចជាព្រះគ្រីស្ទយេស៊ូវវិញ ដែលទោះបើទ្រង់មានរូបអង្គជាព្រះក៏ដោយ គង់តែមិនបានរាប់សេចក្តីដែលស្មើនឹងព្រះនោះ ទុកជាសេចក្តីដែលគួរកាន់ខ្ជាប់ឡើយ គឺទ្រង់បានលះបង់ព្រះអង្គទ្រង់ មកយករូបភាពជាបាវបំរើវិញ ព្រមទាំងប្រសូតមកមានរូបជាមនុស្សផង ហើយដែលឃើញទ្រង់មានភាពជាមនុស្សដូច្នោះ នោះក៏បន្ទាបព្រះអង្គទ្រង់ ទាំងចុះចូលស្តាប់បង្គាប់ រហូតដល់ទីមរណៈ គឺទ្រង់ទទួលសុគតជាប់លើឈើឆ្កាងផង ដោយហេតុនោះបានជាព្រះបានលើកទ្រង់ឡើងយ៉ាងខ្ពស់ ហើយបានប្រទានឱ្យមាននាមដ៏ប្រសើរ លើសជាងអស់ទាំងនាមផង ដើម្បីកាលណាឮព្រះនាមព្រះយេស៊ូវ នោះឱ្យគ្រប់ទាំងជង្គង់ស្ថានសួគ៌ នៅផែនដី ហើយនៅក្រោមផែនដីត្រូវលុតចុះ ហើយឱ្យគ្រប់ទាំងអណ្តាតបានថ្លែងប្រាប់ថា ព្រះយេស៊ូវគ្រីស្ទទ្រង់ជាព្រះអម្ចាស់ សំរាប់ជាសិរីល្អដល់ព្រះដ៏ជាព្រះវរបិតា ។**

- ⇨ គ្រប់ទាំងអំណាចវិញ្ញាណអាក្រក់ សុទ្ធតែមានឈ្មោះ
- ⇨ គ្រប់បុគ្គលសុទ្ធតែមានឈ្មោះ
- ⇨ គ្រប់ទាំងអ្នកជំងឺ និងជំងឺសុទ្ធតែមានឈ្មោះ
- ⇨ ផែនការរបស់អារក្សសុទ្ធតែមានឈ្មោះ
- ⇨ ពេលដែលយើងនិយាយពីព្រះនាមព្រះយេស៊ូវ អំណាចអារក្សត្រូវតែវិនាសទៅ
- ⇨ ពេលដែលយើងនិយាយពីព្រះនាមព្រះយេស៊ូវ ជំងឺមហារីក និងជំងឺដទៃទៀតទាំងអស់ ត្រូវតែក្រាបចុះ

➡ ពេលដែលយើងនិយាយពីព្រះនាមព្រះយេស៊ូវ ផែនការរបស់សាតាំងត្រូវបរាជ័យ

ព្រះនាមព្រះយេស៊ូវ គឺជានាមខ្ពស់លើអស់ទាំងនាមផង ។ គ្រប់ទាំងជង្គង់នឹងលុតចុះទៅចំពោះភាពជាព្រះអម្ចាស់របស់ព្រះយេស៊ូវ ពេលដែលយើងនិយាយពីព្រះនាមទ្រង់ដោយសេចក្ដីជំនឿ ។

**ពួកវិញ្ញាណអសោចិ៍ ចុះចូលនឹងព្រះនាមទ្រង់**

ពួកវិញ្ញាណអសោចិ៍ ស្គាល់នូវអំណាចព្រះចេស្ដានៃព្រះនាមព្រះយេស៊ូវ ហើយពួកវានឹងចុះចូលចំពោះព្រះនាមនោះ ។

ព្រះគម្ពីរលូកា ១០:១៧,១៩ ចែងថា: **ពួក៧០នាក់នោះក៏មកវិញដោយអំណរ ហើយទូលថា ព្រះអម្ចាស់អើយ ទោះទាំងពួកអារក្សក៏ចុះចូលចំពោះយើងរាល់គ្នា ដោយព្រះនាមទ្រង់ដែរ... មើល ខ្ញុំឱ្យអ្នករាល់គ្នាមានអំណាច នឹងដើរជាន់ទាំងពស់និងខ្យាដំរី ហើយលើគ្រប់ទាំងឥទ្ធិឫទ្ធិរបស់ខ្មាំងសត្រូវផង គ្មានអ្វីនឹងធ្វើទុក្ខអ្នករាល់គ្នាឡើយ ។**

ព្រះគម្ពីរម៉ាថាយ ២៨:១៨ ចែងថា: **ឯព្រះយេស៊ូវ ទ្រង់យាងមកមានបន្ទូលនឹងគេថា គ្រប់ទាំងអំណាចបានប្រគល់មកខ្ញុំនៅស្ថានសួគ៌ ហើយលើផែនដីផង ។**

គ្រប់ទាំងអំណាចត្រូវបានប្រទានមកព្រះយេស៊ូវ ដោយការប្រើព្រះនាមយេស៊ូវ យើងមានអំណាចដូច្នោះនៅលើផែនដីនេះ ។

**ជឿលើព្រះនាម**

យើងត្រូវបានទទួលបញ្ជាឱ្យជឿលើព្រះនាមព្រះយេស៊ូវ ។

ព្រះគម្ពីរ១យ៉ូហាន ៣:២៣ ចែងថា: **ឯបញ្ញត្តិទ្រង់នោះ គឺថា ត្រូវឱ្យយើងជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រនៃទ្រង់ ហើយត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចជាទ្រង់បានបង្គាប់មកហើយ ។**

យើងត្រូវតែជឿលើព្រះនាមព្រះយេស៊ូវ ដើម្បីឱ្យបានជីវិតអស់កល្បជានិច្ច ។

ព្រះគម្ពីរយ៉ូហាន ៣:១៨ ចែងថា: **ឯអ្នកណាដែលជឿដល់ទ្រង់ នោះមិនជាប់មានទោសទេ តែអ្នកណាដែលមិនជឿវិញ នោះត្រូវមានទោសហើយ ពីព្រោះមិនបានជឿដល់ព្រះនាមនៃព្រះរាជបុត្រាតែ១របស់ព្រះ ។**

ព្រះគម្ពីរយ៉ូហាន ២០:៣១ ចែងថា: **បានចែងទុកតែប៉ុណ្ណោះ ដើម្បីឱ្យអ្នករាល់គ្នាបានជឿថា ព្រះយេស៊ូវជាព្រះគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះពិត ហើយឱ្យអ្នកអ្នករាល់គ្នាបានជីវិតដោយសារព្រះនាមទ្រង់ ដោយមានសេចក្ដីជំនឿ ។**

យើងអាចមានការធានាពេញលេញពីសេចក្ដីសង្គ្រោះរបស់យើង ដោយសារយើងជឿលើព្រះនាមរបស់ទ្រង់ ។

ព្រះគម្ពីរ១យ៉ូហាន ៥:១៣ ចែងថា: **ខ្ញុំបានសរសេរសេចក្ដីទាំងនេះ ផ្ញើមកអ្នករាល់គ្នា ដែលជឿដល់ព្រះនាមព្រះរាជបុត្រានៃព្រះ ដើម្បីឱ្យអ្នករាល់គ្នាបានដឹងថា អ្នករាល់គ្នាមានជីវិតអស់កល្បជានិច្ចហើយ ។**

## សូមក្នុងព្រះនាមព្រះអង្គ

យើងត្រូវបានទទួលការសិក្សា ដើម្បីសូមក្នុងព្រះនាមព្រះយេស៊ូវ ។

ព្រះគម្ពីរយ៉ូហាន ១៤:១២-១៤ ចែងថា: **ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកណាដែលជឿដល់ខ្ញុំ នោះនឹងធ្វើការដែលខ្ញុំធ្វើដែរ ក៏នឹងធ្វើការធំជាងការទាំងនោះទៅទៀត ពីព្រោះខ្ញុំទៅឯព្រះវរបិតា ហើយការអ្វីក៏ដោយ ដែលអ្នករាល់គ្នានឹងសូម ដោយនូវឈ្មោះខ្ញុំ នោះខ្ញុំនឹងសំរេចឱ្យ ដើម្បីឱ្យព្រះវរបិតាបានដំកើងឡើងក្នុងព្រះរាជបុត្រា បើអ្នករាល់គ្នានឹងសូមអ្វីដោយនូវឈ្មោះខ្ញុំ នោះខ្ញុំនឹងសំរេចឱ្យ ។**

ពេលដែលព្រះយេស៊ូវកំពុងយាងចេញទៅឯព្រះវរបិតា ទ្រង់បានសិក្សាពីអ្នកដើរតាមរបស់ទ្រង់ ដើម្បីប្រើព្រះនាមព្រះអង្គ។ ទ្រង់បានមានព្រះបន្ទូលទៅគេថា អ្វីដែលគេត្រូវទូលសូម ទ្រង់នឹងសម្រេចឱ្យ ដើម្បីឱ្យព្រះវរបិតាទ្រង់បានប្រទានសិរីល្អនៅក្នុងព្រះរាជបុត្រា ។

ព្រះគម្ពីរយ៉ូហាន ១៥:១៦ ចែងថា: **មិនមែនអ្នករាល់គ្នាដែលបានរើសខ្ញុំទេ គឺខ្ញុំទេតើដែលរើសអ្នករាល់គ្នាវិញ ទាំងតាំងអ្នករាល់គ្នាឱ្យទៅបង្កើតផល ហើយឱ្យផលរបស់អ្នករាល់គ្នាបាននៅជាប់ផង ដើម្បីឱ្យព្រះវរបិតាបានប្រោសប្រទានឱ្យអ្នករាល់គ្នាបានអ្វីៗ ដែលនឹងសូមពីទ្រង់ដោយនូវឈ្មោះខ្ញុំ ។**

ព្រះគម្ពីរយ៉ូហាន ១៦:២៣-២៤ ចែងថា: **នៅថ្ងៃនោះឯង អ្នករាល់គ្នានឹងមិនសូមអ្វីពីខ្ញុំទៀត ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្វីៗដែលអ្នករាល់គ្នានឹងសូមដល់ព្រះវរបិតា ដោយនូវឈ្មោះខ្ញុំ នោះទ្រង់នឹងប្រទានឱ្យ តាំងពីដើមមក អ្នករាល់គ្នាមិនបានសូមអ្វី ដោយនូវឈ្មោះខ្ញុំឡើយ ឥឡូវ ចូរសូមចុះ នោះអ្នករាល់គ្នានឹងបាន ដើម្បីឱ្យសេចក្ដីអំណររបស់អ្នករាល់គ្នាបានពោរពេញពិត ។**

យើងត្រូវបានសិក្សាដើម្បីសូម នៅក្នុងព្រះនាមព្រះយេស៊ូវ ។

## ធ្វើគ្រប់ការទាំងអស់ដោយនូវព្រះនាមទ្រង់

យើងត្រូវតែធ្វើគ្រប់ការទាំងអស់ដោយនូវព្រះនាមព្រះយេស៊ូវ ។ តើគួរឱ្យអស្ចារ្យអ្វីម្ល៉េះហ្ន៎ ដែលទ្រង់បានប្រទានឯកសិទ្ធិមកយ៉ាងដូច្នេះ!

ព្រះគម្ពីរកូល៉ុស ៣:១៧ ចែងថា: **ហើយក្នុងគ្រប់ការទាំងអស់ ទោះបើការអ្វីដែលអ្នករាល់គ្នានឹងធ្វើ ដោយពាក្យសំដី ឬកិរិយាក៏ដោយ ចូរធ្វើទាំងអស់ ដោយព្រះនាមនៃព្រះអម្ចាស់យេស៊ូវ ទាំងអរព្រះគុណដល់ព្រះដ៏ជាព្រះវរបិតា ដោយសារទ្រង់ផង ។**

យើងគួរគប្បីគិតពិចារណាគ្រប់ការទាំងអស់ដែលយើងធ្វើនោះឱ្យបានសមរម្យ ដើម្បីធ្វើនៅក្នុងព្រះនាមព្រះយេស៊ូវ ។ ដើម្បីធ្វើនូវការនេះបាន យើងត្រូវតែមានការប្រែប្រួលពីផ្លូវជីវិតរបស់យើង ។

## ពួកសាវកបានប្រើព្រះនាមព្រះយេស៊ូវ

ពួកសាវក និងពួកអ្នកជឿដំបូងនៅក្នុងគម្ពីរកិច្ចការ បានប្រើព្រះនាមព្រះយេស៊ូវយ៉ាងក្លាហាន ដោយមានការអស្ចារ្យជាលទ្ធផល ។

### អំណាចក្នុងព្រះនាមទ្រង់

ព្រះគម្ពីរកិច្ចការ ៣:១-១០ ចែងថាៈ **នៅពេលអធិស្ឋាន ជាពេលម៉ោង៣រសៀល នោះពេត្រុស និងយ៉ូហាន ឡើងទៅក្នុងព្រះវិហារជាមួយគ្នា រីឯនៅត្រង់មាត់ទ្វារព្រះវិហារ ដែលហៅថាទ្វារលំអ នោះមានមនុស្សម្នាក់ ដែលខ្វិនពីកំណើត គេតែងសែងកាត់យកមក ដាក់នៅទីនោះរាល់តែថ្ងៃ ដើម្បីឱ្យបានសូមទានចំពោះអស់អ្នកណាដែលចូលទៅក្នុងព្រះវិហារ កាលគាត់ឃើញពេត្រុស និងយ៉ូហាន កំពុងតែដើរចូលទៅក្នុងព្រះវិហារ នោះគាត់សូមទាន តែពេត្រុសព្រមទាំងយ៉ូហាន ក៏សំឡឹងមើលទៅគាត់ ប្រាប់ថា ចូរមើលមកយើងឯណេះ គាត់ក៏ស្តាប់តាមដោយសង្ឃឹមថានឹងបានអ្វីខ្លះ តែពេត្រុសនិយាយថា ឯប្រាក់ ហើយនិងមាស ខ្ញុំគ្មានទេ តែរបស់ដែលខ្ញុំមាន នោះខ្ញុំនឹងជូនដល់អ្នក គឺដោយសារព្រះនាមព្រះយេស៊ូវគ្រីស្ទ ពីស្រុកណាសារ៉ែត ចូរអ្នកក្រោកឡើងដើរទៅចុះ រួចក៏ចាប់ដៃស្តាំលើកគាត់ឡើង ស្រាប់តែប្រអប់ជើង និងកជើងរបស់គាត់ មានកំឡាំងឡើងភ្លាម គាត់ក៏ស្ទុះឈរឡើងដើរទៅមក ហើយចូលទៅក្នុងព្រះវិហារជាមួយនឹងអ្នកទាំង២នោះ ទាំងដើរ ទាំងលោត ទាំងសរសើរដល់ព្រះផង បណ្តាជនទាំងអស់គ្នាក៏ឃើញគាត់ដើរ ទាំងសរសើរព្រះដូច្នោះ ហើយគេស្គាល់គាត់ ថាជាអ្នកដែលតែងតែអង្គុយសូមទានគេ នៅត្រង់មាត់ទ្វារលំអរបស់ព្រះវិហារ នោះគេក៏មានពេញជាសេចក្តីអស្ចារ្យ ហើយមមិងមមាំងពីការដែលកើតមកនោះ ។**

### សេចក្តីជំនឿលើព្រះនាមទ្រង់

លោកសាវកពេត្រុសបានពន្យល់ថា កូនសោរដែលប្រើក្នុងព្រះនាមព្រះយេស៊ូវ ត្រូវតែសម្តែងនូវអំណាចនៃព្រះនាមនោះ ដោយសេចក្តីជំនឿ ។

ព្រះគម្ពីរកិច្ចការ ៣:១២ ចែងថាៈ **កាលពេត្រុសបានឃើញដូច្នោះ នោះគាត់និយាយទៅប្រជាជនថា ឱសាសន៍អ៊ីស្រាអែលរាល់គ្នាអើយ ហេតុអ្វីបានជាមានសេចក្តីប្លែកក្នុងចិត្តពីការនេះ ហើយសំឡឹងមើលមកយើងខ្ញុំ ហាក់ដូចជាយើងខ្ញុំបានធ្វើឱ្យមនុស្សនេះដើររួច ដោយអាងអំណាច ឬគុណានុភាពរបស់ខ្លួនយើងខ្ញុំដូច្នេះ ។**

ព្រះគម្ពីរកិច្ចការ ៣:១៦ ចែងថាៈ **ហើយគឺដោយសារសេចក្តីជំនឿជឿដល់ព្រះនាមទ្រង់ នោះព្រះមានទ្រង់បានប្រោសមនុស្សនេះ ដែលអ្នករាល់គ្នាឃើញហើយស្គាល់ ឱ្យមានកំឡាំងឡើង គឺជាសេចក្តីជំនឿដែលកើតមក ដោយសារព្រះអង្គនោះឯង បានធ្វើឱ្យគាត់ជាស្រឡះ នៅមុខអ្នករាល់គ្នាដូច្នេះ ។**

### ការប្រោសឱ្យជាក្នុងព្រះនាមទ្រង់

លទ្ធផលនៃការប្រោសឱ្យជានេះ លោកសាវកពេត្រុស និងយ៉ូហាន បានត្រូវគេចាប់ចងទៅឃុំទុកនៅក្នុងគុកទាំងពាក់កណ្តាលយប់ ហើយគំរាមកំហែងដោយអ្នកដឹកនាំសាសនា មិនឱ្យ

និយាយអ្វីទៀតពីព្រះនាមព្រះយេស៊ូវឡើយ ។ លោកសាវកពេត្រុសបានឆ្លើយដោយក្លាហាន ទៅកាន់សំណួររបស់ពួកគេអំពីការប្រោសឱ្យជានេះ ដោយមានប្រសាសន៍ថា:

**នោះសូមឱ្យលោករាល់គ្នាជ្រាបដូច្នេះ ហើយឱ្យសាសន៍អ៊ីស្រាអែលទាំងអស់ដឹងផងថា ដែលមនុស្សនេះជាស្រឡះ ហើយឈរនៅមុខលោករាល់គ្នាដូច្នេះ គឺដោយសារព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ពីស្រុកណាសារ៉ែត ដែលលោករាល់គ្នាបានឆ្កាងទ្រង់ តែព្រះបានប្រោសឱ្យមានព្រះជន្មរស់ពីស្លាប់ឡើងវិញ** (កិច្ចការ ៤:១០) ។

## ការសង្គ្រោះក្នុងព្រះនាមទ្រង់

គឺជាលទ្ធផលរបស់លោកសាវកពេត្រុស និងយ៉ូហាន ក្នុងការប្រើព្រះនាមព្រះយេស៊ូវនៅក្នុងការប្រោសមនុស្សពិការឱ្យជា ចំនួនមនុស្សអ្នកជឿបានកើនឡើងប្រហែល៥ពាន់នាក់ ។

ព្រះគម្ពីរកិច្ចការ ៤:៤ ចែងថា: **ប៉ុន្តែ ឯពួកអ្នកដែលឮព្រះបន្ទូល នោះមានគ្នាជាច្រើនបានជឿ ហើយពួកអ្នកដែលជឿ ក៏បានកើនឡើង មានប្រុស១ ប្រហែលជា៥ពាន់នាក់ ។**

សេចក្តីសង្គ្រោះដំបូងរបស់យើង គឺនៅក្នុងអំណាចព្រះនាមព្រះយេស៊ូវ ។

ព្រះគម្ពីរកិច្ចការ ៤:១២ ចែងថា: **ហើយគ្មានសេចក្តីសង្គ្រោះ ដោយសារអ្នកណាទៀតសោះ ដ្បិតនៅក្រោមមេឃ គ្មាននាមឈ្មោះណាទៀត បានប្រទានមកមនុស្សលោក ឱ្យយើងរាល់គ្នាបានសង្គ្រោះនោះឡើយ ។**

## សេចក្តីភ័យខ្លាចរបស់មនុស្សចំពោះព្រះនាមទ្រង់

លោកសាវកពេត្រុស និងយ៉ូហាន ត្រូវបានអ្នកដឹកនាំសាសនាគំរាមកំហែង មិនឱ្យនិយាយដោយនូវព្រះនាមព្រះយេស៊ូវទៀត ។

ព្រះគម្ពីរកិច្ចការ ៤:១៧-១៨ ចែងថា: **ប៉ុន្តែ ចូរយើងកំហែងហាមគេ មិនឱ្យនិយាយនឹងអ្នកណាទៀត ដោយឈ្មោះនោះទៀតឡើយ ដើម្បីកុំឱ្យរឿងនេះផ្សាយទៅក្នុងពួកជនទៀត រួចលោកហៅមកវិញ ហាមផ្តាច់មិនឱ្យនិយាយ ឬបង្រៀន ដោយនូវនាមព្រះយេស៊ូវទៀតឡើយ ។**

## ភាពក្លាហានក្នុងព្រះនាមទ្រង់

រំពេចនោះ វិញ្ញាណនៃសេចក្តីក្លាហានបានមកសណ្ឋិតលើលោកសាវកពេត្រុស និងយ៉ូហាន ។

ព្រះគម្ពីរកិច្ចការ ៤:២៩-៣០ ចែងថា: **ឥឡូវនេះ ឱព្រះអម្ចាស់អើយ សូមទតមើលសេចក្តីដែលកំហែងរបស់គេ ហើយសូមប្រទានឱ្យពួកអ្នកបំរើទ្រង់ បានផ្សាយព្រះបន្ទូល ដោយសេចក្តីក្លាហានដ៏ពេញលេញ ដោយទ្រង់លូកព្រះហស្តមក សំរាប់នឹងប្រោសមនុស្សឱ្យជា ហើយនិងធ្វើទីសំគាល់ និងការអស្ចារ្យ ដោយសារព្រះនាមព្រះយេស៊ូវ ជាអ្នកបំរើបរិសុទ្ធរបស់ទ្រង់ ។**

## លោកភីលីពបានអធិប្បាយដោយនូវព្រះនាមទ្រង់

ព្រះគម្ពីរកិច្ចការ ៨:១២ ចែងថា: **តែកាលមនុស្សទាំងអស់បានជឿតាមភីលីព ដែលគាត់ប្រាប់ដំណឹងល្អពីនគរនៃព្រះ ហើយពីព្រះនាមព្រះយេស៊ូវគ្រីស្ទវិញ នោះគេក៏ទទួលបុណ្យ**

ជ្រមុជទឹកទាំងប្រុសទាំងស្រី ។

**ការចាប់ចងដោយសារព្រះនាមទ្រង់**

លោកប៉ុលត្រូវបានគេជ្រើសរើស ឱ្យទៅចាប់ចងអស់អ្នកដែលអំពាវនាវដល់ព្រះនាមព្រះយេស៊ូវ ។

ព្រះគម្ពីរកិច្ចការ ៩:១៤ ចែងថា: **ហើយនៅទីនេះ គាត់ក៏មានអំណាចពីពួកសង្គ្រាជ អាចនឹងទៅចាប់ចងនូវអស់អ្នកណា ដែលអំពាវនាវដល់ព្រះនាមទ្រង់ដែរ ។**

**ការជ្រើសរើសឱ្យនាំមនុស្សក្នុងព្រះនាមទ្រង់**

លោកសាវកប៉ុលត្រូវបានព្រះទ្រង់ជ្រើសរើសឱ្យនាំមនុស្សទូទាំងពិភពលោក ក្នុងព្រះនាមព្រះយេស៊ូវ ។

ព្រះគម្ពីរកិច្ចការ ៩:១៥ ចែងថា: **ប៉ុន្តែព្រះអម្ចាស់មានបន្ទូលថា ចូរទៅចុះ ពីព្រោះអ្នកនោះជាប្រដាប់រើសតាំងដល់ខ្ញុំ សំរាប់នឹងប្រកាសឈ្មោះខ្ញុំ ដល់ពួកសាសន៍ដទៃ និងពួកស្តេច ហើយនិងពួកកូនចៅសាសន៍អ៊ីស្រាអែលផង ។**

**ចែកចាយដោយគ្មានការភ័យខ្លាចក្នុងព្រះនាម**

ព្រះគម្ពីរកិច្ចការ ៩:២៧ ចែងថា: **តែបាណាបាសនាំគាត់ទៅឯពួកសាវក រ៉ាយរឿងប្រាប់គេ ពីដំណើរដែលគាត់បានឃើញព្រះអម្ចាស់តាមផ្លូវ ហើយទ្រង់បានមានបន្ទូលនឹងគាត់ ក៏និយាយពីបែបយ៉ាងណា ដែលគាត់មានចិត្តក្លាហាននឹងអធិប្បាយ ដោយនូវព្រះនាមព្រះយេស៊ូវ នៅក្រុងដាម៉ាសផង ។**

**ការរំដោះដោយនូវព្រះនាម**

ព្រះគម្ពីរកិច្ចការ ១៦:១៨ ចែងថា: **នាងក៏ធ្វើដូច្នោះជាយូរថ្ងៃ ទាល់តែប៉ុលមានសេចក្តីរំខានចិត្ត ហើយបែរទៅនិយាយនឹងអារក្សនោះថា អញបង្គាប់ឯងដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ ឱ្យឯងចេញពីនាងនេះទៅ វាក៏ចេញទៅនៅវេលានោះឯង ។**

**ការកោតខ្លាចដ៏ខ្ពង់ខ្ពស់ចំពោះព្រះនាមទ្រង់**

ព្រះគម្ពីរកិច្ចការ ១៩:១៧-១៨ ចែងថា: **ឯអស់មនុស្សនៅក្រុងអេភេសូរ ទាំងសាសន៍យូដា និងសាសន៍ក្រេកផង បានដឹងរឿងនោះ ក៏កើតមានចិត្តភ័យខ្លាចទាំងអស់គ្នា ហើយព្រះនាមព្រះអម្ចាស់យេស៊ូវក៏បានថ្កើងឡើង មានមនុស្សជាច្រើនដែលបានជឿ គេមកលន់តួ ព្រមទាំងសំដែងប្រាប់ពីការដែលខ្លួនបានប្រព្រឹត្តផង ។**

## ទីសម្គាល់ និងការអស្ចារ្យដោយនូវព្រះនាមព្រះយេស៊ូវ

ពេលដែលយើងស្តាប់ព្រះ និងស្តាប់បង្គាប់នូវព្រះសូរសៀងព្រះ យើងត្រូវតែឈានជំហ៊ានដោយក្លាហាន និងដោយសេចក្តីជំនឿ ដោយប្រើអំណាចដែលគួរឱ្យភ័យខ្លាចរបស់ព្រះយេស៊ូវ ។ ពេលដែលយើងធ្វើ យើងនឹងមានការពិសោធន៍នូវទីសម្គាល់ និងការអស្ចារ្យ ក្នុងជីវិតរស់នៅ ហើយនិងការបំពេញការងារប្រចាំថ្ងៃរបស់យើង ។

ព្រះគម្ពីរកិច្ចការ ៤:២៩-៣១ ចែងថា: **ឥឡូវនេះ ឱព្រះអម្ចាស់អើយ សូមទតមើលសេចក្តីដែលគំហែងរបស់គេ ហើយសូមប្រទានឱ្យពួកអ្នកបំរើទ្រង់ បានផ្សាយព្រះបន្ទូល ដោយសេចក្តីក្លាហានដ៏ពេញលេញ ដោយទ្រង់លូកព្រះហស្តមក សំរាប់នឹងប្រោសមនុស្សឱ្យជា ហើយនិងធ្វើទីសំគាល់ និងការអស្ចារ្យ ដោយសារព្រះនាមព្រះយេស៊ូវ ជាអ្នកបំរើបរិសុទ្ធរបស់ទ្រង់ កាលបានអធិស្ឋានរួចហើយ នោះកន្លែងដែលគេប្រជុំគ្នាក៏រញ្ជួយ ហើយគេបានពេញជាព្រះវិញ្ញាណបរិសុទ្ធទាំងអស់គ្នា រួចក៏ផ្សាយព្រះបន្ទូលដោយចិត្តក្លាហាន ។**

ពេលដែលយើងបន្តប្រើប្រាស់អំណាច និងអំណាចចេស្តានៃព្រះនាមព្រះយេស៊ូវ យើងក៏នឹងធ្វើឱ្យជីវិតលោកិយរបស់យើងត្រូវរំគោះរង្គើរ ដោយព្រះវត្តមាន និងចេស្តារបស់ព្រះដែលគួរឱ្យភ័យខ្លាច ។

កូនសោរសម្រាប់ជ័យជម្នះនៅក្នុងជីវិតគ្រីស្ទាន គឺត្រូវបានគេរកឃើញនៅក្នុងអំណាចព្រះយេស៊ូវ ។

យើងអាចដើរដោយមានអំណាចដដែលនេះ ដែលបានពណ៌នាទុកមកនៅក្នុងព្រះគម្ពីរកិច្ចការ ពេលដែលយើងចងភ្ជាប់ជាមួយនឹងពួកអ្នកជឿដំបូង ដោយប្រើអំណាចនៃព្រះនាមព្រះយេស៊ូវ ។

## សំណួររំឭកសារឡើងវិញ

១- ចូរឱ្យគំរូពីរយ៉ាងពីក្នុងព្រះគម្ពីរកិច្ចការ ដែលពួកសាវកធ្លាប់បានប្រើព្រះនាមព្រះយេស៊ូវ ។

២- តើមានន័យដូចម្តេច ពេលដែលយើងនិយាយក្នុងព្រះនាមព្រះយេស៊ូវដូចជាមានអំណាចស្នារក្តី ?

៣- នៅក្នុងការប្រឹងប្រែងដូចម្តេចខ្លះ ដែលលោកអ្នកកំពុងប្រឈមមុខឥឡូវនេះ តើលោកអ្នកមានគម្រោងអ្វីខ្លះដើម្បីពិសោធនូវជ័យជម្នះដោយប្រើព្រះនាមព្រះយេស៊ូវ ?

# មេរៀនទី១២
# ជោគជ័យនៅក្នុងសង្គ្រាមខាងវិញ្ញាណ

## ការផ្តត់ផ្គង់ដល់សមរភូមិ

**អំណាចទេវភាព**

ឥឡូវនេះដែលយើងបានយល់ពីការប្រយុទ្ធដ៏អស់កល្ប ព្រមទាំងបានស្គាល់នូវអំណាច និងអាវុធដ៏ពេញដោយចេស្តារបស់យើងហើយ យើងត្រូវតែមានឧបករណ៍ សម្រាប់អំណាចជ័យជម្នះ ព្រមទាំងការឈ្នះនៅក្នុងសង្គ្រាម ។

លោកសាវកប៉ុលបានសរសេរថា:

**ព្រោះគ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមរបស់យើង ខ្ញុំ មិនមែនជារបស់ខាងសាច់ឈាមទេ គឺជាឥទ្ធិឫទ្ធិដែលមកពីព្រះ សំរាប់នឹងរំលំទីមាំមួនវិញ** (២កូរិនថូស ១០:៤) **។**

មានមនុស្សជាច្រើនបានព្យាយាមចូលទៅក្នុងសង្គ្រាម ដោយគ្មានការបើកសម្តែង ។ ពួកគេមិនបានយល់នូវអំណាច ដែលពួកគេមាននៅក្នុងព្រះយេស៊ូវនោះទេ ។

កាលណាសង្គ្រាមខាងវិញ្ញាណបានត្រឡប់ជាមានពេញដោយកម្លាំង ដែលពួកវាបានឈរមាំមួន គឺជាពួកខ្មាំងសត្រូវដែលមានពេញដោយអំណាចជាមិនខាន ។ ពួកវាបានចូលមកកាន់កាប់ មានទាំងវិញ្ញាណអាក្រក់ និងវិញ្ញាណអសោចិ៍របស់វាហើយនោះ ពួកវានឹងមានការប្រុងប្រយ័ត្នបន្ថែមទៀត ដោយមានវិញ្ញាណអាក្រក់ និងវិញ្ញាណអសោចិ៍របស់វា តាំងនៅកាន់តែធំឡើងៗ ដែលមើលទៅហាក់ដូចជាពួកវាមានអំណាចកាន់តែខ្លាំងឡើង ។

**ការធ្វើឱ្យខ្មាំងសត្រូវបរាជ័យ**

លោកហោរាអេសាយបានថែងពីអនាគតរបស់សាតាំង ដោយបានផ្តល់នូវរូបភាពយ៉ាងច្បាស់លាស់ពីអំពើរបស់វាថា:

**តែឯងបានត្រូវទំលាក់ចុះដល់ស្ថានឃុំព្រលឹងមនុស្សស្លាប់វិញ គឺដល់ទីជំរៅនៃជង្ហុកធំ ពួកអ្នកដែលឃើញឯង គេនឹងសំឡឹងមើលចំឯង ហើយពិចារណាឯងដោយពាក្យថា តើមនុស្សនេះឬអី ដែលធ្លាប់ធ្វើឱ្យផែនដីញាប់ញ័រ ហើយឱ្យនគរទាំងប៉ុន្មានកក្រើករំពើកនោះ ជាអ្នកដែលបានធ្វើឱ្យលោកីយរលីងដូចជាសមុទ្រខ្សាច់ ព្រមទាំងបំផ្លាញទីក្រុងទាំងប៉ុន្មាន ឥតដែលលែងពួកឈ្លើយឱ្យត្រឡប់ទៅឯផ្ទះគេវិញឡើយ** (អេសាយ ១៤:១៥-១៧) **។**

មនុស្សនឹងសម្លឹងមើលទៅឯអាមួយនោះ ដែលគេហៅថាសាតាំង ដែលត្រូវបរាជ័យ និងទទួលការបាក់មុខ ដោយគ្មានភាពសង្ឃឹម ។ ពួកគេនឹងមើលទៅអានួយនោះដោយភ្ញាក់ផ្អើល ដោយគិតថាវាធំសម្បើម ហើយមានអំណាចផង ។ ពួកគេនឹងមើលឃើញវាក្រាបចុះទៅក្នុងភាពអាម៉ាសមុខ ។ ពួកគេនឹងសួរថា "នេះគឺជាអ្នកនោះឬ . . .?" "នេះគឺជាមនុស្សដែលគ្រប់គ្នាបានធ្វើឱ្យការទាក់ទងត្រូវកន្លងផុតទៅឬអី?"

ពួកគេនឹងសម្លឹងមើលទៅឯអាមួយនោះ ដែលត្រូវបានបំបោះបង់ទៅកាន់ទីសូន្យសុង ។ ពួកគេនឹងក្រឡេកមើលទៅវាដោយគ្មានអ្នករាប់រក ។ ពួកគេនឹងមើលទៅវាដែលមានការបរាជ័យគ្រប់ទាំងអស់ ។

ពេលដែលយើងមានការបើកសម្តែង ចំពោះអ្នកដែលយើងឃើញនៅក្នុងព្រះយេស៊ូវ យើងនឹងមិនត្រូវបានខ្វល់ព្រួយថា អ្នកនោះនៅមានវិញ្ញាណអាក្រក់យូរអង្វែងតទៅទៀតឡើយ ។ យើងនៅតែបន្តការកាន់កាប់ដោយមានព្រះយេស៊ូវដដែល!

វិញ្ញាណអាក្រក់ គឺជាខ្មាំងសត្រូវដែលបរាជ័យ ។ អំណាចរបស់វាត្រូវបានបំផ្លាញអស់ហើយ ។ ព្រះយេស៊ូវទ្រង់បានធ្វើវាឱ្យក្លាយទៅជា "ចំណុចសូន្យ" ។ វាត្រូវបានធ្វើឱ្យចុះចាញ់ ឱ្យគ្មានលទ្ធភាព ព្រមទាំងបានហាលមុខវាទៀតផង ។

**ការនាំនៅកាន់ចំណុចសូន្យ**

ព្រះគម្ពីរហេព្រើរ ២:១៤ខ ចែងថា: **នោះទ្រង់ក៏ទទួលចំណែកជាសាច់ឈាមដូច្នេះដែរ ដើម្បីឱ្យទ្រង់បានបំផ្លាញអានោះ ដែលមានអំណាចលើសេចក្តីស្លាប់ គឺជាអារក្ស ដោយទ្រង់សុគត ។**

យើងមិនត្រូវបានខូចប្រយោជន៍ក្នុងការទាក់ទងអារក្ស ព្រមទាំងពួកវិញ្ញាណអសោចិ៍របស់វានោះឡើយ ។ យើងបានត្រូវប្រទាននូវអំណាច លើគ្រប់ទាំងអំណាចរបស់ខ្មាំងសត្រូវហើយ ។

ពេលដែលយើងចូលទៅក្នុងទីសង្គ្រាម វាត្រូវតែចេញពីកន្លែងដែលត្រូវបានធានាដោយទុកចិត្ត ព្រមទាំងជឿជាក់ថា យើងនឹងមានជ័យជម្នះ ។ យើងត្រូវតែចូលទៅក្នុងទីសង្គ្រាម ពីកន្លែងនៃចំណេះចេះស្ទាត់របស់អស់អ្នកដែលនៅក្នុងព្រះគ្រីស្ទ ។ យើងមិនត្រូវដាក់ផែនការ ទៅលើការព្យាយាមតស៊ូយ៉ាងខ្លាំងក្លា ជាមួយនឹងខ្មាំងសត្រូវដែលមានអំណាចនោះឡើយ ។ ជំនួសឱ្យការនេះ យើងត្រូវតែទន្ទឹងរង់ចាំនូវជ័យជម្នះដែលពេញដោយអំណរ ពេលដែលយើងសម្តែងដោយពិតត្រង់ថា អារក្សគឺត្រូវបានទទួលការបរាជ័យហើយ ។

- ⇨ អារក្សវាគ្មាន "ភាគចំណែកធំទេ"
- ⇨ ព្រះយេស៊ូវទ្រង់មាន "ភាគចំណែកធំ"
- ⇨ យើងក៏អាចធ្វើគ្រប់ការទាំងអស់ តាមរយៈទ្រង់ដែរ!

ព្រះគម្ពីរភីលីព ៤:១៣ ចែងថា: **ខ្ញុំអាចនឹងធ្វើគ្រប់ការទាំងអស់បាន ដោយសារព្រះគ្រីស្ទដែលទ្រង់ចំរើនកំឡាំងដល់ខ្ញុំ ។**

**ជំហ៊ាននៅកាន់ជ័យជម្នះ**

ចេស្តា និងអំណាចរបស់អ្នកជឿ គឺមិនមែនជា "តុក្កា" ដើម្បីសម្រេចនូវការសម្រេចចិត្តខាងផ្នែកសាច់ឈាមរបស់យើងនោះទេ ។ យើងត្រូវតែមានការស៊ីសង្វាក់ដ៏ពេញលេញ ដោយបំណងព្រះហឫទ័យរបស់ព្រះ ។

**ការសារភាពបាប**

ប្រសិនបើយើងត្រូវតែមានជ័យជម្នះ នៅក្នុងសង្គ្រាមខាងវិញ្ញាណរបស់យើង នោះជាដំបូងយើងត្រូវតែប្រែចិត្ត ហើយលន់តួនូវអំពើបាបទាំងឡាយរបស់យើងចំពោះព្រះ ព្រមទាំងទទួលនូវការអត់របស់ព្រះអង្គ ។ លោកសាវកយ៉ូហានបានប្រាប់យើងនូវរបៀបធ្វើយ៉ាងដូច្នេះថាៈ

**បើយើងលន់តួទោសវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបឱ្យយើង ហើយនិងសំអាតយើង ពីគ្រប់អំពើទុច្ចរិតទាំងអស់ផង** (១យ៉ូហាន ១:៩) ។

**ការចុះចូល**

យើងត្រូវតែថ្វាយជីវិតរបស់យើង មួយរយភាគរយទៅព្រះយេស៊ូវដ៏ជាព្រះអម្ចាស់នៃជីវិតរបស់យើង ។

ព្រះគម្ពីររ៉ូម ១២:១-២ ចែងថាៈ **ដូច្នេះ បងប្អូនអើយ ខ្ញុំទូន្មានអ្នករាល់គ្នា ដោយសេចក្តីមេត្តាករុណានៃព្រះ ឱ្យបានថ្វាយរូបកាយទុកជាយញ្ញបូជារស់ ហើយបរិសុទ្ធ ដែលគាប់ព្រះហឫទ័យដល់ព្រះ ជាការគោរពនៃអ្នករាល់គ្នា ដែលមានទំនង កុំឱ្យត្រាប់តាមសម័យនេះឡើយ ចូរឱ្យអ្នករាល់គ្នាបានផ្លាស់ប្រែវិញ ដោយគំនិតបានកែជាថ្មីឡើង ដើម្បីនឹងអាចលមើលឱ្យបានស្គាល់បំណងព្រះហឫទ័យនៃព្រះ ដែលល្អ ស្រួលទទួល ហើយគ្រប់លក្ខណ៍ផង ។**

**ការបែរចេញពីលោកិយ**

យើងត្រូវតែបែរចេញពីខ្លួនយើង ពីការចូលរួមជាមួយនឹងការក្នុងលោកិយនេះ ។

ព្រះគម្ពីរ២ធីម៉ូថេ ២:៤ ចែងថាៈ **ធម្មតាអ្នកដែលធ្វើទាហាន នោះមិនដែលជាប់ទាក់ទិននឹងការក្នុងជីវិតនេះទៀតទេ គឺដើម្បីឱ្យបានគាប់ចិត្តដល់ចៅហ្វាយ ដែលកេណ្ឌខ្លួនទៅនោះវិញ ។**

**ត្រូវទុកការសម្រេចចិត្តរបស់យើងទៅម្ខាង**

យើងត្រូវតែទុកដាក់សេចក្តីសម្រេចចិត្តផ្ទាល់ខ្លួនរបស់យើង ហើយអនុញ្ញាតឱ្យព្រះវិញ្ញាណនៃព្រះទ្រង់ដឹកនាំយើងវិញ ។ យើងត្រូវតែនិយាយដូចព្រះយេស៊ូវថា "ខ្ញុំធ្វើអ្វីដែលខ្ញុំឃើញព្រះវរបិតាខ្ញុំទ្រង់ធ្វើ" ។

ព្រះគម្ពីរយ៉ូហាន ៥:១៩ ចែងថាៈ **ដូច្នេះ ព្រះយេស៊ូវ ទ្រង់មានបន្ទូលឆ្លើយទៅគេថា ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា ព្រះរាជបុត្រាពុំអាចនឹងធ្វើការអ្វី ដោយព្រះអង្គទ្រង់ទេ ធ្វើបានតែការអ្វីដែលឃើញព្រះវរបិតាធ្វើ ដ្បិតការអ្វីដែលព្រះវរបិតាធ្វើ នោះព្រះរាជបុត្រាក៏ធ្វើដូច្នោះដែរ ។**

ព្រះទ្រង់បានប្រទានដល់អ្នកជឿគ្រប់គ្នា នូវនគរនៃអំណាចគ្រប់គ្រងដ៏ពិតប្រាកដលើៈ

- ⇨ អាពាហ៍ពិពាហ៍របស់ពួកគេ គឺជាកូនចៅ និងជាគ្រួសារ
- ⇨ កន្លែងដែលពួកគេរស់នៅ - មានអ្នកជិតខាង ទីក្រុង ប្រជាជាតិ
- ⇨ កន្លែងដែលពួកគេត្រូវបានព្រះបញ្ជូនទៅបំពេញការងារ

ជានិច្ចកាលយើងនឹងមិនត្រូវបានបោះបង់ នៅក្នុងវិញ្ញាណរបស់យើង ដើម្បីឱ្យចូលទៅក្នុងសង្គ្រាមដែលមានកម្លាំងគ្រប់គ្រងរបស់អារក្ស នៅខាងក្រៅតំបន់នគរនៃអំណាចដែលព្រះទ្រង់បានប្រទានឱ្យយើងនោះឡើយ ។ ព្រះទ្រង់សព្វព្រះហឫទ័យចង់ឱ្យពួកអ្នកជឿនៅក្នុងដំបន់នោះ ដើម្បីរៀនពីអំណាចរបស់គេ ព្រមទាំងរុញច្រានភាពខ្លាំងនោះ ។

**មានឥរិយាបទនៃក្ដីស្រឡាញ់**

ទាំងប្រុសទាំងស្រីក្នុងសេចក្ដីជំនឿ គឺជាទាហ៊ានរបស់ព្រះ យើងមិនត្រូវក្លាយមកជាទាហ៊ានដែលមានសេចក្ដីអំណួត និងយង់ឃ្នង់ នៅក្នុងឥរិយាបទរបស់យើង ចំពោះអ្នកដទៃនោះឡើយ ។

ព្រះគម្ពីរភីលេម៉ូន ១.៤-៥ ចែងថា: **ខ្ញុំអរព្រះគុណដល់ព្រះនៃខ្ញុំ ទាំងដំណាលពីអ្នករាល់គ្នាជានិច្ច ក្នុងកាលដែលខ្ញុំអធិស្ឋានផង ដោយបានឮនិយាយពីសេចក្ដីស្រឡាញ់ និងសេចក្ដីជំនឿដែលអ្នកមានដល់ព្រះអម្ចាស់យេស៊ូវ ហើយដល់ពួកបរិសុទ្ធទាំងអស់គ្នាដែរ ។**

យើងត្រូវតែតស៊ូជាមួយអារក្ស និងវិញ្ញាណអសោចិ៍ តែយើងត្រូវតែបន្តដើរក្នុងសេចក្ដីស្រឡាញ់ ចំពោះមនុស្សដទៃទៀត ។ យើងស្អប់អារក្ស តែយើងស្រឡាញ់ដល់មនុស្ស ។

យើងត្រូវតែចងចាំជានិច្ចថា អំណាចរបស់យើងដែលជាអ្នកជឿ មិនមែនយកមកគ្រប់គ្រងលើមនុស្សទេ គឺយកមកគ្រប់គ្រងលើអារក្ស និងវិញ្ញាណអសោចិ៍របស់វាវិញ ។

ពេលដែលយើងដើរនៅក្នុងសេចក្ដីស្រឡាញ់ចំពោះព្រះ ព្រមទាំងមនុស្សដទៃទៀត យើងមិនត្រូវបន្តនូវការធ្វើសង្គ្រាមជាមួយនឹងអារក្សទេ ។

**គ្មានការសម្រុះសម្រួល**

ពេលដែលយើងដើរនៅក្នុងការប្រកបទាក់ទងដ៏ជិតស្និតជាមួយនឹងព្រះ មិនត្រូវមានការលាយលំ និងការសម្រុះសម្រួលទៅលើអំពើបាប ឬភាពជាលោកិយ នៅក្នុងជីវិតរបស់យើងឡើយ ។ ព្រះទ្រង់សព្វព្រះហឫទ័យដាស់តឿនក្រើនរំឭកដល់យើង នូវយុទ្ធសាស្ត្ររបស់សាតាំងពីការធ្វើឱ្យបរាជ័យរបស់យើង ដោយការបំពេញភារកិច្ចនូវអំណោចទានជាភាពវៃឆ្លាតខាងឯវិញ្ញាណ ។

យើងកាន់តែចូលជិតព្រះកាលណា យើងនឹងត្រូវតែជួបប្រទះនូវវត្តមានរបស់អារក្ស ការខកចិត្ត ការសម្រុះសម្រួលជាមួយវា ឬក៏ការលាយលំជាមួយវា ចូលមកកាលនោះដែរ ។

យើងត្រូវតែថែរក្សានូវភ្នែកទាំងគូររបស់យើង ហើយសម្លឹងមើលទៅឯព្រះយេស៊ូវជានិច្ច ។ ប្រសិនបើសាតាំង ឬវិញ្ញាណអសោចិ៍របស់វាចាប់យកផ្លូវ ហើយយើងទាក់ទងជាមួយពួកវា តទល់ជាមួយនឹងពួកវា នោះយើងត្រូវតែបណ្ដេញពួកវាចេញ បណ្ដេញគំនិត និងបណ្ដេញគំនិតរវើរវាយ ដែលមិនមែនមកពីព្រះនោះចេញ ។ បន្ទាប់មកយើងត្រូវតែបែរភ្នែករបស់ផងយើងចេញពីពួកវា ទៅរកព្រះយេស៊ូវវិញ គឺយើងត្រូវតែសរសើរតម្កើងព្រះអង្គ ដើម្បីឱ្យមានជ័យជម្នះ ។

ព្រះគម្ពីរ ២កូរិនថូស ២:១៤ ចែងថា: **តែអរព្រះគុណដល់ព្រះអង្គ ដែលទ្រង់ចេះតែនាំយើងខ្ញុំ ឱ្យមានជ័យជំនះក្នុងព្រះគ្រីស្ទ ហើយក៏ផ្សាយក្លិនពីដំណើរដែលយើងខ្ញុំស្គាល់ព្រះ ឱ្យបានសុសសាយទូទៅគ្រប់កន្លែងផង ។**

**គ្មានឯកទេសខាងវិញ្ញាណ**

នៅក្នុងនគររបស់ព្រះ ទ្រង់គ្មានផែនការដែលធ្វើឱ្យមានសង្គ្រាម និងការរំដោះឱ្យបានសម្រេច ដោយការត្រាស់ហៅ ឬក៏ចូលទៅក្នុងឯកទេស "អ្នកបណ្ដេញវិញ្ញាណអសោចិ៍ដែលមានអំណាចដ៏ខ្ពស់បំផុត" នោះឡើយ ។ ជំនួសនូវការនេះ លោកសាវកយ៉ាកុបបានចែងថា អ្នកជឿគ្រប់គ្នា គឺត្រូវតែតទល់នឹងអារក្ស ។

ព្រះគម្ពីរយ៉ាកុប ៤:៧ ចែងថា: **ដូច្នេះ ត្រូវចុះចូលចំពោះព្រះ ហើយតស៊ូនឹងអារក្សវិញចុះ នោះវានឹងរត់ចេញពីអ្នករាល់គ្នាទៅ ។**

**គ្រឿងសឹករបស់ព្រះ**

ព្រះទ្រង់បានឱ្យយើងនូវគ្រឿងសឹកសម្រាប់ប្រយុទ្ធនៅក្នុងសមរភូមិ ។ លោកសាវកប៉ុលមិនបានសរសេរថា យើងត្រូវតែពាក់គ្រឿងសឹករបស់យើងនោះទេ គឺគាត់បានសរសេរថា យើងត្រូវតែពាក់គ្រឿងសឹករបស់ព្រះវិញ ។

អ្នកជិះសេះនៅមជ្ឈិមសម័យ បានពាក់គ្រឿងសឹករបស់គេ ព្រមទាំងមួកសឹក និងពាក់ក្បាំងមុខគ្របលើមុខរបស់គេ ពួកគេមើលទៅដូចជាពេញដោយអំណាច មាឌធំ ជាអ្នកធ្វើសង្គ្រាមដ៏គួរឱ្យគ្រោះថ្នាក់ចំពោះខ្មាំងសត្រូវ ។ ការការពាររយៈខ្លីលើខ្លួនរបស់ពួកគេ នៅផ្នែកខាងក្នុងនៃគ្រឿងសឹកនោះ ពួកគេមើលទៅហាក់ដូចជាអ្នកធ្វើសង្គ្រាមដ៏មានអំណាច ។

ពេលដែលយើងពាក់គ្រឿងសឹករបស់ព្រះ យើងត្រូវបានមើលទៅហាក់ដូចជាព្រះចំពោះអារក្ស ។ យើងទាំងអស់គ្នាត្រូវតែឈ្នះសង្គ្រាម គឺជាការនិយាយ ការដើរ និងសកម្មភាពរបស់យើងដូចជាព្រះ!

**អំណាចរបស់យើងរាល់គ្នា**

យើងត្រូវតែបំពេញការងារនៅក្នុងអំណាចចេស្ដារបស់ព្រះ គឺយើងត្រូវតែចូលទៅក្នុងសមរភូមិ ដោយពេញកម្លាំង ។

ព្រះគម្ពីរអេភេសូរ ៦:១០-១១ ចែងថា: **ឯសេចក្តីឯទៀត បងប្អូនអើយ ចូរឱ្យមានកំឡាំងឡើងក្នុងព្រះអម្ចាស់ ដោយឫទ្ធិបារមីរបស់ព្រះចេស្ដាទ្រង់ ចូរពាក់គ្រប់គ្រឿងសឹករបស់ព្រះ ដើម្បីអាចនឹងឈរមាំមួន ទាស់នឹងឧបាយកលទាំងអម្បាលម៉ានរបស់អារក្ស ។**

**ការតយុទ្ធរបស់យើង**

ខ.១២ ចែងថា: **ដ្បិតយើងរាល់គ្នាមិនមែនតយុទ្ធនឹងសាច់ឈាមទេ គឺនឹងពួកគ្រប់គ្រង ពួកមានអំណាច និងពួកម្ចាស់នៃសេចក្តីងងឹតនៅលោកិយនេះវិញ ហើយទាស់នឹងអំណាចអាក្រក់ខាងវិញ្ញាណ នៅស្ថានដ៏ខ្ពស់ដែរ ។**

លោកសាវកប៉ុលរំឭកយើងថា ការតយុទ្ធរបស់យើងមិនមែនតយុទ្ធជាមួយសាច់ និងឈាមទេ គឺតយុទ្ធនឹងពួកគ្រប់គ្រង ពួកមានអំណាច និងវិញ្ញាណដ៏មានកម្លាំងរបស់អារក្សវិញ ។ កាតតយុទ្ធរបស់យើងគឺមិនមែននៅតំបន់ផែនដីនេះទេ គឺនៅឯនគរខាងឯវិញ្ញាណវិញ ។

**គ្រឿងសឹករបស់យើង**

- ⇨ ខ្សែក្រវាត់នៃសេចក្តីពិត
- ⇨ ប្រដាប់បាំងដើមទ្រូងនៃសេចក្តីសុចរិត
- ⇨ ពាក់ស្បែកជើងនៃដំណឹងល្អ

ខ.១៣-១៥ ចែងថា: **ហេតុនោះបានជាត្រូវឱ្យយកគ្រប់គ្រឿងសឹករបស់ព្រះ ដើម្បីឱ្យអ្នករាល់គ្នាអាចនឹងទប់ទល់ក្នុងថ្ងៃអាក្រក់បាន រួចកាលណាបានតតាំងសព្វគ្រប់ហើយ នោះឱ្យបាននៅតែឈរមាំមួនដដែល ដូច្នេះ ចូរឈរឱ្យមាំមួនចុះ ដោយក្រវាត់សេចក្តីពិតនៅចង្កេះ ហើយពាក់សេចក្តីសុចរិតទុកជាប្រដាប់បាំងដើមទ្រូង ទាំងពាក់សេចក្តីប្រុងប្រៀបរបស់ដំណឹងល្អនៃសេចក្តីសុខសាន្ត ទុកជាស្បែកជើង ។**

លោកសាវកប៉ុលបាននិយាយពាក្យ"ឈរ"នេះ ចំនួន៣ដង ។ ទីមួយគាត់បាននិយាយថា ថ្ងៃរបស់អារក្សមកដល់ យើងត្រូវតែមានលទ្ធភាពឈរនៅលើដីរបស់យើង ។ ចំណុចបន្ទាប់គាត់បាននិយាយថា បន្ទាប់ពីយើងបានធ្វើគ្រប់ការទាំងអស់ហើយ យើងត្រូវតែឈរឱ្យបានមាំមួន ។ ចំណុចចុងក្រោយ គាត់ក៏បាននិយាយថា ដូច្នេះ ចូរឈរឱ្យមាំមួន ដោយក្រវាត់សេចក្តីពិតនៅចង្កេះ ហើយពាក់សេចក្តីប្រុងប្រៀបរបស់ដំណឹងល្អនៃសេចក្តីសុខសាន្ត ទុកជាស្បែកជើង ។

សេចក្តីពិតគឺជាព្រះបន្ទូលរបស់ព្រះ ដើម្បីឱ្យយើងមានការការពារ យើងត្រូវតែដឹងនូវអ្វីដែលព្រះបន្ទូលបានចែងមក ។

ការក្រវាត់សេចក្តីពិតនៅនឹងចង្កេះ គឺជាសេចក្តីពិតរបស់ព្រះ ។ យើងមិនត្រូវគិតថា យើងបានគ្រប់លក្ខណ៍នោះទេ គឺយើងត្រូវគិតថា យើងមិនបានស្គាល់អំពើបាបនៅក្នុងជីវិតរបស់យើងនោះទេ ដោយយើងបានក្រវាត់សេចក្តីពិតនៅនឹងចង្កេះ ។

យើងត្រូវតែពាក់សេចក្តីប្រុងប្រៀបរបស់ដំណឹងល្អនៃសេចក្តីសុខសាន្ត ទុកជាស្បែកជើង។ ការត្រៀមខ្លួនគឺជាផ្នែករបស់យើង ហើយដែលយើងបានធ្វើសម្រេច ដោយសារការសិក្សាព្រះបន្ទូលនៃព្រះ ។

លោកសាវកប៉ុលបានសរសេរទៅកាន់លោកធីម៉ូថេថា:

**ចូរខំប្រឹងនឹងថ្វាយខ្លួនដល់ព្រះ ទុកជាមនុស្សដែលបានល្បងលជាប់ហើយ ជាអ្នកធ្វើការដែលមិនត្រូវខ្មាសឡើយ ដោយកាត់ស្រាយព្រះបន្ទូលនៃ សេចក្តីពិតយ៉ាងត្រឹមត្រូវ** (២ធីម៉ូថេ ២:១៥) **។**

- ⇨ ខែលនៃសេចក្តីជំនឿ
- ⇨ មួកសឹកនៃសេចក្តីសង្គ្រោះ
- ⇨ ដាវនៃព្រះវិញ្ញាណ

ព្រះគម្ពីរអេភេសូរ ៦:១៦-១៧ ចែងថា: **ថែមទាំងយកសេចក្តីជំនឿទុកជាខែលផង ដែលអ្នករាល់គ្នានឹងអាចរំលត់ អស់ទាំងព្រួញឆេះរបស់មេកំណាច ដោយសារខែលនោះបាន ចូរយកសេចក្តីសង្គ្រោះទុកជាមួកសឹក និងដាវរបស់ព្រះវិញ្ញាណដែរ គឺជាព្រះបន្ទូល ។**

យើងត្រូវតែប្រើប្រាស់ខែលនៃសេចក្តីជំនឿ ដើម្បីរំលត់អស់ទាំងព្រួញឆេះរបស់មេកំណាច ។ ព្រួញឆេះគឺជាគំនិត សេចក្តីល្បួង ជំងឺរោគា ព្រមទាំងយុទ្ធសាស្ត្រដទៃទៀត ដែលសាតាំងតម្រង់សំដៅមកយើង ។ យើងត្រូវតែរំលត់ពួកវាដោយសេចក្តីជំនឿលើព្រះ និងលើព្រះបន្ទូលរបស់ទ្រង់ ។

មួកសឹកនៃសេចក្តីសង្គ្រោះ គឺយើងត្រូវតែពាក់នៅពេលយើងទទួលបាននូវសេចក្តីសង្គ្រោះ ។ នេះគឺជាសេចក្តីសង្គ្រោះដែលមិនត្រឹមតែតាំងនៅដ៏អស់កល្បជាមួយយើងប៉ុណ្ណោះទេ គឺបានកែយើងជាថ្មីឡើងវិញ ដើម្បីឱ្យគ្រប់ទាំងអស់ដែលយើងត្រូវបានបង្កើតមក មានរូបភាពដូចរបស់ព្រះ ។ មួកសឹកនៃសេចក្តីសង្គ្រោះបានធ្វើឱ្យយើងមានគំនិតថ្មី ដែលពេញដោយការបើកសម្តែងនៃសេចក្តីសង្គ្រោះ ។

ព្រះគម្ពីររ៉ូម ១២:២ក ចែងថា: **កុំឱ្យត្រាប់តាមសម័យនេះឡើយ ចូរឱ្យអ្នករាល់គ្នាបានផ្លាស់ប្រែវិញ ដោយគំនិតបានកែជាថ្មីឡើង ។**

ការកែគំនិតជាថ្មី បានមកដោយការលាងសម្អាតចិត្តគំនិតរបស់យើងរាល់គ្នា ដោយសារ "ទឹក"រស់ នៃព្រះបន្ទូលព្រះដែលយើងបានអាន សិក្សា និងបានពិចារណាលម្អិត ។

ព្រះគម្ពីរអេភេសូរ ៥:២៦ ចែងថា: **ដើម្បីឱ្យទ្រង់បានញែកពួកជំនុំចេញជាបរិសុទ្ធ ដោយបានលាងសំអាតនឹងទឹក គឺជាព្រះបន្ទូល ។**

យើងត្រូវបានប្រទាន់ឱ្យនូវអាវុធសម្រាប់វាយប្រហារ ព្រមទាំងដាវរបស់ព្រះវិញ្ញាណ គឺជាព្រះបន្ទូលព្រះ ។ លោកសាវកប៉ុលប្រាប់យើងបន្តទៅទៀតអំពីដាវរបស់ព្រះវិញ្ញាណ នៅក្នុងព្រះគម្ពីរហេព្រើរ:

**ពីព្រោះ ឯព្រះបន្ទូលនៃព្រះ នោះរស់នៅ ហើយពូកែផង ក៏មុតជាងដាវណាមានមុខ២ ទាំងធ្លុះចូលទៅ ទាល់តែកាត់ព្រលឹងនិងវិញ្ញាណ ហើយសន្លាក់ និងខួរឆ្អឹងដាច់ពីគ្នា ទាំងពិចារណាអស់ទាំងគំនិតដែលចិត្តគិត ហើយដែលសំរេចដែរ** (ហេព្រើរ ៤:១២) **។**

ព្រះបន្ទូលនៃព្រះគឺជាខ្សែក្រវ៉ាត់នៃសេចក្តីពិត គឺជាការគ្របបាំងសម្រាប់ជើង និងដាវរបស់យើង! តើមានចម្ងល់ដែរឬទេ អំពីសេចក្តីសំខាន់នៃការសិក្សាព្រះបន្ទូលព្រះ?

## សេចក្តីអធិស្ឋានដែលមានជ័យជម្នះ

ដោយនូវសេចក្តីជំនឿ ចូរពាក់គ្រប់គ្រឿងសឹករបស់ព្រះមួយដងជាសម្រេច គឺយើងត្រូវតែអធិស្ឋានដោយនូវព្រះវិញ្ញាណ គ្រប់កាលៈទេសៈទាំងអស់ ។

ព្រះគម្ពីរអេភេសូរ ៦:១៨ ចែងថា: **ព្រមទាំងប្រើសេចក្តីអធិស្ឋាន និងសេចក្តីទូលអង្វរគ្រប់យ៉ាង ដើម្បីអធិស្ឋាន ដោយព្រះវិញ្ញាណរាល់ពេលរាល់វេលា ហើយចាំយាមក្នុងសេចក្តីនោះឯង ដោយនូវគ្រប់ទាំងសេចក្តីខ្ជាប់ខ្ជួន និងសេចក្តីទូលអង្វរឱ្យពួកបរិសុទ្ធទាំងអស់ ។**

យើងនៅតែអធិស្ឋានដោយសេចក្តីជំនឿ សម្រាប់គ្រប់ទាំងមនុស្សសន្តិភាព ដោយប្រើនូវអំណាចដែលបានកែជាថ្មីឡើងវិញរបស់យើង នោះយើងនឹងឃើញនូវកម្លាំងរបស់សាតាំង ត្រូវធ្លាក់ចុះ ។ យើងនឹងត្រឡប់មកជាអ្នកក្លាហាននៅក្នុងសមរភូមិ ព្រមទាំងក្លាយមកជាទាហ៊ានដែលធ្វើឱ្យកម្លាំងរបស់សាតាំងត្រូវថយចុះ ។

ព្រះគម្ពីរហេព្រើរ ១១:៣៣-៣៤ចែងថា: **ដែលដោយសារសេចក្តីជំនឿ នោះគេបានឈ្នះនគរដទៃ បានសំរេចការសុចរិត បានទទួលសេចក្តីសន្យា បានបិទមាត់សិង្ហ បានពន្លត់អំណាចភ្លើង បានរួចពីមុខដាវ បានមានកំឡាំងក្នុងកាលដែលកំពុងតែខ្សោយ ក៏ត្រឡប់ជាពូកែក្នុងចំបាំង ទាំងកំចាត់ពលទ័ពសាសន៍ដទៃផង ។**

## សម្ភារៈសម្រាប់ធ្វើការខារ

ព្រះយេស៊ូវទ្រង់មានបន្ទូលថា យើងត្រូវតែចូលទៅគ្រប់លោកិយទាំងមូល ព្រមទាំងផ្សាយដំណឹងល្អ ។

ព្រះគម្ពីរម៉ាកុស ១៦:១៥ ចែងថា: **ទ្រង់ផ្តាំគេថា ចូរអ្នករាល់គ្នាទៅពេញសព្វ ក្នុងលោកិយទាំងមូល ហើយផ្សាយដំណឹងល្អទូទៅដល់គ្រប់មនុស្សទាំងអស់ចុះ ។**

ហោរាអេសាយបានប្រាប់យើងអំពីអស់អ្នកណាដែលនាំដំណឹងល្អ ។

ព្រះគម្ពីរអេសាយ ៥២:៧ ចែងថា: **អើ ល្អណាស់ហ្ន៎ គឺជើងនៃអ្នកនោះដែលដើរលើភ្នំ ជាអ្នកដែលនាំដំណឹងល្អមក ហើយប្រកាសប្រាប់ពីសេចក្តីមេត្រី ជាអ្នកដែលនាំដំណឹងល្អពីការប្រសើរមក ហើយថ្លែងប្រាប់ពីសេចក្តីសង្គ្រោះ គឺជាអ្នកដែលពោលដល់ក្រុងស៊ីយ៉ូនថា ព្រះនៃឯងទ្រង់សោយរាជ្យ ។**

លោកសាវកប៉ុលប្រាប់យើងថា យើងប្រសើរជាងអស់អ្នកដែលមានជ័យជម្នះ ដែលគ្មានអ្នកណាអាចនឹងបំបែកយើង ចេញពីសេចក្តីស្រឡាញ់របស់ព្រះបានឡើយ ។

ព្រះគម្ពីររ៉ូម ៨:៣៧-៣៩ ចែងថា: **ទេ គឺក្នុងសេចក្តីទាំងនោះ យើងខ្ញុំវិសេសលើសជាងអ្នកដែលមានជ័យជំនះទៅទៀត ដោយសារព្រះអង្គដែលទ្រង់ស្រឡាញ់យើង ដ្បិតខ្ញុំជឿជាក់ថា ទោះស្លាប់ ឬរស់ ពួកទេវតា ឬអំណាចអ្វី ការអ្វីនៅជាន់នេះ ឬទៅមុខ ឬឥទ្ធិឫទ្ធិអ្វី ទីមានកំពស់ ទំជំរៅ ឬរបស់អ្វីដែលកើតមកឯទៀតក្តី នោះពុំអាចនឹងពង្រាត់យើង ចេញពីសេចក្តីស្រឡាញ់របស់ព្រះ ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នាទៅបានឡើយ។**

ព្រះយេស៊ូវទ្រង់ប្រាប់យើងថា ចាប់ពីពេលនៃលោកយ៉ូហាន-បាទីស្ទ រហូតមកដល់ពេលឥឡូវនេះ នគរព្រះត្រូវបានលូតលាស់ទៅមុខដោយកងកម្លាំង ។

ព្រះគម្ពីរម៉ាថាយ ១១:១២ ចែងថា: **តាំងពីគ្រាយ៉ូហាន-បាទីស ដរាបដល់ឥឡូវនេះ នោះមានគេខំប្រឹងចាប់បាននគរស្ថានសួគ៌ ហើយគឺជាពួកខំប្រឹងដែលចាប់បានផង ។**

លោកសាវកប៉ុលប្រាប់យើងថា កងកម្លាំងគឺជាសេចក្តីជំនឿ ។

ព្រះគម្ពីរហេព្រើរ ១១:៣៣ ចែងថា: **ដែលដោយសារសេចក្តីជំនឿ នោះគេបានឈ្នះនគរដទៃ បានសំរេចការសុចរិត បានទទួលសេចក្តីសន្យា បានបិទមាត់សិង្ហ ។**

ព្រះបន្ទូលរបស់ព្រះយេស៊ូវគឺគ្រប់លក្ខណ៍!

ទ្រង់បានធ្វើឱ្យសាតាំងបរាជ័យ ព្រមទាំងបានយកគ្រប់របស់ទាំងអស់ពីសាតាំង ដែលវាបានលួចយកពីលោកអ័ដាម និងនាងអេវ៉ាទៅ ។

ទ្រង់បានកែអំណាចសារជាថ្មីឡើងវិញនៅលើផែនដីនេះ ដើម្បីរំដោះមនុស្សជាតិ គឺជាអស់អ្នកដែលជា ពួកជំនុំរបស់ទ្រង់ - ទាហានជំមានអំណាងរបស់ទ្រង់! ឥឡូវនេះវាជារបស់យើងរាល់គ្នាហើយ!

យើងគឺជាអ្នកចាប់យកព្រះរាជសារនៃសេចក្តីសង្គ្រោះដ៏ធំឧត្តមនេះ ប្រាប់ដល់លោកិយទាំងមូល ។

យើងត្រូវតែរួតរះដោយយើងជាកងកម្លាំងនៃនគររបស់ព្រះ ។

យើងត្រូវតែដាក់ខ្មាំងសត្រូវរបស់ព្រះយេស៊ូវ ឱ្យនៅក្រោមបាទារបស់ទ្រង់ ។

យើងត្រូវតែដើរដោយអំណាចនៅលើផែនដីនេះ ឥឡូវនេះ!

# ខគម្ពីរចងចាំ

ព្រះគម្ពីរអេភេសូរ ៦:១២

**ដ្បិតយើងរាល់គ្នាមិនមែនតយុទ្ធនឹងសាច់ឈាមទេ គឺនឹងពួកគ្រប់គ្រង ពួកមានអំណាច និងពួកម្ចាស់នៃសេចក្តីងងឹតនៅលោកិយនេះវិញ ហើយទាស់នឹងអំណាចអាក្រក់ខាងវិញ្ញាណ នៅស្ថានដ៏ខ្ពស់ដែរ ។**

ព្រះគម្ពីរ១ពេត្រុស ៥:៨-៩

**ចូរឱ្យដឹងខ្លួន ហើយចាំយាមចុះ ព្រោះអារក្សដែលជាខ្មាំងសត្រូវរបស់អ្នករាល់គ្នា វាតែងដើរក្រវែល ទាំងគ្រហឹមដូចជាសិង្ហ ដើម្បីនឹងរកអ្នកណាដែលវានឹងត្របាក់លេបបាន ចូរតស៊ូនឹងវា ដោយមានចិត្តជឿមាំមួន ទាំងដឹងថា ពួកបងប្អូនរបស់អ្នករាល់គ្នាដែលនៅក្នុងលោកិយនេះ គេកំពុងតែរងទុក្ខលំបាកដូចគ្នាដែរ ។**

ព្រះគម្ពីរយ៉ូហាន ១០:១០

**ឯចោរវាមកប្រយោជន៍តែនឹងលួច សំឡាប់ ហើយបំផ្លាញប៉ុណ្ណោះ តែឯខ្ញុំវិញ ខ្ញុំបានមក ដើម្បីឱ្យវារាល់គ្នាមានជីវិត ហើយឱ្យមានជីវិតនោះពេញបរិបូរផង ។**

ព្រះគម្ពីរលោកុប្បត្តិ ១:២៦

**ទ្រង់មានបន្ទូលថា ចូរយើងធ្វើមនុស្សឱ្យដូចជារូបយើង ឱ្យមានភាពដូចជាយើង ហើយឱ្យមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាស និងសត្វជើង៤ដែលនៅលើផែនដីទាំងមូល ព្រមទាំងសត្វលូនវារដែលវារនៅផែនដីផង ។**

ព្រះគម្ពីរលោកុប្បត្តិ ៣:១៥

**អញនឹងធ្វើឱ្យឯងហើយនិងស្ត្រី គឺទាំងពូជឯង និងពូជនាងមានសេចក្តីខ្មាំងនឹងគ្នា ពូជនាងនឹងកិនក្បាលឯង ហើយឯងនឹងចឹកកែងជើងគេ ។**

ព្រះគម្ពីរហេព្រើរ ២:១៤

**ដូច្នេះ ដែលកូនចៅបានប្រកបដោយសាច់ឈាមព្រមគ្នា នោះទ្រង់ក៏ទទួលចំណែកជាសាច់ឈាមដូច្នេះដែរ ដើម្បីឱ្យទ្រង់បានបំផ្លាញអានោះ ដែលមានអំណាចលើសេចក្តីស្លាប់ គឺជាអារក្ស ដោយទ្រង់សុគត ។**

ព្រះគម្ពីរ១យ៉ូហាន ៣:៨

**តែអ្នកណាដែលប្រព្រឹត្តបាបវិញ នោះគឺមកពីអារក្សទេ ពីព្រោះអារក្សបានធ្វើបាប តាំងពីដើមរៀងមក ដោយហេតុនោះបានជាព្រះរាជបុត្រា នៃព្រះបានលេចមក គឺដើម្បីនឹងបំផ្លាញការរបស់អារក្សចេញ ។**

ព្រះគម្ពីរកូល៉ុស ២:១៥

**ទ្រង់បានទាំងទំលាក់ងារពីពួកគ្រប់គ្រង និងពួកមានអំណាច ទាំងដាក់ពួកទាំងនោះនៅកណ្តាលជំនុំឱ្យគេមើល ហើយដឹកនាំគេទៅ ដោយមានជ័យជំនះ ដោយសារឈើឆ្កាងនោះឯង ។**

ព្រះគម្ពីរវិវរណៈ ១:១៨

**ជាព្រះដ៏រស់នៅ អញបានស្លាប់ តែមើល អញរស់នៅអស់កល្បជានិច្ចរៀងរាបតទៅវិញ អញក៏មានកូនសោរនៃសេចក្តីស្លាប់ និងស្ថានឃុំព្រលឹងមនុស្សស្លាប់ដែរ ។**

ព្រះគម្ពីរអេភេសូរ ១:២២-២៣

**ហើយទ្រង់បានបង្ក្រាបគ្រប់ទាំងអស់ នៅក្រោមព្រះបាទនៃព្រះរាជបុត្រា ទាំងប្រទានទ្រង់មកធ្វើជាសិរសាលើគ្រប់ទាំងអស់ ដល់ពួកជំនុំ ដែលជារូបកាយទ្រង់ គឺជាសេចក្តីពោរពេញរបស់ព្រះអង្គ ដែលបំពេញគ្រប់ទាំងអស់ ក្នុងទាំងអស់ ។**

ព្រះគម្ពីរកូល៉ុស ១:១៣

**ទ្រង់បានប្រោសឱ្យយើងរួចពីអំណាចនៃសេចក្តីងងឹត ហើយផ្លាស់យើងមកក្នុងនគររបស់ព្រះរាជបុត្រាស្ងួនភ្ងានៃទ្រង់ ។**

| | |
|---|---|
| ព្រះគម្ពីររ៉ូម ១៦:២០ | ឯព្រះនៃសេចក្តីសុខសាន្ត នៅបន្តិចទៀតទ្រង់នឹងកិនអារក្សសាតាំង នៅក្រោមជើងអ្នករាល់គ្នាហើយ សូមឱ្យអ្នករាល់គ្នាបានប្រកប ដោយនូវព្រះគុណនៃព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើងចុះ ។ |
| ព្រះគម្ពីរលូកា ១០:១៩ | មើល ខ្ញុំឱ្យអ្នករាល់គ្នាមានអំណាច នឹងដើរជាន់ទាំងពស់ និងខ្យាដំរី ហើយលើគ្រប់ទាំងឥទ្ធិឫទ្ធិរបស់ខ្មាំងសត្រូវផង គ្មានអ្វីនឹងធ្វើទុក្ខអ្នករាល់គ្នាឡើយ ។ |
| ព្រះគម្ពីរម៉ាថាយ ១៦:១៨-១៩ | ខ្ញុំប្រាប់អ្នកថា អ្នកឈ្មោះពេត្រុស ខ្ញុំនឹងតាំងពួកជំនុំខ្ញុំនៅលើថ្មដានេះ ហើយទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់នឹងមិនដែលឈ្នះពួកជំនុំឡើយ ខ្ញុំនឹងឱ្យកូនសោរនៃនគរស្ថានសួគ៌ដល់អ្នក បើអ្នកនឹងទុកអ្វីៗនៅផែនដី នោះនឹងត្រូវចងទុកនៅលើស្ថានសួគ៌ដែរ ហើយបើអ្នកនឹងស្រាយអ្វីៗនៅផែនដី នោះនឹងត្រូវស្រាយនៅស្ថានសួគ៌ដែរ ។ |
| ព្រះគម្ពីរវិវរណៈ ១២:១១ | គេបានឈ្នះវា ដោយសារឈាមនៃកូនចៀម ហើយដោយសារសេចក្តីបន្ទាល់របស់គេ ក៏មិនបានស្តាយជីវិតខ្លួនដរាបដល់ស្លាប់ ។ |
| ព្រះគម្ពីរ១យ៉ូហាន ២:១៣-១៤ | ឪពុករាល់គ្នាអើយ ខ្ញុំសរសេរផ្ញើមកអ្នករាល់គ្នា ពីព្រោះបានស្គាល់ព្រះ ដែលទ្រង់គង់នៅតាំងពីដើមរៀងមក កំឡោះរាល់គ្នាអើយ ខ្ញុំសរសេរផ្ញើមកអ្នករាល់គ្នា ពីព្រោះបានឈ្នះមេកំណាចហើយ ក្មេងរាល់គ្នាអើយ ខ្ញុំបានសរសេរផ្ញើមកអ្នករាល់គ្នា ពីព្រោះបានស្គាល់ព្រះវរបិតា ឪពុករាល់គ្នាអើយ ខ្ញុំបានសរសេរផ្ញើមកអ្នករាល់គ្នា ពីព្រោះបានស្គាល់ ដែលគង់នៅតាំងពីដើមរៀងមក កំឡោះរាល់គ្នាអើយ ខ្ញុំបានសរសេរផ្ញើមកអ្នករាល់គ្នា ពីព្រោះមានកំឡាំង ហើយព្រះបន្ទូលក៏ស្ថិតនៅក្នុងអ្នករាល់គ្នា អ្នករាល់គ្នាបានឈ្នះមេកំណាចហើយ ។ |
| ព្រះគម្ពីរភីលីព ២:៩-១០ | ដោយហេតុនោះបានជាព្រះបានលើកទ្រង់ឡើងយ៉ាងខ្ពស់ ហើយបានប្រទានឱ្យមាននាមដ៏ប្រសើរ លើសជាងអស់ទាំងនាមផង ដើម្បីកាលណាឮព្រះនាមព្រះយេស៊ូវ នោះឱ្យគ្រប់ទាំងជង្គង់នៅស្ថានសួគ៌ នៅផែនដី ហើយនៅក្រោមផែនដីត្រូវលុតចុះ ។ |

# ចលនានៃការបណ្តុះបណ្តាលដែលមានលក្ខណៈពេញលេញ

## គឺជាចលនាដ៏ប្រសើរបំផុតសម្រាប់សិក្សា ជាលក្ខណៈ បុគ្គល តាមសាលាព្រះគម្ពីរ សាលារៀនថ្ងៃអាទិត្យ ក្រុមសិក្សាតាមផ្ទះ ពួកសិស្សក្លាយជាគ្រូបង្រៀន

**ព្រះយេស៊ូវបានគង់ជាកណ្តាល មូលដ្ឋានគ្រឹះនៃព្រះបន្ទូល សេចក្តីជំនឿបានសម្រេច ជីវិតផ្លាស់ប្រែ ការបង្រៀនដោយព្រះវិញ្ញាណ**

ការដ៏ប្រសើរបំផុតសម្រាប់ការសិក្សា ជាលក្ខណៈបុគ្គល តាមសាលាព្រះគម្ពីរ សាលារៀនថ្ងៃអាទិត្យ និងក្រុមសិក្សាតាមផ្ទះ ។

ការហ្វឹកហ្វឺន ហ្វឹកហាត់សម្រាប់ការរស់នៅដែលមានជោគជ័យ និងការងារដ៏មមាញឹក ។

លោកអេ.អែល និងចយ ហ្គីល គឺជាអ្នកនិពន្ធសៀវភៅថ្នាក់ខ្ពស់បំផុត ដែលសៀវភៅរបស់គេ ជាថ្នាក់សាវក គ្រូបង្រៀន និងសម្រាប់ការងារផ្សាយដំណឹងល្អ ឈោងចាប់ពិភពលោកទាំងមូល ក្នុងកម្មវិធីផ្សាយដំណឹងល្អទម្រង់ធំ សិក្ខាសាលា ព្រមទាំងតាមមជ្ឈមណ្ឌលគ្រីស្ទាន និងតាមសាលាព្រះគម្ពីរជាដើម ។

### រូបភាពនៃការកើតជាថ្មី

ការរុករកឱ្យឃើញអ្នកដែលបានបង្កើតយើងមក ហើយឱ្យយើងមាននៅផង ។ ការបើកសម្តែងដែលពេញដោយអំណាចនៃសេចក្តីសុចរិតនេះបានរំដោះអ្នកជឿឱ្យចេញពីគំនិតចុះចាញ់ថា ខ្លួនមានកំហុស ទទួលទោសទណ្ឌ ថោកទាប និងភាពមិនពេញលេញ ដើម្បីឱ្យពួកអាចបញ្ជាក់ថា ខ្លួនកើតមកគឺមានភាពដូចជាព្រះ ។

### អំណាចរបស់អ្នកជឿ

ព្រះអាទិករបានបើកសម្តែងនូវបំណងដ៏អស់កល្បរបស់ព្រះអង្គសម្រាប់មនុស្សជាតិពេលដែលទ្រង់មានបន្ទូលថា "ចូរឱ្យមានអំណាច" លោកអ្នកនឹងដើរដោយភាពរឹងប៉ឹងថ្មីមួយ ដូចជាលោកអ្នករស់នៅក្នុងជ័យជម្នះលើសាតាំង និងអំណាចនៃសេចក្តីអាក្រក់ក្នុងការរស់នៅ និងការងារប្រចាំថ្ងៃរបស់លោកអ្នក ។

### អំណោយទាននៃការងារ

ព្រះយេស៊ូវទ្រង់បានប្រទានអំណោយដល់មនុស្ស ការរុករកឃើញនូវរបៀបដែលរកបានអំណោយទានទាំងនេះ គឺបានហូរចេញព្រមគ្នានៅក្នុងពួកជំនុំ "ដើម្បីរៀបចំមនុស្សរបស់ព្រះសម្រាប់ធ្វើការងារ" ។ ការសិក្សានេះនឹងជួយមនុស្សជាច្រើនឱ្យយល់ពីការត្រាសហៅរបស់ព្រះសម្រាប់ជីវិតរបស់ពួកគេ ។

### ពួកជំនុំដែលមានជោគជ័យ

ព្រះយេស៊ូវមានបន្ទូលថា ខ្ញុំនឹងសង់ពួកជំនុំខ្ញុំ ហើយទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់មិនអាចទាស់ទទឹងនឹងគេបានឡើយ ។ តាមរយៈព្រះគម្ពីរកិច្ចការ ពួកជំនុំមានសកម្មភាពទុកជាគំរូ ពីរទីសម្គាល់ និងការអស្ចារ្យជាច្រើនសម្រាប់ពួកជំនុំព្រះអង្គរហូតដល់សព្វថ្ងៃនេះ ។



### ការប្រទានពររបស់ព្រះសម្រាប់ការប្រោសឱ្យជា

ផ្តោតទៅលើគ្រឹះមាំដែលត្រូវបានរំដោះឱ្យមានជំនឿសម្រាប់ទទួលផល ឬក៏ធ្វើជាអ្នកតំណាងនូវការប្រោសឱ្យជា ។ វត្តមាននៃការងាររបស់ព្រះយេស៊ូវ និងពួកសាវកទុកជាគំរូសម្រាប់ការប្រោសឱ្យជាមកដល់សព្វថ្ងៃនេះ ។

### ការអស្ចារ្យនៃការផ្សាយដំណឹងល្អ

តាមរយៈព្រះគម្ពីរកិច្ចការ បង្ហាញពីសកម្មភាពពួកជំនុំ ពីគំរូ ការអស្ចារ្យ អំណាចប្រោសឱ្យជាក្នុងជីវិតដ៏សំខាន់នៃយើង ជាពេលចុងក្រោយនៃរដូវចម្រូត តាមការផ្សាយដំណឹងល្អដ៏អស្ចារ្យនេះ ។

### ការរស់នៅប្រកបដោយអធិធម្មជាតិ

ការសម្រេចនូវការងារថ្មីមួយ គឺជាការប្រកបជិតស្និទ្ធជាមួយនឹងព្រះវិញ្ញាណបរិសុទ្ធ ។ ការរុករកឃើញនូវរបៀបដែលមានដំណើរការក្នុងអំណោយទានទាំង៩នៃព្រះវិញ្ញាណបរិសុទ្ធ ។ លោកអ្នកនឹងសម្រេចចិត្តយ៉ាងមុតមាំ ដើម្បីឱ្យបានទទួលនូវអំណោយទានទាំងនេះ។ ដូចជាអណ្តាតភ្លើងដែលធ្វើឱ្យលោកអ្នកមានជីវិតរស់នៅដោយអធិធម្មជាតិ។

### ការសរសើរនិងការថ្វាយបង្គំ

ការក្លាយមកជាអ្នកថ្វាយបង្គំដល់ព្រះ គឺជាការបើកសម្តែងពីជីវិតផ្លាស់ប្រែ បំណងដ៏អស់កល្បរបស់ព្រះ សម្រាប់ការសរសើរ និងការថ្វាយបង្គំ ការរំដោះអ្នកជឿឱ្យចូលទៅក្នុងការរំភើបចិត្ត ដែលមាននៅក្នុងព្រះគម្ពីរ គឺជាការលាក់ទុកក្នុងការសរសើរ និងការរស់នៅប្រចាំថ្ងៃរបស់គេ អ្នកជឿទាំងឡាយនឹង បានរៀនពីរបៀបចូលទៅក្នុងវត្តមាននៃព្រះក្នុងការថ្វាយបង្គំដ៏ជិតស្និទ្ធបំផុត ។

Powerhouse Publishing
P.O. Box 99, Fawnskin, Ca 92333
1-800-366-3119